

សិលាចារឹកជាស្លាកស្នាមប្រវត្តិសាស្ត្រយ៉ាងសំខាន់ដែលបញ្ជាក់អំពីភាពរុងរឿងនៃអារ្យធម៌ និងកាលប្បវត្តិរបស់ប្រទេសជាតិនៅក្នុងសម័យកាលដែលកន្លងផុតទៅរាប់រយពាន់ឆ្នាំ។ ក្នុងពេលដែលប្រទេសជាច្រើនក្នុងពិភពលោកនេះមានភស្តុតាងប្រវត្តិសាស្ត្រតិចតួច កម្ពុជាមានសិលាចារឹក ប្រហែល១៤០០ដែលកត់ត្រាអំពីដំណាក់កាលប្រវត្តិសាស្ត្រជិតមួយសហស្សវត្សពីសតវត្សទី៦ដល់សតវត្សទី១៤។

សិលាចារឹកមិនត្រឹមតែជាឧបករណ៍កត់ត្រាប្រវត្តិសាស្ត្រ និងព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែសិលាចារឹកកម្ពុជាក៏ឆ្លុះបញ្ចាំងឱ្យឃើញដំណើរវិវត្ត និងទម្រង់សម្បូរបែបនៃការប្រើប្រាស់ភាសាទាំងខ្មែរបុរាណ និងភាសាដែលមានឥទ្ធិពលលើវប្បធម៌ខ្មែរនៅសម័យដើម គឺភាសាសំស្រ្កឹត និងភាសាបាលី។

ISBN: 978-9924-34-087-4

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

អក្សរសិល្ប៍ និងភាសាខ្មែរ
សម័យមុនអង្គរ និងសម័យអង្គរតាមរយៈសិលាចារឹក

# អក្សរសិល្ប៍ និងភាសាខ្មែរ
# សម័យមុនអង្គរ និងសម័យអង្គរ
# តាមរយៈសិលាចារឹក

## អត្ថបទសង្ខេប



ដោយ បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

សហការជាមួយគ្រឹះស្ថានបោះពុម្ពផ្សាយស៊ីប៉ា
២០២០
Sipar

# អក្សរសិល្ប៍ និងភាសាខ្មែរ
## សម័យមុនអង្គរ និងសម័យអង្គរ
## តាមរយៈសិលាចារឹក

### អត្ថបទសង្ខេប

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# អក្សរសិល្ប៍ និងភាសាខ្មែរ
## សម័យមុនអង្គរ និងសម័យអង្គរ
## តាមរយៈសិលាចារឹក

អត្ថបទសង្ខេប

ដោយ បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**២០២០**

រចនាទំព័រ និងសម្រួលអត្ថបទដោយអង្គការSipar
© ហង់ជួន ណារ៉ុន
រក្សាសិទ្ធិគ្រប់យ៉ាង

បោះពុម្ពនៅកម្ពុជាដោយរោងពុម្ព អេស អេច

# មាតិកា


**សេចក្តីផ្តើម** ........................................................................ ៥

*សិលាចារឹកកម្ពុជាសម័យបុរាណ* ............................................ ៧

**ផ្នែកទី ១ ៖ អក្សរសិល្ប៍កម្ពុជាសម័យមុនអង្គរ**

I. អាណាចក្រខ្មែរដំបូង ............................................................ ១៣

*១.១.១. អាណាចក្រភ្នំ ឬហ្វូណន* ............................................... ១៣

*១.១.២. ទស្សនៈរបស់អ្នកប្រាជ្ញផ្សេងទៀត* ................................ ១៤

*១.១.៣. អង្គរបុរី ឬ នរវរនគរ* .................................................. ១៥

*១.១.៤. សិលាចារឹកវ៉ូកាញ់* ....................................................... ១៧

*១.១.៥. អង្គរបុរី ជាជម្រកវប្បធម៌បុរេអង្គរ* ................................ ១៨

*១.១.៦. លិង្គបុរៈនៅសតវត្សទី៥ និងទី៦* ................................ ២១

II. កំណើតភាសាសរសេរខ្មែរចាស់នៅសតវត្សទី៦

*១.២.១. សិលាចារឹកបុរេអង្គរ* .................................................... ២៦

*១.២.២. ការបង្កើតអក្ខរក្រមខ្មែរចាស់* ...................................... ២៧

*១.២.៣. សិលាចារឹកមហាសករាជទី៥* ........................................ ២៨

*១.២.៤. សិលាចារឹកមហាសករាជទី៦* ........................................ ២៨

*១.២.៥. មជ្ឈមណ្ឌលវប្បធម៌ខ្មែរដំបូង*

*(សតវត្សទី ៦ និងដើមទី ៧ នៃគ្រិស្តសករាជ)* .......... ២៩

*១.២.៦. ព្រះបាទភវវម្ម័ ទី១ (៥៥០-៦០០)* ................................ ៣០

*១.២.៧. ស្ថាបត្យកម្មនៃប្រាសាទខ្មែរបុរេអង្គរ* .............................. ៣៣

*១.២.៨. ស្ទឹងត្រែងនៅសតវត្សទី៦* ............................................. ៣៨

១.២.៩. សិលាចារឹកសតវត្សទី៧ ............................................ ៤០
១.២.១០. មហេន្ទ្រវម៌្ម-ចិត្រសេន (៦០០-៦១៦) ...................... ៤១
១.២.១១. ស្ទឹងត្រែងនៅសតវត្សទី៧ ........................................ ៤៦
១.២.១២. អង្គរបុរីនៅសតវត្សទី៧ ........................................... ៤៩

III. ឦសានបុរៈ
១.៣.១. ព្រះបាទឦសានវម៌្ម ទី១ (៦១៦-៦៣៥) ................... ៥៣
១.៣.២. ព្រះបាទភវវម៌្ម ទី២ (៦៣៥/៦-៦៥៧) ....................... ៥៩
១.៣.៣. ព្រះបាទជ័យវម៌្ម ទី១ (៦៥៧-៦៨១) ....................... ៧១
១.៣.៤. បញ្ហាប្រវត្តិសាស្ត្រកម្ពុជានៅសតវត្សទី៨ ................. ៧៨
១.៣.៥. សម្ភុបុរៈ(ក្រចេះ) ...................................................... ៨៣

**ផ្នែកទី ២ ៖ អក្សរសិល្ប៍កម្ពុជាសម័យអង្គរ** .............................................. ៨៩
២.១. ព្រះបាទជ័យវម៌្ម ទី២ (៨០២-៨៥០)
និង ព្រះបាទជ័យវម៌្ម ទី៣ (៨៥៤-៨៧៧) .................... ៩១
២.២. ព្រះបាទឥន្ទ្រវម៌្ម ទី១ (៨៧៧-៨៨៩) ........................... ៩៩
២.៣. ព្រះបាទ យសោវម៌្ម ទី១ (៨៨៩-ប្រហែល៩១៥)....... ១០៥
២.៤. ហស៌វម៌្មទី១-ឦសានវម៌្ម ទី២ (៩១៥-៩២៨) .............. ១១៤
២.៥. ព្រះបាទជ័យវម៌្ម ទី៤ (៩២១-៩៤១)........................... ១១៥
២.៦. ព្រះបាទរាជេន្ទ្រវម៌្ម (៩៤៤–៩៦៨) .......................... ១២៤
២.៧. ព្រះបាទជ័យវម៌្ម ទី៥ (៩៦៨-១០០០)....................... ១៣៦
២.៨. ព្រះបាទសូរ្យវម៌្ម ទី១ (១០១១-១០៤៩)...................... ១៤២
២.៩. ប្រាសាទ និងសិលាចារឹកឯកភ្នំ (១០៥០-១០៦៦) ...... ១៥៦
២.១០.ព្រះបាទឧទ័យាទិត្យវម៌្ម ទី២ (១០៥០-១០៦៦) ......... ១៥៨

២.១១. ព្រះបាទហស៌វម៌្ម ទី៣ (១០៦៦-១០៨០)................ ១៦៤
២.១២. ព្រះបាទជយវម៌្ម ទី៦ នៃរាជវង្សមហីធរបុរ
(១០៨០-១១៦០)........................................................ ១៦៥
២.១៣. ព្រះបាទធរណីន្ទ្រវម៌្ម ទី១ (១១០៧-១១១២)......... ១៦៦
២.១៤. ព្រះបាទសូរ្យវម៌្ម ទី២ (១១១៣-១១៥០)................. ១៦៩
២.១៥. ព្រះបាទធរណីន្ទ្រវម៌្ម ទី២
យសោវម៌្មទី២ (១១៥២-១១៦៥) ............................. ១៧១
២.១៦. ព្រះបាទត្រិភូវនាទិត្យវម៌្ម (១០៦៥-១១៧៧) ......... ១៧២
២.១៧. ព្រះបាទជ័យវម៌្ម ទី៧(១០៨១-១២១៨) ............... ១៧៣
២.១៨. ព្រះបាទឥន្ទ្រវម៌្ម ទី២
និងជ័យវម៌្មទី៨ (១២១៨-១២៩៥) ............................ ១៩៨
២.១៩. សិលាចារឹក គឺជានិមិត្តរូបនៃភាពរុងរឿង ................ ១៩៨
២.២០. ការធ្លាក់ចុះនៃអង្គរ.................................................. ១៩៩

**ផ្នែកទី ៣ ៖ ការវិវត្តនៃភាសាខ្មែរចាស់** ..................................... ២០១
៣.១. ការវិវត្តនៃអក្ខរក្រមភាសាខ្មែរចាស់............................ ២០៤
៣.២. វាក្យសព្ទនៃភាសាខ្មែរចាស់ ...................................... ២១៨
៣.៣. វាក្យសម្ព័ន្ធក្នុងភាសាខ្មែរចាស់ ................................. ២២៤
៣.៤. ការវិវត្តវាក្យសព្ទពីខ្មែរចាស់ ទៅខ្មែរទំនើប................ ២២៦
៣.៥. មូលដ្ឋានគ្រឹះនៃភាសាខ្មែរចាស់................................ ២៣៥
៣.៦. នាមក្នុងភាសាខ្មែរចាស់............................................ ២៤២
**គន្ថនិទ្ទេស**............................................................................ ២៥១

# សេចក្ដីផ្ដើម

*ការសិក្សានេះមានគោលដៅចំនួន ៣ គឺៈ*

*ទី១-សិក្សាពីអក្សរសិល្ប៍កម្ពុជាៈ អក្សរសិល្ប៍កម្ពុជា ជាភាសាសំស្ក្រឹត និងជាភាសាខ្មែរចាស់ សម័យមុនអង្គរ និងសម័យអង្គរ។*

*ទី២-សិក្សាពីប្រវត្តិសាស្ត្រកម្ពុជា តាមរយៈប្រភពសិលាចារឹក។*

*ទី៣-សិក្សាពីការវិវត្តភាសាខ្មែរចាស់ ៖ អក្សរ និងវេយ្យាករណ៍។ អ្នកស្រាវជ្រាវបានចែកដំណាក់កាលវិវត្តភាសាខ្មែរជាបីដំណាក់កាល គឺៈ*
*(១)-ភាសាខ្មែរចាស់ (សម័យមុនអង្គរ ពីសតវត្សទី៦ ដល់ចុងសតវត្សទី៨ និងភាសាខ្មែរចាស់សម័យអង្គរ ពីសតវត្សទី៩ ដល់សតវត្សទី១៤)*
*(២)- ភាសាខ្មែរកណ្ដាលៈ ពីសតវត្សទី១៥ ដល់សតវត្សទី ១៨ និង*
*(៣)-ភាសា ខ្មែរទំនើបៈ ពីពាក់កណ្ដាលសតវត្សទី១៨ មកដល់សព្វថ្ងៃ។*

*ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកគ្រូ បណ្ឌិត ឆោម គន្ធា ដែលបានបង្រៀនភាសាសំស្ក្រឹតដល់រូបខ្ញុំ ណែនាំរូបខ្ញុំឱ្យចេះអានសិលាចារឹក ព្រមទាំងបានផ្ដល់អនុសាសន៍ល្អៗ ដើម្បីកែលម្អការសិក្សានេះ ជាពិសេសបានផ្ដល់ការអនុញ្ញាតឱ្យខ្ញុំប្រើប្រាស់នូវបញ្ជីសាលាចារឹក ដែលជាមូលដ្ឋានសម្រាប់ការសិក្សានេះ។*

*ខ្ញុំសូមអរគុណដល់លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្ទឹងត្រែង លោកហ៊ាង ប៉ូលី ខេត្តក្រចេះ លោកឡាយ បូរ៉ា ខេត្តកំពង់ចាម លោក លី ម៉េងសាន ខេត្តតាកែវ លោកឡោ វិរិទ្ធ និងខេត្តបាត់ដំបង លោកឃី សុងគី ដែលបានជួយខ្ញុំ ក្នុងការរៀបចំដំណើរទស្សនកិច្ចទៅទស្សនានិងថតរូបប្រាសាទ និងសិលាចារឹកដែលស្ថិតនៅតាមខេត្តទាំងនោះ។*




របាយសិលាចារឹកកម្ពុជា

# សិលាចារឹកកម្ពុជាសម័យបុរាណ

*សិលាចារឹកដែលរកឃើញនៅប្រទេសកម្ពុជាបុរាណ ត្រូវបានចារនៅក្នុងរយៈពេល៩សតវត្ស ពីសតវត្សទី៦ ដល់ទី១៤ ហើយមានចំនួនដ៏ច្រើនលើសលប់ ប្រមាណជា ១៤០០ ដែលជាមត៌កដ៏សំខាន់របស់កម្ពុជា សម្រាប់ការសិក្សាភាសាខ្មែរបុរាណ។*[1] *សិលាចារឹកទាំងនេះ ត្រូវបានរកឃើញលើទឹកដីកម្ពុជា ឡាវ ថៃ និងវៀតណាមបច្ចុប្បន្ន ដែលជាដែនដីអាណាចក្រខ្មែរ។ មានប្រទេសតិចតួចណាស់លើសកលលោក ដែលមានសិលាចារឹកជាង ១០០០។*

*សិលាចារឹកនៅប្រទេសកម្ពុជាចារជាបីភាសាៈ (១) ភាសាសំស្ក្រឹត (២) ភាសាខ្មែរបុរាណ និង (៣) ភាសាបាលី (នៅពេលដែលអាណាចក្រខ្មែរទទួលយកព្រះពុទ្ធសាសនា)។ អ្នកប្រាជ្ញខ្មែរចារសិលាចារឹកនេះ ដោយប្រើអក្សរខ្មែរ ដើម្បីសរសេរកំណាព្យជាភាសាសំស្ក្រឹត និងសរសេរបាលី តែក៏មានសិលាចារឹកមួយចំនួនតូចសរសេរ ដោយប្រើអក្សរ ទេវនាគរី* (Deva-Nāgari) *របស់ឥណ្ឌាដែរ។ នៅចុងសតវត្សទី៩ ដើមសតវត្សទី១០ ក្នុងរាជព្រះបាទយសោវរ្ម័នទី១ មានសិលាចារឹកចំនួន ១០ ដែលចារជាអក្សរនាគរីសុទ្ធ ដែលជាអក្សរនៃប្រទេសឥណ្ឌាភាគខាងជើង និងសិលាចារឹកចំនួន ១៧ ទៀត ចារជាអក្សរនាគរីផង និងខ្មែរផង។*[2]

*ក្នុងចំណោមនោះ សិលាចារឹកដែលមានកាលបរិច្ឆេទពេញលេញមានចំនួនជាង ៣០ កាលបរិច្ឆេទលំៗ មានជាង ៥០ សិលាចារឹកភាសាខ្មែរមានជាង ២០០ និងមានបី ជាសិលាចារឹកភាសាបាលី។*[3]

---

1. Pou, 1992
2. *អាំង ជូលាន* 2010
3. Chhom, 2019

ខ្ញុំសូមធ្វើ «កំណត់សម្គាល់» ដូចតទៅ៖

ទី១-សិលាចារឹកចារនៅតាមប្រាសាទនានានៃអាណាចក្រខ្មែរ ហើយមានគោលដៅច្បាស់លាស់ ដោយសារតែមិនមែនប្រាសាទទាំងអស់សុទ្ធតែមានសិលាចារឹកទេ។ សិលាចារឹកពាក់ព័ន្ធនឹងប្រាសាទបុរាណ។ ប្រាសាទពាក់ព័ន្ធនឹងសាសនា និងជំនឿរបស់ប្រជាជនកម្ពុជាតាមសម័យកាលផ្សេងៗ។

ទី២-សិលាចារឹកចារលើ៖ សិលាមូលស្ថាបនា (stele), មេទ្វារ (piédroit), ផ្ទាំងថ្ម (dalle), សសរ ។ល។

ទី៣-សិលាចារឹក គឺជាអត្ថបទបញ្ជាក់ពីការស្ថាបនាប្រាសាទ (កាលបរិច្ឆេទសម្ពោធ នាមរបស់ទេព តង្វាយដល់ទេព)។

ទី៤-សិលាចារឹក គឺជាសារដ៏សំខាន់ដែលម្ចាស់ទានឧទ្ទិសចំពោះព្រះសិវៈ និងទេពផ្សេងៗ។ សិលាចារឹកអាចជាមធ្យោបាយទំនាក់ទំនងរវាងសាសនិកជន និងអាទិទេព តាមរយៈព្រះរាជគ្រូ ឬអ្នកសាងសង់។

ទី៥-សិលាចារឹក គឺជាវណ្ណកម្មអក្សរសិល្ប៍ពីបុរាណ៖ សិលាចារឹកភាសាសំស្ក្រឹត គឺជាកំណាព្យ«កាវ្យ» ជា «ស្តុតី» ឬ «ប្រគស្តិ» ដែលសរសើរដល់អាទិទេព ព្រះរាជា ឥស្សរជនជាន់ខ្ពស់ជាបព្វជិត និងគ្រហស្ថដែលមានសន្តានចិត្តជ្រះថ្លាចំពោះសាសនា តាមរយៈការកសាងប្រាសាទ វត្តអារាម ស្រុកភូមិ សួនឧទ្យាន បារាយណ៍ និងទំនប់ទឹក។

ទី៦- សិលាចារឹកភាសាខ្មែរ គឺជាអត្ថបទអក្សរសិល្ប៍ ដែលរៀបរាប់ពីរឿងរ៉ាវផ្សេងៗទាក់ទងនឹងប្រវត្តិគ្រួសារព្រាហ្មណ៍ ប្រវត្តិនៃបូជនីយដ្ឋាន និងតង្វាយផ្សេងៗចំពោះព្រះអាទិទេព និងបូជនីយដ្ឋាន។ សិលាចារឹកជាច្រើនផ្តល់នូវបញ្ជីឈ្មោះ អ្នកបម្រើ របស់របរប្រើប្រាស់ គ្រឿងឧបភោគបរិភោគ ដីស្រែ និងសត្វពាហនៈ ដែលជាតង្វាយដល់ទេពនៅប្រាសាទ។

ទី៧-សិលាចារឹកគឺជាមធ្យោបាយផ្សព្វផ្សាយធម៌ដោយបព្វជិតខាងព្រហ្មញ្ញសាសនា។[4]

ទី៨-សិលាចារឹក គឺជាកំណត់ត្រារដ្ឋបាលស្តីពីការអនុវត្តកិច្ចការរាជការ ជាពិសេស ការកាប់គាស់ដីថ្មី ដើម្បីចាត់តាំងស្រុក កសាងវត្ត ជីកស្រះ

4. Chhom, 2019



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដីកត្រពាំង សង់ទំនប់ទឹកសម្រាប់ជាទីតាំងលំនៅ ការធ្វើពាណិជ្ជកម្មដោយធ្វើការផ្លាស់ប្តូរគ្រឿងវត្ថុ ផលដំណាំគ្រប់ជំពូក។ សិលាចារឹកខ្លះ គឺជាឯកសារកត់ត្រារបស់មន្ត្រីរាជការនៅតាមមូលដ្ឋាន និងមានលក្ខណៈឯកជនផងដែរ។

ទី៩-សិលាចារឹក គឺជាកម្រងឯកសារគតិយុត្តិ និងជាប័ណ្ណកម្មសិទ្ធិជាឯកសាររាជការ តុលាការ និងព័ត៌មាន និងជាកំណត់ត្រាសុរិយោដី ដើម្បីប្រកាសដល់សាធារណជន ឱ្យបានដឹងពីព្រំប្រទល់ដី ដែលជាកម្មសិទ្ធិរបស់ពួកអភិជន។

ទី១០-សិលាចារឹក គឺជាសក្ខីភាពនៃអានុភាពព្រះរាជា ក្នុងការគ្រប់គ្រង៖ សិលាចារឹកមហេន្ទ្រវម៌្មបង្ហាញពីព្រំប្រទល់នៃអាណាចក្រខ្មែរនៅដើមសតវត្សទី៧។

ទី១១-សិលាចារឹក គឺជាមធ្យោបាយពង្រឹងអំណាច៖ សម្បថនៃព្រះបាទសូរ្យវម៌្ម ទី១។

ទី១២-សិលាចារឹក គឺជាកម្រងឯកសារប្រវត្តិសាស្ត្រ ដែលកត់ត្រាប្រវត្តិនៃគ្រួសារវណ្ណៈអភិជនជាន់ខ្ពស់ ព្រះរាជគ្រូ និងព្រះសង្ឃព្រាហ្មណ៍សាសនា។

ទី១៣-សិលាចារឹក គឺជាឯកសារសម្រាប់ផ្ទេរចំណេះដឹងដល់ជនជំនាន់ក្រោយ ឱ្យអ្នកអានទទួលចំណេះដឹងខាងផ្នែកអក្សរសាស្ត្រទស្សនវិជ្ជា សាសនា និងព័ត៌មានស្តីពីសង្គមខ្មែរនៅតាម សម័យកាលនីមួយៗ។

ទី១៤-សិលាចារឹកមានកាលបរិច្ឆេទជាមហាសករាជ (គក +៧៨ / ៧៩ = គស)។ មហាសករាជចប់ក្នុងខែមីនា-មេសា។ ដូច្នេះ សិលាចារឹកមានកាលបរិច្ឆេទចន្លោះពីខែមករា ដល់ខែមីនា-មេសាត្រូវបូកនឹង ៧៩ ដើម្បីរកកាលបរិច្ឆេទជាគ្រិស្តសករាជ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី ១

# អក្សរសិល្ប៍កម្ពុជាសម័យមុនអង្គរ

# I. អាណាចក្រខ្មែរដំបូង

## ១.១.១. អាណាចក្រភ្នំ ឬ ហ្វូណន

ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាពីសតវត្សទី១ ដល់សតវត្សទី៧ ត្រូវពឹងផ្អែកលើប្រភពឯកសារពង្សាវតារនៃប្រទេសចិន ដោយសារស្តេចចិនបុរាណបានបញ្ជូនបេសកជនមកកាន់ហ្វូណន និងផ្លាស់ប្តូរពាណិជ្ជកម្មជាមួយហ្វូណន និងកំណាយបុរាណវិទ្យានៅអូកែវ និងនៅប្រទេសថៃ។

ពង្សាវតារចិនបានបញ្ជាក់ពីទីតាំងហ្វូណនថា៖ «អាណាចក្រហ្វូណនស្ថិតនៅភាគខាងត្បូងនៃទឹកដី រីណាន (អាណាចក្របុរាណ Nan Yue) នៅក្នុងឈូងសមុទ្រខាងលិចនៃមហាសមុទ្រ (ឈូងសមុទ្រថៃ)។ នៅទីនោះមានទន្លេធំមួយ (ទន្លេមេគង្គ) ដែលហូរពីទិសខាងលិច ចាក់ចូលក្នុងសមុទ្រ។ ទឹកដីហ្វូណនមានទំហំ ៣០០០ លីការ៉េ (រង្វាស់ចិន)។ គេអាចទៅដល់ទីនោះ តាមផ្លូវដីក៏បានផ្លូវទឹកក៏បាន»។

តាមឯកសារប្រវត្តិសាស្ត្រឡាងបានឱ្យដឹងថា៖ «ទីប្រជុំជន (រាជធានី?) នៃហ្វូណនស្ថិតនៅចូលខាងក្នុងជ្រៅប្រមាណ ៥០០លី (២០០គម) ពីសមុទ្រ»។ ប្រភពមួយទៀតបង្ហាញថា៖ «រាជធានីហ្វូណនមានឈ្មោះថា Te Mu (វ្យាធបុរៈ?)។ ក៏ប៉ុន្តែ បន្ទាប់ពីទីក្រុងនេះត្រូវបានចេនឡាចូលកាន់កាប់ នៅឆ្នាំ ៥៣៥ រាជធានីត្រូវបានរើទៅនៅឯ Nafuna។

នៅសតវត្សទី២ ហ្វូណនដឹកនាំដោយឧត្តមសេនីយ «ហ្វាន់ម៉ាន់» (ស្រីមារៈ) ដែលមានគោរមងារជា «មហារាជា» និងគ្រប់គ្រងប្រទេសតាមបែបឥណ្ឌា។ រាជវង្សហ្វូណនកើតឡើងពីការរៀបអភិសេករវាងកៅណ្ឌិន្យ និងព្រះនាងសោមា។ ស្តេចគ្រងរាជ្យបន្ទាប់ព្រះនាម «ហ្វាន់ ត្យាន់» ដែលមានទំនាក់ទំនងល្អ និងធ្វើពាណិជ្ជកម្មជាមួយចិន និងឥណ្ឌា ហើយបានបញ្ជូនបេសកជនទៅឥណ្ឌា ហើយឥណ្ឌាក៏បានបញ្ជូនបេសកជនមកហ្វូណនវិញ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែរ។ នៅឆ្នាំ ៣៥៧ ស្តេចហ្វូណនព្រះនាម «ជូ ត្យាន់តាន់» ហើយព្រះនាមជូនេះជាភាសាសំស្រ្កឹត គឺ «ចន្ទតាព»។

នៅដើមសតវត្សទី៥ ប្រវត្តិវិទូចិនបានកត់ត្រាពីការមកដល់នៃកៅណ្ឌិន្យទី២ ដែលធ្វើឱ្យមានការសន្និដ្ឋានពីដំណាក់កាលទី២នៃឥណ្ឌាភាវូបនីយកម្ម (ឯកសារចិនអាចមិនច្បាស់លាស់)។

នៅឆ្នាំ ៤៨០ ព្រះបាទជ័យវម៌្មបានឡើងសោយរាជ្យនៅ «វ្យាធបុរៈ»។ ប្រជាជនជឿអាទិទេព «មហេឝ្វរ» (ឥសូរ) និងព្រះពុទ្ធសាសនា។

History of the Liang Dynasty បានបញ្ជាក់ថា ក្រោយពីព្រះបាទជ័យវម៌្ម ចូលទិវង្គត ព្រះបាទរុទ្រវម៌្ម ដែលជាបុត្រជាមួយស្នំឯកបានឡើងសោយរាជ្យនៅឆ្នាំ ៥១៤។ ចារឹកអ្នកតាដំបងដែក K. 875 (សកទី៥) បញ្ជាក់ថា ព្រះនាង កុលាប្រភាវតី ជាមហេសីនៃព្រះបាទជ័យវម៌្ម។

## ១.១.២. ទស្សនៈរបស់អ្នកប្រាជ្ញផ្សេងទៀត

លោក Cœdes សន្និដ្ឋានថា Te Mu ត្រូវជា វ្យាធបុរៈ (ទីក្រុងអ្នកទាក់ដំរី) គឺស្ថិតនៅស្រុកបាភ្នំ ខេត្តព្រៃវែង។ ក៏ប៉ុន្តែ Jacques សន្និដ្ឋានថារាជធានីដំបូងនៃនគរភ្នំ គឺជាអង្គរបុរីទើបត្រូវ។

លោក Vickery (1998:29) ដោយយោងលើសិលាចារឹកបាភ្នំ ដែលមានកាលបរិច្ឆេទក្រោយសម័យហ្វូណន (ឆ្នាំ ៦៥៥) បានលើកសម្មតិកម្មថា «វ្យាធបុរៈ» គួរតែមានទីតាំងនៅ «បន្ទាយព្រៃនគរ» (រាជធានីរបស់ហ្វូងស្តេចកន) គឺមិនមែនជា បាភ្នំឡើយ។ លោក Claude Jacques បានអះអាងថា រាជធានីរបស់ហ្វូណន «វ្យាធបុរៈ» គួរតែជា «អង្គរបុរី» (៩០គមពីសមុទ្រ) ឬ ភ្នំដា ហើយមិនមែនបាភ្នំឡើយ ដោយសារតែបាភ្នំ ស្ថិតនៅឆ្ងាយពីអូកែវ (Oc Eo) ដែលជាទីក្រុងផែដ៏សំខាន់នៅសម័យហ្វូណន។

ហ្វូណនលាតសន្ធឹងពីតំបន់មេគង្គខាងក្រោមដល់ទន្លេសាប។ ប្រជាជននៅតំបន់អង្គរបុរីសាងសង់ប្រព័ន្ធ ប្រឡាយទឹកខ្វាត់ខ្វែង ដែលប្រើប្រាស់សម្រាប់នាវាចរណ៍។ អ្នកស្រុកប្រើប្រាស់ប្រព័ន្ធប្រឡាយ ដើម្បីតភ្ជាប់ប្រាសាទសាសនាទាំងឡាយនៅក្នុងសម័យនោះ ព្រមទាំងភ្ជាប់អូកែវ ទៅ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងមាត់សមុទ្រ ដែលមានប្រវែង ១១ គីឡូម៉ែត្រ។

## ១.១.៣. អង្គរបុរី ឬ នគរនគរ

អង្គរបុរី គឺជាស្ថានីយប្រវត្តិសាស្ត្រមុនអង្គរ ដែលស្ថិតនៅជិតតំបន់ភ្នំដា។ ចាប់ពីសតវត្សទី៣ មក គេឃើញមានប្រភពឯកសារចិនដែលពិពណ៌នាពីសង្គមខ្មែរ និងផលិតផលនៃតំបន់អង្គរបុរី។ ទន្ទឹមនឹងមានទំនាក់ទំនងជាមួយចិន ចាប់ពីសតវត្សទី៣មក គេបានរកឃើញថា អង្គរបុរីមានទំនាក់ទំនងជាមួយឥណ្ឌា អ៊ីរ៉ង់ និងពិភពម៉េឌីទែរ៉ាណេ។ អាណាចក្រហ្វូណន គឺជាមហាអំណាចខាងផ្នែកពាណិជ្ជកម្មនាវាចរណ៍។

អង្គរបុរីព័ទ្ធជុំវិញដោយកំពែងឥដ្ឋយ៉ាងធំ ដោយមានកសិន្ធុ ទាំងនៅក្នុងទាំងនៅក្រៅកំពែង ដែលបង្ហាញទម្រង់ជាទីក្រុងចំណាស់។ កំពែងនេះមានបណ្តោយ ៥,៧ គីឡូម៉ែត្រ ទទឹង ២០ ម៉ែត្រ និងកម្ពស់ពី ៤ ទៅ ៧ ម៉ែត្រ។ កសិន្ធុនេះត្រូវបានប្រើប្រាស់ជាមធ្យោបាយគ្រប់គ្រងទឹកផង។

អូកែវ គឺជាកំពង់ផែសមុទ្រដ៏សំខាន់មួយ ដែលមានប្រព័ន្ធប្រឡាយខ្វាត់ខ្វែងភ្ជាប់ជាមួយនឹងដីគោក។ អាណាចក្រហ្វូណននៅបន្តអត្ថិភាពរបស់ខ្លួន រហូតដល់សតវត្សទី៧ នៅពេលដែលអានុភាពរបស់ចេនឡា ដែលជារដ្ឋកសិកម្មនៅប៉ែកខាងជើង បានក្លាយទៅជាមជ្ឈមណ្ឌលនយោបាយ និងសេដ្ឋកិច្ច។ ការធ្លាក់ចុះនៃហ្វូណន គឺអាចបណ្តាលមកពីប្រជាជនចាប់ផ្តើមចាកចេញពីតំបន់មាត់សមុទ្រ នៅដើមសតវត្សទី៧ ដើម្បីទៅប្រកបរបរធ្វើស្រែចម្ការនៅក្នុងតំបន់វាលទំនាបជិតបឹងទន្លេសាប។ ប្រការនេះធ្វើឱ្យតួនាទីរបស់«អូកែវ» ធ្លាក់ចុះ ហើយមជ្ឈមណ្ឌលនយោបាយ និងទីប្រជុំជនបានរើចូលទៅភាគខាងក្នុងប្រទេសជិតបឹងទន្លេសាប។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia




ព្រែកជីកភ្ជាប់អង្គរបុរីទៅកំពង់ផែអូកែវ

## ព្រះមហាក្សត្រមុនអង្គរ (ឯកសារចិន)

| ឈ្មោះព្រះមហាក្សត្រ | គ្រិស្តសករាជ | រាជធានី | ប្រភពឯកសារ |
|---|---|---|---|
| *ហ្វាន ឆេមាន (ស្រមារៈ)* | *២២៥-២៣០?* | Te Mu (*អង្គបុរី?*) | *វ៉ូកាញ់* (VO-CANH) |
| *ហ្វាន់ ត្សាន់* | *២៤៣* | Te Mu (*អង្គបុរី?*) | *ឯកសារចិន* |
| *ហ្វាន់ ស្យុន* | *២៤៤-២៨៩* | Te Mu (*អង្គបុរី?*) | *ឯកសារចិន* |
| *ត្សាន់តាន់ (អូកែវ)* | *៣៥៧* | Te Mu (*អង្គបុរី?*) | *ឯកសារចិន* |
| *កៅណ្ឌិន្យ* | *៤០០* | Te Mu (*អង្គបុរី?*) | *ឯកសារចិន* |
| *ស្រីជ័យវម៌្ម* | *៤៨៤-៥១៧* | Te Mu (*អង្គបុរី?*) | *ចិន និងសិលាចារឹក* |
| *ស្រីរុទ្រវម៌្ម ទី ១ (បុត្រព្រះបាទជ័យវម៌្ម)* | *៥១៧-៥៣៩* | Te Mu (*អង្គបុរី?*) | *ចិន និងសិលាចារឹក* |

## ១.១.៤. សិលាចារឹកវ៉ូកាញ់

*សិលាចារឹក វ៉ូកាញ់* (VO-CANH) *ជាភាសាសំស្ក្រឹត ចារក្នុងរវាងសតវត្សទី២ ឬទី៣នៃគ្រិស្តសករាជ គឺជាសិលាចារឹកដែលមានវ័យចាស់ជាងគេនៅអាស៊ីអាគ្នេយ៍ ដែលមានរូបរាងអក្សរដូចគ្នាទៅនឹងសិលាចារឹកមថុរា (ឆ្នាំ១៥៦ គ.ស.) របស់ឥណ្ឌា។*[5] *សិលាចារឹកនេះរកឃើញនៅតំបន់ខេត្តញ៉ាត្រាង* (NHA-TRANG) *ប្រទេសវៀតណាម ដែលធ្លាប់ជាសាមន្តរាជរបស់នគរភ្នំ។*[6]

*«ព្រះរាជាព្រះនាមព្រះបាទស្រីមារៈ (គ្រីមារ) ជារាជកុល ក្នុងសម័យនគរភ្នំ ទ្រង់មានព្រះទ័យជ្រះថ្លាក្នុងសាសនា ហើយទ្រង់ត្រាស់បង្គាប់ឱ្យចារឹកទុក... ទ្រង់បង្គាប់ឱ្យចំណាយព្រះរាជទ្រព្យ ធ្វើជាប្រយោជន៍ដល់ សាធារណជនទូទៅ ឱ្យសមតាមព្រះរាជបំណង ដែលទ្រង់មានព្រះទ័យប្រកបដោយមេត្តាករុណា ប្រាថ្នាចង់ដោះទុក្ខសត្វ ដែលកំពុងតែហែលឆ្លង កាត់សមុទ្រសាគរ គឺសង្សារវដ្ត។ ព្រះរាជាទាំងឡាយតទៅមុខចូរប្រត្តិបត្តិ តាមព្រះរាជបញ្ជានេះ ហើយប្រឹក្សាជាមួយអាមាត្យឈ្មោះ វីរៈ»។*

5. *យៀង វីរបុត្រ*, 2017
6. Finot, 1928



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



*សិលាចារឹកវ៉ូកាញ់* ( Vo-canh)

## ១.១.៥. អង្គរបុរី ជាជម្រុកវប្បធម៌បុរេអង្គរ

*អង្គរបុរីនៅរីកចម្រើន រហូតដល់សតវត្សទី៧ នៅពេលដែលអានុភាពរបស់ឦសានបុរៈ ដែលជារដ្ឋកសិកម្មនៅប៉ែកខាងជើង បានក្លាយទៅជាមជ្ឈមណ្ឌលនយោបាយ និងសេដ្ឋកិច្ច។ គេបានរកឃើញផងដែរនូវសិលាចារឹកជាភាសាសំស្ក្រឹតយ៉ាងកម្រ។ សិលាចារឹកវត្តផ្គាំ* K. 28 *ខេត្តតាកែវ គឺជាសិលាចារឹកជាភាសាខ្មែរ ចារនៅសតវត្សទី ៦ ដែលបង្ហាញពីការប្រើប្រាស់ភាសាខ្មែរជាលាយលក្ខណ៍អក្សរ។*[7]

*សិលាចារឹក* K. 946៖ *ដែលមានសិលាចារឹកពីរជុំ ជាអត្ថបទក្នុងសតវត្ស ទី៦។*

---

7. *ឡុង សៀម*, 1997



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



*ព្រះពុទ្ធរូបកាច់ចង្កេះ*
*សតវត្សទី៧?*



Ka. 26 *វត្តគំនូរ សតវត្សទី៦-៧?*
*( សារមន្ទីរអង្គរបុរី)*



Ka.1254 អង្គរបុរី សតវត្សទី៧-៨? នមស្សការ ទៅព្រះហរិ ( នារាយណ៍) ស្រីត្រីភូវនញ្ជយ



កុលាលភាជន៍បុរេអង្គរនៅអង្គរបុរី



## ១.១.៦. លិង្គបុរៈ នៅសតវត្សទី៥ និងទី៦

*ឯកសារចិន* History of the Liang Dynasty *បានបញ្ជាក់ថា នៅពេលដែលស្តេចគ្រប់គ្រងហ្វូណានចូលទិវង្គតនៅឆ្នាំ ៥៥០ ចលាចលបានកើតឡើង។ នៅពេលនោះ ស្តេចចេនឡា (ភវវម៌្មទី១) ដែលជាសាមន្តរដ្ឋនៅខាងជើងប្រទេស បានឆក់យកឱកាស ដើម្បីវាយយក ហ្វូណាន ជាសាមន្តរដ្ឋវិញ។*

*ឯកសារចិន* History of the Sui *បានបញ្ជាក់ថា ចេនឡាលាតសន្ធិតនៅខាងត្បូងឆៀងខាងលិចនៃលីនយី ប្រហែលនៅចន្លោះចម្ប៉ា និងវៀតណាមដែលមានរាជធានីនៅបាសាក់ ស្ថិតនៅចំកណ្តាលទន្លេមេគង្គ នៅលើខ្នងភ្នំដែលមានប្រាសាទមួយស្ថិតនៅចំកំពូលភ្នំ។* Cœdès *បានសន្និដ្ឋានថា រាជធានីរបស់ចេនឡាស្ថិតនៅត្រង់វត្តភូ ដែលបែរមុខទៅទន្លេបាសាក់ ហើយនៅលើកំពូលភ្នំនេះមានលិង្គឥស្វរ ភទ្រេស្វរៈ* (Bhadresvara) *ដែលអ្នកស្រុកគោរពបូជា។ ថ្វីត្បិតតែសម័យចេនឡាចាប់ផ្តើមពីចុងសតវត្សទី៦ រហូត*



ដល់សតវត្សទី៩ ក៏ប៉ុន្តែចេនឡា គឺជារដ្ឋដែលមានអត្ថិភាពតាំងតែពីសម័យហ្វូណនមកម៉្លេះ ហើយពីពេលមុនចេនឡា គឺជាសាមន្តរដ្ឋរបស់ហ្វូណន។[8]

## វត្តភូ និងការបង្កើតអាណាចក្រ «កម្ពុជ»

លិង្គបុរៈ ដែលជាបុរាណស្ថានដ៏ចំណាស់ ដែលស្ថិតនៅតាមជ្រលងទន្លេសេមូន និងផ្នែកខាងជើងនៃកម្ពុជា។ វត្តភូមានទំនាក់ទំនងជាមួយសម្ភុបុរៈ និងខេត្តស្ទឹងត្រែងផងដែរ។ ស្តេចដែលកសាង «លិង្គបុរៈ» ឬ វត្តភូ ព្រះនាម «ស្រេស្ឋវរ្ម័ន» ដែលមានបិតាព្រះនាម «ស្រុតវរ្ម័ន»។ ស្រេស្ឋបុរៈស្ថិតនៅជិតវត្តភូផង។

នៅពាក់កណ្តាលទី២ នៃស.វ.ទី៦ លិង្គបុរៈមានអានុភាពកាន់តែខ្លាំងឡើងៗ ហើយគឺជារាជធានីរបស់ព្រះបាទភវវរ្ម័ន ទី១។ តាមប្រភពសិលាចារឹកសតវត្សទី៥ រកឃើញនៅជិតវត្តភូ ព្រះបាទភវវរ្ម័ន ទី១ និងចិត្រាសេន បានចេញពីវត្តភូ ដើម្បីវាតទីពង្រីកទឹកដី ដោយលេបយកអាណាចក្រភ្នំ។ អាណាចក្រថ្មីនេះ លាតសន្ធឹងតាមដងទន្លេមេគង្គ ពីសម្បូណ៌ទៅដល់កំពង់ចាម រួចហើយក៏ឆ្ពោះទៅដល់យកអាណាចក្រភ្នំជាចំណុះនៅឆ្នាំ៥៥០។

មកទល់សតវត្សទី៧ អាណាចក្រភ្នំត្រូវបានសាមន្តរដ្ឋរបស់ខ្លួនវាយដណ្តើមយក ហើយស្រូបចូលបន្តិចម្តងៗទៅក្នុងទឹកដីនៃអាណាចក្រថ្មី។ History of the Sui (៥៨១-៦២០) ហៅឈ្មោះរដ្ឋនេះថា «ចេនឡា» តែសិលាចារឹកភាសាសំស្ក្រឹតហៅថា «កម្ពុជ»។

តាមមតិលោក Cœdès រដ្ឋដ៏មហិមានេះលាតសន្ធឹងជិតស្មើនឹងអាណាចក្រខ្មែរ ហើយចែកជាចេនឡាដីគោក ដែលគ្របដណ្តប់ទឹកដីកម្ពុជាបច្ចុប្បន្ន និងខ្ពង់រាបកូរ៉ាត និងចេនឡាទឹក ដែលគ្របដណ្តប់ដីសណ្តទន្លេមេគង្គ។[9]

8 Cœdès, 1968:65-67
9. Coedès, 1968:65-67



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# តារាងសិលាចារឹកមុនអង្គរ

| AD | I | U | V | W | Z | T | R | P | M | H | K | G | D | C-F-E-B-J | Unkown |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Not datable | K.126 | K.755<br>K.811 | | K.11, K. 719<br>K.422 | | K.37 | K.788, K.820<br>K.903,K416 | | | K.441 | | K.159 | | | |
| 600-11 | | K.600/611 | | | | | | | | K.439/Bh | | | | | |
| 612-20 | K.926/624 | K.748/613 | K.60/626<br>K.54/629 | | | K.76 | | K.102 | | K.482 | K.138/620 | | | | |
| 621-30 | | K.709<br>K.790 | | K.13/624<br>K.1, K.22 | | | K.80 | | | K.504/627<br>K.440, K 442 | | | | | |
| 631-40 | K.430<br>K.129 | K.939<br>K.41, K.30 | | K.21, K. 483 | K.9/639<br>K.884<br>K.6, K.8 | | K.42/1 | K.66 | K.81 | K.438<br>K.449<br>K.4337<br>K.451 | K.733 | K.163 | K.658 | K.506/637<br>K.505/639<br>K.1150 | |
| 641-50 | | K.79/639-44 | K.51<br>K.956 | | | K.710<br>K.559 | K.427,K785<br>K.73/K.718 | K.109/655<br>K.493/657 | | | | | | | |
| 651-60 | | K.137, K.24 | K.49/664<br>K.53/667<br>K.55 | K.423, K. 46<br>K.562 | | K.563<br>K.1010 | K.78/K.786<br>59xSaka | | K.648<br>K.90 | K.439<br>K.B16 | K.155 | K.818 | | | |
| 661-70 | | K.25/ K.555<br>K.670 | | K.689 | | L/666/670 | K.426,K.940<br>K.664 | K.762/673 | K.725<br>K.115/665 | | K.757<br>K.140/676 | | | | |
| 671-80 | K.127/683<br>K.133 K. 480 | K.38 | K.652/687 | K.44/674 | | K.560<br>K.765/679 | K.154/585 | | | | | | K.922 | | K.964 |
| 681-90 | | | | K.561/681 | | | | K.113/6987 | K.726 | | | | | | |
| 691-700 | K.132/708<br>K.121/716<br>K.133 | | | | K.3 | K.582/693<br>K.74/697 | | K.107 | | | K.145/706 | | K.753/704<br>K.904/713<br>K.259<br>K.688/719 | | K.728<br>K.1142 |
| 701-20 | K.927/728 | K.1004/691 | | | | | | | | | K.146 | | | K.341 | |
| 721-30 | | | | K.18/726 | | | K.1029/763-74 | | | | | | | K.589,K.590 | |
| 761-70 | | | | | | | | K.103/770 | K.428/751 | | | | | | |
| 771-803 | K.134/781<br>K.124/303 | | K.48/Jay II | | | | | | | | | K.162/J. IV ref. 8th c. | K.583/ref 790 | | |
| Ankor | | | K.518, K. 1036 | | K.7, K.421 | | | | | | | | | | |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ចារឹកអ្នកតាដំបងដែក K-875

សិលាចារឹកមូលស្ថាបនាអ្នកតាដំបងដែក ខេត្តតាកែវ K-875 គឺជាចារឹកមួយ ក្នុងចំណោមចារឹកចាស់ជាងគេបំផុតនៅកម្ពុជា ចារក្នុងសតវត្សទី៥-៦។ អត្ថបទចងក្រងជា ៥ គាថាជាភាសាសំស្ក្រឹត តាមព្រះរាជសវនីយ៍ព្រះនាង កុលប្រភាវតី ដែលជាព្រះឯកអគ្គមហេសីសំណព្វនៃព្រះបាទស្រីជ័យវម្ម័ (៤៨៤-៥១៧)។

ល្បះទី១ជាពាក្យសំបូងសង្រួង សូមឱ្យព្រះនារាយណ៍ដែលផ្ទំលើពស់សេស: (គេបនាគ) នៅមុនពេលបង្កើតលោកឱ្យជួយថែរក្សាព្រះនាង។

«គេឮសុសសាយថា ព្រះនាងគឺជាមហេសីសំណព្វនៃព្រះបាទជ័យវម្ម័ ប្រៀបបានទៅនឹងព្រះសចី ជាព្រះជាយាសំណព្វនៃព្រះឥន្ទ ក៏ប្រៀបបានទៅនឹងព្រះស្វាហា ជាព្រះជាយាសំណព្វ នៃព្រះអគ្និ អណ្តាតភ្លើង៧ ក៏ប្រៀបបានទៅនឹងព្រះរុទ្រាណី ជាព្រះជាយាសំណព្វនៃព្រះឥសូរ ប្រៀបបានទៅនឹងព្រះគ្រី (ព្រះលក្ស្មី) ជាព្រះជាយាសំណព្វនៃព្រះនារាយណ៍ (ល្បះទី២)៕»




ចារឹកអ្នកតាដំបងដែក K-875



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ទំនាក់ទំនងរវាងលិង្គបុរៈ និងសម្ភុបុរៈ

*លិង្គបុរៈ ដែលជាបុរាណស្ថានដ៏ចំណាស់ ដែលស្ថិតនៅតាមជ្រលងទន្លេសេមួន និងផ្នែកខាងជើងនៃកម្ពុជា។ វត្តភូមានទំនាក់ទំនងជាមួយសម្ភុបុរៈ និងខេត្តស្ទឹងត្រែងផងដែរ។ ស្ដេចដែលកសាង «លិង្គបុរៈ» ឬ វត្តភូ ព្រះនាម «គ្រេម្ពវម៌្ម» ដែលមានបិតាព្រះនាម «គ្រុតវម៌្ម»។ គ្រេម្ពបុរៈ ស្ថិតនៅជិតវត្តភូផង។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# II- កំណើតភាសាសរសេរខ្មែរ ចាស់នៅសតវត្សទី៦

## ១.២.១. សិលាចារឹកបុរេអង្គរ



ការបែងចែកដំណាក់កាលនៃការវិវត្តខាងផ្នែកភាសា និងសំណេរ ដោយឈរលើមូលដ្ឋាននៃសិលាចារឹកបានបង្ហាញថាៈ

(១)ដំណាក់កាលបុរេអង្គរៈ ចាប់ផ្ដើមពីសិលាចារឹក K. 600 ចារនៅឆ្នាំ ៦១១ ដល់ឆ្នាំ ៧៩០ (បូក K. 124 ចារនៅឆ្នាំ ៨០៣)

(២)ដំណាក់កាលអង្គរ ៖ ចាប់ផ្ដើមពីឆ្នាំ ៨៧៧ នៃសិលាចារឹកព្រះគោ។ សិលាចារឹកបុរេអង្គរទាំងអស់មានចំនួនប្រមាណជា ៤៧០។ បញ្ជីដែលរៀបចំឡើង ដោយលោក Cœdes មានចំនួន ២៣០ ដល់លេខ K. 1050។ បន្ទាប់មកលោក Jacques បានបំពេញបន្ថែមដល់ចំនួន ៣៣០ ហើយលេខ ចុះបញ្ជីដល់ K. 1150។ បន្ទាប់ពីឆ្នាំ ១៩៩១ គេបានរកឃើញសិលាចារឹកបុរេអង្គរថ្មីៗទៀតចំនួនប្រមាណជា ១៣៤។

ក្នុងចំណោមសិលាចារឹកបុរេអង្គរទាំងនោះ សិលាចារឹកភាសាខ្មែរ មានចំនួន ៥២ និងសិលាចារឹកភាសាសំស្ក្រឹតមានចំនួន ២៥៧។ សិលាចារឹក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បុរេអង្គរចំនួន ៥៤ មានកាលបរិច្ឆេទត្រឹមត្រូវ។[10]

## ១.២.២. ការបង្កើតអក្ខរក្រមខ្មែរចាស់

ព្រឹត្តិការណ៍សំខាន់នៅក្នុងសតវត្សទី៦ គឺការនិយមចារសិលាចារឹកជាភាសាខ្មែរ។ ការស្រាវជ្រាវបង្ហាញឱ្យឃើញថា ចាប់ពីសតវត្សទី ៦ មកទើបប្រជាជនកម្ពុជាចាប់ផ្តើមមានឯកសារសរសេរជាអក្សរបុរាណ។ ដូនតាខ្មែរបានខ្ចីអក្សរពីប្រទេសឥណ្ឌានៅអំឡុងសតវត្សទី៥ ដោយចម្លង សម្រួល និងកែច្នៃតាមតួអក្សរព្រាហ្មី ( Brahmi ) ក្នុងសម័យរាជវង្សបល្លវៈ ( Pallava ) និងចាលុក្យៈ ដែលគេប្រើនៅប្រទេសឥណ្ឌាភាគខាងត្បូង និងអាគ្នេយ៍នៅសតវត្សទី៥ និងទី៦ នៃគ្រិស្តសករាជ ដើម្បីប្រើប្រាស់ជាទម្រង់សម្រាប់សរសេរភាសាខ្មែរបុរាណ ប្រើប្រាស់សម្រាប់សរសេរអត្ថបទលើសិលាចារឹក។[11] បន្ទាប់មកសៀម និងឡាវបានខ្ចី អក្សរខ្មែរនៅសម័យអង្គរយកទៅប្រើ។[12]

សិលាចារឹកភាសាខ្មែរចាស់ ដូចជាសិលាចារឹក K. 28 នៅខេត្តតាកែវ សិលាចារឹកK. 137 នៅខេត្តក្រចេះ និងសិលាចារឹកK. 426 នៅខេត្តកណ្តាល ដែលមានអក្ខរក្រមប្រហាក់ប្រហែលនឹងអក្ខរក្រម ដែលប្រើក្នុងសិលាចារឹកទាំងនេះបញ្ជាក់ថា ភាសាខ្មែរបុរាណត្រូវបានប្រើប្រាស់ក្នុងសំណេរចាប់ពីសតវត្សទី៦ ថ្វីត្បិតតែសិលាចារឹកភាសាខ្មែរមានកាលបរិច្ឆេទត្រឹមត្រូវមាននៅដើមសតវត្សទី៧ក៏ដោយ។[13]

---

10 Vickery 1998

11. វង់ សុធារ៉ា, 2003, អាំង ជូលាន, 2018

12. Uraisi Varasarin, 1984

13. ឡុង សៀម, ១៩៩៦



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១.២.៣. សិលាចារឹកមហាសករាជទី៥

ចាប់ពីសតវត្សទី៦ ដល់ទី៨ មជ្ឈមណ្ឌលវប្បធម៌បុរេអង្គរបានលេចឡើង នៅតាមដងទន្លេមេគង្គ ចាប់តាំងពីតំបន់វត្តភូនៅភាគខាងត្បូងនៃប្រទេសឡាវ ចុះមកខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម កណ្ដាល រហូតដល់កំពង់ស្ពឺ។

សិលាចារឹកភាសាសំស្ក្រឹត គ្មានកាលបរិច្ឆេទ ដែលប្រហែលជាចារក្នុងសតវត្សទី៦ និងដើមទី៧ ត្រូវបានរកឃើញនៅតាមតំបន់ឆ្ងាយនៅលើទឹកដីកម្ពុជាបុរាណ ដូចជា៖

នៅប្រទេសថៃ៖ (១) ស៊ីទេព K. 499 (មហាសករាជទី៤-៥); K. 975 (មហាសករាជទី៥);

នៅតាកែវ៖ អ្នកតាដំបង់ដែក K. 875 (មហាសករាជទី៥); វត្តបាទី K. 40 (មហាសករាជទី៥)

នៅកូសាំងស៊ីន៖ (១) ថាប់ មួយ, ប្រាសាទប្រាំល្វែង K. 5 (មហាសករាជទី៥); (២) ចាប់ដា វត្តចេតីយ K. 924 (មហាសករាជ ទី៥), និងសិលាចារឹក K. 365

នៅបាសាក់ ប្រទេសឡាវ៖ វត្តភូ/វត្តល្អួងកៅ K. 365 (មហាសករាជទី៥)

### ១.២.៤. សិលាចារឹកមហាសករាជទី៦

នៅបន្ទាយមានជ័យ៖ ភ្នំបន្ទាយនាង K. 213 (មហាសករាជទី៦);

នៅប្រទេសថៃ៖ (១) ស៊ីទេព K. 978 (មហាសករាជទី៦); នគររាជសីមា K. 1009;

នៅបាសាក់ ប្រទេសឡាវ៖ ច័ន្ទណាខោន ចំប៉ាសាក់ K. 363 (មហាសករាជទី៦)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្រចេះ៖ (១) វត្តជ្រោយអំពិល K. 116 (មហាសកករាជទី៦); (២) ថ្មក្រៃ K. 122 (មហាសកករាជទី៦)

នៅព្រៃវែង៖ ក្តីអង្គ K. 55 (មហាសកករាជទី៦)

សិលាចារឹកភាសាខ្មែរ គ្មានកាលបរិច្ឆេទ ដែលប្រហែលជាចារក្នុងសតវត្សទី៦ ត្រូវបានរកឃើញនៅតាមតំបន់ផ្សេងៗ ដូចជា៖

នៅតាកែវ៖ (១) វត្តឈ្នះ K. 755; ពពេល K. 719; វត្តលើ K. 422, K. 11; ប្រាសាទនាងខ្មៅ K. 37; (២) អង្គរបុរី K. 548

កំពង់ស្ពឺ៖ វត្តចាស់ K. 416; វត្តអង្គសិរី K. 788

កណ្តាល៖ អ្នកតាស្វាយដំបូ K. 903

នៅក្រចេះ៖ (១) សំបូរ K. 130

## ១.២.៥. មជ្ឈមណ្ឌលវប្បធម៌ខ្មែរដំបូង (សតវត្សទី ៦ និងដើមទី ៧ នៃគ្រិស្តសករាជ)

ប្រសិនបើយើងវិភាគប្រភពនៃសិលាចារឹកសតវត្សទី៦ យើងឃើញថា មជ្ឈមណ្ឌលវប្បធម៌ និងសាសនាសំខាន់ៗ ដែលជារដ្ឋមុនការបង្កើតអាណាចក្រខ្មែរមានតំបន់បីសំខាន់ គឺ៖

តំបន់ខ្ពង់រាបកូរ៉ាត៖ ចារឹកស៊ីទេពចំនួន៣ K. 499, K. 975

អង្គរបុរី-អូកែវ-កូសាំងស៊ីន៖ ចារឹកប្រាសាទប្រាំល្វែង K. 5 ផ្សារដែក, ចារឹកវត្តបាទី K. 40 តាកែវ, ចារឹកវត្តចេតីយ K. 924 និងសិលាចារឹក វត្តជ្រោយ K.946៖ ដែលមានសិលាចារឹកពីរជុំ ជាអត្ថបទក្នុងសតវត្សទី៦។

លិង្គបុរៈ (វត្តភូ)៖ ចារឹក វត្តភូ K. 365។

អក្ខរក្រមខ្មែរចាស់ នៅសតវត្សទី៦មានជើងវែងៗនិងមានលក្ខណៈដូចអក្ខរក្រម ឥណ្ឌាដែរ។ នៅពេលក្រោយមក ទើបអក្ខរក្រមខ្មែរចាស់ត្រូវបានកែសម្រួលឱ្យមានជើងខ្លីៗវិញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia




ចារឹកសតវត្សទី៦

## ១.២.៦. ព្រះបាទភវវម៌្ម ទី១ (៥៥០-៦០០)

*នៅពាក់កណ្ដាល សតវត្សទី៦ ព្រះបាទ «ភវវម៌្ម ទី១» (ជនដែលព្រះសិវៈការពារ) (៥៥០-៦០០) ដែលជាបុត្រព្រះបាទវីរវម៌្ម ដែលមានរាជាណាចក្រនៅលិង្គបុរៈ (វត្តភូ) បានបង្កើតនិវាសនដ្ឋាននៅភវបុរៈ នៅភាគខាងជើងនៃបឹងទន្លេសាប ប្រហែលជានៅម្ដុំជិតតំបន់សំបូរព្រៃគុក។*

*ចាប់ពីពាក់កណ្ដាលទី២ នៃ ស.វ.ទី ៦ ព្រះបាទភវវម៌្ម ទី១ បានវាតទីពង្រីកអានុភាពលើដែនដីនៃវ្យាធបុរៈ ហើយបង្កើតអាណាចក្រខ្មែរនៅប្រមាណឆ្នាំ ៥៥០ ដែលមានដែនដីលាតសន្ធឹងតាមដងទន្លេមេគង្គពីលិង្គបុរៈរហូតដល់សម្ភុបុរៈ (សំបូរ)។*

*សិលាចារឹកក្នុងរជ្ជកាលនេះ គឺជាចារឹកដើម្បីប្រារព្ធការស្ថាបនាព្រះលិង្គ ដើម្បីឧទ្ទិសដល់ព្រះសិវៈមានព្រះនាមផ្សេងៗ៖*

*(១) សម្ភុ (នៅថ្មក្រែ, វត្តជ្រោយអំពិល K. 116 ខេត្តក្រចេះ និងចារឹកថាំបិតថុង K. 513, K. 514 នៅបុរីរម្យ)*

*(២) ត្រ្យម្ពក (ភ្នំបន្ទាយនាង K. 213 នៅបន្ទាយមានជ័យ) និង*

*(៣) ត្រិភូវមេគ្វរ (វាលកន្ដាល)៖ ចារឹក K. 359 រកឃើញនៅវាលកន្ដាល ទន្លេរពៅ ជិតប្រទេសឡាវ (ចុងសតវត្សទី៦) និយាយពីព្រាហ្មណ៍*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សោមាគម្ម័ ដែលជាស្វាមីរបស់បុត្រីនៃព្រះបាទ វីរវម្ម័ និងជាប្អូនស្រីរបស់ព្រះបាទភវវម្ម័ទី១ (ចុងសតវត្សទី៦) បានស្ថាបនារូបបដិមា «ត្រីភូវមេឝ្វរ» (ម្ចាស់នៃលោកទាំងបី)។ ព្រាហ្មណ៍បានប្រគល់តង្វាយជារបស់របរ អ្នកបម្រើ និងសៀវភៅ «មហាភារត» «រាមាយន» និង «បុរាណាស»។ អ្នកដែលអានសៀវភៅទាំងនេះនឹងទទួលផលបុណ្យ ហើយអ្នកដែលធ្វើឱ្យអន្តរាយដល់សៀវភៅទាំងនេះនឹងទទួលបណ្តាសា។

សិលាចារឹកផ្សេងទៀត ដែលផ្តល់ព័ត៌មានពីព្រះបាទភវវម្ម័ និងព្រះរាជាដទៃទៀត៖

K. 213៖ បាត់ដំបង ៖ ភវវម្ម័

K. 978៖ ស៊ីទេព ៖ ព្រះបាទភវវម្ម័ ជាបុត្ររបស់ ប្រថិវីន្ទ្រវម្ម័ និងជាចៅរបស់ព្រះបាទចក្រវតិន

K. 359៖ ស្ទឹងត្រែង ៖ ហិរណ្យវម្ម័ ជាបុត្ររបស់សោមគម្ម័ ជាមួយនឹងប្អូនស្រីរបស់ភវវម្ម័ ដែលជាបុត្រីរបស់ព្រះបាទ វីរវម្ម័។

## សិលាចារឹកវត្តបាទី K. 40

សិលាចារឹកវត្តបាទី (K. 40)៖ គ្មានកាលបរិច្ឆេទ ភាសាសំស្ក្រឹតចំនួន ២២ បន្ទាត់ (១០ ស្លោក ឬគាថា) ចារលើមេទ្វារប្រាសាទ ជាអក្សរព្រហ្មីសម័យមុនអង្គរ រកឃើញនៅវត្តបាទី ភូមិថ្នល់ទក្សិណ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ។

រៀបរាប់ពីព្រះបាទ ស្រីរុទ្រវម្ម័ ដែលជាព្រះរាជាដ៏ឯក ប្រាថ្នានូវការប្រព្រឹត្តអំពើសប្បុរស និងការប្រតិបត្តិធម៌ និងបានបំពេញតួនាទីជាឧបាសកដ៏ប្រសើរបរិសុទ្ធ។[14]

---

14. យៀង វីរបុត្រ, 2017



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បញ្ជាក់ថា ព្រះបាទស្រីជ័យវម៌្ម គឺជាព្រះវររាជបិតារបស់ព្រះបាទរុទ្រវម៌្ម ដែលទ្រង់ត្រូវបានតែងតាំងជាព្រះរាជអធិការកិច្ចត្រួតពិនិត្យមើលក្រុមរាជវង្សានុវង្ស ដែលជាក្រុមអាចារ្យប្រធានខាងព្រហ្មញ្ញសាសនា។ ប្រភពចិនបានឱ្យដឹងថា ព្រះបាទ ស្រីជ័យវម៌្ម និងព្រះបាទ រុទ្រវម៌្ម គឺជាព្រះរាជាចុងក្រោយនៃអាណាចក្រហ្វូណនហើយ គឺព្រះបាទរុទ្រវម៌្ម ជាមួយនឹងស្រីស្នំរបស់ព្រះអង្គ ដែលឡើងសោយរាជ្យបន្ទាប់ពីបានធ្វើគុតព្រះអង្គម្ចាស់ស្របច្បាប់រួចមក។[15]

## សិលាចារឹករបងរមាស K. 151



n. 281 haut / K. 151

សិលាចារឹករបងរមាស (K.151)៖ សិលាចារឹកភាសាសំស្ក្រឹតចារឹកពីរបងរមាស ជិតសំបូរព្រៃគុកនៅសតវត្ស ទី៦ បញ្ជាក់ថា ព្រះបាទភវវម៌្ម ទី១ ព្រះអង្គបានសោយរាជ្យនៅឆ្នាំ ៥៩៨ (ស្ដេចគរតេទ្រ្ទបុរេស្វរ ព្រះនាមនរសិង្ហគុប្តប្រកាសថា ខ្លួនជាស្ដេចចំណុះឱ្យព្រះរាជាភវវម៌្ម ដែលទ្រង់សោយរាជ្យនៅឆ្នាំ ៥៩៨)។[16] សិលាចារឹកភ្នំបន្ទាយនាង មង្គលបុរី ខេត្តបាត់ដំបង រៀបរាប់ពីការកសាងលិង្គព្រះឥស្វរ និងសិលាចារឹកស៊ីទេព និយាយពីការកសាងសិលាចារឹកនៅពេលដែលព្រះបាទភវវម៌្មឡើងសោយរាជ្យ។

15. Cœdes (1931)
16. Vickery, 1998:336

## សិលាចារឹកស៊ីទេព K. 978



សិលាចារឹកស៊ីទេព K.978 (សតវត្សទី៦)៖ រកឃើញនៅ ឆ្នាំ ១៩៨៦ នៅស៊ីទេព (ស្រីទេព) ខេត្ត ពេជ្របុ៊ន មាន១២ បន្ទាត់ សរសេរ ក្នុងរាជ្យព្រះបាទជ័យវម៌្ម ទី១ និង បានបញ្ជាក់ពីសែស្រឡាយ ស្តេច តភ្ជាប់គ្នា តាំងពីរាជ្យព្រះបាទ កៅណ្ឌិន្យ ទី២ រហូតមក និងថា ព្រះបាទភវវម៌្ម ទី១ គ្រប់គ្រងកម្ពុជា នៅសតវត្សទី៦ ចាប់ពីតំបន់ស៊ីទេព ចុះមកកម្ពុជាបច្ចុប្បន្ន និងពិពណ៌នា ពីចៅនៃព្រះបាទស្រីចក្រវាទិន ឈ្មោះភវវម៌្ម ដែលមានឫទ្ធិតេជះបីដូចជា ព្រះឥន្ទ និងបានកសាងព្រះបដិមា ព្រះសិវៈ ដើម្បីឡើងគ្រងរាជ្យ។ ព្រះបាទ វីរវម៌្ម ជាបិតាព្រះបាទមហេន្ទ្រវម៌្ម និងជាឪពុកមារបស់ព្រះបាទភវវម៌្ម ទី១ នោះ ក៏ជាស្តេចសោយរាជ្យដែរ។

## ១.២.៧. ស្ថាបត្យកម្មនៃប្រាសាទខ្មែរបុរេអង្គរ

ការសាងសង់ប្រាសាទបុរាណខ្មែរមានការវិវត្ត និងកែលម្អជាប្រចាំ ដែលឆ្លុះបញ្ចាំងពីដំណាក់កាលយុវវ័យ ភាពចាស់ទុំ និងជរាភាព។ អ្នកដែល សិក្សាសិល្បៈខ្មែរ បានបែងចែកប្រាសាទបុរាណខ្មែរជាស្ថាបត្យកម្មបុរេអង្គរ (ពីស.វ.ទី១ ដល់ ស.វ. ទី ៨) ស្ថាបត្យកម្មសម័យអង្គរ (ពី ស.វ.ទី ៩ ដល់ ស.វ. ទី ១៣) និងស្ថាបត្យកម្មក្រោយអង្គរ(ពីស.វ.ទី១៤ ដល់សព្វថ្ងៃនេះ) ។ លោក Jacquesបានគូសបញ្ជាក់ថា សិល្បៈខ្មែរបានវិវត្តទៅតាមវិធីសាស្ត្រ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បួនយ៉ាងគឺ៖

ទីមួយ-គឺ តក្កកម្ម មានន័យថា ការបង្កើតអ្វីៗថ្មីទាំងស្រុង ។

ទីពីរ-ការចូលរួមវិភាគទានពីសិល្បៈបរទេស (គឺពីសិល្បៈឥណ្ឌា តែក៏មានសារធាតុខ្លះនៃសិល្បៈជ្វា និង សិល្បៈចាមដែរ) ។

ទីបី-ការខ្ចីនូវរចនាបថពីអតីតកាល តែមិនបានចម្លងទាំងស្រុងនូវរចនាបថទេ ដោយគ្រាន់តែស្វែងរកប្រធានបទចាស់ៗ ដើម្បីបញ្ចូលសារជាថ្មី ដោយមានធ្វើវិសោធនកម្មទៅលើអ្វីដែលមានចាស់ ។

ទីបួន-ការចម្លងតាមនូវបច្ចេកទេសផ្សេងៗ ហើយអ្វីដែលគេច្រើនជួបប្រទះ គឺការចម្លងតាមនូវក្បូរក្បាច់រចនានៃសំណង់ឈើតូចតាច ។

## រចនាបថ ភ្នំដា (១)

រចនាបថប្រាសាទមុនសម័យអង្គរមាន៖ (១) រចនាបថភ្នំដា (២) រចនាបថសំបូរព្រៃគុក (៣) រចនាបថព្រៃក្មេង (៤) រចនាបថប្រាសាទអណ្តែត (៥) រចនាបថកំពង់ព្រះ និង (៦) រចនាបថគូលែន។

(១) រចនាបថ ភ្នំដា (រចនាបថចម្លាក់)

សិល្បៈខ្មែរនៃរចនាបថភ្នំដា គឺជាសិល្បៈដែលនៅក្មេងខ្ចីនៅឡើយ នៅក្នុងចន្លោះសតវត្សរ៍ទី៦ និងដើមសតវត្សរ៍ទី ៧។ ប្រាសាទភ្នំដា គឺជាប្រាសាទឥដ្ឋ ដែលសង់លើកំពូលភ្នំនៃខេត្តតាកែវ។ គេសង់ប្រាសាទពីថ្មបាយក្រៀម ដែលបន្ទុបលើខឿនប្រាសាទបុរាណ ហើយមានប្រអប់ទ្វារធ្វើពីថ្មភក់។ គេបានរកឃើញនូវសសរពេជ្រផងដែរ។ គេស្គាល់រចនាបថភ្នំដាតាមរយៈចម្លាក់ដ៏សែនស្រស់ស្អាតនៅភ្នំដារ។ តែតួប្រាសាទ គឺសាងសង់ក្នុងសតវត្សទី ១១ រីឯរចនាបថវិញ គឺសំដៅលើរូបបដិមាចំនួន ៣ ដែលរកឃើញក្នុងប្រាសាទខ្មែរនៅសតវត្សទី៧មានលក្ខណៈជាប្រាសាទតូចៗ ដូចជា៖ (១) ប្រាសាទភ្នំបាយ៉ង់ និង (៣) ប្រាសាទភ្នំហាន់ជ័យ។







ព្រះវិស្ណុដៃ៨ ភ្នំដា សតវត្សទី៦



ព្រះពុទ្ធវត្តរំលក អង្គរបុរី
រចនាបថភ្នំដា សតវត្សទី៦



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ១.២.៨. ស្ទឹងត្រែងនៅសតវត្សទី៦


ប្រាសាទព្រះគោថាឡាបរិវ៉ាត់

ស្ទឹងត្រែង គឺជាតំបន់ប្រវត្តិសាស្ត្រ ដ៏សំខាន់ក្នុងសម័យបុរេអង្គរ។ វត្តមាននៃប្រាសាទ និងសិលាចារឹកជាច្រើននៅខេត្តស្ទឹងត្រែង និងនៅថាឡាបរិវ៉ាត់ បានជំរុញអ្នកស្រាវជ្រាវឱ្យសន្និដ្ឋានថា ខេត្តស្ទឹងត្រែង ជាពិសេសតំបន់ថាឡាបរិវ៉ាត់ប្រហែលជាដើរតួនាទីសំខាន់ដូចជានៅសម្ភុបុរៈ (សំបូរ) ឬស្រេស្ឋបុរៈ (វត្តភូ) ដែរ។ ដោយមានសិលាចារឹកសតវត្សទី៦ គេបានថែមទាំងលើកឡើងពីសម្មតិកម្មមួយថា ខេត្តស្ទឹងត្រែង និងថាឡាបរិវ៉ាត់អាចជារាជធានីនៃព្រះបាទភវវរ្ម័ន ទី១ (៥៥០-) ផងដែរ ។[17]

17. Bruguier et Lacroix, T. IV, 2016



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## ១.២.៩. សិលាចារឹកសតវត្សទី៧

នៅសតវត្សទី ៧ នៃគ្រិស្តសករាជ ប្រទេសឥណ្ឌា មានឥទ្ធិពលយ៉ាងខ្លាំងមកលើអាណាចក្រខ្មែរ ដោយសារបណ្តាក្រុមឧបនិវេសន៍ដែលនាំយកអារ្យធម៌មកផ្សព្វផ្សាយ។ បន្តិចម្តងៗ គឺក្រុមឧបនិវេសន៍គឺជាអ្នកផ្សព្វផ្សាយព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា។

រាជវង្សស្តេចដែលសោយរាជ្យនៅអាណាចក្រខ្មែរសុទ្ធតែជាប់អម្បូរក្សត្រិយ៍ ឬព្រាហ្មណ៍។ ច្បាប់ទម្លាប់ ប្រពៃណីដែលគេអនុវត្តសុទ្ធតែមានប្រភពចេញមកពីឥណ្ឌា។ គេគោរពបូជាអាទិទេពរបស់ឥណ្ឌា គេអានសៀវភៅដែលសរសេរនៅឥណ្ឌា (K.359)។

សិលាចារឹកបុរេអង្គរភាគច្រើនបំផុត គឺជាសិលាចារឹកនៅសតវត្សទី ៧ ដែលមានចំនួនប្រមាណជា ២០០។ ភាសាខ្មែរចាស់បុរេអង្គរ គឺចារនៅចន្លោះឆ្នាំ ៦១១ និង ៧៩០។

ភាសាខ្មែរចាស់បុរេអង្គរ គឺជាភាសាដែលចារលើសិលាចារឹកប្រមាណជា ១៤០ ប៉ុណ្ណោះ។[18] លោក Jenner បានរាប់ពាក្យនៅក្នុងសិលាចារឹកបុរេអង្គរមានតែ ៤៧៦១ ពាក្យដែលមាននាម«ខ្ញុំ»ចំនួន ២០០០។

នៅសតវត្សទី ៧ គេបានរកឃើញសិលាចារឹកនៅតាមតំបន់ផ្សេងៗជាច្រើន ជាពិសេសតាមដងទន្លេមេគង្គ ដៃទន្លេមេគង្គ។ យើងយកចារឹកខាងក្រោមមកសិក្សា៖

(១) ចារឹក មហេន្ទ្រវម៌្ម-ចិត្រសេន (K. 969; K. 508; K. 122)

(២) ស្ទឹងត្រែង៖ (K. 1287; K. 1288; K. 360)

(៥) តាកែវ៖ (K. 600; K. 38; K. 79; K. 422; K. 13; K. 38)

(៣) សម្បុរៈ (ក្រចេះ)៖ (K. 127)

(៤) បាភ្នំ ខេត្តព្រៃវែង៖ K. 53 (ឆ្នាំ ៦២៨)

18. Vickery, 1998

( ៦ ) ភ្នំពេញ៖ (K. 428)

( ៧ ) កំពង់ចាម៖ (K. 81)

( ៨ ) កណ្តាល៖ (K. 664)

( ៩ ) កំពង់ធំ៖ ចារឹកសំបូរព្រៃគុក (K. 149; K. 436)

## ១.២.១០. មហេន្ទ្រវម៌្ម-ចិត្រសេន (៦០០-៦១៦)

នៅពេលដែលព្រះបាទភវវម៌្ម ទី១ ចូលទិវង្គត ប្អូនជីដូនមួយរបស់ព្រះអង្គព្រះនាមចិត្រសេន ឡើងសោយរាជ្យក្នុងគ.ស.៦០០ ដោយមានព្រះនាមព្រះបាទមហេន្ទ្រវម៌្ម។ ព្រះអង្គជាបុត្ររបស់ព្រះបាទវីរវម៌្ម និងជាព្រះអនុជរបស់ព្រះបាទភវវម៌្ម ទី១។ ទន្លេមេគង្គដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍ និងផ្សព្វផ្សាយវប្បធម៌ និងសាសនានៅសម័យមុនអង្គរ។

បន្ទាប់ពីវាតទីយកបាន «អាណាចក្រភ្នំ» ហើយព្រះអង្គបានស្ថាបនាចារឹកអង្គក្តី K. 53 នៅបាភ្នំ ដើម្បីឧទ្ទិសដល់អាទិទេព «គិរីឝ» ( ស្តេចសោយរាជ្យលើភ្នំ)។ សិលាចារឹកមហេន្ទ្រវម៌្មមានគោលដៅបោះបង្គោលព្រំប្រទល់អាណាចក្រ និងបង្ហាញថា ព្រះអង្គបានធ្វើសឹកសង្គ្រាមវាតទីបន្តពីព្រះរាមរបស់ព្រះអង្គទៅទិសខាងលិច និងខាងត្បូង។ សិលាចារឹកទាំងនេះ គឺជាអត្ថបទអក្សរសិល្ប៍ ចារឹកនៅដើមសតវត្សរ៍ទី ៧ មានលក្ខណៈសាមញ្ញខ្លីៗ សរសេរជាភាសាសំស្រ្កឹត និងលើកសរសើរដល់ព្រះរាជា ដែលហៅថា ប្រឝស្តិ (Praśasti)។

ក្នុងចំណោមសិលាចារឹកនៃព្រះបាទ ចិត្រសេន/ មហិន្ទ្រវម៌្ម ចំនួនជាង ២០ ដែលគេរកឃើញនៅកម្ពុជា ប្រទេសឡាវ និងប្រទេសថៃ ភាគច្រើនរកឃើញនៅជិតមាត់ទន្លេមេគង្គនិងដៃទន្លេមេគង្គហើយស្ថិតនៅរាយប៉ាយចាប់ពីតំបន់ខាងជើងនិងខាងត្បូងភ្នំដងរែក នៅតាមតំបន់វាលទំនាបនៃដងទន្លេមេណាមនៅភាគឦសាននៃប្រទេសថៃ និងខេត្តបាត់ដំបងដល់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខាងកើតវត្តភូ ខេត្តស្ទឹងត្រែង និងក្រចេះ[19]៖

K. 116៖ ស្ទឹងត្រែង ចិត្រសេន

K. 122៖ ថ្មក្រែ (ក្រចេះ) ចិត្រសេន

K. 514៖ ភូប៉ាត ចិត្រសេន

K. 363៖ ភូល្ខោន, បាសាក់, ឡាវ៖ ចិត្រសេន ដែលមានឈ្មោះថា មហេន្ទ្រវម៌្ម ជាព្រះអនុជរបស់ព្រះបាទ ភវវម៌្ម និងជាបុត្ររបស់ព្រះបាទវីរវម៌្ម។

K. 496-K. 497៖ ខាន់ថេវដា អ៊ូប៊ុន អត្ថបទដូច K. 363 ដែរ

K. 508៖ ចិត្រសេន ដែលមានឈ្មោះថា មហេន្ទ្រវម៌្ម ជាព្រះអនុជរបស់ព្រះបាទភវវម៌្ម និងជាបុត្ររបស់ព្រះបាទ វីរវម៌្ម និងជាចៅព្រះបាទសាវ៌ភោម ។

K. 1102៖ ខុន កែន អត្ថបទដូច K. 508 ដែរ

K. 1106៖ ភិម័យ អត្ថបទដូច K. 508 ដែរ

K. 377៖ សុរិន្ទ្ន ចិត្រសេន ដែលមានឈ្មោះថា មហេន្ទ្រវម៌្ម

K. 509៖ ថាំប្រាសាទ ចិត្រសេន ដែលមានឈ្មោះថា មហេន្ទ្រវម៌្ម

K. 969៖ ជងស្រះបែង ប្រទេសថៃ មហេន្ទ្រវម៌្ម

K. 1190៖ ប៉ាក់ដុម ប្រទេសថៃ

K. 1193 និង K. 1194៖ ជិតវត្តភូ ចំប៉ាសាក់ នៅប្រទេសឡាវ[20]

លោក Claude Jacques សន្និដ្ឋានថា សិលាចារឹក ចិត្រសេន ចារនៅពេលដែលព្រះអង្គមិនទាន់ឡើងសោយរាជ្យ ចំណែកឯសិលាចារឹក មហេន្ទ្រវម៌្ម ចារនៅពេលព្រះអង្គឡើងសោយរាជ្យ។

ខេត្តស្ទឹងត្រែង ដែលមានសិលាចារឹក K. 116 និង K. 122 គឺជាផ្នែកមួយនៃដែនដីគ្រប់គ្រងដោយចិត្រាសេន។

---

19. Vickery, 1998

20. Bruguier et Lacroix, T. IV, 2016



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សិលាចារឹកជខស្រះថែង K. 969 សតវត្សទី៧



| ចារឹក | ភាសាខ្មែរ | បកប្រែ[21] |
|---|---|---|
|  | *យគ្គ្រីមហេន្ទ្រវម្មតិ* | *ព្រះបាទ ស្រីមហេន្ទ្រវម្មនេះ* |
|  | *មហេន្ទ្រតវរិគ្រេតះ* | *ពិតជាប្រៀបដូចនឹង ព្រះមហេន្ទ្រ ( សិវ)* |
|  | *ស គង្ករ តដាកាខ្យ* | *ស្រះទឹកសង្ករ តដាកនោះ* |
|  | *ញ្ញ ខានេមញ្ចលាគយម* | *ត្រូវបានព្រះអង្គបញ្ជា ឱ្យជីកដើម្បីដាក់ទឹក* |

21. *យឿង វីរៈបុត្រ*, 2017



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia



## សិលាចារឹកថាំប្រាសាទ K. 508

| | |
|---|---|
| នប្តាគ្រីសាវ៌ភៅមស្យ | សូនុគ្រ្គីវីរវម៌្មណះ |
| គត្ត្យាន្ទូន ម្គនិប្ពោបិ | ភ្រាតា គ្រីភវវម៌្មណះ |
| គ្រីចិត្រសេន នាមាយ | បូ្វ៌មាហតលក្សណះ |
| ស គ្រីមហេន្ទ្រវម៌្មេតិ | នាមភេជេភិបេក្ខជម |
| ជិត្វេមន្ទេគមខិល | ង្គិរិគស្យេហភូភតិ |
| លិង្គន្និវេគយាមាស | ជយចិហ្នមិវាត្មនះ។ |

ព្រះអង្គជាចៅនៃស្តេចផែនដី ជាបុត្រនៃព្រះបាទស្រីវីរវម៌្ម
ប្រកបដោយអំណាចពិតប្រាកដ ទោះបីជាព្រះអនុជស្រីភវវម៌្ម
ព្រះនាម ស្រីចិត្រសេន មានលក្ខណៈសម្បត្តិដ៏ប្រពៃ
ទទួលព្រះនាម ស្រីមហេន្ទ្រវម៌្ម ក្រោយពីបានអភិសេករួច
ផ្ចាប់ច្បាំងឈ្នះគ្រប់ទិសទីទាំងអស់ ជាម្ចាស់ភ្នំព្រះឥសូរនិងជាស្តេចផែនដី
ហើយសាងសង់លិង្គមាស និមិត្តរូបនៃជ័យជម្នះព្រះអង្គ។[22]

22. *យៀង វីរៈបុត្រ*, 2017



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## សិលាចារឹកថ្មក្រែ K. 122

*ភូមិថ្មក្រែស្ថិតនៅតាមមាត់ទន្លេមេគង្គ ប្រមាណជា ៨ គីឡូម៉ែត្រពីទីរួមខេត្តក្រចេះ ដែលមានបេតិកភ័ណ្ឌបុរាណវិទ្យា និងប្រាសាទជាច្រើនដែលសាងសង់នៅសតវត្សទី៨។ គេរកឃើញនូវចារឹកជាច្រើនដែលចារលើសិលាដែលមាននៅថ្មក្រែ ជាសិលាស្ថាបនាដែលគ្មានជើង ដូចមានរក្សាទុកនៅសុព័រកាឡឺ និងនៅសារមន្ទីរខេត្តក្រចេះ។ សិលាចារឹកទាំងនេះចារនៅចុងសតវត្សទី៦ និងដើមសតវត្សទី៧ ដើម្បីកត់ត្រាពីការបង្កើតបូជនីយដ្ឋាន សាសនា (រូបបដិមា ព្រះលិង្គ និងព្រះគោ) និងការរៀបចំខាងផ្នែករដ្ឋបាលផ្សេងៗ។*

*សិលាចារឹក* K. 122*៖ ជាភាសាសំស្ក្រឹត មាន ៤ បន្ទាត់ ដែលលោក* Finot *បានបកប្រែនៅឆ្នាំ ១៩០៣។ អត្ថបទនេះមានន័យថា៖ «ជយោព្រះលិង្គ សម្ភុ ដែលចិត្រាសេនបានស្ថាបនាឡើង ដោយក្តីអាណិតស្រឡាញ់ដល់ព្រះសម្ភុ ជាទីគោរព ដោយមានការយល់ព្រមពីបិតា និងមាតាព្រះអង្គ»។ អត្ថបទនេះដូចទាំងស្រុងជាមួយនឹងសិលាចារឹកភ្នំសុពណ៌កាឡឺ* K. 116 (*នៅសារមន្ទីរជាតិ*) *ដែលជាភ្នំស្ថិតនៅលើមាត់ទន្លេមេគង្គខាងស្តាំ ប្រមាណជា ៣០ គីឡូម៉ែត្រពីថ្មក្រែ និងសិលាចារឹក* K.1338 *ដែលរក្សាទុកនៅសារមន្ទីរខេត្តក្រចេះ ហើយដែលគេមិនដឹងពីប្រភពច្បាស់លាស់។*[23]

23. Bruguier et Lacroix, T. IV, 2016



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## សិលាចារឹកថ្មក្រែ K. 1338



សិលាចារឹកនេះ រកឃើញនៅតំបន់មាត់ទន្លេមេគង្គ ប្រមាណជា ៣០ គីឡូម៉ែត្រពីខេត្តក្រចេះ។ អត្ថបទមានលក្ខណៈដូចសិលាចារឹកថ្មក្រែ និងភ្នំសុព័រកាឡីដែរ។ គឺជាបញ្ញត្តិរបស់ចិត្រសេន ជាភាសាសំស្ក្រឹត ប្រហែលជានៅឆ្នាំ ៦១៥ ដោយចុះលេខ Ka 172 និង K. 1338។

| ជាអក្សរខ្មែរ | ជាអក្សរខ្មែរ[24] |
|---|---|
| ភ ក្ត្យា ភ គ វ ត ត្ក ម្ភោ | ប្រកបភក្តីភាពចំពោះព្រះសម្ភុ |
| ម៌្មា តា បិ ត្រោ រ នុ ជ្ញ យា | អនុញ្ញាតពីព្រះមាតាបិតា |
| ស្ថា បិ ត ញ្ជិ ត្រ សេ នេ ន | ស្ថាបនាដោយចិត្រាសេនា |
| លិ ង្គ ញ្ច យ តិ គា ម្ភ វ ម | លិង្គព្រះសម្ភុ មានជោគមានជ័យ |

## ១.២.១១. ស្ទឹងត្រែងនៅសតវត្សទី៧

សិលាចារឹក K. 359៖ ដើផទម្រ (Dalle) រកឃើញនៅវាលកន្ទេល ជាភាសាសំស្ក្រឹតមាន ៧ បន្ទាត់ ចារនៅចុងសតវត្សទី ៦-ដើមសតវត្សទី៧ បាត់ទៅហើយ។ លោក Barth (1885-89) បានសិក្សាអត្ថបទជាភាសាសំស្ក្រឹតនេះដែលមាន ៧ បន្ទាត់ ចែកចេញជា ៤ ជួរ។ អត្ថបទនេះលើកឡើងពីព្រាហ្មណ៍

24 បកប្រែដោយ អ្នកគ្រូ ឆោម គន្ធា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សោមាគម្ម៌ ដែលជាស្វាមីរបស់បុត្រីនៃព្រះបាទវីរវម្ម៌ និងជាប្អូនស្រីរបស់ព្រះបាទភវវម្ម៌ទី១ (ចុងសតវត្សទី៦) បានស្ថាបនារូបបដិមា «ត្រីភូវមេគ្វរ» (ម្ចាស់នៃលោកទាំងបី)។ ដូច្នេះ ចារឹកនេះចារនៅចុងសតវត្សទី៦ ឬដើមសតវត្សទី៧។

សិលាចារឹក K. 1287៖ សិលាមូលស្ថាបនា (stèle) ដែលមានកម្ពស់ជិត ១ ម៉ែត្រ និងទទឹង ៤០ សង់ទីម៉ែត្រ រកឃើញនៅឆ្នាំ ២០០០ នៅជិតប្រាសាទកណ្ដាល ជាភាសាខ្មែរ រក្សាទុកនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង។ អត្ថបទនេះគ្មានកាលបរិច្ឆេទ តែបើពិនិត្យអក្សរប្រហែលជាចារនៅចុងសតវត្សទី៧។[25] អត្ថបទនេះនិយាយពីបោញរាម ដែលបានធ្វើអំណោយជាអ្នកបម្រើ ដីស្រែ និងសត្វពាហនៈដល់ព្រះសិវៈដែលមានព្រះនាមថា សុវណ៌លិង្គ និងចនទេគ្វរ ដូចនាមនៅក្នុងចារឹកធាតុបាដើម K. 360 ចារនៅចុងសតវត្សទី៧ដែរ។[26]


K. 1287


K. 1288

25. វង់ សុជាវ៉ា 2003, 2010

26. Bruguier et Lacroix, T. IV, 2016



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សិលាចារឹក ប្រាសាទចារឹក K. 1288 ៖ ប្រាសាទចារឹកស្ថិតនៅជិត ១ គីឡូម៉ែត្រពីប្រាសាទព្រះគោប្រមាណជា ៥០ ម៉ែត្រពីមាត់ទន្លេមេគង្គនៅក្នុងស្រុកថាឡាបរិវ៉ាត់។ K. 1288 ចារលើមេទ្វារប្រាសាទ៖ គឺជាអត្ថបទមាន ១៣ បន្ទាត់ដែលផ្នែកខាងលើខូចខាតយ៉ាងខ្លាំង ដែលជាបញ្ជីនៃឈ្មោះ អ្នកបម្រើនៅប្រាសាទ។[27]





K. 360

សិលាមូលស្ថាបនាប្រាសាទធាតុបាដើម K. 360៖ ស្ទឹងត្រែង គឺជាតំបន់ទន្លេ «ចតុមុខ» ដែលទន្លេសេសាន និងទន្លេស្រែពកជួបប្រសព្វគ្នា មុននឹងហូរចូលទន្លេសេកុង។ ប្រាសាទធាតុបាដើមនេះ ស្ថិតនៅចំទីប្រសព្វរវាងសេសាន និងសេកុងនេះឯង ប្រមាណជា ១០ គីឡូម៉ែត្រពីទីរួមខេត្ត នៅតាមមាត់ទន្លេ។ នៅទីនេះគេបានរកឃើញសិលាចារឹកចារឹក K. 360 ដូចតទៅមានកម្ពស់ជិតមួយម៉ែត្រ ជាភាសា សំស្ក្រឹតមាន ៤ ស្លោក ដែលចាប់ផ្ដើមពីការសរសើរដល់ព្រះសិវៈ និងរៀបរាប់ពីគ្រឿងឧបភោគបរិភោគដែលចាំបាច់ សម្រាប់ការរៀបចំពិធីបុណ្យ និងការតែងតាំង ចន្ទ្រវិន្ទុ ឱ្យទទួលខុសត្រូវក្នុងការសាងសង់ប្រាសាទឥដ្ឋមួយ ដើម្បីឧទ្ទិសដល់សិវៈ «ចន្ទេគ្វរ»។ ចារឹកដែលគ្មានកាលបរិច្ឆេទនេះ បង្ហាញពីដំណាក់កាលដំបូងនៃការវិវត្តសិលាចារឹកកម្ពុជា ហើយបើតាមមតិលោក Cœdes គឺអាចជាចារឹកនៅក្នុងសតវត្សទី៧។[28]

27. វង់ សុធារ៉ា 2011

28. Bruguier et Lacroix, T. IV, 2016

# ព្រះមហាក្សត្រសម័យមុនអង្គរ

| ឈ្មោះព្រះមហាក្សត្រ | គ្រឹស្តសករាជ | រាជធានី |
|---|---|---|
| ស្រី វីរវម្ម័ | | លិង្គបុរ<br>(វត្តភូ) |
| ភវវម្ម័ ទី១ | ៥៥០-៦០០ | ភវបុរ |
| មហេន្ទ្រវម្ម័-ចិត្រសេន | ៦០០-៦១៦ | ? |
| ឦសានវម្ម័ ទី១ | ៦១៦-៦៣៥ | ឦសានបុរ |
| ភវវម្ម័ ទី២ | ៦៣៥/៦-៦៥៧ | ? |
| ជ័យវម្ម័ ទី១ | ៦៥៧-៦៨១? | ? |
| ជ័យទេវី | ៧១៣- | ? |

## ១.២.១២. អង្គរបុរីនៅសតវត្សទី៧

ខេត្តតាកែវ គឺជាជម្រកនៃអារ្យធម៌បុរាណខ្មែរមុនអង្គរ។ នៅទីនោះមានប្រាសាទបុរាណជាច្រើនដែលមានសិលាចារឹក ដូចជាៈ

(១) ក្រុមប្រាសាទបាទីៈ ប្រាសាទតាព្រហ្ម (ចាប់ពីសតវត្សទី៧ ដល់ទី១២) ប្រាសាទយាយពៅ (សតវត្សទី១១) ប្រាសាទភ្នំតាម៉ៅ (សតវត្សទី១១) ប្រាសាទភ្នំថ្មដុះ (សតវត្សទី១១) ប្រាសាទនាងខ្មៅ (សតវត្សទី១០) ប្រាសាទភ្នំជីសូរ្យ (សតវត្សទី១១)

(២) អង្គរបុរី និងក្រុមប្រាសាទភ្នំដាៈ ប្រាសាទភ្នំដា (សតវត្សទី១១ សាងសង់លើប្រាសាទមុនអង្គរ) ប្រាសាទភ្នំបាយ៉ង់ (សតវត្សទី៧) ប្រាសាទតាញាណខាងកើត ប្រាសាទតាញាណលិច។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នៅទួលវត្តគំនូរ ស្រុកអង្គរបុរី ខេត្តតាកែវ គឺជាកន្លែងដែលគេបានរកឃើញសិលាចារឹកភាសាខ្មែរចាស់ ដែលមានកាលបរិច្ឆេទចាស់ជាងគេ K.600។

## សិលាចារឹក K.600 ភាសាខ្មែរចាស់ជាងគេ




K.600-ចារឹកខ្មែរចាស់មានកាលបរិច្ឆេទចាស់ជាងគេ

សិលាចារឹកទួលវត្តគំនូរ K. 557 និង K. 600៖ គឺជាសិលាចារឹកយ៉ាងធំសម្បើម (កម្ពស់ ០,៨ ម៉ែត្រ និងទទឹងប្រវែង ១,២ ម៉ែត្រ) ដែលជាសិលាចារឹកភាសាខ្មែរបុរាណចាស់ជាងគេ ដែលមានចុះកាលបរិច្ឆេទត្រឹមត្រូវ នៅឆ្នាំ ៥៣៣ នៃមហាសករាជ (ឆ្នាំ ៦១១ នៃ គ.ស.) ដែលរកឃើញនៅទួលវត្តគំនូរ (K. 600) ស្រុកអង្គរបុរី ខេត្តតាកែវ រាជធានីនៃនគរភ្នំ។ សិលាចារឹកនេះចារនៅក្នុងរជ្ជកាលព្រះបាទមហេន្ទ្រវម៌្ម ដែលជាបញ្ជីរាយនាមអ្នករបាំ អ្នកលេងភ្លេង អ្នកបម្រើ និងដីធ្លី ដែលយើងនឹងលើកយកមកពិភាក្សាខាងក្រោយ។

*កាលបរិច្ឆេទ៖ ត្រៃត្រី(ម)សោត្តរបញ្ចសត សគ បរិគ្រ(ហ) ត្រយោទសី កេត មាឃ បុស្យ នក្សត្រ តុលលគ្ន០*

*«មហាសករាជ ៣ ៣០ បូក ៥០០ (៥៣៣ សគ ត្រូវជា ៦១១ នៃ គ.ស) ដែលកន្ទង់ទៅ ទី១៣ កើត ខែមាឃ នៅពេលបណ្តុំផ្កាយ «បុស្យ» ចំតារាង តារាសាស្ត្រ «តុល» (ព្រះចន្ទនិងព្រះអាទិត្យមកជួបគ្នា) ដែលមានលក្ខណៈ»។*

## សិលាចារឹក K.600 ជ្រុងទី១ ខាងជើង

*បោញឧយឱយខ្ញុំដល់ក្បោញកម្រតាងអញ៖ ប្រុសឈ្មោះក្ញបិត១ នាក់ ប្រុសឈ្មោះកន្ទាង៍ស្រាង១នាក់ ប្រុសឈ្មោះត្លោង១នាក់ ប្រុសឈ្មោះក្ញារ១នាក់ ស្រីឈ្មោះកន្តៅ១នាក់ កូនប្រុសរបស់មនុស្សស្រីឈ្មោះអលង១នាក់ ស្រីឈ្មោះយលេង១នាក់គោ៦០ ក្របី២ ពពែ១០ ដើមដូង៤០ ស្រែ ២សន្រេនៅឯអំបោង ០ ជំអញផ្តល់អំណោយជាខ្ញុំដល់កម្រតាងអញមហាគនបតិ៖ ប្រុសឈ្មោះទ្វា១ នាក់ ប្រុសឈ្មោះកន្ទាង១នាក់ ប្រុសឈ្មោះក្នោច ១នាក់ ប្រុសឈ្មោះត្នោ១នាក់ ប្រុសឈ្មោះទសមី១នាក់ ស្រីឈ្មោះកោញ វ្រះ១នាក់ ស្រីឈ្មោះផុងបោញ១នាក់ កូនស្រី១នាក់ ស្រីឈ្មោះមាទ្រអញ ១ នាក់ ស្រីឈ្មោះបូស១នាក់ គោ២០ក្បាល ស្ត្រីដែលបោសឱយម្ចាស់ដើមទាន ព្រះ(ក្បោញ)១នាក់ ដែលចុះថ្ងៃព្រះជូនផ្កាភ្ញី គ្រឿងក្រអូប១នាក់ មនុស្សឈ្មោះចិអញ១នាក់ និងមនុស្សឈ្មោះតាញ១នាក់។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



# III. ឦសានបុរៈ

## ១.៣.១. ព្រះបាទឦសានវម្ម័ ទី ១ (៦១៦-៦៣៥)

បន្ទាប់ពីព្រះបាទមហេន្ទ្រវម្ម័ សោយទិវង្គត បុត្ររបស់ព្រះអង្គ គឺព្រះបាទឦសានវម្ម័ទី១ (៦១៦-៦៣៥) (អ្នកដែលលោកម្ចាស់សិវៈការពារ) បានឡើងសោយរាជ្យនៅឆ្នាំ ៦១៦។ ព្រះអង្គបានបញ្ចប់ទាំងស្រុងនូវគោលនយោបាយវាតទីទឹកដី ដោយពង្រីកឥទ្ធិពលដល់រាជធានី នរវរនគរ (អង្គរបុរី) ប្រមាណនៅឆ្នាំ ៦៣០។ ព្រះអង្គបានលើករាជធានី ដែលប្រហែលជានៅវត្តភូ ឬ នៅខេត្តស្ទឹងត្រែង មកឦសានបុរៈ គឺសំបូរព្រៃគុក នៅក្នុងខេត្តកំពង់ធំ ដែលជារាជធានីរហូតដល់ដើមសតវត្សទី៩។ ការគោរពព្រហ្មញ្ញសាសនាមានសន្ទុះកើនយ៉ាងខ្លាំងក្នុងរជ្ជកាលនេះ តែក្នុងរូបភាពជាការគោរព «ហរិហរ» គឺការគោរពព្រះវិស្ណុ និងព្រះសិវៈ ក្នុងខ្លួនតែមួយ (ម្ខាងជាវិស្ណុ និងម្ខាងទៀតជាសិវៈ) (សិលាចារឹក វត្តចង្រិត, សិលាចារឹក អង្គពូ, សិលាចារឹក សំបូរព្រៃគុក)។



គ្រីគានវម្ម័



ឦសានបុរ



ហរិហរ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## សិលាចារឹកសំបូរព្រៃគុក

*សិលាចារឹកសំបូរព្រៃគុក* K. 149៖ *ក្ញុំនៃព្រះកម្រតាងអញ ស្រីរតនេស្វរៈ ដែលជាអំណោយរបស់អាចារ្យ ដែលមានគោរមងាវជា ម្រតាង អញ ដែលបានទទួលគោរមងារនេះពីព្រះបាទ ស្រីភវវម៌្ម ពីព្រះបាទ ស្រីមហេន្ទ្រវម៌្ម និងពីព្រះបាទ ឦសានវម៌្ម។ គ្រឿងឧបភោគបរិភោគត្រូវបានប្រគល់ឱ្យមេការនៃខ្ញុំទាំងនោះ។ មានបញ្ជីឈ្មោះខ្ញុំប្រុស (វា) និងខ្ញុំស្រី (កុ)។ អំណោយជាខ្ញុំបម្រើដល់ក្មារ វហ្វ មានបញ្ជីឈ្មោះខ្ញុំប្រុស និងខ្ញុំស្រី មានគោចំនួន ២៨០ និងក្របី។*[29]

*សិលាចារឹកសំបូរព្រៃគុក* K. 436៖ *គាត់បានធ្វើអំណោយជាដីស្រែសាជាថ្មីទៀត។ អ្នកដែលយកពីព្រះសិវៈនៃដីស្រែទាំងនោះ ទោះបីគ្រាន់តែគិតក៏ដោយ នៅត្រូវធ្លាក់នរក ដោយចាប់ផ្ដើមពីនរកឈ្មោះថា រោរវ។ សូមក្រាបថ្វាយបង្គំដល់ព្រះសិវៈ។ សូមក្រាបថ្វាយបង្គំដល់ព្រះនិលកន្ឋ។ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះដែលមានព្រះភ័ក្ត្របួនបែទៅទិសទាំងបួន។ កាលនោះមានព្រះមហាក្សត្រមួយអង្គ ព្រះនាម បាជិន្ទ្រវម៌្ម ដែលមានពន្លឺភ្លឺចាំងដល់ព្រះរាជវង្សានុវង្សនៃស្ដេច***កម្ពុជទេស** *និងដែលបានបង្ក្រាបឈ្នះអស់មារសត្រូវ។ ព្រះអាទិទេព ប្រាជ្ញាបាតិ បានបង្កើតស្ដេចអង្គនេះមក ប្រកបដោយរូបឆោមល្អស្រស់លើសគេលើប្រថពី។ ព្រះអង្គមានជំនួយការម្នាក់ (ស្រីមទ វិក្រមសិង្ហ) ដែលកើតនៅក្នុងគ្រួសារដែលធ្លាប់បម្រើស្ដេចចក្រពត្តិ មានអានុភាពដូចស្ដេចតោដែលបង្ក្រាបអស់ស្ដេចដំរីជាបច្ចាមិត្រទាំងឡាយ។ លោកជាចៅរបស់ ស្រីមទ វិរេន្ទ្រវម៌្ម ដ៏ល្បីល្បាញ និងជាកូនរបស់ សិរិ នរបេន្ទ្រវិជយ ដែលជាអ្នកបម្រើរបស់ ស្រីយសោវម៌្ម។ ព្រះមហាក្សត្រទ្រង់បានចេញរាជបញ្ជា ឱ្យគាត់ទៅបង្ក្រាបដោយអានុភាពរបស់ខ្លួន ស្ដេចនៃប្រទេសចម្ប៉ា ហើយត្រឡប់មកវិញ ដោយនាំយកនូវរបស់របរសព្វសារពើ ដើម្បី*

29. IC, IV, p. 30



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រគល់ថ្វាយព្រះមហាក្សត្រទៀតផង។ គាត់បានស្ថាបនាអាស្រមនៅលិង្គបុរី (វត្តភូ) នៅនគស្ថានបុរ និងនៅសម្ភុបុរៈ (ក្រចេះ)។ ស្រីមទ វិក្រមសិង្គនេះ ដែលនៅក្នុងសមរភូមិមានដំណើរដូចសីង្ហ បាន..នៅព្ញៀសានបុរ និងបានធ្វើអំណោយជាក្របី និងខ្ញុំបម្រើ។ នរណាដែលប៉ះពាល់ដល់អំណោយទាំងនេះ បើនៅរស់ នឹងរស់នៅក្នុងក្តីវេទនា ហើយនឹងស្លាប់តែហោង ដោយត្រូវគេកាត់ខ្លួនជាកង់ៗ។[30]

សិលាចារឹកសំបូរព្រៃគុក K. 438៖ ផ្នែក A៖ នៅពេលដែលព្រះបាទជ័យវម្ម័ ថែរក្សាទឹកដីឱ្យមានវិបុលភាព អ្នកបម្រើស្តេចដ៏ចំណានម្នាក់ ដែលបានទទួលគោរមងាររជា វលធិបាតិ បានស្ថាបនាលិង្គមាស ដែលមានព្រះនាមថា ស្រី ប្រកសោមេស្វរៈ ហើយបានធ្វើអំណោយជាមាស ប្រាក់ សំរឹទ្ធ ទង់ដែង គោ ក្របី ដីស្រែចម្ការ និងមនុស្សបម្រើ។ អ្នកប្រាជ្ញម្នាក់ឈ្មោះរុទ្រកត្តិ ត្រូវបានតែងតាំងឱ្យមើលការខុសត្រូវនៅបូជនីយដ្ឋាននេះ។ នរណាដែលមានចិត្តលោភចង់លួចរបស់របរទាំងនេះ នឹងធ្លាក់ចុះទៅស្ថាននរកជាមួយញាតិសន្តានគេ ហើយនៅទីនោះរហូតដល់លោករលាយ។[31]

ផ្នែក B៖ ទទួលបានកិត្តិយស ដោយសារព្រះបាទ ព្ញៀសានវម្ម័ បានប្រទានបុត្រីរបស់ព្រះអង្គដល់(ព្រាហ្មណ៍នេះ)។ ព្រាហ្មណ៍នេះចេះអស់នូវគម្ពីរសព្វសារពើនៃព្រហ្មញ្ញសាសនា សាស្ត្រា និងកើតនៅទក្សិណាបថ ហៅ ទុគ៌ស្វាមី។ ព្រាហ្មណ៍ ដោយទទួលបាននូវទ្រព្យសម្បត្តិនៅពេលរៀបមង្គលការ បានស្ថាបនាព្រះលិង្គ តាមទំនៀមទម្លាប់។ ម្រតាង ទុគ៌ស្វមិ បានប្រទានអំណោយជាគោ ក្របី ដីស្រែ ចម្ការដល់ស្ថានអាទិទេព ស្រី ប្រហាសិតេស្វរៈ។ ម្រតាង ទុគ៌ស្វមិ ធ្វើអំណោយដល់ក្មោញ ម្រតាង ក ដែលជាអ្នកថែរក្សានៅសាលា ត្នាហ នៅព្ញៀសានបុរៈ។[32]

សិលាចារឹកសំបូរព្រៃគុក K. 440៖ ចារនៅសតវត្សទី៧ ក្នុងរជ្ជកាល

30. IC, IV, p. 22-24

31. IC, IV, p. 32

32. IC, IV, p. 27



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រះបាទ ឦសានវម៌្ម ទី១ (ពាក់កណ្ដាលទី១នៃសតវត្សទី៧) ដើម្បីឧទ្ទិស ដល់ព្រះសិវៈ-ប្រហសិតេស្វរៈ (អាទិទេពញញឹម) និងដើម្បីកោតសរសើរ ដល់ឦសានវម៌្ម ទី១ ដែលជាព្រះអាទិត្យបំភ្លឺលោក ចាប់កំណើតក្នុងត្រកូល ក្សត្រិយ៍ដ៏ល្បីល្បាញ។

សិលាចារឹកសំបូរព្រៃគុក K. 440៖ ជើងទ្វារខាងកើតទាំងពីរនៃរបង ក្រៅខាងកើតមានចារឹកភាសាសំស្ក្រឹតចំនួន ១៧ បន្ទាត់។ ចារឹកសរសើរដល់ អាទិទេព ឝ្រី ប្រហសិតេឝ្វរ (Çrī Prahasiteçvara) និងដល់ព្រះ មហាក្សត្រ ព្រះបាទឦសានវម៌្មទី ១ ដែលជាក្សត្រជាទីគោរពលើផែនដី និងមានរាជា នុភាពខ្លាំងក្លា។ ព្រះអង្គមានវ័យក្មេង និងរូបសម្ផស្សឥតខ្ចោះ តែចូលចិត្ត សិក្សាវិទ្យាសាស្ត្រ។ ព្រះអង្គមានរាជានុភាពខ្លាំងក្លាលើព្រះរាជមាតាបិតា របស់ព្រះអង្គទៅទៀត។

## រចនាបថ ប្រាសាទសំបូរព្រៃគុក (២)

ប្រាសាទសំបូរព្រៃគុក ស្ថិតនៅក្នុងខេត្តកំពង់ធំដែលសាងសង់ឡើង នៅក្នុងស.វ.ទី៧ ក្នុងរជ្ជកាលព្រះបាទ ឦសានវម៌្ម ដែលបានតាំងរាជធានី នៅឦសានបុរ ដែលជាដើមកំណើត នៃអាណាចក្រខ្មែរ។

ប្រាសាទទាំងនេះសង់ ដោយឥដ្ឋ លើកលែងតែផ្ដែរ សសរពេជ្រ និង ស៊ុមទ្វារដែលធ្វើពីថ្មភក់។ ប្រាសាទសំបូរព្រៃគុក ចែកចេញជាពីរក្រុម។ ប្រាសាទមួយចំនួនដែលស្ថិតនៅផ្នែកខាងត្បូង និងខាងជើងត្រូវបានសាង សង់ឡើងនៅក្នុងសតវត្សទី៧។ ចំណែកប្រាសាទមួយក្រុមទៀតសាងសង់ ឡើងនៅពេលក្រោយ។

ក្បាច់រចនា និងផ្ដែរទ្វាររចនាបថសំបូរព្រៃគុកមានចម្លាក់ផ្ដេករាងជាធ្នូ ដែលមានរូបបណ្ដោងនៅចំកណ្ដាល។ នៅខាងចុងផ្ដែរមានលម្អដោយសត្វ មករ ដែលជាសត្វសមុទ្រតំណាងទឹក ងាកក្បាលចូលក្នុង និងលើកកន្ទុយ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឡើងលើ។ នេះគឺជាក្បាច់នៃសត្វមករងើកក្បាលចូលក្នុងនេះហើយ ដែល ឆ្លុះបញ្ចាំងពី «ចលនាដូចគ្នា» នៃផ្តែរទ្វារចុងរចនាបថសំបូរព្រៃគុក។ នៅក្រោមធ្នូ គេមានព្យួររំយោលទងផ្កា ស្លឹកឈើ និងមែកឈើដែលមានលក្ខណៈដូចជាប្រាសាទនៅឥណ្ឌាដែរ។ ចំណែកឯសសរពេជ្រមានរាងមូល។

ផ្តែរទ្វារនៃប្រាសាទសំបូរព្រៃគុកខាងលើនេះក៏មានលក្ខណៈដូចៗគ្នាដែរ ដែលលម្អដោយក្បូរក្បាច់ ឆ្លុះបញ្ចាំងពីធម្មជាតិ លម្អដោយស្លឹកឈើ និងមានលក្ខណៈឆ្លុះបញ្ចាំងគ្នាល្អ។ ចំណុចសំខាន់ គឺស្ថាបត្យកម្មសំបូរព្រៃគុកមានស្លាកស្នាមដ៏ច្រើនលើសលប់នៃវប្បធម៌ឥណ្ឌា។



ផ្តែរនៃរចនាបថប្រាសាទសំបូរព្រៃគុក



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia



## ១.៣.២. ព្រះបាទភវវម៌្ម ទី២ (៦៣៥/៦-៦៥៧)

*ព្រះបាទភវវម៌្ម ទី២ (៦៣៥/៦-៦៥៧) (អ្នកដែលព្រះសិវៈការពារ) និងបោញ គិរទត្ត ជាបុត្ររបស់ព្រះបាទ ឦសានវម៌្ម ទី១ (K. 1150)។ ចារឹក K. 53 បង្ហាញថាបោញ គិរទត្ត របស់ព្រះបាទ ឦសានវម៌្ម ទី១ ជាមួយព្រះរាជមហេសីពីគ្រួសារ«អាធ្យបុរៈ»។[33] ក្រុមគ្រួសារបោញ គឺជាមេសហគមន៍ ឬចៅហ្វាយស្រុកនៅក្នុងសតវត្សទី៧។ តែគោរមងារនេះត្រូវគេឈប់ប្រើក្រោយសតវត្សទី៨មក។*

## រចនាបថ ព្រៃក្មេង (៣)

*បន្តិចម្តងៗ ស្ថាបត្យករបុរាណខ្មែរបានច្នៃប្រឌិតផ្តែរទ្វារ ដែលវិវត្តទៅតាមរចនាបថ ដូចជាផ្តែរទ្វារនៃរចនាបថព្រៃក្មេង ក្នុងពាក់កណ្តាលទី២ នៃស.វ.ទី៧ (ពីឆ្នាំ ៦៣៥ ដល់ ៧០០)។ រចនាបថព្រៃក្មេងចាប់ផ្តើមពីពេលដែលព្រះបាទភវវម៌្មន ទី២ បានឡើងសោយរាជ្យបន្ទាប់ពីព្រះបាទឦសានវម៌្មន បានចូលទិវង្គតនៅក្នុងឆ្នាំ ៦៣៥។ ដែលជាសតវត្សដែលអាណាចក្រចេនឡាកំពុងរីកចម្រើន ឆ្លុះបញ្ចាំងតាមរយៈការខិតខំប្រឹងប្រែងរបស់សិល្បករក្នុងការស្វែងរកសុក្រឹតភាពនៃសមាមាត្រ និងសមតា។*

*ផ្តែរទ្វារនៃរចនាបថព្រៃក្មេងមិនសូវល្អដូចមុនឡើយ។ ផ្តែរលែងមានរូបសត្វមករទៀតហើយ។ យើងឃើញមានគំនូសផ្តេកខាងលើ មានកូនផ្ទូតូចៗពីរជារម្មូរស្នឹកឈើដែលមានលក្ខណៈរាបស្មើ ហើយខាងចុងមានរាងខុបចូលកបុង។ ក្បាច់មូលនៅចំកណ្តាលលែងមានចម្លាក់រូបមនុស្សហើយ គេឃើញមានតែរំយោលផ្កាវល្លិព្យួរចុះក្រោមដែលគេហៅថា «ចលនានៅមួយកន្លែង»។ សសរពេជ្រមានរាងមូល ដូចរចនាបថសំបូរព្រៃគុកដែរ តែមាន*

33. Vickery, 1998



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បន្ថែមក្បាច់ខ្សែ ជាពិសេសមានរំយោល និងបន្ទោងរយ៉ាប្លែកៗជាច្រើន។

ប្រាសាទនៃរចនាបទព្រៃក្មេងមាន ៖ ប្រាសាទព្រៃក្មេងដែលជាប្រាសាទមួយតូចនៅក្នុងតំបន់អង្គរ ប្រាសាទស្វាយព្រាម ប្រាសាទបាសិត ប្រាសាទព្រៃប្រាសាទ និងប្រាសាទភ្នំបយ៉ង់ភ្លោ។



ផ្តែរនៃរចនាបថព្រៃក្មេង

## សិលាចារឹកកំពង់ស្ពឺ K. 1419 ឆ្នាំ ៦៣៣

ចារឹកនេះរកឃើញនៅភូមិ ត្រពាំងខ្ទុំ ឃុំស្វាយចចិប ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។ ផ្ទាំងចារឹកនេះ មានរាងជាសន្ទឹកសីមាមានអក្សរចារជាកំណាព្យ ភាសាសំស្ក្រឹតចំនួន ២២បន្ទាត់ ត្រូវជា ១១ល្បះ។ បីល្បះដំបូងជាបទនមស្ការ ចំពោះព្រះឥសូរ ព្រះស្រីសានវិស្ណុ និងព្រះនារាយណ៍។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ជាងគេ គឺនៅក្នុងល្បះទី៤ មានពាក្យ «សុវណ្ណភូមិ» ប្រើក្នុងការសរសើរតម្កើង ព្រះបាទឦសានវម៌្ម ទី១ ជាស្តេចគ្រងរាជ្យលើផែនដីសុវណ្ណភូមិ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



*សិលាចារឹកកំពង់ស្ពឺ K. 1419 ឆ្នាំ៦៣៣*

## ប្រាសាទនិងចារឹកភ្នំបយ៉ង់ខ្មោ

*ភ្នំបយ៉ង់ខ្មោស្ថិតនៅលើជួរភ្នំដំរី ខេត្តតាកែវ មិនឆ្ងាយប៉ុន្មានពីអង្គរបុរី ដែលជាមានប្រាសាទសិរៈធ្វើពីឥដ្ឋមួយចំនួន ហើយក្នុងនោះ ប្រាសាទដែលស្អាតជាងគេ គឺប្រាសាទភ្នំបយ៉ង់ខ្មោ។ ប្រាសាទភ្នំបយ៉ង់ខ្មោមានសណ្ឋានរូបរាងស្រដៀងទៅនឹងប្រាសាទសំបូរព្រៃគុក និងអាស្រមឥសីនៅភ្នំដាដែរ។ នៅទីនោះមានប្រាសាទមួយចំនួន គឺ៖ (១) ប្រាសាទវត្តលើ ដែលមានសិលាចារឹកមួយចំនួន ដូចជា សិលាចារឹក* Ka 62, *សិលាចារឹក* K. 11៖ *សិលាចារឹកចារលើដុំថ្ម ជាភាសាខ្មែរមុនអង្គរចំនួន ៩ បន្ទាត់ និយាយពីឈ្មោះអ្នកបម្រើប្រុសស្រី សត្វពាហនៈ និងស្រូវសម្រាប់បូជនីយដ្ឋាន, សិលាចារឹក* K. 12៖ *សិលាចារឹកភាសាសំស្ក្រឹតចែកជាបីផ្នែក ដែលជាមូលស្ថាបនានៃមន្ទីរពេទ្យខាងត្បូងគេបង្អស់របស់ព្រះបាទជ័យវម៌្ម ទី៧, សិលាចារឹក* K. 422៖ *អត្ថបទ*

ចំនួន ៤ បន្ទាត់ជាភាសាខ្មែរសម័យមុនអង្គរ (២) ប្រាសាទតាញាណខាង កើត (៣) ប្រាសាទតាញាណខាងលិច (៤) ប្រាសាទកំពូលតានទន់ ដែល គេរកឃើញនៅឆ្នាំ ១៩៩៧ នូវសិលាមូលស្ថាបនាមាន ៣០ បន្ទាត់ (២១ បន្ទាត់ជាភាសាសំស្ក្រឹត និង ៩ បន្ទាត់ជាភាសាខ្មែរ) (៥) ប្រាសាទព្រះគោ (៦) ប្រាសាទវត្តកំផែង និង (៧) ប្រាសាទភ្នំបយ៉ង្កោ។



## សិលាចារឹកត្នំបយ័ង្កោ

*សិលាចារឹកK.13៖គឺជាសិលាមូលស្ថាបនា* (stèle) *ជាភាសាសំស្រ្កឹត មាន ១៤ បន្ទាត់ ដែលរកឃើញនៅក្នុងប៉មកណ្តាលនៃប្រាសាទ ហើយនាពេលបច្ចុប្បន្នស្ថិតនៅសារមន្ទីរ* Guimet*។ អត្ថបទចាប់ផ្តើមពីការសរសើរដល់ព្រះសិវៈ។ អ្នកចារឹកឈ្មោះ វិទ្យាវិន្ទុ បានស្ថាបនារូបព្រះបាទព្រះសិវៈសិវបាទ (ដែលជាធម្មតា គេតែងតែយកព្រះលិង្គជានិមិត្តរូបតំណាងព្រះសិវៈ)។ នៅឆ្នាំ ៦០៤/៦០៥ នៃគ្រិស្តសករាជ គេបានយកឥដ្ឋមកធ្វើជាគែមព័ទ្ធជុំវិញ «សិវបាទ» នេះ ហើយនៅឆ្នាំ ៦២៤/៦២៥ គេបានសាងសង់អាងទឹកមួយនៅជិតនោះ ហើយគេបានធ្វើអំណោយជាដីធ្លី អ្នកបម្រើ និងសត្វដល់ព្រះសិវៈ។*

*សិលាចារឹក* K. 483៖ *គឺជាអត្ថបទចារនៅលើមេទ្វារ* (piédroit) *ខាងផ្នែកអគ្នេយ៍ មាន ២៩ បន្ទាត់ ជាភាសាសំស្រ្កឹត។ គឺជាសិលាចារឹកនៃព្រះបាទភវវម៌្មទី២ និងចារនៅឆ្នាំ ៦៤០។ សិលាចារឹកនេះបង្ហាញពីព្រំប្រទល់នៃប្រាសាទធ្វើពីរបងឥដ្ឋ និងនិយាយពី «ឧតបន្នេស្វរៈ» ដែលព្រះនាមនៃអាទិទេព ក្នុងប៉មកណ្តាល។ ព្រះនាមរបស់ព្រះសិវៈនេះ ត្រូវបានគេប្រទះឃើញនៅក្នុងសិលាចារឹក គុហារព្រះល្អង* (K. 44) *និង នៅក្នុំចង់ក* (K. 46) *ដែលលោក* K. Bhattacharya *ចាត់ទុកថា គឺជា «អាទិទេពរបស់សត្វលោក» ព្រះនាមភូតេស្វរៈ។*



## ភវវម៌្ម ទី២៖ សិលាចារឹកហាន់ជ័យ K. 81

*សិលាចារឹកហាន់ជ័យ* (K. 81)៖ *ចារឹកលើមេទ្វារទាំងសងខាង៖ លើមេទ្វារខាងត្បូង ជាភាសាសំស្ក្រឹត មាន ១២ បន្ទាត់ និងចារឹកលើមេទ្វារខាងជើង ជាភាសាសំស្ក្រឹត មាន ៣៥ បន្ទាត់ ចារនៅពាក់កណ្តាលទី១នៃសតវត្សទី៧។*

*អត្ថបទសរសើរព្រះបាទ ភវវម៌្ម ទី២ថា ជាមហាក្សត្រឥតមាននរណាឈ្នះបាន ប្រៀបបីដូចភ្នំព្រះសុមេរុ។ ព្រះអង្គមានពលានុភាពខ្លាំងក្លា មានជ័យជម្នះលើពួកខ្មាំងសត្រូវ និងបានពង្រីកទឹកដីរហូតដល់មាត់សមុទ្រ។ ព្រះអង្គមានព្រះរាជបុត្រមួយអង្គ ប្រកបដោយគុណធម៌ សោភ័ណភាព និងទេពកោសល្យ និងត្រូវបានប្រជានុរាស្ត្រកោតសរសើរស្ញប់ស្ញែង។ ព្រះអង្គមានព្រះរាជគ្រូម្នាក់ ដែលជួយបំពេញការងារ ហើយព្រះមហាក្សត្របានផ្តល់សេចក្តីទុកចិត្ត កិត្យានុភាព និងសេចក្តីថ្លៃថ្នូរដល់គាត់។ ព្រះរាជគ្រូបានខិតខំប្រឹងប្រែងបម្រើការងារជាផលប្រយោជន៍ ប្រកបដោយកិត្តិយស និងជោគជ័យ។ ទោះបីត្រូវព្រះនាងលក្ស្មីឱបក្រសោបក៏ដោយ ក៏ព្រះរាជគ្រូប្រកាន់វិន័យជាឥសី មានសេចក្តីអត់ធន និងប្រកបដោយធម៌ឧបេក្ខា។ គាត់មានឋានៈជាអភិបាលក្រុងឧគ្របុរ (បុរីប្រសើរ) និងបានស្ថាបនាលិង្គនាម គ្រីកទ្រេគ្វរ ដែលមានអានុភាពក្រៃលែង។ លោកបានធ្វើអំណោយដល់ប្រាសាទមានអ្នកបម្រើប្រុសស្រី សត្វពាហនៈ ដីភូមិ ដែលជាកម្មសិទ្ធិរបស់ព្រះអាទិទេព។ នរណាដែលលួចទ្រព្យសម្បត្តិរបស់អាស្រមនេះត្រូវចុះនរកដ៏យូរលង់។*[34]

34. *អត្ថបទសង្ខេបពី យៀង វីរបុត្រ*, 2017



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



*ភវវម្មទី២៖ សិលាចារឹកហាន់ជ័យ* K. 81



*សិលាចារឹកមូលស្ថាបនា* K. 79 *ខេត្តតាកែវ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សិលាចារឹកមូលស្ថាបនា K. 79 ខេត្តតាកែវ

*សិលាចារឹកព្រះបាទ ភវវម៌្ម ទី២* K. 79 ( *មហាសករាជ ៥៦១ គ.ស. ៦៣៩, ខេត្តតាកែវ?* )៖ *សិលាចារឹកមូលស្ថាបនានេះ* ( Foundation stone ) *មានសរសេរជាភាសាសំស្ក្រឹតចំនួន ៦ បន្ទាត់ និងជាភាសាខ្មែរចាស់ចំនួន ១៦ បន្ទាត់ ដែលលោក* Cœdes *យកមកសិក្សានៅឆ្នាំ ១៩០៤។ សិលាចារឹកនេះប្រហែលជាមានប្រភពពីខេត្តតាកែវ។ បន្ទាប់ពីសម្តែងការកោតសរសើរដល់ព្រះបាទ ភវវម៌្ម ទី២រួចមក សិលាចារឹកនិយាយពីការស្ថាបនាទីសក្ការៈបូជានៅមហាសករាជ ៥៦១ ( គស ៦៣៩)។*

*អត្ថបទជាភាសាសំស្ក្រឹតចំនួន ៦ បន្ទាត់ គឺជាស្តុតី (ការសរសើរ) ចំពោះព្រះបាទ ភវវម៌្ម ទី២។ អត្ថបទខ្មែរចំនួន១៨ បន្ទាត់ រៀបរាប់ពីអំណោយដីស្រែចំនួន ២ មាជេ ដោយម្រតាញ ព្លៀគានបវិត្រ ( ប្រហែលជាម្ចាស់នៃមូលស្ថាបនា) ថ្វាយចំពោះព្រះមហេសីព្រះឥស្វរ។ ដីស្រែទាំងនេះពីមុនជាកម្មសិទ្ធិរបស់ម្ចាស់ដីផ្សេងៗ ហើយត្រូវបានអ្នកលក់ដោះដូរ ដោយប្រើប្រាស់របស់របរផ្សេងៗ ស្រូវ និងសម្លៀកបំពាក់។*[35]



*សិលាចារឹក* K. 79 *ខេត្តតាកែវ*

*- អស្តិ មន្ទាទិភូបាល        វណ្ណ៌មុប្តិយ៌្យគោនិធិះ*

*- រាជា គ្រីភវវម្មេតិ        តបសាធារណោទិតិះ*

---

35. IC, IV, p. 22-24



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- មុខតុំវាណៃរ, គកាពេ្វ ឈធោទយេកន្យាគតាទ្វំចន្រ្ទេ
- បុម្យស្យ ក្ទប្លេ ទិវសេ, ទគាទ្វេំ ប្រតិម្ទិតំ ទេវីចតុកុំជាខ្យំ
- ភក្សាភគវតគ្គំភោ បិតាមាត្រោវិមុក្កយេ
- ទេវីយថាត្តំចរិតែ ស្វគ្គាបិតំ យមិនា កុវិ

- ព្រះអង្គជាស្តេចផែនដី ដូចព្រះមនុជាដើម
  ជាទីប្រជុំនៃកត្តិនាមនិងឃ្លាំងនៃកិត្តិយស
- ព្រះរាជាព្រះនាមថាស្រីភវវម្ម៌
  ដោយអំណាចតេជះ ប្រកបដោយចិត្តគ្រប់គ្រងខ្លួនឯងបាន
- មុខ(១) វដូវ(៦) និងព្រួញ(៥) គិតតាមឆ្នាំមហាសករាជ
  នៅចំល្វែងរាសីមីនា ព្រះច័ន្ទ្រកន្ទះវង់ចរចំល្វែងរាសីកញ្ញា
- នៅខែបុស្ស នៅខែរនោច នៅចំថ្ងៃពាក់កណ្តាលដប់ (ប្រាំ)
  ត្រូវគេតម្កល់ឬបញ្ចុះ(ព្រះបដិមា)ព្រះនាម«ទេពីចតុកុំជា»(ឬព្រះម៉ែដៃបួន)
- ដោយចិត្តសទ្ធា ចំពោះព្រះសម្ភុ
  ដើម្បីឱ្យព្រះមាតាបិតាបានរួចរំដោះ(ពីវដ្តសង្សារ)
- ទៅតាមក្បួនពិធីសម្រាប់ព្រះទេពី
  ត្រូវព្រះរាជាដ៏ចេះគ្រប់គ្រងចិត្តតម្កល់នៅលើផែនដី[36]

36. អ្នកគ្រូ ឆោម គន្ធា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សិលាចារឹកវត្តជើងឯក K-426

ចារឹកនេះរកឃើញនៅវត្តជើងឯករាជធានីភ្នំពេញ។ លោក Cœdes បានសិក្សាចារឹក K-426 ចំនួនពីរដង ហើយបណ្ឌិត អាំង ជូលាន បានយកមកសិក្សាម្ដងទៀត នៅក្នុងសៀវភៅ «មូលដ្ឋានរៀនខ្មែរបុរាណ»។



| ខ្មែរចាស់ | ខ្មែរទំនើប |
|---|---|
| អាជ្ញាវ្រះកម្រតាងអញទីវ្រះកម្រតាងអញ | 1. ព្រះបញ្ញត្តិព្រះរាជាស្ដីពីទេព |
| សិទ្ធាយតន ត អាយចុងមុហាតេល ឱយ សំបរិ | 2. សិទ្ធាយតន នៅស្រុកចុងមុហាដែលប្រមូល |
| ភោគ ត វ្រះកម្រតាងអញ គ្រី អចលេ គ្នរ ក្ញុំ | 3. ទ្រព្យធន ជាមួយទ្រព្យធននៅបូជនីយដ្ឋានព្រះគម្ដែង ស្រីអចលេ ស្វរ មានខ្ញុំ |
| ត្នុរ ០ ក្របី ០ ស្រេ ០ ស្រូ ០ ទំរេង ០ ករោម ០ ចំ | 4. គោ ក្របី ស្រែ ស្រូវ ច្បារ វាល ទំនាប ចំ |
| កា ០ គនប្រទានអ្នកផោងអាយ តវ្រះ ០ គេ ត ស | 5. ការដែលជាតង្វាយទាំងអស់ របស់អ្នកផងដល់ព្រះ។ នរណាគេដែល |

| | |
|---|---|
| កគិុ ០ គេតចបអ្នកតគិុ ០ គេត ត្វេក លង៍ត | 6. លួចនៅទីនេះ នរណាគេដែលចាប់អ្នកនៅទីនេះ នរណាគេដែលធ្វើបំពាន |
| គិុ ០ គេតប្របោះគិុ ០ គេតទារ បញ្ជ សតគិុ ០ | 7. នៅទីនេះ នរណាគេដែលប្រើរបស់នៅទីនេះ នរណាគេដែលទារដោយក្រអឺតក្រទម នៅទីនេះ |
| គេតប្តោបរេង៍ចុង៍ស្តៅតគិុ ០ គេត ចបត្នុរ | 8. នរណាគេដែលយកពន្ធរៀង៍ចុង៍ស្តៅនៅទីនេះ នរណាគេដែលចាប់គោ |
| រទេះទោកតគិុ គេបេរ អាផ្សាគេ ទណ្ឌាតន | 9. រទេះ ទូកនៅទីនេះ នរណាគេដែលរំលោភព្រះបញ្ញត្តិ អ្នកនោះ ត្រូវទទួលទណ្ឌកម្ម |



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia



## ១.៣.៣. ព្រះបាទជ័យវម៌្ម ទី១ (៦៥៧-៦៨១)

*ព្រះបាទជ័យវម៌្ម ទី១ (៦៥៧-៦៨១) (ប្រកបដោយជ័យជម្នះ,* K. 453) *ជាញាតិវង្សរបស់ព្រះបាទ ឦសានវម៌្ម ទី១ តាមខ្សែព្រះមាតា តែមិនមែនជាបុត្រព្រះបាទភវវម៌្ម ទី២ ទេ ហើយថែមទាំងអាចជាគូប្រកួតប្រជែងរបស់ព្រះបាទភវវម៌្ម ទី២ ក្នុងការឡើងសោយរាជ្យទៀតផង។*[37] *ព្រះបាទជ័យវម៌្ម ទី១ ចេញមកពីតំបន់ឦសានបុរៈ។ សិលាចារឹកតំបន់បាត់ដំបង និងព្រៃវែងបញ្ជាក់ថា ព្រះអង្គសោយរាជ្យនៅឆ្នាំ ៦៥៧។ តាមរយៈរបាយនៃសិលាចារឹកក្នុងរជ្ជកាលព្រះអង្គ ព្រះបាទជ័យវម៌្ម ទី១ ព្រះអង្គគ្រប់គ្រងតំបន់កណ្តាល និងខាងត្បូង តំបន់អង្គរ និងទន្លេសាប។ បើតាមសិលាចារឹកប្រាសាទវត្តភូ ព្រះបាទជ័យវម៌្ម ទី១ មិនបានគ្រប់គ្រងតំបន់ដែលស្ថិតនៅ*

37. Vickery, 1998

ចន្ទោះវត្តភូ និងតំបន់ព្សានបុរៈ ពោលគឺខេត្តកំពង់ចាមឡើយ។ តាមការសន្និដ្ឋានរបស់លោក Vickery តំបន់ខាងកើតខេត្តកំពង់ចាម គឺបន្ទាយព្រៃនគរ គឺជា «វ្យាធបុរៈ» ( មិនមែននៅបាភ្នំ ដូចការសន្និដ្ឋានរបស់លោក Cœdes ) ដែលគ្រប់គ្រងដោយស្តេច «វ្យាធបុរេគ្វរ»។

## សិលាចារឹកព្រះបាទជ័យវម៌្ម ទី១

ព្រះបាទជ័យវម៌្ម ទី១ បានសោយរាជ្យក្នុងរយៈពេល៤០ឆ្នាំ ដោយសន្តិភាព។ ព្រះអង្គបានពង្រីក និងពង្រឹងអំណាចរបស់ព្រះអង្គនៅតណ្ហចិនភាគខាងត្បូង និងបានសាងសង់ប្រាសាទនៅតំបន់ វ្យាធបុរៈ និងនៅវត្តភូ ផងដែរ។ គេឃើញមានសិលាចារឹក និងប្រាសាទជាច្រើនដែលត្រូវបានសាងសង់នៅក្នុងរជ្ជកាលនេះ។យើងមិនដឹងច្បាស់ពីរាជធានីនៅសម័យនោះឡើយ។ លោក Vickery អះអាងថារាជធានីព្រះអង្គ គឺ បុរានទរបុរ តែមិនដឹងនៅទីណា ហើយក៏មិនមែនជាព្សានបុរ ឬភវបុរ។ តែប្រវត្តិវិទូខ្លះបានសន្និដ្ឋានថា រាជធានីនេះគឺ អមរេន្ទ្របុរ ប្រហែលស្ថិតនៅម្តុំអង្គរ ដែលមានប្រាសាទអកយំ នៅចំកណ្តាល។ បន្ទាប់មក ប្រហែលជារាជធានីត្រូវបានលើកយកមកកាន់តំបន់នៃប្រាសាទត្រពាំងផុង ដែលត្រូវបានព្រះបាទជ័យវម៌្ម ទី២ កែលម្អថែមទៀត។ ក្នុងរជ្ជកាលនៃព្រះបាទ ជ័យវម៌្ម ទី១ ព្រហ្មញ្ញសាសនាសិវនិយមកំពុងរីកចម្រើន ជាពិសេសការគោរពបូជាលិង្គព្រះឥសូរ តែគេមិនសូវឃើញចម្លាក់ព្រះពុទ្ធរូបទេ ដែលបញ្ជាក់ថាការគោរពបូជាព្រះពុទ្ធសាសនាធ្លាក់ចុះ។

ព្រះអង្គប្រហែលជាគ្មានបុត្រ ហើយព្រះរាជបុត្រីព្រះអង្គព្រះនាមជយទេវី ឡើងសោយរាជ្យបន្តពីព្រះអង្គ។ នៅចុងសតវត្សទី៧ សិលាចារឹកមានកាន់តែតិចទៅៗ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



*ក្រដាសផ្តាមពីចារឹកវត្តគូ K. 367 សតវត្សទី៧*

ចារឹកវត្តគូ K. 367 មានរចនាលម្អ ដោយត្រីសូល៍ និងភ្ញីផ្កា។ សិលាចារឹកនេះបានចារឡើង ក្រោមរាជអាជ្ញា ព្រះបាទជយវម៌្ម ទី១ (៦៥៧-៦៨១)។ ចារឹកមានចំនួន ១០ បន្ទាត់ជាភាសាសំស្ក្រឹត ចំនួន ៥ គាថា។ បន្ទាប់ពីបទនមស្ការដល់ព្រះឥសូរ ជាព្រះកម្ទេចកាមទេព ទៅជាផេះ និងបន្ទាប់ពីបទស្តុតី សរសើរចំពោះព្រះបាទ ជយវម៌្ម ទី១ (គាថាទី២ និងទី៣) ចារឹកនេះ ចែងអំពីព្រះរាជអាជ្ញាទាក់ទងនឹងឯកសិទ្ធិ និងច្បាប់ត្រួតត្រានៃប្រាសាទនៅលិង្គបព៌ត (វត្តគូ)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

 

*សិលាចារឹកក្ដីអង្គ ឬអង្គជំនីក K. 53 (ឆ្នាំ៦៦៧)*

សិលាចារឹកនេះមានពីរផ្ទាំង A និង B ដែលរកឃើញនៅអង្គជំនីកឬវត្តអង្គក្ដី ដែលស្ថិតនៅក្នុងភូមិតាទ្រោន សង្កាត់កោះ ស្រុកបាភ្នំ ខេត្តព្រៃវែង។ អត្ថបទនៃចារឹកក្ដីអង្គមាន ២៦ គាថា ត្រូវបានព្រះមហាវីរិយបណ្ឌិតោ ប៉ាង ខាត់ បកប្រែពីភាសាបាលីង ដែលមានន័យសង្ខេបដូចខាងក្រោម៖

នៅក្នុងរាជ្យព្រះបាទរុទ្រវរ្ម័ (មានតេជានុភាព) មានបងប្អូនពីរនាក់ បងឈ្មោះព្រហ្មទត្ត ប្អូនឈ្មោះព្រហ្មសិង្ហ ជាប្រធានលើគ្រូពេទ្យទាំងឡាយ មានកេរ្តិ៍ឈ្មោះល្បីល្បាញ។ ពួកគេមានក្មួយពីរនាក់ ជាអ្នកមានបុណ្យ បងឈ្មោះធម៌ទេព ហើយប្អូនឈ្មោះសិង្ហទេព។

បន្ទាប់មក មានព្រះរាជាព្រះនាម គ្រីភវវម៌្ម បានឡើងសោយរាជ្យ ហើយបានសាងសិវលិង្គព្រះនាម គម្ភិរេឝ្វរៈ។ ធម៌ទេព និងសិង្ហទេព បានក្លាយជារដ្ឋមន្ត្រីក្នុងរាជ្យព្រះបាទ គ្រីភវវម៌្ម ហើយចេះដឹងកិច្ចការ និងស្ទាត់ជំនាញក្នុងកិច្ចការរដ្ឋ សាសនា និងនយោបាយ។ លោកសិង្ហទេពធ្វើតែកិច្ចការជាកុសល ហើយត្រូវបានព្រះបាទ គ្រីភវវម៌្ម តែងតាំងជាឯកអគ្គរាជទូត ដើម្បីចងស្ពានមេត្រីជាមួយប្រទេសចម្ប៉ា។

ធម៌ទេពមានបុត្រមួយឈ្មោះ សិង្ហវិរៈ ជាអ្នកមានប្រាជ្ញាខ្ពង់ខ្ពស់ ជាអ្នកប្រាជ្ញ ចេះតែងកាព្យដ៏ចំណាន ហើយបានក្លាយជារដ្ឋមន្ត្រីក្នុងរាជ្យនៃព្រះបាទ ឦសានវម៌្ម ទៀតផង។

សិង្ហវិរៈ មានបុត្រមួយ ដែលមានប្រាជ្ញាខ្ពង់ខ្ពស់ មានវិន័យ យកចិត្តទុកដាក់លើព្រះធម៌ និងជាពេទ្យ (វៃទ្យ) របស់ព្រះបាទ ជយវម៌្ម។ ព្រះបាទ ជយវម៌្ម ទ្រង់ឈ្វេងយល់ថា សិង្ហវិរៈ គឺជាមនុស្សចេះដឹងការងារ ក៏ទ្រង់តែងតាំងជានាយកក្រុងអាឍ្យបុរៈ។

## រចនាបថ ប្រាសាទអណ្តែត (៤)

រចនាបថប្រាសាទអណ្តែត មានរយៈកាលជំនាន់រចនាបថព្រៃក្មេងដែរ។ ក្រោយពីព្រះបាទ ភវវម៌្មនទី ២ សោយទិវង្គតទៅ ព្រះបាទ ជ័យវម៌្មនទី ១ (៦៥៧-៦៨១) ដែលជាបុត្របានឡើងសោយរាជ្យនៅមុនឆ្នាំ ៦៥៧។ ព្រះអង្គបានពង្រីក និងពង្រឹងអំណាចរបស់ព្រះអង្គនៅក្នុងតំបន់ចិនភាគខាងត្បូង។ គេឃើញមានសិលាចារឹក និងប្រាសាទជាច្រើនដែលបានសាងសង់នៅក្នុងរជ្ជកាលនេះ។

ស្ថាបត្យកម្មនៃដំណាក់កាលនេះ មានលក្ខណៈបន្តពីរចនាបថព្រៃក្មេង ហើយត្រូវបានគេចាត់ទុកថាជាដំណាក់កាលទីពីរនៃរចនាបថព្រៃក្មេងថែមទៀតផង ហើយរចនាបថប្រាសាទអណ្តែត មានរយៈកាលជំនាន់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រចនាបថព្រៃក្មេងដែរ។ ស្ថាដៃវិចិត្រដែលឆ្លុះបញ្ចាំងជាងគេនៃរចនាបថប្រាសាទអណ្តែត គឺរូបចម្លាក់ ហរិហរៈនៃប្រាសាទអណ្តែត ដែលស្ថិតនៅក្នុងសារៈមន្ទីរជាតិនៃទីក្រុងភ្នំពេញ ។

## លេខសូន្យ ឆ្នាំ ៦៨២/៨៣





សិលាចារឹកទួលកំណប់ត្រពាំងព្រៃ K.127៖ នៅឆ្នាំ ១៨៩១ លោក Adhémard Leclere បានរកឃើញសិលាចារឹកមួយផ្ទាំង ចារលើមេទ្វារនៃប្រាសាទទួលកំណប់ត្រពាំងព្រៃ ស្រុកសំបូរ ខេត្តក្រចេះ ដែលចារជាអក្សរ ស.វ. ទី៧។ ការស្រាវជ្រាវរបស់លោក Cœdès តាមរយៈការសិក្សាសិលាចារឹក ស.វ.ទី៧ K-127 ដែលនាពេលបច្ចុប្បន្ន ស្ថិតនៅក្នុងសារមន្ទីរ ជាតិកម្ពុជានៅភ្នំពេញ និងបញ្ជាក់ដោយលោក Amir Aczel បានរកឃើញថា ដូនតាខ្មែរ គឺជាអ្នកបង្កើតលេខសូន្យមុនគេលើពិភពលោក។ ក្នុងឆ្នាំ ១៩៣១ លោក Cœdès បានបកប្រែអត្ថបទលើសិលាចារឹក K-127 នេះ មកជាភាសាបារាំង និងបានកត់ សម្គាល់ថា លេខជាភាសាខ្មែរ ៦០៥ នេះ គឺជាលេខសូន្យចាស់ជាងគេលើសិលាចារឹក ដែលគាត់បានរកឃើញ។ លោក Cœdès បានសរសេរអត្ថបទមួយក្នុងឆ្នាំ១៩៣១។ តែលោក Damais ស្នើឱ្យអាន ៦០៨ វិញទើបត្រូវជាង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## ១.៣.៤. បញ្ហាប្រវត្តិសាស្ត្រកម្ពុជានៅសតវត្សទី៨

### មានសម្មតិកម្មពីរ៖

( ១ ) លោក Cœdes ដោយសិក្សាប្រកពឯកសារចិនបានលើកពីសម្មតិកម្មអស្ថិរភាពការបែកបាក់និងសង្គ្រាមជាមួយ«ជវា» ដែលធ្វើចេនឡាបែកជាពីរ គឺ៖ ចេនឡាដីគោក និងចេនឡាទឹក។

នៅដើម ស.វ.ទី៨ (៧០៦) អំណាចកណ្តាលនៃភ្ញៀសានបុរៈចុះខ្សោយ ៖ ភាគខាងជើង គឺជាតំបន់ភ្នំ (ប្រទេសឡាវភាគកណ្តាល) និងភាគខាងត្បូង គឺជាតំបន់ទឹកលិច ដែលសម្បូណ៌ដោយបឹង និងមានសមុទ្រព័ទ្ធជុំវិញ ( ពីអាងទន្លេមេគង្គ ត្រង់ល្បាក់ខោន ដល់សមុទ្រ ) ។ អាណាចក្រដំបូងបានបែកបាក់ខ្ចាយទៅជារដ្ឋតូចៗ គ្មានលំនឹង។

ការបាក់បែកផ្ទៃក្នុងនៃអាណាចក្រភ្ញៀសានបុរៈបង្កើតឱ្យមានអស្ថិរភាពនយោបាយ និងបណ្តាលឱ្យកងទ័ព «ជវា» ចូលមកលុកលុយ ហើយដាក់ភ្ញៀសានបុរៈជាចំណុះ ។

នៅ ស.វ.ទី៨ ( ឆ្នាំ ៧៧៤ និង ៧៨៧ ) រាជវង្សសៃលេន្ទ្រ បានលើកទ័ពទៅវាតត្បាតឆ្នេរសមុទ្រប្រទេសចម្ប៉ា ។ ពួក«ជវា»បានធ្វើដំណើរឡើងតាមទន្លេមេគង្គដល់សម្ភុបុរៈ ដុតបំផ្លាញទីក្រុង ឡោមព័ទ្ធរាជវាំង ចាប់បានព្រះរាជានាម មហីបតិវរ្ម័ន កាត់យកព្រះសិរ ហើយយកទៅ «ជវា»។

ក្នុងរយៈពេលមួយសតវត្សនេះ យើងគ្មានតឹកតាងអ្វីបញ្ជាក់ពីរាជវង្សនៃស្តេចខ្មែរឡើយ។

( ២ ) លោក Vickery ដោយសិក្សាសិលាចារឹកបានលើកពីសម្មតិកម្មស្ថិរភាពនយោបាយ ហើយគ្មានរដ្ឋដែលមានឈ្មោះចេនឡាទេ ហើយក៏គ្មានការបែងចែកចេនឡាជាពីរដែរ។

នៅសតវត្សទី៨ មានសិលាចារឹកចំនួន ១៦ តែប៉ុណ្ណោះ ហើយក្នុងនោះចំនួន ១១ ជាភាសាខ្មែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅចន្លោះឆ្នាំ ៧៩១ និង ៨៧៧ អត់មានចារសិលាចារឹកទេ។ សិលាចារឹកសម័យអង្គរមានចារចាប់ផ្ដើមពីសិលាចារឹកប្រាសាទព្រះគោ នៅឆ្នាំ ៨៧៧។ លោក Veckery បានលើកឡើងពីការវិវត្តខាងផ្នែកវប្បធម៌ និងការសាងសង់ប្រាសាទមកបញ្ជាក់។

## រចនាបថ កំពង់ព្រះ (៥)

ប្រាសាទភូមិប្រាសាទ និងប្រាសាទកំពង់ព្រះ គឺជាតំណាងនៃរចនាបថកំពង់ព្រះ ដែលសាងសង់ពីឥដ្ឋ។

សិល្បៈខ្មែរធ្លុះបញ្ចាំងនូវភាពបែកបាក់នេះ ដោយរលត់បាត់អស់នូវវិញ្ញាណ នៅសល់តែភាពសាមញ្ញដែលខ្វះភាពច្នៃប្រឌិត។ ផ្តែរទ្វារនៃរចនាបថកំពង់ព្រះមានលក្ខណៈសាមញ្ញ ហើយចម្ងក់ភ្ជាប់បិទបន្តបន្ទាប់គ្នា មានរាងជាស្លឹកឈើមួយសំណុំដាក់ផ្ដេកគងលើគ្នាជាបន្តបន្ទាប់។ នៅចំកណ្ដាលក៏គេឃើញមានស្លឹកឈើ ដែលមានលក្ខណៈដូចរាហូ ឬ កាល។ រចនាបថកំពង់ព្រះបង្ហាញពីធម្មជាតិនិយម ដោយលម្អផ្តែរទ្វារដោយស្លឹកឈើ និងទងឈើទាំងស្រុង។ សសរពេជ្រនៅរក្សារាងមូលដដែល តែលម្អដោយក្បាច់ចិញ្ចៀនកង់ៗបន្តបន្ទាប់គ្នា បីដូចជាទងផ្កា។ ចំណែកឯហោជាងវិញមានរាងដូចអក្សរ U ផ្កាប់ចុះក្រោម ហើយនៅលើផ្ទៃហោជាងមានរូបតូចៗ មួយចំនួន។

ប្រាសាទនៃរចនាបទកំពង់ព្រះមាន៖ ប្រាសាទកំពង់ព្រះ (កំពង់ឆ្នាំង) ប្រាសាទអកយំ ប្រាសាទត្រពាំងផុង ប្រាសាទបាសិត ប្រាសាទភូមិប្រាសាទ (កំពង់ធំ)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



*ផ្តែរនៃរចនាបថកំពង់ព្រះ សតវត្សទី៨*

## សិលាចារឹកភូមិកំរៀង K. 154

*ចារឹកនេះ ជាគោលសីមា រក ឃើញនៅភូមិកំរៀង ឃុំកន្ទាក ស្រុកអង្គស្នួលខេត្តកណ្តាលចារនៅថ្ងៃចន្ទ៩រោចខែជេស្ឋឧត្តរភទ្រនក្សត្របូក្ស ឆ្នាំ ៦៥៦ សក ដែលត្រូវជាថ្ងៃចន្ទ ទី៣១ ខែឧសភា ឆ្នាំ ៧៣៤។*[38]

---

38. Cœdes. (1942). IC, T.II, p. 123 និង *យៀង វីរបុត្រ ២០១៧*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



- ឆ្នាំដែលកំណត់រាប់សករាជកន្លងទៅហើយបាន ៦៥៦ សក
- ៩ រោច ខែជេស្ឋ ថ្ងៃចន្ទ ប្រកបដោយចក្ររាសី ខ្ពស់ កទ្រុបទ
- ថ្ងៃនក្ខត្តប្ញក្ស ពេលនោះម្រតាញ ទេវស្វាមិ ធ្វើពិធីយញ្ញដ័យូរ បួងសួងព្រះ
- កម្រតាងអញ គ្រី កេទារេគ្វរ បុណ្យរបស់ម្រ
- តាញ៖ អង្គរបីលិហ សម្លៀកបំពាក់យៅ ១ វ៉ះ១ អ្នកដាំស្ល។
- វេរខ្ញុំឱយទៅព្រះ៖ បុរសកញយោច បុរសសិទ្ធិយា
- ត នាងក្ងួសកោន នាងបិតិ នាងហរិនិ កូនស្រីបិតិ
- គោ ស្រែ ១០-១ ត្លោង ស្រូវ ៤ ស្ទឹក គឺនេះដែលម្រ
- តាញឱញទៅបោញ សង្កថ៍ណ ថ្វាយព្រះរាជាម្ចាស់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- នៅហង្សបុរ  សភាតែងតាំង គឺ ម្រតា
- ញ បុរុមបាលភាគ ម្រតាញសុទវគនកគវត
- ម្រតាញកវាទិត្យ បព្វជិតចាត់ចែងពិធី៖ បោញគង្គរគណ
- បោញគង្គរកក្តិ បោញភារិគារ បោញវិ
- គេមនន គេជាអ្នកដើមបុណ្យ៖ តាងច្នោត វ្រចរុង បោញ
- គ្រុត វត្នគន ជម្ទ័រក្សួនរាយ វិគេវិន ជានមិត
- បាទមូល បុរសវិទគ្គ បុរសទារុន
- នរណាគេដែលទប់  គឺជាអ្នកលួចនៅទីនេះ  ញាតិ៧សន្តានខាងមាតា ៧ សន្តានខាងបិតាធ្លាក់នរកជ្រៅ
- គួរខ្លាច មហានរក គេគឺជាអ្នកសម្លាប់ព្រាហ្មណ៍ តាមកម្មគេមាន។

## សិលាចារឹកតួមិកំរៀង K. 154-B ជ្រុងទី២



1. ម្រតាញទេវស្វាមិ ជាអ្នកធ្វើពិធីយញ្ញដ៏យូរថ្វាយព្រះកម្រតាង
2. អញ្ញាគីកេទារេគ្វរ បុណ្យរបស់ម្រតាញ៖ អង្គុរ
3. ២លិះ អ្នកដាំស្វ១ សម្លៀកបំពាក់យោ១ គោ ស្រែ ថ្នារ
4. បិណ្ឌ គឺស្រែ២០ផង ខ្ញុំដែលឱយទៅព្រះ៖ នាងវៃនា កូន
5. ស្រីបិតិ នាងស្បាំ កូនស្រីបិតិ គឺដែលម្រតាញទេវស្វាមិ
6. ឱយទៅបោញគ្រុត ថ្វាយព្រះកម្រតាញអញ
7. ត្រីកេទារេគ្វរ បព្វជិតរៀបចំពិធីកាលនោះ គឺម្រតាញកវាទិត្យ
8. សភាដែលបង្កើត និងដែលតែងតាំង គឺ៖ ម្រតាញបុរុបបាល សុទរគន
9. សង្ករមេន តាងក្រហប តាងច្នោត ចន្ទ្រគិល សុក្ខតវទ្ធ
10. ណ ក្បោក គន្ត្រគុប ស្ថានុគន ទេវគម្ម ធម្មទិត្យ កុមារវិ
11. សេស វិសេសវៃ វិសេសគន ឧតទ្យម ធម្មរក្សរតនគន ចន្ទ្រគ
12. ន ជាធរគន សុទ្ធសឹងជាសមាជិកសភា
13. នរណាគេទប់ គឺជាអ្នកលួច គឺញាតិ៧សន្តានខាងមាតា និងបិតា ត្រូវចុះនរក
14. អតិរោរ មហារោរោរ ដូចអ្នកសម្លាប់ព្រាហ្មណ៍ តាមកម្មផលគេ មាន។

## ១.៣.៥. សម្ភុបុរៈ (ក្រចេះ)

ខេត្តក្រចេះគឺជាទីតាំងនៃក្រុងបុរាណបុរេអង្គរ «សម្ភុបុរៈ»។ ទន្លេមេគង្គដើរតួនាទីយ៉ាងសំខាន់ ខាងផ្នែកផ្សព្វផ្សាយសាសនា។ សម្ភុបុរៈមានទំនាក់ទំនងជិតស្និទ្ធជាមួយតំបន់ជុំវិញតាមដងទន្លេមេគង្គ ហើយគេឃើញមានការគោរពព្រះអាទិទេព (គ្រមាត) «អាម្រាតគេគ្វរ» (អាទិទេពស្វាយ) ពីក្រចេះដល់ដីសណ្តទន្លេមេគង្គ (K. 8), ជិតបាភ្នំ (K. 54-55) (ឆ្នាំ ៦២៩),



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កណ្ដាល (K. 1003-4) (ឆ្នាំ ៦៩១, ព្រៃវែង (K. 493) (ឆ្នាំ ៦៥៧), កំពង់ចាម (K. 115, K. 725) និងក្រចេះ (K. 124) (ឆ្នាំ ៨០៣)។

សិលាចារឹកវត្តសសរមួយរយ K. 124 ផ្ដល់នូវព័ត៌មានពីប្រវត្តិពង្សាវតារវង្សរាជវង្ស៖ ក្រោយពីព្រះបាទជ័យវម៌្ម ទី១ បានចូលទិវង្គត បុត្រីរបស់ព្រះអង្គ ព្រះនាងជយទេវី បានឡើងសោយរាជ្យ ហើយបន្ដដោយព្រះមហាក្សត្រីបីអង្គទៀត នៅសម្ភុបុរៈនៅសតវត្សទី៨។ លោក Vickery សន្និដ្ឋានថា៖ នៅសតវត្សទី៧ នៅសម្ភុបុរៈ មានស្ដេចសោយរាជ្យខ្លួនឯង និងមិនមែនចំណុះឱ្យព្រះរាជាដែលសោយរាជ្យនៅរដ្ឋផ្នែកកណ្ដាល រហូតដល់រាជ្យព្រះបាទជ័យវម៌្ម ទី២។

នៅសារមន្ទីរខេត្តក្រចេះគេឃើញមានសិលាចារឹកមួយចំនួន ដែលរកឃើញនៅក្នុងខេត្តក្រចេះ។

## សិលាចារឹកខេត្តក្រចេះនៅសតវត្សទី៨

សិលាចារឹកប្រាសាទព្រះធាតុខ្វាន់ពីរ K. 121៖ ប្រាសាទព្រះធាតុខ្វាន់ពីរ ស្ថិតនៅចម្ងាយប្រមាណជា ៤០ គីឡូម៉ែត្រ ខាងជើងឆៀងខាងកើត ទីរួមខេត្តក្រចេះ ដែលជាសំណង់ដើមសតវត្សទី៨ ដើម្បីឧទ្ទិសដល់ព្រះសិវៈ។ ទ្វារខាងជើងនៃប្រាសាទព្រះធាតុខ្វាន់ពីរមានចារឹកលើមេទ្វារ។ ចារលើមេទ្វារខាងជើង ជាភាសាសំស្ក្រឹត មាន ២ បន្ទាត់ ចារនៅឆ្នាំ ៧១៧។ លោក Finot បានបកប្រែចារឹកនេះថា៖ «ព្រាហ្មណ៍បុស្ការ បានស្ថាបនា ប្រាសាទនេះឡើង ហើយនៅមហាសករាជ ៦៣៨ (ដែលត្រូវជាថ្ងៃអង្គារ ទី៥ ខែមករា ឆ្នាំ ៧១៧) បានសាងសង់ព្រះលិង្គរាជ្យទីមួយនៅអាណាចក្រខ្មែរឈ្មោះលិង្គ បុស្ករេគ»។

Cœdes និង Dupont បានបង្ហាញថា តាមរយៈសកម្មភាពនេះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រាហ្មណ៍បុស្ករមានបំណងក្លាយជាព្រះរាជានៃសម្ភុបុរ ហើយបានប្រកាសខ្លួនថាជាស្តេចនៃចេនឡា។ ដោយសារសកម្មភាពនេះ ចេនឡាបានបែកជារាជវង្សពីរ ជាពិសេសសន្តានរាជវង្សរបស់ក្មួយទួត (ចៅទួត) របស់មហេសីព្រះអង្គ គឺព្រះបាទជ័យវម៌្មទី២ (៧៧០-៨៣០) ដែលបានបង្កើតអាណាចក្រអង្គរឡើង។[39]



## សិលាចារឹកចត្តសសរមួយរយ K. 124 និង K. 1014

សិលាចារឹកK.124៖មាន ២៥បន្ទាត់៖២បន្ទាត់ដំបូងជាភាសាសំស្ក្រឹត ១៩ បន្ទាត់ជាភាសាខ្មែរ និង៤ បន្ទាត់ចុងក្រោយជាភាសាសំស្ក្រឹត។ អត្ថបទភាសាខ្មែរចាប់ផ្តើមពីកាលបរិច្ឆេទ ៨០៣/៤ ដើម្បីកត់ត្រាជង្វាយរបស់ព្រះរាជអគ្គមហេសី ជ្យេសថាយា ដល់ទេព «គ្រីមទ អាម្រាតក» ជាទេពដែលគេរកឃើញនៅក្នុងចារឹកសម័យមុនអង្គរជាពិសេស K. 1014។

សិលាចារឹក K. 1014៖ គឺជាបំណែកដែលរកឃើញនៅឆ្នាំ ១៩៦៦ នៅតាមមាត់ទន្លេមេគង្គ។ អត្ថបទជាភាសាសំស្ក្រឹតមាន ៣ បន្ទាត់ ចារនៅសតវត្សទី១០ (បាត់មិនដឹងនៅឯណា)។ លោក Jacquesយល់ឃើញថាបំណែកនេះ គឺជាសិលាមូលស្ថាបនា និយាយពីទេព «គ្រីមទ អាម្រាតក» ដូចនៅក្នុង K. 124 ដែរ។

ដូច្នេះ ចារឹកទាំងពីរនេះមកពីប្រាសាទតែមួយ។ ដោយ K. 124 មានកាលបរិច្ឆេទត្រឹមត្រូវ គឺចារនៅឆ្នាំ ៨០៣/៤ តែប្រើអក្សរសម័យមុនអង្គរ ចំណែកឯK. 1014 មិនមានកាលបរិច្ឆេទ តែចារដោយប្រើអក្សរសម័យអង្គរ

39. Bruguier et Lacroix, T. IV, 2016



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូចចារឹកប្រាសាទលលៃ (សតវត្សទី ៩) និងចារឹកប្រាសាទកោះកេរ (សតវត្សទី ១០។ ដូច្នេះ យើងឃើញថា K. 1014 ចារពេលក្រោយ គឺនៅចុងសតវត្សទី៩ ដើមសតវត្សទី១០ បើប្រៀបធៀបនឹងK.124 ដែលចារនៅដើមសតវត្សទី៩។

សិលាចារឹកទាំងពីរនេះបង្ហាញថា៖

(១) សម្ពុបុរៈមិនស្ថិតនៅក្រោមការគ្រងរាជ្យនៃរាជវង្សានុវង្សអង្គរឡើយ។

(២) នៅឆ្នាំ ៨០២ គឺជាការផ្លាស់ប្តូរ របបនយោបាយតែភាសាខ្មែរចាស់នៅមិនទាន់មានការផ្លាស់ប្តូរទេ។

(៣) ពាក់កណ្តាលទី ១ នៃសតវត្សទី៩ គឺជាដំណាក់កាលនៃការវិវត្តភាសាខ្មែរចាស់ពីបុរេអង្គរទៅអង្គរ តែគ្មានសិលាចារឹកចារឡើយ។[40]



K. 124




K. 124

40. Bruguier et Lacroix, T. IV, 2016

# សិលាចារឹកខេត្តក្រចេះ

*សិលាចារឹក Ka. 177៖ គឺជាបំណែកនៃសិលាមូលស្ថាបនា ដែលរកឃើញនៅភូមិគោលាប់ ឃុំគោលាប់ ស្រុកចិត្តបុរី ខេត្តក្រចេះ។ អត្ថបទជា*



*ភាសាខ្មែរចាស់នេះ និយាយពីការធ្វើអំណោយដល់ព្រះអាទិទេព ជាមនុស្ស ដីស្រែ និងសត្វពាហនៈ ដោយមានបញ្ជីឈ្មោះអ្នកបម្រើជាមនុស្សស្រី (តៃ) និងកូន (កោន) និងមានរៀបរាប់ពីគោ (ត្មុរ) ។ល។ បើតាមភាសាដែលប្រើប្រាស់នេះ ស្រដៀងនឹងសិលាចារឹកលលៃ និងព្រះគោនៅសតវត្សទី៩។*

# ផ្នែកទី២

# អក្សរសិល្ប៍កម្ពុជាសម័យអង្គរ



## ២.១. ព្រះបាទជ័យវម៌្ម ទី២ (៨០២-៨៥០)
## និង ព្រះបាទជ័យវម៌្ម ទី៣ (៨៥៤-៨៧៧)

សតវត្សទី៩៖ សម័យអង្គរចាប់ផ្ដើមពីព្រះបាទជ័យវម៌្ម ទី២ (៨០២-៨៥០) ដែលបង្រួបបង្រួមទឹកដី ហើយបានបង្កើតរាជធានីនៅ ឥន្ទ្របុរៈ (កំពង់ចាម) បន្ទាប់មករើមកនៅហរិហរាល័យ (រលួស សៀមរាប) បន្ទាប់មករើមកនៅ ស្រីមហេន្ទ្របុរៈ បន្ទាប់មករើមកនៅ អមរេន្ទ្របុរៈ (ប្រាសាទអកយំ បារាយណ៍) និងចុងក្រោយបំផុតព្រះអង្គរៀបចំរាជធានីនៅ មហេន្ទ្របព៌ត (ភ្នំគូលែន)។

ភ្នំគូលែន គឺជាតំណាងភ្នំសុមេរុ។ នៅលើកំពូលភ្នំគូលែន ព្រះបាទជ័យវម៌្ម ទី២ បញ្ជាឱ្យព្រាហ្មណ៍ឈ្មោះ ហិរណ្យទាម ដែលជាអ្នកប្រាជ្ញមកប្រារព្ធ «ពិធីទេវរាជ» ដែលជាប្រភពនៃអំណាចតេជៈ ហើយអភិសេកព្រះអង្គឱ្យមានឋានៈជា ចក្រវាទីន (ស្ដេចចក្រវាល) នៅគ.ស.៨០២។ ព្រាហ្មណ៍





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហិរណ្យទាម បានបង្រៀនព្រាហ្មណ៍ សិវកៃវល្យ ឱ្យចេះអស់សាស្ត្រាទាំងបួន និងបង្រៀនឱ្យចេះរៀបចំពិធីទេវរាជ។ ដូនតារបស់ព្រាហ្មណ៍ សិវកៃវល្យ រស់នៅលើទឹកដីផ្តល់ដោយព្រះមហាក្សត្រនៃ ភវបុរៈ ក្នុងវិស័យ ឥន្ទ្របុរៈ ហើយគោរពបូជាសិវលិង្គ នៅក្នុងក្រុងឈ្មោះ ភទ្រយោគិ។ ចុងបញ្ចប់ ព្រះអង្គសុគតនៅក្រុងហរិហរាល័យ។

ព្រះបាទជ័យវម៌្មទី៣ (៨៥៤-៨៧៧) ជាព្រះរាជបុត្ររបស់ព្រះបាទជ័យវម៌្ម ទី២ បានឡើងសោយរាជ្យស្នង ដែលមានព្រាហ្មណ៍ សូក្ស្មវិន្ទុ ជាបុរោហិត និងដោយគង់នៅ ហរិហរាល័យ រហូតដល់គ.ស.៨៧៧។ ព្រះអង្គបានសាងប្រាសាទមួយចំនួននៅ ហរិហរាល័យ (រលួស)។

## រចនាបថ គូលែន (៦)

រចនាបថ គូលែន ឆ្លុះបញ្ចាំងផងដែរនូវស្ថិរភាពនយោបាយ និងសង្គមនៃរជ្ជកាលព្រះបាទជ័យវម៌្មន ទី ២ ដែលបានបានរំដោះប្រទេសជាតិឱ្យមានឥស្សរភាពឡើងវិញ និងបង្រួបបង្រួមប្រទេសឱ្យមានឯកភាពជាតិឡើងវិញ។ លោក ហ្វីលីព ស្ទែន បានបរិយាយដោយខ្លីថា៖ ការសិក្សាសសរពេជ្រ ផ្តែរ និងរូបបដិមាបានបង្ហាញថា រចនាបថ គូលែនមានទិដ្ឋភាពបីយ៉ាងដែលបង្រ្គប់គ្នា៖ (១) សសរពេជ្រមានរចនាបថឯកភាពគ្នា (២) ផ្តែរមានលក្ខណៈកែលម្អ យ៉ាងវិចិត្រ និងការច្នៃប្រឌិតយ៉ាងរស់រវើករបស់សិល្បករ ដែលខ្ចីសិល្បៈពីគេខ្លះ តែកែច្នៃឱ្យក្លាយទៅជាអត្តសញ្ញាណរបស់ខ្លួន និង (៣) រូបបដិមាដែលឆ្លុះបញ្ចាំងពីសម័យអន្តរកាល នៅចន្លោះរចនាបថដែលកន្លងផុត និង រចនាបថដែលនឹងមកដល់។

ដំណាក់កាលនៃរចនាបថគូលែន គឺជាដំណាក់កាលនៃការរស់ឡើងវិញនៃសិល្បៈជាតិ ដែលបង្ហាញពីការបង្កើតឡើងថ្មី និងតក្កកម្មយ៉ាងផុសផុល កម្ចីពីរចនាបថមុនៗហើយកែច្នៃបន្ត និងការចម្លងខ្លះៗពីទស្សនាទាននៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*សិល្បៈបរទេស ដូចជាសិល្បៈចាម និងជ្វាជាដើម។ ឧទាហរណ៍ នៅលើខ្នង់រាបគូលែនមានប្រាសាទពីរ ដែលស្រដៀងបេះបិទទៅនឹងសិល្បៈចាម។ ស្ថាបត្យកម្មនៃប្រាសាទដំរីក្រាបមានលក្ខណៈដូចស្ថាបត្យកម្មចាម លើកលែងតែទ្វារមុខ សសរពេជ្រ ផ្ដែរ ហោជាង និង សសរដែលមានលក្ខណៈជាសិល្បៈខ្មែរ។*



*ផ្ដែរនៃរចនាបថគូលែន ដើមសតវត្សទី៩ប្រាសាទអូប៉ោង ភ្នំគូលែន*

## ការបង្រួបបង្រួមជាតិ

*សិលាចារឹក គឺជាសារខាងផ្នែកសាសនា នយោបាយ វប្បធម៌ អក្សរសិល្ប៍និងខាងផ្នែកភាសា។*

*នៅដំណាក់កាលដំបូងនៃការបង្រួបបង្រួមជាតិលើផ្ទៃប្រទេសទាំងមូល ក្រោមរជ្ជកាលនៃព្រះបាទ ជ័យវម៌្មទី២ និងព្រះបាទ ជ័យវម៌្មទី៣ ដែលបានប្រកាសខ្លួនជា «ទេវរាជ» ដើម្បីបង្កើតអាណាចក្រអង្គរក្រោមការដឹកនាំរួមនៃរដ្ឋបាលកណ្ដាល គេមិនឃើញមានសិលាចារឹកទេ។*

*មានសម្មតិកម្មថា ដើម្បីបង្រួបបង្រួមជាតិ ព្រះរាជាបានហាមឃាត់មិន*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឱ្យចារសិលាចារឹក ដែលអាចនាំឱ្យមានការបែកបាក់ជាតិ។ ដូច្នេះ នេះក៏អាចជាយុទ្ធសាស្ត្រក្នុងការដឹកនាំ ដោយទុកឱ្យពេលវេលាជាអ្នកដោះស្រាយ។

## ការវិវត្តភាសាខ្មែរនៅសតវត្សទី ៩-១២

សតវត្សទី៩ គឺជាសតវត្សនៃយុគសម័យថ្មី សម័យអាណាចក្រអង្គរ ដែលមានការផ្លាស់ប្ដូរយ៉ាងខ្លាំងខាងផ្នែកភាសា រចនាបថប្រាសាទ សេដ្ឋកិច្ច សង្គម និងសាសនា។ ទាំងតួអក្សរ ទាំងពាក្យ និងទស្សនទានសាសនាក៏មានការប្រែប្រួលខ្លាំង បើប្រៀបធៀបនឹងសម័យមុនអង្គរ។ ដូច្នេះ ការផ្លាស់ប្ដូរខាងផ្នែកនយោបាយ និងការគ្រប់គ្រងប្រទេស ជាពិសេសកំណែទម្រង់ខាងផ្នែកសាសនា នាសម័យអង្គរមានផលជះយ៉ាងខ្លាំងក្លាទៅលើការវិវត្តនៃអក្សរ និងភាសាខ្មែរ។

ការប្រែប្រួលទម្រង់អក្សរពីបុរេអង្គរទៅអង្គរចាប់ផ្ដើមពីសិលាចារឹកប្រាសាទព្រះគោ ក្នុងរជ្ជកាលព្រះបាទឥន្ទ្រវម៌្ម ទី១។ ក៏ប៉ុន្តែ ទាំងទម្រង់អក្សរ ទាំងពាក្យ និងទាំងវេយ្យាករណ៍មានការប្រែប្រួលខ្លាំង ក្នុងរជ្ជកាលព្រះបាទយសោវម៌្ម ទី១ ( ចារឹកប្រាសាទលលៃ)។

នៅសតវត្សទី១០ តាមរយៈសិលាចារឹកកោះកេរ K. 183-10 និងចារឹកបក្សីចាំក្រុង K. 286 ទម្រង់អក្សរប្រែជាមូលខ្លាំង។





ផ្ដេរនៃរចនាបថគូលែន ដើមសតវត្សទី៩ប្រាសាទអូប៉ោង ភ្នំគូលែន



*អក្សរមូលនៃចារឹកកោះកេរ និងបក្សីចាំក្រុង*

## ការវិវត្តភាសាខ្មែរនៅសតវត្សទី ១១-១៣

*នៅសតវត្សទី១១ តាមរយៈសិលាចារឹកចារឹកប៉ាលហាល K. 449 និងចារឹកដទៃទៀត គេចាប់ឃើញមានចារឹក ក្នុងទម្រង់ជាអក្សរជ្រុង។*

*ក៏ប៉ុន្តែ នៅសតវត្សទី១១នេះ ថ្វីត្បិតតែមានទំនោរទៅរកអក្សរជ្រុងយ៉ាងលឿនដូច្នេះមែន តែចារឹកស្តុកកក់ធំ K. 235 គេនៅប្រើអក្សរមូល ហើយចារឹកវត្តព្រះជាតុទឹកថា K. 702 ទៀតសោត គេនៅសរសេរជាអក្សរមូលតាមទម្រង់ចារឹកប្រាសាទបន្ទាយស្រីនៅឡើយ។*

*នៅសតវត្សទី១២ និង១៣ សិលាចារឹកចារសុទ្ធសឹងតែក្នុងទម្រង់អក្សរជ្រុង។ ក៏ប៉ុន្តែ មិនមែនមានន័យថាអក្សរមូលគេលែងប្រើនោះទេ។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ចារឹកប៉ាលហាល K. 449 និងចារឹកវត្តព្រះធាតុ ទឹកឆា K. 702 នៅសតវត្ស ទី១១




ចារឹកអក្សរជ្រុងនៅសតវត្ស ទី១២ និងទី១៣

# ព្រះមហាក្សត្រអង្គរ

| ព្រះនាម | គ្រិស្តសករាជ | រាជធានី | សាសនា/ប្រភព |
|---|---|---|---|
| ជយវម៌្ម ទី២ | ៨០២-៨៥០ | មហេន្ទ្របវ៌ត | បរមេស្វរ |
| ជយវម៌្ម ទី៣ | ៨៥៤-៨៧៧ | ហរិហរាល័យ | វិស្ណុលោក |
| ឥន្ទ្រវម៌្ម ទី១ | ៨៧៧-៨៨៩ | ហរិហរាល័យ | ឥស្វរលោក |
| យសោវម៌្ម ទី១ | ៨៨៩-៩១៥ | យសោធរបុរ | បរមសិវលោក |
| ហស៌វម៌្ម ទី១-ឦសានវម៌្ម ទី២ | ៩១៥-៩២៨ | យសោធរបុរ | រុទ្រលោក-បរមរុទ្រលោក |
| ជ័យវម៌្ម ទី៤ | ៩២១-៩៤១ | កោះកេរ | ? |
| ហស៌វម៌្ម ទី២ | ៩៤២-៩៤៤ | កោះកេរ | ព្រហ្មលោក |
| រាជេន្ទ្រវម៌្ម | ៩៤៤-៩៦៦ | យសោធរបុរ | សិវលោក |
| ជ័យវម៌្ម ទី៥ | ៩៦៨-១០០០ | យសោធរបុរ | បរមវិរលោក |
| សូរ្យវម៌្ម ទី១ | ១០១១-១០៥០ | យសោធរបុរ | និវាន៌បទ |
| ឧទ័យាទិត្យវម៌្ម ទី២ | ១០៥០-១០៦៦ | អង្គរទី២ | ? |
| ហស៌វម៌្ម ទី៣ | ១០៦៦-១០៧៩ | យសោធរបុរ | ? |
| នឫបតីន្ទ្រវម៌្ម | ១០៨០-១១១២ | អង្គរ | ? |



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

| | | | |
|---|---|---|---|
| ជ័យវម៌្ម ទី៦ | ១០៨០-១១០៦ | មហិធរបុរ | បរមកៃវល្យបទ |
| ធរណីន្ទ្រវម៌្ម ទី១ | ១១០៧-១១១២ | មហិធរបុរ | បរមនិស្កលបទ |
| សូរ្យវម៌្ម ទី២ | ១១១៣-១១៥២ | អង្គរ | បរមវិស្ណុលោក |
| ធរណីន្ទ្រវម៌្ម ទី២ | ១១៥២-១១? | អង្គរ | ? |
| យសោវម៌្ម ទី២ | ១១?-១១៦៥ | អង្គរ | ? |
| ត្រិភូវនាទិត្យវម៌្ម | ១១៦៥-១១៧៧ | អង្គរ | ព្រហ្មញ្ញសាសនា/ ពុទ្ធសាសនាមហាយាន |
| ជ័យវម៌្ម ទី៧ | ១១៨១-១២១៨ | អង្គរទី៣ | មហាបរមសៅគត/ ពុទ្ធសាសនាមហាយាន |
| ឥន្ទ្រវម៌្ម ទី២ | ១២១៨-១២៤២ | អង្គរ | ពុទ្ធសាសនាមហាយាន |
| ជយវម៌្ម ទី៨ | ១២៤៣-២៩៥ | អង្គរ | ព្រហ្មញ្ញសាសនា |
| ឥន្ទ្រវម៌្ម ទី៣ | ១២៩៦-១៣០៨ | អង្គរ | ? |
| ស្រិន្ទ្រជ័យវម៌្ម | ១៣០៨-១៣២៧ | អង្គរ | ពុទ្ធសាសនាថេរវាទ |
| ជ័យវម៌បរមេស្វរ/ ជ័យវម៌្ម ទី៩ | ១៣២៧-១៣? | អង្គរ | សិលាចារឹក |
| និពាន្ទនបទ- លំពង់រាជា | ១៣៤០-១៣៥១? | អង្គរ | រាជពង្សាវតា |
| ពញាយ៉ាត | ១៤៣១ | ចាកចោល អង្គរ | រាជពង្សាវតា |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.២. ព្រះបាទ ឥន្ទ្រវម៌្ម ទី ១ (៨៧៧-៨៨៩)

ព្រះបាទឥន្ទ្រវម៌្ម ទី១ (ជនដែលព្រះឥន្ទ្រការពារ, K. 14) (៨៧៧-៨៨៩) ប្អូនជីដូនមួយរបស់ព្រះបាទជ័យវម៌្ម ទី៣ បានឡើងគ្រងរាជសម្បត្តិនៅឆ្នាំ ៨៧៧។ នៅក្នុងរាជ្យព្រះបាទឥន្ទ្រវម៌្ម ទី១ រលួសបានក្លាយជាទីក្រុងមួយយ៉ាងល្អឯក ដែលមានប្រជាជនរស់នៅតាមមាត់បឹងទន្លេសាប និងប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត។ ព្រះអង្គបានជីកបារាយណ៍ឥន្ទ្រតដាក (សមុទ្រព្រះឥន្ទ) នៅខាងជើងរាជធានី ដែលមានប្រវែង៣៨០០ម៉ែត្រ និងទទឹង៨០០ម៉ែត្រ ដើម្បីបម្រើឱ្យសាសនាផង និងជាប្រព័ន្ធស្រោចស្រពផង (អាចផ្ទុកទឹកបានជិត៨លានម៉ែត្រគូប)។ នៅឆ្នាំ ៨៧៩ ព្រះអង្គបានកសាងប្រាសាទព្រះគោ ដើម្បីឧទ្ទិសថ្វាយចំពោះព្រះមាតា ព្រះបិតា និង



ជីដូនជីតា។ នៅឆ្នាំ៨៨១ ទ្រង់បានកសាងប្រាសាទបាគង ដែលជាប្រាសាទរដ្ឋ (សម្រាប់តម្កល់ទេវលិង្គ) និងប្រាសាទភ្នំទីមួយ សាងពីថ្មភក់សម្រាប់តម្កល់ទេវលិង្គ ឥន្ទ្រេស្វរៈ។

ក្នុងរជ្ជកាលព្រះអង្គ គេបានរកឃើញសិលាចារឹក ២៥ ផ្ទាំង៖ ចារឹកព្រះគោ ១៣ផ្ទាំង (K.310-317, K.713, សក ៨០១; K. 415 សក ៧៩៩), សិលាចារឹកបាគង ៦ ផ្ទាំង (K304-308; K. 826, សក ៨០៣); ចារឹកប្រាសាទស្រង៉ែ (K.937, សក ៨០៥); ចារឹកបុងកេ យសុធោន (K.495, សក ៨០៨); ចារឹកភូមិបូខ្ពស់ ព្រៃវែង (K.655, សក ៨០៤); ចារឹកប្រាសាទកណ្ដាលដុំ សៀមរាប(K.809, សក ៨០០?); ចារឹកតាមាន់ធំ បូរីរម្យ (K.1185, សក ៨០០); និងសិលាចារឹកភ្នំបាយ៉ង់ (K.14)។



សិលាចារឹកព្រះគោ

## សិលាចារឹកព្រះគោ

សិលាចារឹកព្រះគោ៖ សិលាចារឹកមូលស្ថាបនា ( Stèle de fondation ) នៃប្រាសាទព្រះគោ ហើយត្រូវបានរកឃើញនៅឆ្នាំ ១៩៣២ ហើយលោក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Cœdes បានសិក្សានៅក្នុងសៀវភៅ Inscriptions du Cambodge (Volume 1)។ ចំហៀងទី១ សរសេរជាកំណាព្យ ដែលចាប់ផ្ដើមពីការជូនពរសូមឱ្យទ្រព្យសម្បត្តិ (ស្រី) ជោគជ័យ (សិទ្ធិ) សុភមង្គល (ស្វស្តិ) ជ័យជម្នះ (ជយ) និងកិត្តិយស (នមៈ) ចូរមានដល់បរមេស្វរ និងកំណាព្យសំស្ក្រឹតចំនួន ៤៣ បន្ទាត់ ជា៤០វគ្គ។ កំណាព្យនេះរៀបរាប់ថា ព្រះបាទព្រះបាទ ឥន្ទ្រវម៌្ម បានឡើងសោយរាជ្យនៅមហាសករាជឆ្នាំ ៧៩៩ (គស ៨៧៧)។ ព្រះអង្គមានថ្វីព្រះហស្តក្នុងការប្រយុទ្ធ ហើយគ្មានសត្រូវណាអាចឈ្នះព្រះអង្គបានឡើយ។ ព្រះអង្គបានធ្វើពិធីអភិសេក ដើម្បីក្លាយទៅជា «ទេវរាជ»។ ព្រះអង្គមានព្រះកិត្តិនាមល្បីរន្ទឺសុះសាយក្នុងលោកទាំងបី។ ព្រះអង្គបានថ្វាយព្រះនូវស្វេតច័ត្រ មាសប្រាក់ គ្រឿងអលង្ការ អ្នករបាំ អ្នកចម្រៀង តន្ត្រីករ និងតន្ត្រីការិនី មនុស្សប្រុស ស្រី និងគ្រឿងឧបភោគបរិភោគ។

ចំហៀងទី២ គឺជាអត្ថបទជាភាសាខ្មែរចាស់ ដែលរៀបរាប់ថា នៅមហាសករាជឆ្នាំ ៨១៥ (គស ៨៩៣) ព្រះបាទ យសោវម៌្ម បានថ្វាយដល់ព្រះបរមេស្វរ នូវមាស ប្រាក់ និងខ្ញុំបម្រើ៖ ស្វេតច័ត្រមាស និងប្រាក់ ខ្ញុំបម្រើ អ្នកគង្វាល ស្ត្រី ប្រុស និងក្មេង។

## សិលាចារឹកបាគង

ប្រាសាទបាគង «ឥន្ទ្រេស្វរ» គឺជាប្រាសាទភ្នំរាងជាសាជី ដែលត្រូវបានសាងសង់ដោយព្រះបាទ ឥន្ទ្រវម៌្ម នៅឆ្នាំ ៨៨១។ សិលាចារឹកភាសាសំស្ក្រឹតមានចារនៅលើមេទ្វារទាំង ៥ នៃប៉មទាំង ៨ នៅព័ទ្ធជុំវិញប្រាសាទសាជីនេះ (K. 304-308) និងមានសិលាមូលស្ថាបនាដែលមានចារឹកមួយទៀត (K. 826)។

សិលាចារឹកបាគង K. 923៖ ចារឹកលើមេទ្វារនៃប៉មទី ១៧ ដែលស្ថិត


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅចន្លោះខ្សែក្រវ៉ាត់ទី ២ និងទី ៣ ផ្នែកខាងលិចនៃមាត់ច្រកខាងជើង ជាចារឹកភាសាសំស្រ្កឹត។ ចារឹកនេះសរសើរដល់ព្រះរាជាព្រះបាទ ឥន្រ្ទវម៌្ម និងដល់ព្រះរាជបុរោហិត នាម គ្រីនិវាសកវិ ដែលបន្ទាប់ពីបានបម្រើព្រះបាទជ័យវម៌្មទី៣ រួចមកបន្តបម្រើព្រះបាទ ឥន្រ្ទវម៌្មទៀត។ ព្រះរាជបុរោហិតគ្រីនិវាសកវិ ជាអ្នកប្រាជ្ញដែលចេះគម្ពីរវេទយ៉ាងស្ទាត់ជំនាញ ហើយដែលមកដល់ទីនេះ ដើម្បីធ្វើវិសុទ្ធកម្មនៃប្រទេសកម្ពុ។[41]

សិលាមូលស្ថាបនាបាគង K. 829៖ ចារឹកនេះ គឺជាអត្ថបទពីរាជ្យព្រះបាទសូរ្យវម៌្មទី១ ដែលនិយាយពីសំណើសុំឱ្យព្រះមហាក្សត្រចេញបញ្ញត្តិសុំដកអាស្រមពីការគ្រប់គ្រងរបស់មន្ត្រីថ្នាក់មូលដ្ឋាន ដែលក្នុងនោះក៏មានអាស្រមខ្វះត្រូវបានគេបោះបង់ចោលនៅពេលសង្រ្គាមដណ្តើមរាជ្យមុនរាជ្យរបស់ព្រះបាទសូរ្យវម៌្មទី១ផងដែរ ដើម្បីដាក់អាស្រមទាំងនោះ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ត្រីថ្នាក់ខ្ពស់វិញ។[42]



41. Cœdes, IC, IV, 1952

42. Cœdes, IC, IV, 1952



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# រចនាបថ ព្រះគោ (៧)

*រចនាបថសម័យអង្គរបែកចេញជា៖ (៧) រចនាបថព្រះគោ (៨) រចនាបថបាខែង (៩) រចនាបថកោះកេរ (១០) រចនាបថប្រែរូប (១១) រចនាបថបន្ទាយស្រី (១២) រចនាបថឃ្លាំង (១៣) រចនាបថបាពួន (១៤) រចនាបថអង្គរវត្ត និង (១៥) រចនាបថបាយ័ន។*

*ប្រាសាទនៃក្រុមប្រាសាទរលួស ដូចជាប្រាសាទព្រះគោ ប្រាសាទបាគង និង ប្រាសាទលលៃ ត្រូវបានកសាងឡើងដោយមានទូវសមាសធាតុទាំងអស់នៃសិល្បៈខ្មែរសម័យអង្គរ៖ ប្រាសាទរាបស្មើ និង ប្រាសាទ-ភ្នំ មានរបងព័ទ្ធជុំវិញ គោបុរៈ ខ្លោងទ្វារចូល បណ្ណាល័យ សាលទ្រវែង ដែលបន្ទាប់មកក្លាយទៅជាកំពែងថែវ គូទឹកព័ទ្ធជុំវិញប្រាសាទ ផ្ដែរ សសរពេជ្រ សសរទ្រ ហោជាង ហើយថែមទាំង ចាប់ផ្ដើមមានចម្លាក់លិប (Bas-relief) ធំៗទៀតផង។ ផ្ដែរទ្វារនៃប្រាសាទព្រះគោ គឺជាផ្ដែរដ៏ល្អបំផុត និងមានលក្ខណៈពេញលេញបំផុតនៃសិល្បៈខ្មែរ។*

*សមាសធាតុនៃផ្ដែរមាន៖ ក្បាច់ផ្ដេក ក្បាច់កណ្ដាល ក្បាច់គែមសងខាងក្បាច់ពុះកាត់ជាបួនផ្នែក ក្បាច់ខាងលើ ក្បាច់ផ្ដេក ក្បាច់ខាងក្រោម ក្បាច់ផ្ដេក ក្បាច់ទម្រ ក្បាច់គែម ក្បាច់គែមខាងក្រោម និងក្បាច់គែមខាងលើ។*

*លោក ហ្សីលប៊ែត ដឺ កូរ៉ាល់-រ៉េមុយហ្សាត បានពិពណ៌នាយ៉ាងល្អិតល្អន់ពីផ្ដែរនៃប្រាសាទព្រះគោថា៖ «ក្បាច់ផ្ដេកជាសំណុំស្លឹកឈើ ដែលពេលខ្លះត្រង់ ហើយពេលខ្លះពត់ពែនត្រូវបានបង្កើតឡើងដើម្បីជំនួសធ្នូ។ បន្ទាប់មកក្បាច់ផ្ដេកជាមែកឈើនេះ បែកចេញជាក្បាច់គែមសងខាង ជាក្បាលសត្វមករ ជាក្បាលនាគរាជ ជាស្លឹកឈើវិញត្របាញ់ ឬទៅតាមការស្រមើស្រមៃរបស់សិល្បករ។ នៅក្រោមក្បាច់ផ្ដេក គេឃើញមាននៅសល់តែក្បាច់ជាស្លឹកឈើវិញត្របាញ់ប៉ុណ្ណោះ ហើយសិល្បករខ្មែរលែងប្រើក្បាច់រំយោល និងបន្ដោងរយ៉ាទៀតហើយ»។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំពោះក្បាច់នៅកណ្ដាលនៃផ្ដែទ្វាររចនាបថព្រះគោបង្ហាញពីតួអង្គ រាហូ គ្រុឌ ព្រះឥន្ទ្រជិះដំរីក្បាលបី ទេវរូប ឬមួយក៏ផ្កាឈូក។ រាហូ គឺជាតំណាងភាពអមតៈនៃសង្គមខ្មែរ ដែលខ្នាក់ធម្មជាតិពីប្រអប់មាត់។ សសរពេជ្រនៃរចនាបថព្រះគោ នៅតែមានរាងមូលដដែល ហើយហោជាងមានរាងជា U ផ្កាប់ចុះ។ ចាប់ពីរចនាបថនេះទៅផ្ដែរទ្វារនៃរចនាបថក្រោយៗ ចាប់ផ្ដើមបាត់បន្តិចម្ដងៗនូវសមាសធាតុបង្កើតនៃផ្ដែរទ្វារប្រាសាទខ្មែរ។



ផ្ដែរនៃរចនាបថព្រះគោ ចុងសតវត្សទី៩ ប្រាសាទព្រះគោ

## «**ភម្ពុជទេស**»

សិលាចារឹកភ្នំបយ៉ង់ក្ដោ K. 14៖ គឺជាសិលាចារឹកមូលស្ថាបនា មាន ២០ បន្ទាត់ ជាភាសាសំស្ក្រឹត ចារនៅក្នុងរជ្ជកាលព្រះបាទឥន្ទ្រវម៌្មទី១ ( សតវត្សទី៩-សតវត្សទី១០)។ នាពេលបច្ចុប្បន្នស្ថិតនៅសារមន្ទីរ Guimet។ ក្រោយពីថ្លៃងសរសើរព្រះសិរៈរួចមក អត្ថបទបានលើកឡើងពីការឡើងសោយរាជ្យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់ព្រះបាទឥន្ទ្រវម្ម័ ទី២ និងបានបន្តថា នៅក្នុងទីក្រុង សិរបុរ (ភ្នំសណ្តក) ព្រះចៅក្រុងកម្ពុជាបានថ្វាយអាទិទេពនូវប៉ម ដើម្បី«ការពារពីគ្រោះភ័យ»។ ព្រះអង្គបានថ្វាយផងដែរនូវគ្រឿងមាស គ្រឿងប្រាក់ សម្រាប់ថ្វាយព្រះ និង ថ្វាយអំណោយជាគ្រឿងឧបភោគបរិភោគដល់ប្រាសាទនោះ និងដល់វត្ថុពីរទៀត។ នេះប្រហែលជាលើកទី១ ហើយដែលគេប្រទះឃើញមានប្រើពាក្យ «កម្ពុជទេស» ហើយពាក្យនេះក៏មានប្រើនៅឆ្នាំ ៨១៧ នៅក្នុងសិលាចារឹកចម្ប៉ានៃប្រាសាទពោ នគរ។

## ២.៣. ព្រះបាទយសោវម្ម័ ទី១ (៨៨៩-ប្រហែល៩១៥)

បន្ទាប់ពីព្រះបាទឥន្ទ្រវម្ម័ ទី១ ចូលទិវង្គត ជម្លោះដណ្តើមរាជ្យបានកើតឡើង ប្រហែលជារវាងបុត្រទាំងពីររបស់ព្រះអង្គ។ ព្រះបាទយសោវម្ម័ ទី១ (៨៨៩-ប្រហែល៩១៥) ជាអ្នកឈ្នះ ហើយឡើងសោយរាជ្យ ដែល





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មានព្រាហ្មណ៍វាមសិវៈជាបុរោហិត។ ព្រះអង្គបានសាងសង់អាស្រមជាច្រើន ដើម្បីឧទ្ទិសដល់និកាយផ្សេងៗនៃព្រហ្មញ្ញសាសនា ជាពិសេសព្រះសិវៈ និងព្រះវិស្ណុ។ តាមរយៈអាស្រមទាំងនេះ គេអាចដឹងបានថា ផ្ទៃដីនៃអាណាចក្រខ្មែរលាតសន្ធឹងពីតំបន់ខាងជើងភ្នំរុង នៅខ្ពង់រាបកូរ៉ាត ដល់តំបន់វត្តភូ នៅចម្ប៉ាសាក់។ ព្រះអង្គបានសាងសង់ប្រាសាទលលៃ នៅចំកណ្ដាលបារាយណ៍ ឥន្ទ្រតដាក ដើម្បីឧទ្ទិសជូនដល់ព្រះមាតាបិតារបស់ព្រះអង្គ។ បន្ទាប់មក ព្រះអង្គបានរើរាជធានីពីហរិហរាល័យ មកដាក់នៅយសោធរបុរៈ (អង្គរទី១) ដែលក្លាយជារាជធានីនៃអាណាចក្រខ្មែរក្នុងរយៈពេលជាង ៥០០ឆ្នាំ។ ព្រះអង្គបានជ្រើសរើសយកភ្នំមួយ ដើម្បីសាងសង់ប្រាសាទ ភ្នំបាខែង មានរាងសាជីជាខឿនច្រើនថ្នាក់ ដែលស្ថិតនៅចំកណ្ដាលរាជធានី សម្រាប់តម្កល់សិវលិង្គ យសោធរេស្វរ (គ.ស. ៨៩៣)។ ព្រះអង្គបានជីកបារាយណ៍ យសោធរតដាក មានប្រវែង៧,៥ គម និងមានទទឹង ១,៨ គម។

## សិលាចារឹកព្រះបាទយសោវម៌្ម ទី ១

ក្នុងរជ្ជកាលព្រះអង្គ គេបានរកឃើញសិលាចារឹក ៤០ ផ្ទាំង៖ ជាភាសាសំស្រ្កឹតចំនួន ១៦ ជាភាសាខ្មែរចំនួន ១៧ និងជាភាសាខ្មែរ និងសំស្រ្កឹតចំនួន ៧។

ក្នុងមហាសករាជ ៨១១ (K.223; K. 346; K.479; K.309; K.323; K.42; K.45; K.47; K.57; K.95; K.101; K.110; K.1005; K.362);

ក្នុងមហាសករាជ ៨១៣ (K.314; K.1065)

ក្នុងមហាសករាជ ៨១៤ (K.457; K.713B; K.324);

ក្នុងមហាសករាជ ៨១៥៖ ចារឹកភ្នំដី (K.223); ចារឹកព្រះគោ (K.713B); ចារឹកប្រាសាទលលៃ (K.324; K.327; K.324-330-

សិលាចារឹកភាគច្រើន គឺនៅរលួសនិងសៀមរាប នៅព្រះវិហារ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

(ប្រាសាទអ្នកបួស) នៅកំពត (ប្រាសាទភ្នំទទឹង) នៅព្រៃវែង (វត្តកណ្ដាល) នៅចំប៉ាសាក់ (វត្តភូ) និងនៅកំពង់ចាម (ភ្នំព្រះបាទ ព្រះធាតុព្រះស្រី និងព្រះធាតុខ្ញុំ)។



សិលាចារឹកលលៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## សិលាចារឹកលលៃ K.330 ខាងជើង

| ខ្មែរចាស់ | ខ្មែរទំនើប |
|---|---|
|  | (១) ត្រីសិទ្ធិស្វស្តិជយ ០ រាណៃ កាម្ត<br>គកេគុបេគតិ<br>(២) នេមម្តេឈធាទ្វីរីជៅ<br>សិង្ហញ្ជទ្រូសុតេវ្ឋំបំសក្ភគុ |
|  | (៣) ដេលគ្នេកុលីរំរពៅ ចាបន្ទេវ<br>គុពៅតុលាសរវិជេ<br>(៤) កៅមេគ តេស្នាបិតា គៅរីគ<br>ប្រតិមាស្សម៌ស្វរ ចិតាស្តាត្រី |
|  | (៥) យគោវម្ទ៌ណា ០ អ្នកបំរេតោ<br>យណ្ដ៌ាច្ចម្ទាំ តៃមាយ១<br>(៦) តៃសុជាតា១ តៃឧទុម្វរ១ បំ<br>យ៌្យាងតៃចំរិះ១ តៃចន្ទន១<br>តៃកញ |
|  | (៧) យស១ តៃសុភាក១ តៃហិរន១<br>តៃទ្រលប១ តៃជាំ១ តៃត្រី ក្មោ១<br>(៨) តៃកំបត១ តៃសុនន្ទា១ តៃក្ញ១<br>តៃសុរស១ តៃទ្រករ១ តៃនន់១ |
|  | (៩) តៃស្ទុំង១តៃកញ្ជន១ តៃត្រី១<br>តៃកំបតសោត១ តៃកន្សុន<br>១តៃមល្វ១<br>(១០) ត្មោង១ តៃបន្ទន១ តៃកន<br>ហ្យង១ តៃលង្គាយ១<br>ធ្មបធេង តៃ |
|  | (១១) មហិ១ គន្លរ៌ តៃត្វំ១ ត្មិងកិន្នរ<br>តៃអក្សរ១ តៃកញយស១<br>(១២) តៃកុល១ ត្មិងវីណ តៃនា១<br>តៃសុវណ្ណ៌១តៃថរ១ ត្មិងលាវ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | |
|---|---|
|  | (១៣) តៃនោ១ ត្និងត្រិសរី តៃមូល<br>១ចំយ៉្យាងស្មុត តៃសុវណ្ណ៍១០<br>(១៤) ក្ញោញស្រុកសីកន្ខោញ១<br>វរសេនវ១ បមេកសីកន្សោ១ |
|  | (១៥) ថ្នាំប្ដុះសីសំអប១ បីលេ<br>សីកញ្ជុ១ ថ្នាំមាសប្រក<br>សីកន្ដែង១<br>(១៦) អាកបសីកញយោ១<br>តៃកមលា១ ស្នញសីក្រៅ១<br>សីអន្ទ្រាក១ |
|  | (១៧) មាលាការគ្នាលកញ្ជុ១<br>គ្នាលស្របតទេវ១ តៃខេ១<br>អ្នុះទិកស្រោង<br>(១៨) គ្នាលសំអប១ សីកន្ទេ១<br>ឆត្ត្រជារសីបន្ទន១<br>សីអ្នត១ សីកន |
|  | (១៩) អស១ ល្នាំវ្រះបិតៃសីលក្សី<br>ការ១ គ្នាលអនឌន១ ចំយ៉្យាង<br>(២០) គីខពគ្នាលមន្ទស១<br>គ្នាលវ្រហ្ម១<br>គន្ធរ្វ៝គ្នាលក្រៅ១ថ្នាំវ្រះ |
|  | (២១) វ្រង់សីកមលការ១ ថ្នាំកន្ទោង<br>សីកញ្ជន១ ប្រតីហារសី<br>(២២) ច្នោងបមោសគ្នាលវ្រយហា១<br>មហានសសីសំអប១<br>សីក្នួស១ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## សិលាចារឹកលលៃ K.330 Na សេចក្តីបកប្រែ [43]

1. ចូរមានសិរី សម្រេចតាមបំណង (សិទ្ធិ) មានសួស្តី និងជយជម្នះ។ នៅឆ្នាំនៃស្តេចសក កំណត់ដោយព្រួញ (៥) លេខ១ និងលេខ៨ (ឆ្នាំ ៨១៥ សក ត្រូវនឹងគស ៨៩៣)
2. ថ្ងៃទី៦ កើត (ឬ) រោចនៃខែសុចិ ព្រះចន្ទនៅកណ្តាលមីនរាសី បុត្រព្រះចន្ទ (ព្រះពុធ)នៅក្នុងវិមានសត្វសិង្ហ ទំនាយសរុបជាមួយបុត្រព្រះភ្គុ (ព្រះសុក្រ)
3. ព្រះអាទិត្យនៅវិមានមេស ព្រះគុរុនៃព្រះព្រហស្បត្តិ នៅធនុរាសី បុត្ររបស់ផែនដីជាមួយគ្នានឹង
4. បុត្ររបស់ព្រះអាទិត្យនៅតុលារាសី ព្រះបដិមារបស់ព្រះសិវៈ និងព្រះគៅរី ត្រូវបានស្ថាបនា (ប្រតិមា) ដោយព្រះអង្គ គឺព្រះបាទ គ្រី
5. យសោវម្ម័ នេះឯង។ អ្នកបម្រើ ដោយរនោច អ្នករាំ (ម្ចាំ)៖ នាង (តៃ) មាយ១
6. នាងសុជាតា១ នាងឧទុម្វរ១, អ្នកច្រៀង (ចំរៀង)៖ នាងចំរិះ១ នាងចន្ទន១ នាងកញ
7. យស១ នាងសុភាក១ នាងហិរន១ នាងទ្រលច១ នាងជាំ១ នាងគ្រីក្មៅ១
8. នាងកំបត១ នាងសុនន្ទា១ នាងក្ញុំ១ នាងសុរស១ នាងទ្រករ១ នាងនន១
9. នាងស្មង១ នាងកញ្ចន១ នាងគ្រី១ នាងកំបតសោត១ នាងកន្សុន១ នាងមល្ង១
10. អ្នកទូងស្គ (ត្មោង)៖ នាងបន្ទន១ នាងកនហ្យង១ នាងលង្កាយ១, អ្នកចាប់ឈិង (ឆ្មបឆេង)៖ នាង
11. មហិ១ អ្នកចៀងផងរាំផង (គន្ធវ៌)៖ នាងត្លុំ១ អ្នកដេញកិន្នរ (ត្មិងកិន្នរ)៖ នាងអក្សរ១ នាងកញយស១

43. វង់ សុធារ៉ា ២០១៦



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

12. នាងកុល១, អ្នកដេញពិណ (ត្មិងវីណា)៖ នាងនា១ នាងសុវណ្ណ១ នាងថវ១, អ្នកដេញលាវ (ត្មិង លាវ)៖

13. នាងនោ១, អ្នកដេញត្រិសរី (ត្មិងត្រិសរី)៖ នាងមូល១, អ្នកច្រៀងស្មុតី (ចំយ៉្យាស្មុតី)៖ នាងសុវណ្ណ១។

14. (១៤) ប្រធានភូមិ (ក្លោញស្រុក) បុរស (សី) កន្ទោញ១ អ្នកកាន់ទឹកផឹក (វរី) សីនំរី១ អ្នកបើកទ្វារ (បមេក) សីកន្ទេរ្យា១

15. ឆ្មាំបោសផ្ទះ (ឋ្មាំប្ទុះ) សីសំអប១, អ្នកចាំបីលេ (បីលេ) សីកញ្ចូ១, ឆ្មាំមាសប្រាក់ (ឋ្មាំមាសប្រក) សីកន្តេង១

16. អ្នកចាំអាគស: (អាគម)៖ សីកញយោ១ នាងកមលា១, អ្នកចាំស្មួញ (ស្មួញ) សីក្រៅ១ សីអន្ទ្រាក ១

17. អ្នកក្រងផ្កា (មាលាការ) ប្រុសជំទង់ (គ្វាល) កញ្ចូ១ គ្វាលស្រេចតទៃវ១ នាងខេ១ អ្នករកអុសដាំទឹកឆ្អិត (អ្នុះទិកស្រោង)

18. គ្វាលសំអប១ សីកន្ទែ១ អ្នកកាន់ឆ័ត្រ (ឆត្ត្រធារ) សីបន្ទន១ សីអ្គត១ សីកន

19. អស១ អ្នកឃ្មាំព្រះ (ឈ្មាំវ្រះបិ) នាងសីលក្សីភាវ១ គ្វាលអនឧន១ អ្នកច្រៀងគីខរា (ចំយ៉្យាង

20. គីខរា) គ្វាលមន្ទស១ គ្វាលវ្រហ្ម១, អ្នកច្រៀងរាំ (គន្ធវ៌ព) គ្វាលក្រៅ១, ឆ្មាំព្រះភ្លើង (ឋ្មាំវ្រះ

21. វ្លង) សីកមលភាវ១ អ្នកចាំបណ្ណាល័យ (ឋ្មាំកន្ទោង) សីកញ្ចន១ អ្នកចាំទ្វារ (ប្រតីហារ) សី

22. (២២) ថ្នោង អ្នកបោស (បមោស) គ្វាលវ្រយហ១ អ្នកដាំស្ល (មហានស) សីសំអប១ សីក្ងស១



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# រចនាបថ បាខែង (៨)

*រចនាបថបាខែង គឺជាប្រាសាទដែលបានសាងសង់នៅចុងសតវត្សទី៩ និង ដើមសតវត្សទី១០។ ព្រះបាទ យសោវរ្ម័ន បានចាកចេញពី ហរិហរាល័យ (រលួស) ហើយមកសង់រាជធានីនៅ យសោធបុរ (អង្គរទី ១) ដោយជ្រើសរើសយកភ្នំមួយ ដើម្បីសង់ប្រាសាទ ភ្នំបាខែង មានរាងជាសាជីមានខឿនច្រើនថ្នាក់ ដែលស្ថិតនៅចំកណ្ដាលរាជធានីសម្រាប់តម្កល់សិវលិង្គ យសោធរេស្វរ (គ.ស. ៨៩៣)។ ព្រះអង្គបានជីកបារាយណ៍ យសោធរតដាក មានប្រវែង ៧,៥ គម និង ទទឹង ១,៨ គម ។ ព្រះអង្គបានសាងសង់ប្រាសាទលលៃ នៅចំកណ្ដាលបារាណ៍ ឥន្ទ្រតដាក ដើម្បីមទ្ទិសជូនដល់ព្រះមាតាបិតារបស់ព្រះអង្គ។*

*រចនាបថបាខែងបានបន្តនូវប្រពៃណីនៃរចនាបថព្រះគោ ប៉ុន្តែបានបោះបង់ចោលឥដ្ឋ ដោយយកថ្មភក់ និងថ្មបាយក្រៀមទៅសាងប្រាសាទវិញ។ ប្រាសាទនៃរចនាបទបាខែងមាន៖ ប្រាសាទភ្នំបាខែង ប្រាសាទ ភ្នំក្រោម និង ប្រាសាទភ្នំបូក។ រចនាបថនេះបានប្រឌិតសម្លៀកបំពាក់ចាប់ភ្លីជាលើកដំបូង ចំពោះផ្តែរវិញ រចនាបថបាខែងមានលក្ខណៈអន់ថយជាងផ្តែរនៃរចនាបទព្រះគោ។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia


35
N°45
1097

## ២.៤. ហស៌វម៌្ម ទី១-ឦសានវម៌្ម ទី២ (៩១៥-៩២៨)

*ក្រោយពីព្រះបាទយសោវម៌្ម ទី១ ចូលទិវង្គតមក ព្រះបាទហស៌វម៌្ម ទី១ ដែលជាបុត្របានឡើងសោយរាជ្យ ប្រហែលជានៅឆ្នាំ ៩១៥ នៅរាជធានីនៅយសោធរបុរៈ។ នៅក្នុងរជ្ជកាលរបស់ព្រះបាទហស៌វម៌្ម ទី១ ព្រះអង្គបានសាងសង់ប្រាសាទពីរ គឺប្រាសាទបក្សីចាំក្រុងនៅជិតប្រាសាទភ្នំបាខែង និងប្រាសាទក្រវ៉ាន់ដែលមានបីជាន់ ដើម្បីឧទ្ទិសដល់ព្រះវិស្ណុ។ ព្រះបាទ ហស៌វម៌្ម ទី១ មានព្រះអនុជម្នាក់ទៀត ព្រះនាមឦសានវម៌្ម ទី២។*

*នៅក្នុងរជ្ជកាលព្រះរាជាទាំងពីរអង្គនេះ មានតែសិលាចារឹកចំនួន ៩ ប៉ុណ្ណោះ៖ ២ ជាភាសាសំស្ក្រឹត ៣ ជាភាសាខ្មែរ និង ៤ជាភាសាសំស្ក្រឹត និងជាភាសាខ្មែរ។ សិលាចារឹកទាំងនេះមាននៅសៀមរាប (វត្តធិបតី) និងនៅព្រៃវែង (ព្រះវិហារគុក និងវត្តក្រាំងស្វាយ)។*





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## ២.៥. ព្រះបាទជ័យវម៌្ម ទី៤ (៩២១-៩៤១)

ព្រះបាទជ័យវម៌្ម ទី៤ បានយាងទៅតាំងទីលំនៅនៅចោកគគីរ (កោះកេរ) និងបានកសាងប្រាសាទធំ មានខឿន ៧ ជាន់ សម្រាប់តម្កល់រាជលិង្គត្រិភូវនេស្វរ នៅ គ.ស. ៩២១ តាំងតែពីពេលដែលព្រះអង្គនៅមិនទាន់ឡើងសោយរាជ្យមកម្ល៉េះ។

សិលាចារឹក K. 35-37 ប្រាសាទនាងខ្មៅបានសរសើរដល់ព្រះបាទជយវម៌្ម ទី៤ ដែលបានឡើងស្នងរាជ្យបន្តនៅឆ្នាំ ៩២៨/២៩ ពីព្រះបាទឦសានវម៌្ម ទី២ ដែលពោរពេញដោយអំណាច។ អត្ថបទបានបញ្ជាក់ថា នៅឆ្នាំ ៩២១ ព្រះបាទជ័យវម៌្ម ទី៤ មានព្រះរាជវត្តមាននៅកោះកេររួចទៅ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហើយ។[44] ឆ្នាំ ៩២៨/២៩ ប្រហែលជាកាលបរិច្ឆេទនៃការសោយទិវង្គតរបស់ ព្រះបាទឦសានវម៌្ម ទី២ ពីព្រោះចាប់ពីពេលនោះមក ដែលព្រះបិតុលា ( ពូ ) របស់ព្រះអង្គមានឋានៈជាព្រះរាជាពេញលក្ខណៈ។

នៅក្នុងរជ្ជកាលព្រះបាទ ជ័យវម៌្ម ទី៤ មានតែសិលាចារឹកចំនួន ២៧៖ ២ ជាភាសាសំស្ក្រឹត ២០ ជាភាសាខ្មែរ និង ៥ ជាភាសាសំស្ក្រឹតនិងជាភាសាខ្មែរ។ សិលាចារឹកទាំងនេះមាននៅសៀមរាប ( ប្រាសាទក្រវ៉ាន់ ) នៅកោះកេរ ( ប្រាសាទធំ ប្រាសាទពីរជាន់ និងប្រាសាទបឹងវែង ) កំពង់ចាម ( ប្រាសាទជើងអង្គ ) នៅខេត្តកណ្ដាល ( ទួលកណ្ដោក ) និងនៅប្រាសាទព្រះវិហារ។

## ប្រាសាទធំ

ប្រាសាទធំ គឺជាប្រាសាទដែលសំខាន់ជាងគេ នៃប្រាសាទកោះកេរ ដោយសារប្រាសាទនេះមានទំហំធំជាងគេ ហើយជានិមិត្តរូបនៃក្រុមប្រាសាទកោះកេរទាំងមូល។ ប្រាសាទនេះចែកចេញជាពីរផ្នែក៖ ប្រាសាទកណ្ដាល និងប្រាង្គ។ ប្រាសាទកណ្ដាលព័ទ្ធជុំវិញដោយគោបុរៈបួនជាន់ និងមានច្រកទ្វារចូល ៤ ជាន់ដែរ។ ប្រាង្គនៃប្រាសាទធំមានរាងជាពីរាមីដ ដែលមាន ៧ ថ្នាក់។ ប្រាសាទទាំងនេះមានចម្លាក់ធំៗ ដូចជាអ្នកប្រយុទ្ធ គ្រុឌ គណេស និងព្រះសិវៈ ដែលមានទំហំធំៗ ហើយបង្កើតបានជារចនាបថកោះកេរយ៉ាងប្រណីត។ ចារឹកភាគច្រើនចារលើសសរនៃប្រាសាទ។

សិលាចារឹក K. 184៖ នៅគោបុរៈទី២ ទ្វារចូលប្រាសាទខាងកើត ទ្វារខាងក្នុងខាងជើង ជាភាសាសំស្ក្រឹតមាន ៥ បន្ទាត់ និងជាភាសាខ្មែរមាន ១៨ បន្ទាត់ នៅនឹងកន្ទែង។ អត្ថបទភាសាសំស្ក្រឹត សរសើរពីទេព «ត្រិភូវនេឝ្វរ» ( លោកម្ចាស់នៃភពទាំងបី ) ដែលជាទេវរាជកម្រតេង ជគត្តរាជ្យនៅតំបន់កោះកេរ ដែលព្រះបាទជ័យវម៌្ម ទី៤ បានសាងសង់ឡើងនៅមហាសករាជ ៨៤៣ ( គស ៩២១ )។ អត្ថបទជាភាសាខ្មែរផ្តល់ព័ត៌មានពីបញ្ជីតង្វាយនិង

44. Cœdes, IC, II, p. 33



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រុំបម្រើ ដែលមកពីស្រុកផ្សេងៗ ដូចជា៖ ស្រុកវ្នរតង្កោ ស្រុកវង ស្រុកទម្នប ស្រុកវ្នរចម្បោក សង្កេ វីរេន្ទ្រ វ្នស្រុក។

## សិលាចារឹកកោះកេរ K. 186

សិលាចារឹក K. 186៖ នៅគោបុរៈទី១ ទ្វារចូលប្រាសាទខាងលិច ជញ្ជាំងខាងក្នុងខាងជើង ជាភាសាខ្មែរមាន ៥ បន្ទាត់ និងលើជញ្ជាំងខាងក្នុងខាងលិច ផ្នែកខាងជើង មានចារឹកជាភាសាខ្មែរមាន ៤ បន្ទាត់ នៅនឹងកន្លែង។ ចារឹកនេះនិយាយពីការធ្វើអំណោយជាវត្ថុប្រើប្រាស់ និងអ្នកបម្រើដល់អង្គភាពរដ្ឋបាលផ្សេងៗនៅចន្លោះពីឆ្នាំ ៩៣០ ដល់ ៩៣២។

អត្ថបទភាសាខ្មែរចំនួន ៤ បន្ទាត់មានដូចតទៅ៖

(១) [៨]៥២ គក បិកេត វៃគា២ នុ មានវ្រះ គាសន ធូលិ វ្រះបាទធូលិ

(២) ជេងវ្រះកម្រតេងអញ ប្រេវ្រះនៃម្រតេញ រុទ្រាចារ្យ

(៣) វាប គិរវ្យាបិ សសិ-----វ្រះកម្រតេងអញ

(៤) ជគ្គតរាជ្យ . វ្រះអាយកវេល ប្រមាន ភីមបុរ

ជាភាសាខ្មែរទំនើប៖

(១) [៨]៥២ សក ថ្ងៃទីបីកើត វៃគា២ មានព្រះរាជបញ្ជាព្រះករុណា តម្កល់លើត្បូង

(២) នៅទីបូជនីយដ្ឋាននៃម្រតេញ រុទ្រាចារ្យ

(៣) និងវាប គិរវ្យាបិ នៃ-----ព្រះទេវរាជ្យ

(៤) ជគ្គតរាជ្យ . ព្រះប្រាសាទករេល នៅតំបន់ ភីមបុរ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សិលាចារឹកកោះកេរ K.682

សិលាចារឹក K. 682៖ គឺជាចារឹកដែលចាស់ជាងគេ និងដែលរកឃើញនៅកោះកេរ ដោយលោក Parmentier នៅឆ្នាំ ១៩៣០ ដែលបញ្ជាក់ថា ចារឹកនេះគឺជាជើងតាងខាងជើងផ្នែកខាងលិច នៃទ្វារខាងលិចនៃគោបុរៈទី២។ ទ្វារចូលប្រាសាទខាងកើត ទ្វារខាងលិចសសរកណ្តាលចៀងខាងជើងចារឹក ជាភាសាខ្មែរមាន ១២ + ៦ + ២៨ បន្ទាត់នៅនឹងកន្ទេងចារនៅឆ្នាំ ៩២១។ អត្ថបទទី១និយាយពីកម្រតេង ជគត ត រាជ្យ និង



សិលាចារឹកកោះកេរ K.682

មហិច្ឆតារបស់ព្រះបាទជយវម៌្ម ទី៤។ នៅពេលដែលព្រះបាទហស៌វម៌្ម ទី១ និងព្រះបាទឦសានវម៌្ម ទី២ (ប្រហែល៩១៥-៩២៨) នៅគ្រងរាជ្យនៅអង្គរនៅឡើយ ព្រះបាទជយវម៌្ម ទី៤ (បច្ឆាមរណនាម បរមឝិវបទ) បានចាប់ផ្តើមនៅឆ្នាំ ៩២១ ការងារសាងសង់ប្រាសាទ ពីរ៉ាមីដ ដែលជានិមិត្តរូបនៃអានុភាពរបស់ព្រះអង្គ។ ព្រះអង្គបានរៀបចំវិញ នូវអង្គការនយោបាយ និងសាសនា ដែលធ្លាប់មាននៅ ហរិហរាលយ (លលៃ) និងនៅឥន្ទ្របុរ (បាខែង)។ ដូច្នេះ ដំបូងព្រះអង្គចាប់ផ្តើមត្រួតត្រា នៅតំបន់ឆោកគគីរ (កោះកេរ) ហើយបន្ទាប់មកទើបឡើងគ្រងរាជ្យបន្តពីព្រះបាទឦសានវម៌្ម ទី២ ដោយពង្រីកអំណាចរបស់ព្រះអង្គលើដែនដីនៃអាណាចក្រអង្គរតែម្តង។[45] អត្ថបទទី២ ចារក្រោយចារឹកប្រាសាទធំ នៅឆ្នាំ ១០០១ ដែលនិយាយ

45. Cl. Jacques, 2004



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពីកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ ចំពោះព្រះអាទិទេព។ អ្នកណាជឿលើអាទិទេពនឹងបានឡើងស្ថានសួគ៌ ចំណែកអ្នកមិនជឿនឹងចុះនរក។ អត្ថបទលើកឡើងថា នៅក្នុងរាជ្យព្រះបាទឧទយាទិត្យវរ្ម័ន ទី១ (១០១០-១០០២) តំបន់កោះកេរនេះ មិនបានត្រូវគេបោះបង់ចោលឡើយ ហើយបន្ទាប់ពីព្រះបាទរាជេន្ទ្រវរ្ម័ន ទី២ បានផ្លាស់ប្តូររាជធានីទៅអង្គរវិញ ក្នុងឆ្នាំ ៩៤៤ ឆោកគគីរបានក្លាយជាទីក្រុងទីពីរនៃអាណាចក្រអង្គរ។[46]

## រចនាបថ កោះកេរ (៩)





ស្វាប្រយុទ្ធគ្នា ប្រាសាទចិន កោះកេរ ស.វ.ទី ១០

ប្រាសាទនៃរចនាបថកោះកេរត្រូវបានសាងសង់ចាប់ពីឆ្នាំ ៩២១ ដល់ឆ្នាំ ៩៤៤។ ប្លង់ប្រាសាទ គឺអនុវត្តយកខ្សែបន្ទាត់មេដ្យាទ័រជាមេនៅលើវាលរាប។ រូបចម្លាក់នៃរចនាបថកោះកេរចាប់ផ្តើមបង្ហាញពីរូបមានចលនា ដូចរូបគ្រុឌដើររូបចំបាប់រវាងសុគ្រីព និងពាលី រូបចំបាប់រវាង យក្ខ និងទេវតា។

46. Bruguier et Lacroix, T. V, 2013



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្តែរទ្វារនៃរចនាបថកោះកេរលុបក្បាច់ត្របកឈូកចោល ដោយដាក់រូបទេពប្រណម្យជំនួសវិញ ដែលជានិមិត្តរូបនៃការស្វាគមន៍ចំពោះព្រះបាទជ័យវរ្ម័ន ទី៤ និងការកាត់ផ្តាច់នូវទំនាក់ទំនងជាមួយ យសោធរបុរៈ។

## ប្រាសាទនាងខ្មៅ

តួប៉មប្រាសាទនាងខ្មៅត្រូវបានស្ថាបនាឡើងនៅសតវត្សទី១០ ដើម្បីឧទ្ទិសដល់ព្រះវិស្ណុ ហើយតួប៉មនេះឧទ្ទិសដល់នាងកាលី (ទេពខ្មៅ)។ ប្រាសាទនេះស្ថិតនៅក្នុងស្រុកសំរោង ខេត្តតាកែវ ចម្ងាយប្រមាណជា ២ គីឡូម៉ែត្រខាងលិចភ្នំជីសូរ្យ។ ប្រាសាទនេះមានប៉មចំនួន ៣ តែនាពេលបច្ចុប្បន្ន នៅសល់តែប៉មកណ្តាល និងប៉មខាងជើងប៉ុណ្ណោះ។ សិលាចារឹកប្រាសាទនាងខ្មៅមាន៖

សិលាចារឹក K. 35៖ សិលាចារឹកនេះឧទ្ទិសដល់ព្រះវិស្ណុ ដែលជា «ស្តេចចក្រវាឡ» ដោយលើកឡើងថាព្រះអង្គជាអវតារទី៥។

កំណាព្យនៃសិលាចារឹក K. 35 នេះដូចគ្នាទៅនឹងប្រធានបទនៃរូបចម្លាក់មួយនៅប្រាសាទនាងខ្មៅ ដែលឧទ្ទិសដល់អាទិទេព ស្រី លោកនាថ ដែលមានអានុភាពខ្លាំងក្លាលើសលប់ អាចបោះបីជំហានឆ្លងកពផែនដី ដែលបីដូចជាភ្នែករបស់ព្រះព្រហ្ម។ អត្ថបទបានសរសើរដល់ព្រះបាទជ័យវម៌្ម ទី៤ ដែលបានឡើងសោយរាជ្យនៅឆ្នាំ ៩២៨/២៩ ហើយបានបញ្ជាក់ថា នៅឆ្នាំ ៩២១ ព្រះបាទជ័យវម៌្ម ទី៤ មានព្រះរាជវត្តមាននៅកោះកេររួចទៅហើយ។[47]

47. Cœdes, IC, II, p. 33



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## សិលាចារឹកវត្តសំរោង K. 956

សិលាចារឹកត្រូវបានលោក Jean Boisselier រកឃើញនៅវត្តសំរោង ស្រុកបាភ្នំ ខេត្តព្រៃវែង ហើយយកមកតម្កល់នៅសារមន្ទីរភ្នំពេញ។ សិលាចារឹកនេះគ្មានកាលបរិច្ឆេទ មាន៥៥ បន្ទាត់ ជាអក្សរនៅសតវត្សទី១០។ សិលាចារឹកពិពណ៌នាពីអំណោយរបស់ម្រតាញអ្នកស្ថាបនា ដើម្បីគោរពបូជាដល់ព្រះគម្តែងអញ ព្រះ ស្វម្ភុ (ព្រះព្រហ្ម)។

នៅក្នុងរាជ្យព្រះបាទបរមេស្វរ (ជ័យវម៌្ម ទី២) មានញាតិសន្តានបីរូបខាងម្តាយៈ (១) លោញ លក្សន ជាសេនាបតីនៃកងពលត្មាលស្រុក មានតេងអ្យក ជាទេពី ដែលមកពីភវបុរ (២) តេងបិត ជាប្រពន្ធរបស់ខ្លោញពល (ទាហាន) ដែលជាខ្សែរពូជពង្សរបស់ព្រះបាទឥស្វរលោក (ឥន្ទ្រវម៌្ម ទី១) ដែលមានឈ្មោះថា លោញហរធម៌្ម ដែលជាអ្នកគ្រប់គ្រងការងារលើអ្នកធ្វើការឱ្យព្រះរាជាទាំងអស់។

នៅក្នុងរាជព្រះបាទបរមេស្វរ (ជ័យវម៌្ម ទី២) ទ្រង់បាននាំញាតិវង្សរបស់យើងមកពីកទ្របុរ ហើយបានបង្កើតបានកូនប្រុស៤ និង កូនស្រី៣ នាក់។ តេងឥន្ទ្រានី និង តេងវសុទេវី ត្រូវបានក្លាយជាភរិយារបស់ម្រតាញស្រីប្រថិវីនរេន្ទ្រ។ តេងបវិត្រ បានក្លាយជាភរិយារបស់កម្រតេងអញ ព្រះមូល ដែលត្រូវជាក្មួយរបស់ព្រះខ្លោញពល។ ខ្លោញពល គឺជាព្រះមារបស់ព្រះបាទវិស្ណុលោក (ជ័យវម៌្ម ទី៣)។

ព្រះបាទបរមេស្វរ (ជ័យវម៌្ម ទី២) គង់នៅស្រុករទូល ហើយបានបញ្ជាដល់ព្រាហ្មណ៍ ស្រីប្រធិវិនរេន្ទ្រ ឱ្យរៀបចំពិធី «កល្យានសិទ្ធិ» ដើម្បីបួងសួងសុំឱ្យកម្ពុជារួចចាកផុតពីការចាប់នៃពួក «ជវា»។ ទ្រង់បានប្រទានដល់ព្រាហ្មណ៍ ស្រីប្រធិវិនរេន្ទ្រ ភូមិស្រតាច និងរទូល និងទ្រព្យសម្បត្តិទៀតផង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងរាជ្យព្រះបាទវិស្ណុលោក (ជ័យវរ្ម័ន ទី៣) លោញព្រាហ្មណ៍បាស ដែលត្រូវជាកូនរបស់តេងវសុទេវី បានទទួលគោរមងារជាម្រតាញ ស្រីសត្យ យុទ្ធ និងជាអធិការនៃព្រះដំរីរបស់ព្រះរាជា។ តេងហៀងនរេន្ទ្រ ជាកូនរបស់ តេងបពិត្រជាមួយព្រះកម្រតេងអញព្រះមូល បានក្លាយជាទេពីនៃព្រះបាទ ឥស្វរលោក (ឥន្ទ្រវរ្ម័ន ទី១)។

ព្រះបាទស្រីជ័យវរ្ម័ន ទី៣ បានយាងទៅចាប់ដំរីនៅឯភ្នំ។ នៅពេលនោះ ព្រះបាទឥន្ទ្រវរ្ម័ន និងតេងហៀងនរេន្ទ្រ ជាទេពីបានយាងទៅដែរ។ ព្រះបាទ ស្រីជ័យវរ្ម័ន ទី៣ បានប្រទានដីដល់ព្រះកម្រតេងអញ ព្រះមូលនៅឯស្រតាច។ លោញសានជាព្រះមូលបានដីកត្រពាំង និងសង់ប្រាសាទ ៨ នៅស្រុកនោះ។ ក្រុមញាតិយើងបានមកតាំងទីលំនៅនៅស្រុកភូមិនោះ។

ព្រះបាទស្រីជ័យវរ្ម័ន ទី៣ បានបញ្ជាឱ្យម្រតាញស្រីសត្យយុទ្ធ និង ស្រីវិបុមថ ដែលជាកូនម្រតាញ ស្រីប្រធិវិនរេន្ទ្រ ជាអ្នករក្សាសិលាចារឹកនេះ។ ហើយនៅសក ៧៤៩ (គស ៨២៧) ទើបគេចារប្រសាសន៍នេះឡើង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## ២.៦. ព្រះបាទរាជេន្ទ្រវរ្ម័ន (៩៤៤–៩៦៨)

ក្រោយពីព្រះបាទជ័យវម៌្ម ទី៤ បានចូលទិវង្គតនៅឆ្នាំ ៩៤១ វិបត្តិស្នងរាជ្យបានកើតឡើង។ ព្រះបាទហស៌វម៌្ម ទី២ (គ.ស ៩៤២-៩៤៤) ដែលជាបុត្រជាមួយព្រះនាងជ័យទេវី បានដណ្តើមរាជ្យ ហើយបានរៀបអភិសេកនៅឆ្នាំ ៩៤២។ តែព្រះអង្គត្រូវបានព្រះរាម ព្រះនាម រាជេន្ទ្រវម៌្ម ទី២ (គ.ស ៩៤៤-៩៦៦) ដែលជាបុត្ររបស់ព្រះបាទជ័យវម៌្ម ទី៤ ជាមួយព្រះនាង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មហេន្ទ្រទេវី បានវាយដណ្តើមរាជ្យពី ព្រះបាទ ហស៌វម្ម័ ទី២ និងបានរៀបអភិសេកនៅឆ្នាំ ៩៤៤។ ហើយព្រះបាទ រាជេន្ទ្រវម៌្ម បានឡើងសោយរាជ្យដោយមានការគាំទ្រពីសំណាក់ព្រាហ្មណ៍ដែលរស់នៅ យសោធរបុរៈ។ ដូច្នេះ ព្រះបាទ រាជេន្ទ្រវម៌្ម បានលើករាជធានីពីកោះកេរ មកយសោធរបុរៈវិញ ហើយបង្កើតជា «អង្គរទី២» ដែលមានព្រាហ្មណ៍ សិវាចារ្យ ជាហោតរកវិន្ទ្រារីមថន ជាស្ថាបត្យករ និងព្រាហ្មណ៍ យជ្ញវរាហៈ ជាព្រះរាជគ្រូ។ ព្រះអង្គបានកសាងប្រាសាទមេបុណ្យខាងកើត និងប្រាសាទប្រែរូប ដែលជាប្រាសាទសំខាន់នៃរចនាបថប្រែរូប។

នៅក្នុងរជ្ជកាលព្រះអង្គមានតែសិលាចារឹកចំនួន ៣៥៖ ៨ ជាភាសាសំស្ក្រឹត ១៨ ជាភាសាខ្មែរ និង ៩ ជាភាសាសំស្ក្រឹតនិងជាភាសាខ្មែរ។ សិលាចារឹកទាំងនេះមាននៅសៀមរាប (ប្រាសាទបក្សីចាំក្រុង ប្រាសាទតារស់ ប្រាសាទប្រែរូប ប្រាសាទមេបុណ្យខាងកើត) នៅព្រះវិហារ (ប្រាសាទព្រះវិហារ ប្រាសាទប្រាំ និងនៅភ្នំសណ្តុក) នៅបន្ទាយមានជ័យ (ភ្នំព្រះនេត្រព្រះ)។

## ប្រាសាទបក្សីចាំក្រុង

ប្រាសាទបក្សីចាំក្រុង ស្ថិតនៅជាប់ខ្លោងទ្វារអង្គរធំ មានរាងជាសាជីជា ៤ថ្នាក់ ធ្វើពីថ្មបាយក្រៀមបន្ទុប បែរមុខទៅទិសខាងកើត មានជណ្តើរគ្រប់ទិសទាំងបួន និងមានទ្វារបញ្ឆោតបីទិសដែលចាប់ផ្តើមកសាងឡើងដោយព្រះបាទហស៌វម្ម័ ទី២ (៩៤២–៩៤៤) និងបញ្ចប់ការកសាងដោយព្រះបាទ រាជេន្ទ្រវម្ម័ (៩៤៤–៩៦៨) ដើម្បីឧទ្ទិសថ្វាយព្រះឥសូរ។ ក្បាច់ផ្តែរលើខ្លោងទ្វារមានព្រះឥន្ទ្រគង់លើដំរីឰរាវ៍ណ (ដំរីមានក្បាលបី) ឯចុងទាំងសងខាងមានគណោស និងមាត់ទ្វារខាងកើតមានសិលាចារឹក។ សិលាចារឹកនៅលើទ្វារប្រាសាទបញ្ជាក់អំពីកាលបរិច្ឆេទរបស់ប្រាសាទ និងពីរូប



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បដិមាព្រះឥសូរធ្វើអំពីមាស និងករីទេវកថានៃអារ្យធម៌ខ្មែរ។ នៅពេលព្រះបាទរាជេន្ទ្រវរ្ម័ននាំរាជធានីពីកោះកេរ មកតាំងនៅអង្គរសាជាថ្មី នៅគ្រិស្តសករាជ ៩៤៨ ព្រះអង្គឱ្យគេចារឹកកាព្យសំស្ក្រឹតនៅលើមេទ្វារ។ នៅក្នុងចារឹកនេះមាននិទានអំពីបុព្វការីជនដំបូងបង្អស់នៃជនជាតិខ្មែរក្នុងលំនាំរឿងព្រេង ដែលបាននិយាយថា ខ្មែរមានតំណពូជពង្សមកពីឥសីមួយអង្គព្រះនាម "កម្ពុ" ដែលបង្កើតដោយឯកឯង (ស្វាយម្ភូ) ឥសីនោះ ទៅកពប្រសព្វនឹងទេពកញ្ញាឈ្មោះ"មេរា" ទើបបង្កើតជាកូនចៅតរៀងមក ប្រាសាទបក្សីចាំក្រុងកសាងនៅលើស្ថានីយបុរេប្រវត្តិមួយនៃយុគសំរឹទ្ធិ។ នៅប្រអប់ទ្វារខាងឆ្វេង និងស្តាំនៃខ្លោងទ្វារទៅកាន់អាសនៈនៃប្រាង្គប្រាសាទ គេឃើញមានសិលាចារឹករៀបរាប់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាចរន្តវប្បធម៌នាសម័យបុរាណ។

ព្រះបាទជ័យវរ្ម័ន ទី២ ដែលជាអ្នកនយោបាយដ៏មហិមា និងជាអប់រំវិទូដ៏ឆ្នើម បានដឹកនាំប្រជារាស្ត្រខ្មែរ យ៉ាងស្ទាត់ជំនាញ ឆ្ពោះទៅរកភាពបរិសុទ្ធ (XXIII)។ ព្រះបិតុលាខាងមាតារបស់ព្រះអង្គមានព្រះរាជបុត្រមួយអង្គព្រះនាមស្រី ឥន្ទ្រវរ្ម័ន។ បន្ទាប់មកព្រះបាទ ឥន្ទ្រវរ្ម័ន បានឡើងសោយរាជ្យសម្បត្តិបន្តពីព្រះបាទជ័យវរ្ម័ន ទី២។ ព្រះអង្គមានព្រះរាជបុត្រមួយអង្គ ដែលគ្មានគូប្រៀប ព្រះនាមយសោវរ្ម័ន (XXVII)។ នៅពេលនោះព្រំប្រទល់នៃអាណាចក្រខ្មែរបានលាតសន្ធឹងដល់ សូកម្ម-ករាត, មហាសមុទ្រប្រទេសចិន និងចម្ប៉ា។ ព្រះអង្គបានដឹកបារាយមួយឈ្មោះ យសោធរ(បារាយខាងលិច)។

ព្រះបាទ យសោវរ្ម័នមានព្រះរាជបុត្រមួយអង្គព្រះនាម ត្រីហប៌វរ្ម័ន ដែលជាក្តីសោមនស្សនៃពិភពលោកទាំងមូល។ ព្រះបាទរបស់ព្រះអង្គមានពន្លឺដូចកម្រងផ្កាត្បូងទទឹម ដែលលម្អមកុដព្រះរាជាចែងចាំងគ្រប់ទិសទី។ ព្រះបាទ ត្រីហប៌វរ្ម័ន មានកេរ្តិ៍ឈ្មោះរន្ទឺ កាយសម្បទារហ័សរហួន ប្រតិបត្តិសមាធិយ៉ាងខ្ជាប់ខ្ជួន មានវីរភាពខ្លាំងក្លា ព្រមទាំងគោរពប្រតិបត្តិព្រះធម៌



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងបានសាងសង់នៅប្រាសាទបក្សីចាំក្រុង នូវព្រះបដិមារបស់ព្រះសិវ និង ព្រះនាងឧមា និងព្រះវិស្ណុ (XXXII)។ ព្រះកនិដ្ឋារបស់ព្រះអង្គដែលមានមាតាជាមួយ គឺ ស្រីឦសានវម៌្ម ដែលឈ្នះអស់មារសត្រូវគ្រប់ទិសទី និងចេះអស់សិល្ប៍គ្រប់យ៉ាង (XXXIII)។

ស្វាមីនៃម្ដាយមីងរបស់ព្រះអង្គ ព្រះបាទ ស្រីជ័យវម៌្ម ទី៤ ដែលជាព្រះរាជាយ៉ាងប៉ិនប្រសប់ បានសាងសង់ទីក្រុងមួយនៅឆោក គគ៌្យរ (កោះកេរ) ដែលក្លាយទៅជារាជធានីដ៏មហិមា ដែលមានទេព ត្រិភូវនេគ្វរ ត្រូវបានប្រតិស្ឋាននៅទីនោះ។ ព្រះអង្គបានសាងសង់លិង្គព្រះសិវ នៅលើកំពូលនៃប្រាសាទធំ។ ព្រះរាជបុត្ររបស់ព្រះអង្គ ព្រះបាទ ហស៌វម៌្ម ទី២ គឺជាព្រះរាជាដែលមានជ័យជោគគ្រប់ទិសទី ជាអ្នកប្រាជ្ញដែលមានអានុភាពដ៏មហិមា។

ព្រះរាមរបស់ព្រះអង្គ ព្រះនាម រាជេន្ទ្រវម៌្ម គឺជាក្សត្រិយ៍ដែលចក្រវាឡទាំងមូលគោរពស្ញប់ស្ញែងឥតបីដូច។ ព្រះអង្គជាព្រះរាជាប្រកបដោយទសពិធរាជធម៌។ ព្រះអង្គបានប្រតិស្ឋានបដិមាលិង្គព្រះសិវ សិទ្ធេគ្វរ នៅនគរព្រះសិវ (ភ្នំសន្ទុក) ដែលមានមហិទ្ធិឫទ្ធិគួរឱ្យស្ញប់ស្ញែង និងបានសាងសង់ព្រះលិង្គនៅយសោធរ (មេបុណ្យខាងកើត) (XLIV)។





សិលាចារឹកភាសាសំស្ក្រឹតបក្សីចាំក្រុង K. 286



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ប្រាសាទភ្នំសណ្ដក

ភ្នំសណ្ដកស្ថិតនៅប្រមាណ២៥គីឡូម៉ែត្រនៅភាគខាងជើងឆៀងខាងលិចនៃកោះកេរ។ ប្រាសាទភ្នំសណ្ដក ដែលមានឈ្មោះដើមថា «គិរបុរ» គឺជាបូជនីយដ្ឋានឧទ្ទិសដល់ព្រះសិវៈមួយដ៏សំខាន់នៅចន្លោះសតវត្សទី៩ ដល់ទី១២ ហើយនៅសតវត្សទី១៣ ព្រះបាទជ័យវរ្ម័ន ទី ៧ បានសាងសង់មន្ទីរពេទ្យមួយនៅទីនោះ។ ប្រាសាទភ្នំសណ្ដកមានគោបុរៈចំនួនពីរ ដែលមានចារឹកលើមេទ្វារ និងផ្លូវចូលប្រាសាទនៅគោបុរៈទី១ និងទី២។ សិលាចារឹកទាំងនេះបង្ហាញថាព្រះមហាក្សត្រចំនួន ៥ អង្គមានព្រះបាទយសោវរ្ម័ន ទី១ ព្រះបាទរាជេន្ទ្រវរ្ម័ន ទី២ ព្រះបាទសូរ្យវរ្ម័ន ទី១ ព្រះបាទធរណីន្ទ្រវរ្ម័ន ទី១ និងព្រះបាទសូរ្យវរ្ម័ន ទី២ យកចិត្តទុកដាក់ដល់ការឧបត្ថម្ភគាំទ្រដល់ប្រាសាទភ្នំសណ្ដក។

សិលាចារឹកK.190៖ ជើងទម្រ(dalle) មានរាងជាសិលាមូលស្ថាបនានៅគោបុរៈទី២ ទ្វារចូលប្រាសាទខាងកើត ជាភាសាសំស្ក្រឹតមាន ២៦ (A)+១៥ (B) បន្ទាត់ និង ជាភាសាខ្មែរមាន ៣៣ បន្ទាត់ (C)៖ ផ្នែក A កោតសរសើរដល់ព្រះសិវៈ ព្រះវិស្ណុ និងព្រះព្រហ្ម។ បន្ទាប់មកគឺជាការកោតសរសើរដល់ព្រះបាទយសោវរ្ម័ន ទី១ (៨៨៩-៩១០) និងការស្ថាបនាអាស្រមនិងព្រះលិង្គនៅភ្នំសណ្ដក ដែលមានព្រះនាមថា «គិរបុរ» នៅឆ្នាំ ៨៩៥/៦។ ចារឹកនេះប្រហែលជាចារនៅក្រោយរាជ្យព្រះបាទយសោវរ្ម័ន ទី១ ក្នុងរជ្ជកាលព្រះបាទហស៌វរ្ម័ន ទី១ (ដែលជាបុត្រ) នៅចន្លោះឆ្នាំ ៩១០ និង ៩១៥។ ផ្នែក B កោតសរសើរដល់ព្រះសិវៈ ព្រះវិស្ណុ ព្រះព្រហ្ម និងអាទិទេព អបនាំដែលជាអវតាមួយនៃទុគាំ។ អត្ថបទលើកឡើងពីការបង្កើតរាជវង្សអង្គរលើភ្នំមហេន្ទ្រ (គូលេន) ដោយព្រះបាទជ័យវរ្ម័ន ទី២។ អត្ថបទភាសាខ្មែរ (C) និយាយអំពីអំណោយ និងដែនដី ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ «គិរបុរ» និងការដាក់បណ្ដាសាដល់អ្នកដែលមិនគោរពបទបញ្ញត្តិនេះ។[48]

48. Bruguier et Lacroix, T. V, 2013

## រចនាបថ ប្រែរូប (១០)

*រចនាបថប្រែរូបឆ្លុះបញ្ចាំងការត្រលប់ទៅរកអតីតកាល ក្នុងវិស័យស្ថាបត្យកម្ម និងក្បូរក្បាច់រចនាប្រាសាទ។ ការវិលទៅរកអតីតកាល គឺការចម្លងតាមផ្តែរនៃប្រាសាទក្រុមរលួស ដូចជាប្រាសាទព្រះគោ ប្រាសាទបាគង និង ប្រាសាទលលៃ ហើយជាពិសេស គឺប្រាង្គនៃប្រាសាទមេបុណ្យខាងកើត និង ប្រាសាទប្រែរូបត្រូវបានសាងសង់ដោយប្រើឥដ្ឋ ហើយក្បាច់រចនាមានស្រោបបាយអរ និងក្នុងទ្រង់ទ្រាយជាប្រាសាទភ្នំ ដែលមានខឿនសាងអំពីថ្មដែលទ្រ ប្រាសាទធំៗចំនួនប្រាំដែលធ្វើអំពីឥដ្ឋ។*

*ប្រាសាទប្រែរូប គឺជាស្នាដៃដ៏ធំធេង និងមានសមាមាត្រល្អបំផុតសាងសង់ពីថ្មបាយក្រៀម និងឥដ្ឋ។ រចនាបថនេះឆ្លុះបញ្ចាំងពីការសាងសង់ប្រាសាទកបំដោយគ្មានថែវ តែមានបន្ទប់វែងព័ទ្ធជុំវិញសាជីស្ទើរតែជាប់នឹងរបងទី១ របស់ប្រាសាទ។*

*ផ្តែរទ្វារនៃប្រាសាទមេបុណ្យខាងកើត បង្ហាញពីព្រះឥន្ទ្រជិះលើដំរីក្បាលបី ដែលជាម្ចាស់លើសត្វ ទឹក និងធម្មជាតិ។ ទន្ទឹមនឹងនេះ ស្ថាបត្យករលម្អផ្តែរដោយសត្វមករ សត្វនាគ គឺជាតំណាងទឹក ហើយនិងរាហូ ដែលជាតំណាងដួងព្រលឹងអមតៈ។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ប្រាសាទប្រែរូប ( សតវត្សទី១០ )



សិលាមូលស្ថាបនាប្រែរូប K. 806 ( ឆ្នាំ៩៤៤ )



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ប្រាសាទមេបុណ្យខាងកើត សតវត្សទី១០



សិលាចារឹកមេបុណ្យខាងកើត K. 528 ( គស ៩៥២)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## សិលាចារឹកមេបុណ្យខាងកើត K. 528 ( គស ៩៥២ )

*ទុគ្ធាម្ពុរាគេរិវបូណ៌ចន្ទ្រ   គ្ធណ្ឌាំគុរត្នាទិវចិត្រភានុះ*

Dughāmburāśer iva pūrṇacandraś    caṇḍāṃśuratnādiva citrabhānuḥ

*ប្រៀបបីដូចជាព្រះច័ន្ទពេញបូរមី   ដែលកើតពីសមុទ្រទឹកដោះនិងភ្លើង*

*គុទ្ធាន្វយាទេ្យានិតរាំវិគុទ្ធះ*   śuddhānvayā yo nitarāṃ viśuddhaḥ

*ដែលកើតពីថ្មព្រះសុរិយា*   *ព្រះអង្គមានខ្សែស្រឡាយបរិសុទ្ធ*

*ប្រាទុព៌ភូវាខិលភូបវន្ទ្យះ។*   prādurbabhūvākhilabhūpavandyaḥ //

*ដែលមានបុព្វសិទ្ធិនៃភាពបរិសុទ្ធដ៏ខ្ពង់ខ្ពស់និងគួរមហាក្សត្រឯទៀតកោតសរសើរ។*

*ព្រះបាទ រាជេន្ទ្រវម្ម័   ដូចជាព្រះចន្ទ   នៅថ្ងៃពេញបូរមី*
*សម្រស់ដូចទេពអប្សរ   ល្អស្រស់បវរ   ចេញពីសមុទ្រទឹកដោះ។*
*សន្តានរាជវង្សស្ម័គ្រស្មោះ   បរិសុទ្ធឥតទាស់   ដូចសែងព្រះសូរិយា*
*តេជៈស្តុកស្តម្ភថ្លៃថ្លា   សមជាបុត្រភ្វា   ដែលគួរឱ្យកោតសរសើរ។*





fb.com/krou.moeys.gov.kh   www.moeys.gov.kh   YouTube youtube.com/moeyscambodia





ផ្តែរនៃរចនាបថបន្ទាយស្រី ចុងសតវត្សទី១០ប្រាសាទស្រឡៅ សៀមរាប

## រចនាបថ បន្ទាយស្រី (១១)

ប្រាសាទបន្ទាយស្រី ត្រូវបានចាប់ផ្តើមសាងសង់នៅ គ.ស. ៩៦៧ ដោយព្រះរាជគ្រូរបស់ព្រះបាទ រាជេន្ទ្រវម៌្ម ឈ្មោះ យជ្ញវរាហៈ នៅទិសខាងជើងនៃយសោធរបុរៈ។ ប្រាសាទបន្ទាយស្រីសង់ពីថ្មភក់ពណ៌ផ្កាឈូកប្រកបដោយចម្លាក់យ៉ាងល្អពាសពេញតួប្រាសាទ។ រចនាបថបន្ទាយស្រីគឺជារចនាបថឯក ដែលល្អយ៉ាងវិសេសវិសាល ដែលឆ្លុះបញ្ចាំងពីសម្រស់ដ៏ឧត្តុង្គឧត្តម និងសុក្រឹតភាព។

ផ្តែរនៃប្រាសាទបន្ទាយស្រីបង្ហាញពីការបន្តរចនាបថនៃប្រាសាទប្រែរូប និងមេបុណ្យខាងកើត និងការចម្លងតាមផ្តែរនៃប្រាសាទលលៃ ប្រាសាទព្រះគោ និងប្រាសាទបាគង។ ផ្តែរប្រាសាទបន្ទាយស្រីមានក្បាច់ផ្តេក ដែលកាត់ផ្តែរជាបួនកង ដែលមានលក្ខណៈដូចរចនាបថសំបូរព្រៃគុក និងរចនាបថព្រៃក្មេង។ ចំពោះសសរពេជ្រវិញ យើងឃើញមានប្រើឡើងវិញនូវសសរពេជ្រមូលជាលើកចុងក្រោយនៃប្រាសាទបុរាណខ្មែរ ដោយប្រើប្រាស់លាយឡំជាមួយនឹងសសរពេជ្ររាងអដ្ឋកោណ។ ចំណែកឯក្បូរក្បាច់កម្រងផ្កា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និង ភ្ញីផ្កាវិញ ត្រូវបានប្រើប្រាស់ទាំងនៅផ្នែកខាងលើ និង ផ្នែកខាងក្រោម នៃសសរពេជ្រ។

ហោជាង គឺជាសមាសធាតុដ៏សំខាន់បំផុតនៃរចនាបថបន្ទាយស្រី។ ហោជាងនៃប្រាសាទបន្ទាយស្រីមានបីប្រភេទ៖ មានរាងជាអក្សរ U ផ្កាប់ចុះ មានបីជាន់ និងមានរាងធ្មេញរណា (រូបខាងលើ) ហោជាងខ្មែរមានច្រើនជាន់ និងហោជាងត្រីកោណ។ ចំណែកឯក្បូរក្បាច់រចនាលើផ្ទៃហោជាងវិញ មានលម្អដោយស្លឹកឈើព័ទ្ធជុំវិញទេវរូប ដែលដកស្រង់ពីទេវកថាឥណ្ឌា។ គែមខាងក្រៅនៃហោជាង ពត់ពេនចេញជាក្បាលនាគរាជយ៉ាងវិសេសវិសាល។ ចំណែកឯសសរប្រាសាទបន្ទាយស្រីមានលម្អដោយក្បូរក្បាច់រចនា និងការកែច្នៃរូបរាហូ មករនរសិង្ហ និងនាគរាជ ហើយជាពិសេសគឺផ្កាឈូក។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## ២.៧. ព្រះបាទ ជ័យវម៌្ម ទី៥ (៩៦៨-១០០០)

ព្រះបាទជ័យវម៌្ម ទី៥ (៩៦៨-១០០០) បានឡើងសោយរាជ្យ ក្រោយពីព្រះបិតាព្រះអង្គព្រះបាទ រាជេន្ទ្រវរ្ម័ន ចូលទិវង្គតនៅឆ្នាំ ៩៦៨។ ព្រះបាទជ័យវរ្ម័ន ទី៥ ជាស្ដេចដែលគោរពបូជាព្រហ្មញ្ញសាសនា (ព្រះសិវៈ និងវិស្ណុ) ផង និងព្រះពុទ្ធសាសនាមហាយានផង ដូចព្រះបិតាព្រះអង្គ។ ព្រះអង្គបានសាងសង់ប្រាសាទតាកែវ សម្រាប់តម្កល់ព្រះសិវលិង្គ។ ព្រះបាទ ជ័យវម៌្ម ទី៥ មានព្រាហ្មណ៍អាត្មសិវៈ ជាបុរោហិត និងមានរាជធានីនៅយសោធរបុរៈ។ តាមសិលាចារឹកកំពង់ធំ (K. 444) ព្រះរាជគ្រូរបស់ព្រះបាទជ័យវម៌្ម ទី៥ ព្រាហ្មណ៍ យជ្ញវរាហៈ (Yajñvarāha) បានបានរៀបចំពិធីយជ្ញ«មហាទ្វារវិធី» ឬពិធីមហាធ្វារ (ការលះបង់ធំ) ឱ្យព្រះបាទជ័យវម៌្ម ទី៥ ក្រោយពេលរៀនចប់។ ព្រាហ្មណ៍ យជ្ញវរាហៈ គឺជាអ្នកដែលបានសាងសង់ប្រាសាទបន្ទាយស្រីដ៏ល្បីល្បាញនេះឯង។ ក្សត្រាដែលរៀនចប់ត្រូវប្រារព្ធពិធី «ទីក្សា» (dīkṣā) ដើម្បីបញ្ជាក់ថា ព្រះអង្គបានក្លាយទៅជាអ្នកចេះដឹងខាងផ្នែកព្រហ្មញ្ញសាសនា។[49]

49. *ពៅ សាវរស*, 2013



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្នុងរជ្ជកាលព្រះបាទជ័យវម៌្ម ទី៥ មានសិលាចារឹកចំនួន ១៥០៖ ៣៩ ជាភាសាសំស្ក្រឹត ៧៨ ជាភាសាខ្មែរ និង ៣១ ជាភាសាសំស្ក្រឹតនិងជាភាសាខ្មែរ។ សិលាចារឹកទាំងនេះមាននៅសៀមរាប, ព្រះវិហារ, កំពង់ធំ, កំពង់ចាម, បន្ទាយមានជ័យ, បាត់ដំបង, ក្រចេះ, ព្រៃវែង, កំពត, កំពង់ឆ្នាំង, នគរាជសីមា, បុរីរំ, និងប្រាជិនបុរី។

## សិលាចារឹក (K. 842) ខ្មែរចាស់



n. 1090-B / K. 842

១. ៨៩០ គក សប្តមើកត៌ អាបាឍ តោយិការមាសគុក្រវារឧត្តរផល្គុណី នក្សត្រនុ មាទ្រិវះគាសនធ្វូលីវ្រះបា-

២. ទធូលីជេង៍វ្រះកម្រតេង៍អញ្ស្រីជយវម៌្មទេវបិបុរោហិតាចាយ៌្យរាជកុល មហាមន្ត្រីខ្ញោញគ្នាង៍វ្យបារត្រ្វ-

៣. ចិវ្រះក្រលាផ្ទំទូលិ ០ នេះវ្រះ កម្រតេងអញ គ្រីត្រិភុវនមហេគ្វរ ត បុណ្យនៃស្តេងអញ វ្រះគុរុអាយិល្លិគ្វរបុរ
៤. នុវបុណ្យស្តេងអញវ្រះគុរុ ត គិ ទេគផោង ត តិ ផ្សំម្វាយិកុលបតិនុវ្រះ កម្រតេងអញ គ្រីត្រិភុវនមហេគ្វរ
៥. ប្រេស្យផ្តសំ គណានុវ្រះកម្រតេងអញគ្រីកទ្រេគ្វរ អន្រាយិលិង្គបុរ ០ វ្នំជាមានិ រាជ  កាយ៌្យ តទៃ តិ លេងផ្វនទិក
៦. វ្រះរាជ្រគីថ្វាយិ វ្រះភោគ ០ អាយត្ត ត គៃវាចាយ៌្យ ត ជា រាជគុរុ ស្ថាបវត្តមានតោយកល្បនាស្តេងអញវ្រះគុរុ ០ វ្នំ
៧. ជា បិ កម្រតេងផ្ទែកវាំអ្នក ត សញ្ចក លហិយោគទៃវ្នំ ជា បិ ឧយិ ត អ្នក ០ នៅអំបាល្វបុណ្យ បិ កម្រតេងផ្ទែកវាំមានិ
៨. ចតុឋាំង្គលហិ កម្រតេងផ្ទែកវាំ ត បរិបាលន មានិបុណ្យផលអទ្វាំង្គ ០ អ្នក ត វល្វក ត បរិបាលន មានិ បុ-
៩. ណ្យផល ចតុឋាំង្គ ០ ទហមានិ អបតិ ត គិ ទេវស្ថាន ០ គៃវាចាយ៌្យ ត ប្រធានរាជកុលមហាមន្ត្រី សាធុជនបង្គំផ្សងនិ-
១០. វេទន ត កម្រតេងផ្ទែកវាំ ប្រំវ្យលិ ហ្វត្តគេមានិបុណ្យផល អទ្វាំង្គសោតិ ០ កុលបតិបូជា អតិថិនុភោជនាទិ ០ អ-
១១. ធ្យាបក ថ្ងៃ វ្រហ្មសត្រលេងអវិច្ឆិន្នប្រតិទិន

## សិលាចារឹក ( K. 842 ) ខ្មែរចាស់

១. មហាសករាជ ៨៩០ ទី៧ ( សប្តមី ) កើត ខែអាបាឍ ដោយរាប់តាម ចន្ទគតិ ថ្ងៃសុក្រ ថ្ងៃនក្ខតឫក្សឧត្តរផល្គុណី មានព្រះបន្ទូលនៃ
២. ព្រះបាទ គ្រីជយវម៌្មទេវ ដើម្បីឱ្យបុរោហិត អាចាយ៌្យ រាជកុលមហា មន្ត្រី ខ្ញោញឃ្វាំង ដែលត្រួត

៣. ត្រាព្រះក្រលាផ្ទំគោរព០ នេះព្រះគម្តែង គ្រីត្រិកុវនមហេគ្វរ ( បន្ទាយស្រី) ដែលជាបុណ្យនៃស្តេងអញ ជ្រះគុរុនៅឰគ្វរបុរ

៤. និងបុណ្យស្តេង និងបុណ្យស្តេងអញជ្រះគុរុស្រុកទេសផ្សេងផងនិងរួមផ្សំតែមួយកុលបតិនិងជ្រះកម្រតេងអញ គ្រីត្រិកុវនមហេគ្វរ

៥. បញ្ចូលគណនិងជ្រះកម្រតេងអព្រាគិកទ្រេគ្វរ ស្រុកលិង្គបុរ០ ពុំត្រូវមានរាជការដទៃទៀត ជូនទឹក

៦. ជ្រះរាជ្រគី ថ្វាយិជ្រះភោគ០ នេះជាការផោរគៃវាចាយ៌្យ ដែលជា រាជគុរុស្តាប់វត្តមាន ដោយបញ្ញត្តិស្តេងអញជ្រះគុរុ០ ពុំ

៧. ត្រូវមានព្រះរាជា អ្នកិសញ្ជកិ ផងយកទៅទីផ្សេង ពុំត្រូវមានឱយិអ្នកផ្សេង០ ពីអំបាល្ងបុណ្យនេះ ព្រះរាជា មានិ

៨. ១/៤ (ចតុប៌ាង្គ) ផង ព្រះរាជាមានិបុណ្យផលពាក់កណ្តាល (អទ្ធ៌ាង្គ) ០ អ្នកជំនិត (ព្រះរាជា) ដែលថែរក្សា (បរិបាល) មានិ

៩. ផលបុណ្យ១/៤ (ចតុប៌ាង្គ) ០ ប្រសិន( ទហ )មានិអាសន្ន(អបតិ) នៅទេវស្ថាន០ គៃវាចាយ៌្យ ជាប្រធានរាជកុលមហាមន្ត្រី សាធុជននឹងបង្គំទូលថ្វាយ

១០. ទៅព្រះរាជា ៧ដង (ប្រំវ្យលិ ហូត្ត) គេមានិបុណ្យផល ពាក់កណ្តាល (អទ្ធ៌ាង្គ) ទៀតសោតិ ០ ត្រូវ(កុលបតិ)បូជាដល់អតិថិជន នូវភោជនាទិ០

១១. គ្រូ (អធ្យាបក) ធ្វើ (ថ្វេ) សូត្រព្រហ្ម (ជ្រហ្មសត្រ) កុំឱ្យខាន (លេងអវិច្ឆិន្ន) តាមប្រតិទិន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ផ្ទាំបន្ទាយនាង K. 214 មង្គលបុរី ( ឆ្នាំ៩៨១ )











fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## ២.៨. ព្រះបាទសូរ្យវម៌្ម ទី១ (១០១១-១០៤៩)

ព្រះបាទសូរ្យវម៌្ម ទី១ (១០១១-១០៤៩) បានទទួលរាជាភិសេកជាចក្រវតិ្ត និងមានរាជធានីនៅអង្គរនៅឆ្នាំ ១០១១។ សិលាចារឹកស្តុកកក់ធំ បានបញ្ជាក់ថា នៅក្នុងឆ្នាំ១០០២ព្រះបាទ សូរ្យវម៌្ម ទី១ ដែលមានទីតាំងនៅភូមិភាគពាយព្យនៃប្រទេសកម្ពុជា ប្រហែលជានៅម៉ុំដងទន្លេមេណាំផ្នែកកណ្តាល បានចាប់ផ្តើមប្រតិបត្តិការសឹកប្រឆាំងនឹងគូបដិបក្ខរបស់ព្រះអង្គ។ នៅឆ្នាំ ១០០៤ ព្រះអង្គបានកាន់កាប់នូវទឹកដីផ្នែកខាងជើងនៃភ្នំដងរែក។ នៅពេលនោះ ព្រះបាទ ជ័យវីរវម៌្ម នៅសោយរាជ្យនៅអង្គរនៅឡើយ។

បន្ទាប់ពីបានពង្រឹងមូលដ្ឋាននៅទីនោះហើយ នៅចន្លោះឆ្នាំ ១០០៥ និង ១០០៧ ព្រះបាទសូរ្យវម៌្ម ទី១ បានលើកទ័ពវាយចូលអង្គរ ហើយបានទទួលជោគជ័យជាស្ថាពរនៅឆ្នាំ ១០១០។ បន្ទាប់មកព្រះអង្គខិតខំពង្រឹងសណ្តាប់ធ្នាប់សង្គម និងស្តារព្រះរាជាណាចក្រ ពង្រឹងក្បាលម៉ាសីនរដ្ឋបាល និងកសាងប្រាសាទឡើងវិញ ដើម្បីឱ្យប្រជាពលរដ្ឋអាចរស់នៅក្នុងសុខសន្តិភាព។ ព្រះបាទសូរ្យវម៌្ម ទី១ បានសោយរាជ្យរហូតដល់ឆ្នាំ ១០៤៩។ ព្រះអង្គគឺជាយុទ្ធវិទូ និងជាមេដឹកនាំសឹកដ៏ចំណានម្នាក់ ដែលបានពង្រីកទឹកដីនៃអាណាចក្រអង្គរ ដល់ត្រើយខាងស្តាំនៃទន្លេមេណាំ និងបន្ទាប់មកដល់ម៉ាឡេស៊ីភាគកណ្តាល។

នៅក្នុងរាជ្យរបស់ ព្រះបាទ សូរ្យវម៌្ម ទី១ ព្រាហ្មណ៍ សទាសិវ ត្រូវបានតែងតាំងជា ជយេន្ទ្របណ្ឌិត និងបានរៀបអភិសេកជាមួយប្អូនស្រីរបស់ព្រះមហាក្សត្រីយ៍ វិរលក្សី ដែលជាប្អូនថ្លៃរបស់ព្រះអង្គ។ បន្ទាប់មក សទាសិវ ត្រូវបានព្រះបាទ ឧទយាទិត្យវម៌្ម ទី២ តែងតាំងជារាជគ្រូ និងមានឋានៈជាធូលីជើង។

អាទិភាពរបស់ព្រះបាទសូរ្យវម៌្ម ទី១ គឺការផ្សះផ្សាជាតិ និងការពង្រឹងសន្តិភាពនៅក្នុងអាណាចក្រខ្មែរ បន្ទាប់ពីសង្គ្រាមក្នុងស្រុកអស់រយៈពេល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៩ ឆ្នាំមក។ ដើម្បីពង្រឹងអំណាចរបស់ព្រះរាជានៅតាមខេត្ត ព្រះអង្គបានផ្តោតជាសំខាន់លើការសាងសង់ប្រាសាទបុរាណនៅក្រៅអង្គរផងដែរ។ ដូច្នេះហើយ ទើបព្រះអង្គបានបញ្ជាឱ្យព្រាហ្មណ៍និងមន្ត្រីជាន់ខ្ពស់ជួលជុលសំណង់ចាស់ៗ បង្កើយការសាងសង់ និងកសាងប្រាសាទជាច្រើន ដូចជាប្រាសាទភ្នំជីសូរ ប្រាសាទព្រះវិហារ ប្រាសាទបាកាន (ព្រះខ័នកំពង់ស្វាយ) ប្រាសាទអ្នកបួស ប្រាសាទភិមានអាកាស ប្រាសាទបន្ទាយសម្រែ ប្រាសាទវត្តបាសែត ប្រាសាទវត្តឯកភ្នំ ប្រាសាទព្រះធាតុទឹកធារ និងប្រាសាទកំពែងណាយ (នៅប្រទេសថៃ)។

នៅក្នុងរជ្ជកាលព្រះបាទ សូរ្យវម៌្មទី១ មានសិលាចារឹកចំនួន ៨៩៖ ១៥ ជាភាសាសំស្ក្រឹត, ៥៣ ជាភាសាខ្មែរ និង ១១ ជាភាសាសំស្ក្រឹតនិងជាភាសាខ្មែរ។ សិលាចារឹកទាំងនេះមាននៅសៀមរាប, ព្រះវិហារ, កំពង់ចាម, បន្ទាយមានជ័យ, បាត់ដំបង (ព្រះនេត្រព្រះ), ក្រចេះ (សំបូរ), ឧត្តរមានជ័យ, ចំប៉ាសាក់, សុរិន្ទ, ស្រះកែវ, លប់បុរី, អាយុធ្យា និងខនកែន។

នៅពេលដែលស្រុកកើតសង្គ្រាមក្នុងស្រុក មន្ត្រីជាន់ខ្ពស់ខ្លះបានគាំទ្រដល់ពួកបះបោរ ដើម្បីចាក់ខ្សែក្នុងគោលដៅរក្សាទ្រព្យសម្បត្តិរបស់ពួកគេ។ បន្ទាប់ពីឡើងសោយរាជ្យនៅឆ្នាំ ១០១១ ព្រះបាទ សូរ្យវម៌្មទី១ បានកោះនាហ្មឺនសព្វមុខមន្ត្រីទាំងអស់ ឱ្យចូលស្បថចំពោះព្រះភក្ត្រព្រះអង្គ ដើម្បីឱ្យពួកគេសម្តែងនូវភាពស្មោះត្រង់ចំពោះព្រះអង្គ។ នៅលើសិលាចារឹកនៃគោបុរៈនៃព្រះបរមរាជវាំង ព្រះអង្គបានចារឹកនូវសម្បថ ដែលមន្ត្រីគ្រប់ជាន់ថ្នាក់ត្រូវធ្វើសច្ចាប្រណិធាន ដើម្បីបញ្ជាក់ពីភាពស្មោះត្រង់របស់ពួកគេចំពោះព្រះអង្គ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# សិលាចារឹកសម្បថតម្រួចព្រះបាទសូរ្យវម្ម៌ ទី១ K. 292



យើងឃើញមានសិលាចារឹកចំនួន ៨ ដែលជាសម្បថដូចគ្នា ខុសគ្នាតែឋានៈរបស់មន្ត្រី «តម្រួត» របស់ព្រះរាជាតែប៉ុណ្ណោះ៖ សិលាចារឹកទី១ មន្ត្រីនេះជាមន្ត្រីថ្នាក់ទី១ ( នា ឯក) ហើយទី២ ថ្នាក់ទី២។

១. ៩៣៣ គក នវមីកេត ភទ្របទ អាទិត្យវារ ០ នេះគិពេះហវទ្ធ ប្រតិជ្ញា ០ យេង៍អំប្វាលនេះហនា ភាគតម្រាច ឯកស្បង្គ

២. គបបវេលាកាត្តេថ្វាយអាយុះ នក្ប្ទតជ្វកក្កិតគុន្ធ តធ្វូលិវ្រះបាទកម្រតេង៍ កំត្វនអញ គ្រីសូយ៌្យវម្ម៌ទេវសកលស្វេយ

៣. វ្រះធម្ម៌រាជ្យនុ ៩២៤ គក វ្នេក្និតវ្រះវ្វេង៍វ្រះរត្ននុវ្រាហ្មណាចាយ៌្យ ០ យេង៍វ្វំបង្គំតកម្រតេង៍ផ្ទែកពាំ តទៃតិលេយវ្វំខ្នាំ

៤. ង្នី វ្វំសំនុខ្នាង្វ វ្វំថ្វេទ្រោហប្រការដោង៍ ០ នៅអំបាល្វអំវេហលភក្តិ យតធ្វូលីវ្រះបាទកម្រតេង៍កំត្វនអញ គ្រីសូយ៌្យវម្ម៌ទេវ

៥. នោះគិបិ យេង៍ឱទ្យោគថ្វេ ០ ទហមានចំបាង្វ យេង៍ឱទ្យោគធ្បោង៍ នុស្វ៌ាត្នាណា វ្វំស្វន្តអាយុះ ហេតុភក្តិវ្វំរត លេង៍ចំបាង្វ ០ ទហអ្យត

៦. ចំបាង្វបិយេង៍ស្វាបនុស្វយំវ្យាធិមុហ្និ លេង៍អ្នកផល្វ តស្វាមិភក្តិមាន្ត



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

យេង្វ០ទហអាយុះយេងអាចទន្តវ្រះរាជកាយ៉្យវេលា ល្ហោះតកាលនៅ

៧. ប្រការលេហយេងស្វាបហេតុកក្តិយ តិបិយេងថ្ងេ០ទហមានវ្រះរាជកាយ៉្យនាកម្រតេងកំត្វនអញ បន្ទូលប្រេយេងទៅនាត

៨. ធ្វាយ បិមានវត្ត៌មានតព្វស្ទេងបឹត្យង វស្តុតវ្យត្តថ្ងេពោះហ វទ្វប្រតិជ្ញាទិទៃវ០ទហយេង្គអំប្វាលនេះ ហមាន្តនុវ្វំថ្ងេពោះហវទ្វប្រតិ

៩. ជ្ញានេះ ហរិយកម្រតេងផ្ទែកពាំតស្ទេយវ្រះធម្មរាជ្យចំន្យរស្វំលេងឱ្យរាជកយត យេងលេងវ្វំម្វាយប្រការ០ទហយេងមាន្តកប

១០. ត បិវ្វំផ្តតពោះហ ប្រតិជ្ញា តពោះហនេះហលេងយេងជាត ទ្វាត្រឹគនរកតរាបវ្រះចន្ទ្រាទិត្យមានលេយ ០ ទហយេងថ្ងេពោះហវទ្វប្រ

១១. តិជ្ញានេះហតគុទ្ធ លេងកម្រតេងផ្ទែកពាំ ប្រេបរិបាលនវ្រះបុន្យស្រុកទេគយេង លេងសំបុរណ អ្នោតកុលេ យេងហេតុយេងស្វា

១២. មិកក្តិតធ្វូលិវ្រះបាទកម្រតេងកំត្វនអញ គ្រីស្វយ៉្យវម្មទេវសកល ស្ទេយវ្រះធម្មរាជ្យនុ ៩២៤ គក០ រិយផលអ្នកតស្វាមិភក្តិ

១៣. លេងមាន្តយេង្វ អំរិតហលោកទៅល្ហោះបរលោក ០

មហាសករាជ ៩៣៣ ប្រាំបួនកើត ខែភទ្របទ ថ្ងៃអាទិត្យ។ នេះគឺពាក្យសច្ចាប្រណិធានរបស់ទូលបង្គំទាំងអស់គ្នា។ ( ទូលបង្គំ) យើង ( ខ្ញុំ) ទាំងអស់គ្នាជាតម្រួតរបស់ភាគ( តំបន់) ថ្នាក់ ( ឯក ទោ ត្រី ចត្វា) នៅពេលស្បថ ( ទូលបង្គំ) យើង ( ខ្ញុំ) សូមសច្ចាកាត់ដៃថ្វាយអាយុនិងថ្វាយនូវកត្តញ្ញូភក្តីភាពដ៏បរិសុទ្ធផូវផង់ចំពោះព្រះករុណាព្រះបាទសម្តេច ស្រីសូយ៌្យវម៌្មទេវៈ( សូរ្យវរ្ម័ន ទី១) ដែលបានសោយរាជ្យជាសកលនៅឆ្នាំ៩២៤ នៃមហាសករាជនៅចំពោះមុខព្រះភ្លើងព្រះរតនៈនិងព្រាហ្មណាចារ្យទាំងឡាយ។ ( ទូលបង្គំ) យើង ( ខ្ញុំ) មិនបង្គំ ( គោរព) គម្តែងផ្ទែក្រោមដទៃទៀត ( ក្រៅពីព្រះអង្គ) ឡើយពុំ ( ធ្វើជា) ខ្មាំងនិងពុំចំណុះខ្មាំង ( ចូលដៃសមគំនិតជាមួយខ្មាំង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សត្រូវ) ពុំធ្វើការអ្វីដែលនឹងនាំមកនូវសេចក្តីវិនាស (ចំពោះព្រះអង្គ) ឡើយ។ រាល់អំពើផងទាំងឡាយដែលជាផលនៃស្វាមីភក្តិភាព (ទូលបង្គំ) យើង (ខ្ញុំ) ចំពោះព្រះករុណាព្រះបាទ ស្រីសូរ្យវម៌្មទេវៈ (ទូលបង្គំ) យើង (ខ្ញុំ) នឹងខិតខំប្រឹងធ្វើឱ្យបានសម្រេច។ ទោះបីមានចម្បាំង (ទូលបង្គំ) យើង (ខ្ញុំ) ប្តេជ្ញាច្បាំងដោយស្មោះអស់ពីចិត្តដោយឥតស្តាយអាយុជីវិតឡើយ។ ដោយស្វាមីភក្តិភាព (ចំពោះព្រះរាជា) (ទូលបង្គំ) យើង (ខ្ញុំ) មិនរត់ចោលចម្បាំងឡើយ។ ទោះគ្មានចម្បាំង ប្រសិនបើ (ទូលបង្គំ) យើង (ខ្ញុំ) ស្លាប់ដោយសារជំងឺបៀតបៀន គឺថាសូមឱ្យ (ទូលបង្គំ) យើង (ខ្ញុំ) ទាំងអស់គ្នាបានទទួលនូវផល (រង្វាន់) ជាអ្នកមានកតញ្ញូកត្តី ចំពោះអម្ចាស់របស់ខ្លួន។ ប្រសិនបើអាយុជីវិតរបស់ (ទូលបង្គំ) យើង (ខ្ញុំ) អាចទាន់ព្រះរាជការ (អាចបម្រើការងាររាជការ) តទៅរហូតដល់ពេលស្លាប់ (ក្នុងមុខងារ) (ទូលបង្គំ) យើង (ខ្ញុំ) និងបម្រើកិច្ចការនោះ ដោយហេតុថា (ទូលបង្គំ) យើង (ខ្ញុំ) មានស្វាមីភក្តិ (ចំពោះព្រះរាជា)។

ប្រសិនបើមានព្រះរាជការ ដែលព្រះមហាក្សត្រ (ទ្រង់ត្រាស់) បន្ទូលប្រើ (ទូលបង្គំ) យើង (ខ្ញុំ) ទៅទីឆ្ងាយដោយសារមានព្រឹត្តិការណ៍ ដែលព្រះរាជាបានឮគេនិយាយនោះ (ទូលបង្គំ) យើង (ខ្ញុំ) និងរកវិធីស្វែងយល់រឿងនោះឱ្យបានល្អិតល្អន់និងប្តេជ្ញាធ្វើតាមពាក្យសច្ចាប្រណិធានរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួនរៀងៗខ្លួន។ ប្រសិនបើក្នុងចំណោម (ទូលបង្គំ) យើង (ខ្ញុំ) ទាំងអស់គ្នានោះមានអ្នកមិនធ្វើតាមពាក្យសច្ចាប្រណិធាននេះ ចំពោះព្រះមហាក្សត្រដែលសោយរាជ្យដ៏យូរលង់ក្រោយៗទៀត (ទូលបង្គំ) យើង (ខ្ញុំ) មានល្បិចកលមិនគោរពខ្ជាប់ខ្ជួននូវពាក្យសម្បថនេះ សូមឱ្យ (ទូលបង្គំ) យើង (ខ្ញុំ) ធ្លាក់ទៅកើតក្នុងឋាននរកទាំង៣២ជាន់ អស់កាលដ៏យូរ ដរាបណានៅព្រះអាទិត្យនិងព្រះចន្ទ។ ប្រសិនបើ (ទូលបង្គំ) យើង (ខ្ញុំ) ទាំងអស់គ្នាបំពេញបានល្អបរិសុទ្ធ តាមពាក្យសច្ចាប្រណិធាននេះ សូមគម្តែងផ្ទៃក្រោមទ្រង់ព្រះមេត្តាព្រះរាជទាន (ប្រើ) ឱ្យ (ទូលបង្គំ) យើង (ខ្ញុំ) បាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថែទាំនូវការស្ថាបនាជាកុសលរបស់ស្រុកទេសយើងនិងផ្តល់នូវភាពស្ថិតស្ថិរសម្បូណ៌រុងរឿងនៃវង្សត្រកូលរបស់ (ទូលបង្គំ) យើង (ខ្ញុំ) ដោយហេតុថា (ទូលបង្គំ) យើង (ខ្ញុំ) មានកតញ្ញូកត្តិភាពចំពោះល្អងធូលីព្រះបាទ (គម្តែងផ្ទៃក្រោម) សម្តេចព្រះសូយ៌្យវម៌្មទេវៈ ដែលព្រះអង្គបានសោយរាជ្យជាសកលនៅឆ្នាំ ៩២៤ នៃមហាសករាជ។ សូមឱ្យផល (រង្វាន់) នៃអ្នកមានស្វាមីភក្តិចំពោះព្រះរាជា ជាអម្ចាស់របស់ខ្លួនកើតមានដល់ (ទូលបង្គំ) យើង (ខ្ញុំ) ចាប់ពីលោកនេះ រហូតដល់បរលោក។[50]

## រចនាបថ ឃ្លាំង (១២)

ស្ថាបត្យកម្ម នៃរចនាបថឃ្លាំងត្រូវបានចាប់ផ្តើមសាងសង់នៅចុង ស.វ.ទី១០ និង ដើមស.វ.១១ តាមរយៈការសាងសង់ប្រាសាទតាកែវ ប្រាសាទវិមានអាកាស (នៅក្នុងព្រះបរមរាជវាំង) ប្រាសាទឃ្លាំង និង ប្រាសាទព្រះវិហារ។ ស្ថាបត្យកម្មនៃរចនាបថឃ្លាំងមានការរីកចម្រើន ក្នុងការសាងសង់ប្រាសាទ-ភ្នំ ដែលមានលក្ខណៈពេញលេញ ដោយដកស្រង់នូវបទពិសោធន៍ក្នុងសាងសង់សាលវែង នៅក្នុងរចនាបថ ដើម្បីច្នៃឱ្យក្លាយទៅជាកំពែងថែវមានដំបូលជារូតប្រក់ឥដ្ឋ ឬថ្មភក់ រត់ពីលើព្រលាននៃខឿនព័ទ្ធជុំវិញប្រាង្គកណ្តាល។ នៅប្រាសាទតាកែវ ស្ថាបត្យករបុរាណខ្មែរសង់ជាលើកដំបូងនូវថែវព័ទ្ធជុំវិញនៅលើខឿនរាងសាជី ដែលមានដំបូលរូតប្រក់ឥដ្ឋ។ តែឥដ្ឋនេះ បែកបាក់ខូចអស់ហើយ។ នៅប្រាសាទវិមានអាកាស ស្ថាបត្យករបុរាណបានសង់ថែវព័ទ្ធជុំវិញ លើខឿនខ្ពស់ជាងគេនៃសាជី។ នេះជាប្រាសាទខ្មែរទីមួយ ដែលមានថែវមានដំបូលប្រក់រូតធ្វើពីថ្មភក់។ ប្រាសាទតាកែវ និងប្រាសាទព្រះវិហារ គឺជាស្នាដៃកំពូលក្នុងចំណោមប្រាសាទបុរាណខ្មែរ។

50. ទស្សនាវដ្តី កម្ពុជាសុរិយា ឆ្នាំទី៤៩ លេខ១ ឆ្នាំ១៩៩៤



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia





## ប្រាសាទព្រះវិហារ

ប្រាសាទព្រះវិហារមានឈ្មោះដើមហៅថា «ស្រី ស៊ិខរេស្វរ» សម្រាប់ឧទ្ទិសដល់ព្រះសិវៈ និង អាទិទេព «ស្រី ស៊ិខរេស្វរ» (ម្ចាស់ភ្នំ) ស្ថាបនាចាប់តាំងពីចុងសតវត្សទី ១០ ក្នុងរជ្ជកាលព្រះបាទ ជ័យវរ្ម័ន ទី៥ (៩៦៨-១០០០) ដល់ពាក់កណ្ដាលសតវត្សទី ១១ ក្នុងរជ្ជកាល ព្រះបាទឧទយាទិត្យវរ្ម័ន ទី២ (១០៤៩-១០៦៦)។ លោក ហម ឆាយលី បានចងក្រងជាភាសាខ្មែរនូវប្រជុំសិលាចារឹកនៃប្រាសាទព្រះស្រីសិខរីស្វរៈ ឬ ប្រាសាទព្រះវិហារ។ សិលាចារឹកនៃប្រាសាទព្រះវិហារត្រូវបានចារនៅក្នុងរជ្ជកាលនៃព្រះមហាក្សត្រពីរអង្គ៖ (១) ព្រះបាទសូរ្យវរ្ម័ន ទី១ (K. 380 ដល់ K. 383) និង (២) ព្រះបាទសូរ្យវរ្ម័ន ទី២ (K. 383)។

## សិលាចារឹកព្រះវិហារ K. 380

សិលាចារឹក K. 380៖ (១) នៅទ្វារចូលប្រាសាទ នៃគោបុរៈទី២ លើមេទ្វារខាងជើង មានអត្ថបទជាភាសាសំស្ក្រឹត ២៧ បន្ទាត់ និងអត្ថបទជាភាសាខ្មែរមាន ២៨ + ១៣ បន្ទាត់ (២) នៅលើមេទ្វារខាងលិច មានអត្ថបទជាភាសាសំស្ក្រឹត ១០ + ២ បន្ទាត់ និងអត្ថបទជាភាសាខ្មែរមាន ១៦ +៥+៤ បន្ទាត់ នៅនឹងកន្ទ្វេង។ អត្ថបទបែកចេញជាបួនផ្នែក ចារក្នុងដំណាក់កាលខុសៗគ្នាក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័ន ទី១ រវាងឆ្នាំ ១០១៨ និង ១០៤៩៖

(១) សិលាចារឹកសំស្ក្រឹតចំនួន ១០ បន្ទាត់ចារលើមេទ្វារខាងលិច ជាការសូត្ររំលឹកដល់ព្រះ និង ២៧ បន្ទាត់ចារលើមេទ្វារខាងកើត គឺជាបញ្ញត្តិរបស់ព្រះរាជា និងការប្រកាសពីការកសាងបូជនីយដ្ឋានដោយព្រះបាទ ស្រីសូរ្យវរ្ម័ន ទី១ ដំបូងនៅក្រុងជ័យក្សេត្រ (បសែត ខេត្តបាត់ដំបង) ហើយបន្ទាប់មកបានកសាងបូជនីយដ្ឋានចំនួន ៣ ទៀតនៅសក ៩៤០ (គស ១០១៨/១៩)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅប្រាសាទព្រះស្រីសិខរីស្វរៈ នៅឦសានតីថៈ (មិនដឹងជានៅទីណា) និង នៅសូរ្យាទ្រិ (ភ្នំជីសូរ្យ)។

(២) អត្ថបទចារលើមេទ្វារខាងលិច នៅសក ៩៥៩-៩៦០ (គស ១០៣៧-១០៣៨) ចំនួន ២៣បន្ទាត់ (១៦ បន្ទាត់ជាភាសាខ្មែរ និង២ បន្ទាត់ជាភាសាសំស្ក្រឹត)៖ ពិពណ៌នាពីកំស្តែង ស្រីសុកម៌ា កើតនៅកុរុក្សេត្រ ដែលជាអ្នកកត់ត្រាប្រវត្តិសាស្ត្រ នៅប្រាសាទព្រះស្រីសិខរីស្វរៈ និងជាបណ្ណាគារក្សនៃព្រះនគរកម្ពុជា ហើយបានធ្វើការកែលម្អប្រាសាទ។ ព្រះបាទសូរ្យវម៌្ម ទី១បានប្រទានដីយ៉ាងធំនៅ សក ៩៥៩ (គស ១០៣៧) ដើម្បីបង្កើតស្រុករិភេទ ដែលត្រូវដូរឈ្មោះមក កុរុក្សេត្រវិញ។ ព្រះស្រីសុកម៌ាបានបង្កើតក្រុមវិជ្ជាជីវៈពិសេស។

## ប្រាសាទភ្នំជីសូរ្យ

ប្រាសាទ«ភ្នំជីសូរ្យ» មានឈ្មោះដើមហៅថា «គ្រីសូយ៌្យបវ៌ត»។ ប្រាសាទនេះត្រូវបានសាងសង់ក្នុងរជ្ជកាលព្រះបាទសូរ្យវម៌្ម ទី១។ ប្រាសាទ«ភ្នំជីសូរ» ស្ថិតនៅក្នុងស្រុកសំរោង ខេត្តតាកែវ ចម្ងាយ ៦០ គីឡូម៉ែត្រពីភ្នំពេញ ក្នុងដែនដីរាជធានីបុរាណអង្គរបុរី ដែលធ្លាប់ជារាជធានីហ្វូណន។ ប្រាសាទនេះសាងសង់លើកំពូលភ្នំ មានតួប្រាង្គចំនួន ៩ ដែលមានប្រាង្គកណ្ដាល និង ប្រាង្គតូចៗចំនួន ៨ នៅព័ទ្ធជុំវិញ។ ប្រាង្គកណ្ដាលសង់ពីឥដ្ឋ ដែលជាកន្លែង សម្រាប់តម្កល់បដិមា។ នៅជញ្ជាំងខាងជើងមានចោះរន្ធបង្ហូរទឹកមន្ត (សោមស៊ូត្រា)។

ហោត្រៃ (បណ្ណាល័យ) មានពីរ ខាងជើង និងខាងត្បូងធ្វើពីថ្មភក់។ នៅលើមេទ្វារនៃហោត្រៃខាងជើងមានចារចារឹក K. 31។

ប្រាង្គប្រាសាទបន្ទាប់បន្សំផ្សេងទៀត ធ្វើពីថ្មភក់ និងឥដ្ឋ។

ប្រាសាទមានកំពែង និងថែវថព័ទ្ធជុំវិញប្រាសាទ និងមានក្លោងទ្វារបី៖ ក្លោងទ្វារទី១មានពីរ ខាងកើតមួយ និងខាងលិចមួយ។ ក្លោងទ្វារទី២ មានមួយ និងទី៣ មានមួយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



# សិលាចារឹកប្រាសាទភ្នំជីសូរ្យ K. 31



សិលាចារឹក K. 31 គឺជាព្រះបញ្ញត្តិ (ព្រះកល្បនា) ស្តីពីតង្វាយដល់ទេពស្រីសូយ៌្យបវ៌្វត (ភ្នំជីសូរ្យ)។

(១) ៩៥១ គក គីនុវ្រះបាទកម្រតេង៑អញ

(២) គ្រីសូយ៌្យវម្ម៌ទេវ ជូនត្វោញអេរ្យាធោ-

(៣) កគរគ្យរនុតេង៑ហ្យង៑នុក្ខត្បោបាយ

(៤) ផោង៑នុស្រុកធ្និង៑ស្លោក ០ សប្តបណាំលោ

(៥) ធ្និង៑កំរ្យិង៑ត្វង៑ ០ ធ្និង៑ ធ្និង៑តោតក្រវេ

(៦) ធ្និង៑ស្វាយ ០ ធ្និង៑

អត្ថបទជាខ្មែរទំនើប

(១) នៅមហាសករាជ ៩៥១



(២) ព្រះបាទស្រីសូរ្យវម៌្មទេវជូនឆ្នោញស តោ
(៣) កគរគីរ និងតេងហ្យងនិងមធ្យោបាយសម្រាប់អ្នកបម្រើ
(៤) ផង និងស្រុកស្ទឹងស្ពោក។ ស្រុកសប្តបណាំលោ
(៥) ស្រុកស្ទឹងកំពីងដួង។ ស្ទឹង ស្ទឹងដោតក្រពើ
(៦) ស្ទឹងស្វាយ។

## ប្រាសាទបាសែត

នៅសម័យអង្គរ ទឹកដីនៃខេត្តបាត់ដំបងត្រូវបានបែងចែកជា «វិសយ» គឺជាស្រុករដ្ឋបាលដើម្បីសម្រួលដល់ការគ្រប់គ្រង។ នៅក្នុងរជ្ជកាលនៃព្រះបាទជយវម៌្ម ទី២ (៧៧០-៨៣០) ព្រះអង្គបានបញ្ជូនប្រជាពលរដ្ឋពីភាគខាងត្បូងប្រទេស ដើម្បីមកតាំងទីលំនៅក្នុងតំបន់នោះ។ មន្ត្រីជាន់ខ្ពស់ដូចជាព្រះកម្រតេងអញ ស្រី យោគិស្វរបណ្ឌិត ដែលជាព្រះរាជគ្រូ



របស់ព្រះបាទសូរ្យវម៌្ម ទី១ បានបង្កើតនូវភូមិដ្ឋានថ្មី ដូចជាមូលស្ថាបនា នៅវត្តឯក (K. 228) និងនៅទួលដូនខ្វាស់ (K. 868) ជាដើម។

ប្រាសាទបាសែតនេះ ដែលមានឈ្មោះថា «ជយក្សេត្រ» ត្រូវបានស្ថាបនាឡើងនៅឆ្នាំ ១០១៨ ហើយបន្ទាប់មក ព្រះបាទសូរ្យវម៌្មទី ១ បានសាងសង់ប្រាសាទព្រះវិហារលើភ្នំដងរែក ប្រាសាទភ្នំជីសូរនៅខេត្តតាកែវ ប្រាសាទ «ឦសានតីរ្ថ» ដែលជាទីសក្ការបូជាទី៤ និងប្រាសាទវត្តឯកភ្នំ។[51]ប្រាសាទបាសែតស្ថាបនានៅឆ្នាំ ១០១៨ ក្នុងរជ្ជកាលព្រះបាទសូរ្យវម៌្ម ទី១ មានទីតាំងស្ថិតនៅក្នុងស្រុកសង្កែខេត្តបាត់ដំបង។ប្រាសាទនេះឧទ្ទិសដល់ព្រះសិវៈ ដែលតំណាងដោយព្រះលិង្គ «សូរ្យវម៌េស្វរៈ»។

## សិលាចារឹកប្រាសាទបាសែត

សិលាចារឹក K. 205៖ សិលាចារឹកនេះស្ថិតនៅក្នុងប៉មកណ្តាលនៃប្រាសាទលើមេទ្វារខាងលិច មាន៤៣ បន្ទាត់ជាភាសាខ្មែរ និងសំស្ក្រឹត ដែលតម្កល់ទុកនៅសារមន្ទីរបាត់ដំបង។ សិលាចារឹកនេះចែកជាពីរផ្នែក៖ (១) អត្ថបទភាសាខ្មែរមាន ២៥ បន្ទាត់ ចារក្នុងឆ្នាំ ១០៣៦ ក្នុងរជ្ជកាលព្រះបាទសូរ្យវម៌្ម ទី១ និងពិពណ៌នាថា គ្រីគុនបតិវម៌្ម បានទិញដី និងធ្វើអំណោយដីនេះ ដល់អាទិទេព «គ្រីជយក្សេត្រ» (ប្រាសាទបាសែត) (២) អត្ថបទភាសាសំស្ក្រឹត មាន ១៨ បន្ទាត់បាននិយាយពីព្រះបាទឧទយាទិត្យវម៌្ម ទី២ ដែលឡើងសោយរាជ្យ ក្រោយព្រះបាទសូរ្យវម៌្ម ទី ១ បានប្រទានគោរមងារកិត្តិយសដល់វិត្តកម្ម៌ ដែលបានបំពេញការងារសាងសង់ថ្វាយដល់ព្រះរាជា។

សិលាចារឹក K. 206៖ សិលាចារឹកនេះស្ថិតនៅក្នុងប៉មកណ្តាលនៃប្រាសាទលើមេទ្វារខាងលិច មាន៤៥ បន្ទាត់ជាភាសាខ្មែរ ដែលតម្កល់ទុកនៅសារមន្ទីរបាត់ដំបង។ សិលាចារឹកនេះចារនៅឆ្នាំ ១០៤២ ហើយ បន្ទាប់ពី

51. Bruguier, 2015



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សរសើរដល់ព្រះសិវៈ បានពិពណ៌នាពី ស្រីគុនបតិវរ្ម័ ដែលបានទិញដីមួយកន្លែងទៀត ដោយយកវត្ថុមានតម្លៃមកដោះដូរ ដើម្បីធ្វើអំណោយដីនេះដល់អាទិទេព «ស្រីជយក្សេត្រ» ផងដែរ។[52]

សិលាចារឹក K. 207៖ សិលាចារឹកនេះស្ថិតនៅក្នុងប៉មកណ្តាលនៃប្រាសាទលើមេទ្វារខាងត្បូង មាន១០ បន្ទាត់ជាភាសាសំស្រ្កឹត និងនៅលើមេទ្វារខាងជើង មាន៦៦ បន្ទាត់ជាភាសាខ្មែរ ដែលស្ថិតនៅលើទ្វារប្រាសាទ។ អត្ថបទភាសាខ្មែរចារនៅឆ្នាំ ១០៤២ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័ ទី១ បាននិយាយពី ស្រីកថបណ្ឌិត ដែលបានធ្វើអំណោយជាវត្ថុមានតម្លៃ ដំរី សម្លៀកបំពាក់ និងគ្រឿងទេសដល់ព្រះអាទិទេព «ស្រីជយក្សេត្រ» ហើយបានទិញដីសម្រាប់ប្រាសាទ។

សិលាចារឹក K. 208៖ គឺជាសិលាចារឹកជាភាសាសំស្រ្កឹតចំនួន ៣០ បន្ទាត់ និងជាភាសាខ្មែរចំនួន ៣៨ បន្ទាត់ ដែលត្រូវគេលួចបាត់ទៅហើយ។ សិលាចារឹកនេះកោតសរសើរដល់ព្រះសិវៈ និងឧទ្ទិសដល់ការស្ថាបនាប្រាសាទ។ អត្ថបទសរសើរដល់ព្រះបាទបរមានិវ៌នបទ (ព្រះបាទសូរ្យវរ្ម័ ទី១) និងព្រះបាទឧទយាទិត្យវរ្ម័ ទី២ (១០៥៥-១០៦៦) ដែលចារសិលាចារឹកនេះ និងនិយាយពីការទិញដីសម្រាប់ប្រាសាទ និងការស្ថាបនាព្រះលិង្គ និងរូបបដិមា «ភគវតិ»។



បដិមាព្រះព្រហ្មរចនាបថ កោះកេរនៅប្រាសាទបាសែត ដែលដាក់តាំងនៅសារមន្ទីរ Guimet ប៉ារីស

52. Cœdès, IC III



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## ២.៩. ប្រាសាទ និងសិលាចារឹកឯកភ្នំ (១០៥០-១០៦៦)

ប្រាសាទវត្តឯកភ្នំ៖ ស្ថាបនានៅសតវត្សទី ១១ នៅឆ្នាំ ១០១៨ ក្នុងរជ្ជកាលព្រះបាទសូរ្យវម៌្ម ទី១។ ប្រាសាទនេះឧទ្ទិសដល់ព្រះសិវៈដែលតំណាងដោយព្រះលិង្គ «សូរ្យវម៌េស្វរៈ»។ ការសាងសង់ប្រាសាទនេះបានលើកឡើងនៅក្នុងសិលាចារឹកភាសាសំស្ក្រឹត K. 380 នៅប្រាសាទព្រះវិហារ។ សិលាចារឹកប្រាសាទវត្តឯកភ្នំមាន៖

សិលាចារឹក K. 211៖ ចារឹកចារលើមេទ្វារត្បូង ជាភាសាខ្មែរចំនួន ៥ បន្ទាត់ តែបាត់បង់ទៅហើយ តែចារឹកភាសាសំស្ក្រឹតចំនួន ២ បន្ទាត់នៅនឹងកន្លែង។ សិលាចារឹកនេះពិពណ៌នាពីអ្នករៀបចំសាងសង់ប្រាសាទវត្តឯកភ្នំគឺព្រះកម្រតេងអញ ស្រីយោគិស្វរបណ្ឌិត ដែលជាព្រះរាជគ្រូរបស់ព្រះបាទសូរ្យវម៌្ម ទី១។ ព្រះអង្គបានលើកព្រះរាជបុត្រី ឱ្យរៀបអភិសេកជាមួយព្រះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



កម្រតេងអញ ស្រីយោគិស្វរបណ្ឌិត ហើយព្រះរាជគ្រូនេះក៏មានតួនាទីត្រួតពិនិត្យការសាងសង់ប្រាសាទតាកែវនៅអង្គរដែរ។ សិលាចារឹកលើកឡើងពីការស្ថាបនាបូជនីយដ្ឋាន «នរេនទ្រគ្រាម» ស្ថិតនៅក្នុងស្រុកព្រះស្រុក ក្នុងខេត្ត ភិមបុរៈ ដើម្បីតម្កល់ព្រះលិង្គ «សុរិយមេគ្វរ» ដែលព្រះបាទសូរ្យវម៌្ម ទី១ ធ្លាប់បានតម្កល់នៅ «ជយក្សេត្រ» (ប្រាសាទបាសែត)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## ២.១០. ព្រះបាទឧទ័យាទិត្យវម៌្ម ទី២ (១០៥០-១០៦៦)

ក្រោយពីព្រះបាទសូរ្យវម៌្ម ទី១ ចូលទិវង្គត ព្រះបាទឧទយាទិត្យវម៌្ម ទី២ (១០៤៩-១០៦៦) ដែលជាបុត្រច្បងនៃព្រះបាទសូរ្យវម៌្ម ទី១ បានឡើងសោយរាជ្យបន្តឆ្នាំ១០៤៩។ ព្រះអង្គបានតែងតាំងព្រាហ្មណ៍សទាសិវ យេទ្រ្ត បណ្ឌិត ជាបុរោហិត និងបានរៀបរាជាភិសេកជាមួយប្អូនថ្លៃស្រីព្រះអង្គ។ ព្រះអង្គបានសាងប្រាសាទបាពួន ដែលស្ថិតនៅចំកណ្តាលក្រុងអង្គរ ទី២ និងបានសាងប្រាសាទភិម័យ ដែលស្ថិតនៅខាងលើនៃទន្លេមន ក្នុងប្រទេសថៃ។

ប្រាសាទស្តុកកក់ធំ គឺជាប្រាសាទខ្មែរបុរាណ ដែលបច្ចុប្បន្នស្ថិតនៅក្នុងស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ដែលមានទីតាំងចម្ងាយប្រមាណ ២ គម. ពីព្រំដែនខ្មែរថៃ។ ប្រាសាទនេះធ្វើពីថ្មភក់ និងថ្មបាយក្រៀម កសាង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឡើងនៅឆ្នាំ ១០៥២ សម្រាប់ឧទ្ទិសដល់ព្រះឥសូរ ដែលស្ថិតក្នុងរាជ្យព្រះបាទឧទ័យាទិត្យវម៌្ម ទី២ (១០៥០-១០៦៦)។

ប្រាសាទស្តុកកក់ធំ សាងសង់ដោយគ្រួសារមន្ត្រីម្នាក់ ដែលអះអាងថា គេជាកូនចៅជំនាន់ក្រោយ របស់ព្រាហ្មណ៍ "សិវកៃវល្យ" ជាព្រាហ្មណ៍ដ៏ល្បីល្បាញម្នាក់ (កាលពី២៥០ឆ្នាំមុន) ធ្លាប់ធ្វើពិធីទេវរាជ ថ្វាយដល់ព្រះបាទជ័យវម៌្ម ទី២ ក្នុងឆ្នាំ៨០២ នៃគ.ស នៅលើភ្នំមហេន្ទ្របព៌ត (ភ្នំគូលែន)។ នៅក្នុងប្រាសាទនេះមានសិលាចារឹកស្តុកកក់ធំ K.235 ដែលមាន ៣៤០ បន្ទាត់ ចារនៅក្នុងឆ្នាំ ១០៥២គស. ជាពីរភាសា គឺភាសាសំស្ក្រឹត និងភាសាខ្មែរ ដោយបានរៀបរាប់អំពីព្រះនាមរបស់ព្រះមហាក្សត្រខ្មែរ ដែលបានសោយរាជ្យជាបន្តបន្ទាប់គ្នាអស់រយៈកាលជាង ២៥០ឆ្នាំ ពោលគឺចាប់ពីព្រះបាទជ័យវម៌្ម ទី២ នៅស.វទី៩ រហូតដល់រាជ្យព្រះបាទឧទ័យាទិត្យវម៌្ម ទី២ នៅពាក់កណ្តាលសតវត្សទី១១។

## សិលាចារឹកស្តុកកក់ធំ K. 235

មានព្រះបាទបរមេស្វរៈ (ជ័យវម៌្ម ទី២, គ.ស. ៨០២-៨៥០) បានប្រតិស្ឋានបូជាព្រះកម្រតេងជគតរាជ (ព្រះគម្តែង) នៅនគរស្រីមហេន្ទ្របព៌ត (ភ្នំគូលែន)។ ព្រះអង្គបានបញ្ញត្តិឱ្យព្រាហ្មណ៍សិវកៃវល្យ មកពីស្តុកឫស្សីជាអ្នករៀបចំពិធី «ទេវរាជ្យ»។ ព្រះអង្គយាងមកពីជវា មកគ្រងរាជ្យនៅនគរឥន្ទ្របុរៈ (ក្រុងរបស់ព្រះបាទភវវម៌្ម ទី២ គឺបន្ទាយព្រៃនគរ) ហើយព្រាហ្មណ៍ស្តេងអញ សិវកៃវល្យ ដែលជាជីតាអ្នកប្រាជ្ញ (របស់សទាសិវ) ជាព្រះរាជគ្រូជារាជបុរោហិតរបស់ព្រះអង្គ។

បន្ទាប់មកព្រះបាទជ័យវម៌្ម ទី២ មកគ្រងរាជ្យនៅនគរហរិហរាល័យ។ ព្រះអង្គបានយាងទៅសាងនគរអមរេន្ទ្របុរៈ ហើយបានរៀបចំស្រុក «ភវាល័យ»។






*សិលាចារឹកស្តុកកក់ធំ* K. 235 ( *គ.ស. ១០៥២* )



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រះបាទជ័យវម៌្ម ទី២ បានទៅគ្រងរាជ្យនៅនគរមហេន្ទ្របព៌ត។ ព្រាហ្មណ៍ហិរណ្យទាម ជាអ្នកប្រាជ្ញខាងវិទ្យាមន្តអាគម ត្រូវបានអញ្ជើញមកធ្វើពិធីបួងសួងកុំឱ្យ «កម្ពុជទេស»នេះចំណុះជវាទៀយ តាមគម្ពីរព្រះវិនាសិខៈ។ សូមឱ្យមានតែព្រះមហាក្សត្រខ្មែរប៉ុណ្ណោះទើបអាចឡើងជាស្ដេចចក្រពត្តិ (ចក្រវត្តិ)។

ព្រាហ្មណ៍ហិរណ្យទាមបង្រៀនគម្ពីរនោះដល់ព្រាហ្មណ៍សិវកៃវល្យ។ ព្រះបាទជ័យវម៌្ម ទី២ សោយទិវង្គតនៅនគរហរិហរាល័យ។

ព្រះបាទវិស្ណុលោក (ជ័យវម៌្ម ទី៣, ៨៥៤-៨៧៧) បានឡើងសោយរាជ្យនៅហរិហរាល័យ។ ក្មួយព្រាហ្មណ៍សិវកៃវល្យ ឈ្មោះសូក្ស្មវិន្ទុ ធ្វើជាបុរោហិត។

ក្នុងរាជ្យព្រះបាទឦស្វរលោក (ឥន្ទ្រវម៌្ម ទី១, ៨៧៧-៨៨៩) ព្រាហ្មណ៍វាមសិវៈ ចៅស្ដេងអញសិវកៃវល្យ ជាព្រះរាជគ្រូ និងឧបាធ្យាយរបស់ព្រះអង្គ។ ព្រះបាទឦស្វរលោក បានឱ្យព្រាហ្មណ៍វាមសិវៈបង្រៀនព្រះបាទបរមសិវលោក (យសោវម៌្ម) កាលនៅក្មេង។ ស្ដេងអញវាមសិវៈ ជាសិស្សនៃស្ដេងអញសិវសោម ដែលជាព្រះគ្រូព្រះបាទឥន្ទ្រវម៌្ម ទី១។ បន្ទាប់មកព្រះបាទយសោវម៌្ម ទី១ចាត់ចែងសាងនគរស្រីយសោធរបុរៈ ហើយនាំព្រះកម្រតេងជគតរាជ ពីហរិហរាល័យមកទុកនគរនោះ។ ព្រះអង្គបានស្ថាបនាភ្នំកណ្ដាល (ភ្នំបាខែង)។ ស្ដេងអញ ហិរណ្យរុចិ ជាប្អូនកម្រតេងសិវាសោម (គ្រូវាមសិវៈ) ទទួលងារជាប្រធាននៃអាចារ្យ។ ត្រកូលនោះបានផ្ដល់ប្រភពអាចារ្យគ្រប់បែបដល់រាជការក្នុងគ្រប់រជ្ជកាលជាបន្តបន្ទាប់ ខ្លះជាប្រធានអាចារ្យ ខ្លះជាអាចារ្យហោម។

ក្នុងរាជ្យព្រះបាទរុទ្រលោក (ហស៌វម៌្ម ទី១, ៩០០-៩២៣) និងព្រះបាទបរមរុទ្រលោក (ឦសានវម៌្ម ទី២, ៩២៥?-) សមាជិកសន្ដាននោះជាអ្នកបំបួសបូជាព្រះកម្រតេងជគតរាជតរៀងមក។ ព្រាហ្មណ៍ កុមារស្វាមីដែលជាក្មួយសិវាស្រម ជាប្រធានអាចារ្យ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងរាជ្យព្រះបាទបរមសិវបទ (ជ័យវម៌្ម ទី៤, គ.ស. ៩២១-៩៤៤) ទ្រង់បានយាងពីនគរស្រីយសោធបុរៈ ទៅគ្រងរាជនៅចោកគគីរ (កោះកេរ) ហើយបាននាំយកព្រះកម្រតេងជគត តរាជ ទៅជាមួយ។ ស្តេងអញ ឦសានមូរតិ ជាចៅកម្រតេងសិវាស្រម ជាប្រធានអាចារ្យ។ ក្នុងរាជព្រះបាទ ព្រហ្មលោក (ហស៌វម៌្ម ទី២, ៩៤២-៩៤៤) ញាតិសន្តាននោះជាអ្នកបំបួសបូជា ហើយស្តេងអញ អាត្មសិវៈ ដែលត្រូវជាក្មួយស្តេងអញ ឦសានមូតិ ជាបុរោហិត និងជាអាចារ្យហោម។

បន្ទាប់មក ព្រះបាទសិវលោក (រាជេន្ទ្រវម៌្ម ទី២, ៩៤៤-៩៦៦) បានយាងមកគ្រងរាជ្យនៅនគរស្រីយសោធបុរៈ ដោយនាំកម្រតេងជគត តរាជមកវិញផង។ ស្តេងអញ អាត្មសិវៈ ជាបុរោហិត ជាអាចារ្យហោម និងប្រធានគ្រូសារ។

ក្នុងរាជ្យព្រះបាទបរមវីរលោក (ជ័យវម៌្ម ទី៥, គ.ស. ៩៦៨-១០០១) ស្តេងអញសិវាចារ្យ ដែលជាចៅស្តេងអញ អាត្មសិវៈ ជាបុរោហិតនៅកម្រតេងជគត តរាជ និងប្រធានគ្រូសារ។

ក្នុងរាជ្យព្រះបាទបរមនិវ៌ានបទ (សូរ្យវម៌្ម ទី១, ១០០២-១០៥០) បន្ទាប់ពីបានឡើងសោយរាជ្យបានពីរឆ្នាំ ស្តេងអញសិវាចារ្យបានស្ថាបនាព្រះនៅកទ្រុបត្តនៈ និងស្តុកឫស្សី។

ក្នុងរាជ្យព្រះបាទសូរ្យវម៌្ម ទី១ ស្តេងអញ សទាសិវៈ ដែលត្រូវជាក្មួយស្តេងអញសិវាចារ្យ គឺជាបុរោហិត និងជាប្រធានគ្រូសារ។ គាត់ត្រូវព្រះបាទសូរ្យវម៌្មទី១បញ្ជាឱ្យផ្សឹក ដើម្បីរៀបការជាមួយប្អូនស្រីរបស់ព្រះអគ្គមហេសីនាមស្រីវីរលក្ស្មី។ ព្រាហ្មណ៍សិវាចារ្យទទួលគោរមងារជា កំស្តេងស្រីជយេន្ទ្របណ្ឌិត ជារាជបុរោហិត និងជាប្រធានក្រុមរាជការថ្នាក់ទី១។ ព្រាហ្មណ៍សទាសិវៈបានស្ថាបនាព្រះលិង្គនៅស្រុកកទ្រុបត្តនៈ និងថ្វាយទ្រព្យសព្វបែបយ៉ាង ហើយបានទទួលគោរមងារជា ព្រះកម្រងតេងអញ ស្រីជយេន្ទបណ្ឌិត។

នៅពេលព្រះបាទឧទយាទិត្យវម៌្ម ទី២ (១០៥០-១០៦៦) ឡើង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សោយរាជ្យ ក្រុមញាតិរបស់សទាសិវៈ ជាអ្នកបំបួសព្រះកម្រតេងជគតរាជតរៀងមក។ ព្រះកម្រង់តេងអញ ស្រីជយេន្ទ្របណ្ឌិតជាព្រះរាជគ្រូបានទទួលងារជា ធូលីជើងព្រះកម្រតេងអញ ស្រីជយេន្ទ្រវម៌្ម។ ព្រះរាជារៀនទូវវិជ្ជាចាប់ពី សិទ្ធាន្ត ព្យាករណ៍ ធម្មសាស្ត្រ រហូតដល់សាស្ត្រដទៃទៀត។ ព្រះអង្គរៀបចំពិធីទិក្សា បញ្ចប់ការសិក្សា និងប្រទានរង្វាន់ជាទ្រព្យសម្បត្តិជាច្រើនដល់ព្រះរាជគ្រូ។ ព្រះបាទកម្រតេងកំតួនអញស្រី ឧទយាទិត្យវម៌្ម ទី២ តែងតែលើកកិត្តិយសព្រះរាជគ្រូជានិច្ច។

## សិលាចារឹកនគររាជ K. 1185

សិលាចារឹក K.1158 ចារក្នុងឆ្នាំ១០៦៦ នៃគ្រិស្តសករាជ លើថ្មកក់ជាលក្ខណៈសីមា ដែលគេរកឃើញនៅខេត្តនគររាជ ប្រទេសថៃ( សិលាចារឹក Sap Bak)។ លោក George Cœdès បានសិក្សា និងផ្សាយក្នុងសៀវភៅ Inscriptions du Cambodge របស់គាត់។ សិលាចារឹកនេះមាន ៣៦ បន្ទាត់៖ ៣០ បន្ទាត់ដំបូងចារជាភាសាសំស្ក្រឹត និង៦បន្ទាត់បន្ទាប់ចារជាភាសាខ្មែរចាស់។ សារសំខាន់នៃសិលាចារឹកនេះគឺ៖

ទីមួយ- ប្រយោគជាភាសំស្ក្រឹតមានអត្ថន័យយ៉ាងខ្លាំងសម្រាប់ខ្មែរគ្រប់រូប៖ «ចេត្តលំមេស្តិ បុណ្យានាំ ជាតោហំកម្ពុជេទ្រុតមិ» ដែលមានន័យ ថា៖ «ប្រសិនបើខ្ញុំនឹងទទួលបានផលបុណ្យមែន ខ្ញុំប្រាថ្នាកើតនៅកម្ពុជាទៀត»។



ចេត្តលំមេស្តិបុណ្យានាំជាតោហំកម្ពុជេទ្រុតម

ទីពីរ- នៅក្នុងសិលាចារឹក K-1158 នេះ យើងឃើញមានការប្រើពាក្យ កម្ពុជ ( កម្ពុជា) និង ពាក្យ ស្រុក៑ខ្មេរ ( ស្រុកខ្មែរ)។



សិលាចារឹកនគរពជ K. 1185

## ២.១១. ព្រះបាទហស៌វម្ម័ ទី ៣ ( ១០៦៦-១០៨០ )

ក្រោយពីព្រះបាទ ឧទយាទិត្យវម្ម័ ទី២ សោយទិវង្គត ព្រះបាទហស៌វម្ម័ ទី៣ (គ.ស ១០៦៦-១០៨០) ដែលជាព្រះអនុជ និងជាបុត្រពៅនៃព្រះបាទ សូរ្យវម្ម័ ទី១ បានឡើងសោយរាជនៅគ.ស ១០៦៦។ ព្រាហ្មណ៍ ទិវាករបណ្ឌិត បានបំពេញតួនាទីជាអាចារ្យប្រធាននៅប្រាសាទព្រះវិហារ។ រាជកិច្ចរបស់ព្រះអង្គផ្តោតលើការជួសជុលប្រាសាទ និងការរៀបចំប្រទេសឱ្យមានសណ្តាប់ធ្នាប់ និងវិបុលភាព។ នៅចុងរជ្ជកាលរបស់ព្រះអង្គ ចម្ប៉ាបានវាយចូលមកដល់ក្រុងសម្ពុបុរៈ នៅរវាងឆ្នាំ១០៧៤ និង ១០៨០ ហើយកេណ្ឌរាស្ត្រ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ខ្មែរជាឈ្លើយសឹកទៀតផង។ ព្រះអង្គសោយទិវង្គតនៅឆ្នាំ ១០៨០ ហើយទទួលមរណនាមថា សទាសិវបទ។

ព្រះរាជាដែលឡើងគ្រងរាជ្យស្នងព្រះបាទ ហស៌វម៌្ម ទី៣ ព្រះនាម ព្រះបាទនព្វបតីន្ទ្រវម៌្ម(គ.ស១០៨០-១១១៣)។ក៏ប៉ុន្តែសិលាចារឹកបង្ហាញថា នៅក្នុងពេលជាមួយគ្នានោះ មានព្រះរាជាមួយអង្គទៀតដែលសោយរាជ្យនៅក្រុង មហីធរបុរ ដែលប្រហែលជានៅត្រង់វាលទំនាបខាងលើនៃទន្លេមូល។ ចាប់ពីពេលនេះមក គឺជាការពង្រឹងអំណាចនៃរាជវង្ស មហីធរបុរ។

នៅក្នុងរជ្ជកាលព្រះអង្គ មានសិលាចារឹកចំនួន ៣៥៖ ៩ ជាភាសាសំស្ក្រឹត, ២០ ជាភាសាខ្មែរ និង ៦ ជាភាសាសំស្ក្រឹតនិងជាភាសាខ្មែរ។ សិលាចារឹកទាំងនេះមាននៅសៀមរាប, ពោធិសាត់, បន្ទាយមានជ័យ, បាត់ដំបង, តាកែវ, ព្រះវិហារ, កំពង់ធំ, កំពង់ចាម, ព្រៃវែង, កណ្តាល, ស្វាយរៀង, ចំប៉ាសាក់, និងបុរីរាំ។

## ២.១២. ព្រះបាទជយវម៌្ម ទី ៦ នៃរាជវង្ស មហីធរបុរ (១០៨០-១១៦០)

សិលាចារឹកភ្នំរុងបង្ហាញថា ព្រះរាជាមួយអង្គទៀតដែលសោយរាជ្យនៅក្រុង មហីធរបុរ នៅពេលដែលព្រះបាទ នព្វបតីន្ទ្រវម៌្ម សោយរាជ្យនៅអង្គរមានព្រះនាមថាព្រះបាទជ័យវរ្ម័ន ទី ៦។ ព្រះអង្គមិនមែនជាញាតិជាមួយរាជវង្សមុនទេ គ្រាន់តែជាបុត្រស្តេច ហិរណ្យវម៌្ម និងព្រះនាង ហិរណ្យលក្ស្មី។ ដូច្នេះ នៅពេលតែមួយមានស្តេចពីរអង្គសោយរាជ្យ មួយនៅអង្គរ និងមួយទៀតនៅ មហីធរបុរ។

ពិធីអភិសេកព្រះបាទជ័យវរម៌្ម ទី៦ (គ.ស. ១០៨០-១១០៧) ប្រារព្ធឡើង ដោយព្រាហ្មណ៍ ទិវាករបណ្ឌិត ដែលត្រូវបានតែងតាំងជាព្រះគ្រូ ដើម្បីពិធីអភិសេកនេះ ហើយបានបម្រើព្រះអង្គក្នុងរយៈពេល៤០ឆ្នាំ។ ព្រះបាទ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជ័យវម៌្ម ទី៦ បានផ្តល់គោរមងារដល់ព្រាហ្មណ៍ ទិវាករបណ្ឌិត ជា កគវតបាទ កម្រតេងអញតគុរុ ស្រី ទិវាករបណ្ឌិត។ ព្រាហ្មណ៍នេះមានតួនាទីជាអ្នកជួសជុល និងសាងសង់ប្រាសាទ និងចែកអំណោយដល់ប្រាសាទជាទីសក្ការៈនានា។ ព្រះបាទជ័យវម៌្ម ទី៦ បន្តកសាងប្រាសាទព្រះវិហារ និងប្រាសាទដទៃទៀត ដូចជាប្រាសាទភ្នំសណ្តុក វត្តភូ និងភិម៉ៃ(ខាងព្រះពុទ្ធសាសនា)។ ព្រះបាទជ័យវម៌្ម ទី៦ទទួលមរណនាមថា បរមកៃវល្យបទ។ ក្នុងរជ្ជកាលព្រះអង្គមានសិលាចារឹកតែ ៩ ប៉ុណ្ណោះ៖ ២ ជាភាសាសំស្ក្រឹត និង ៧ ជាភាសាខ្មែរ នៅខេត្តសៀមរាប(ប្រែរូប) នៅកំពង់ចាម(បោសព្រះនន្ទ) និងតាកែវ(ភ្នំដា)។

## ២.១៣. ព្រះបាទធរណីន្ទ្រវម៌្ម ទី១ (១១០៧-១១១២)

ព្រះបាទ ធរណីន្ទ្រវម៌្ម ទី១ ឡើងសោយរាជ្យ ក្រោយពីព្រះរៀមច្បងព្រះអង្គព្រះបាទ ជ័យវម៌្ម ទី៦ បានសោយទិវង្គត។ ព្រះបាទធរណីន្ទ្រវម៌្ម ទី១ មិនបានសោយរាជ្យនៅអង្គរទេ។ ព្រះបាទធរណីន្ទ្រវម៌្ម ទី១ បានបញ្ជាឱ្យព្រាហ្មណ៍ ទិវាករបណ្ឌិត ចែកអំណោយនៅតាមបណ្តាប្រាសាទនានា។ ព្រះអង្គបានរៀបអភិសេកជាមួយព្រះនាង វិជយេន្ទ្រលក្ស្មី ដែលជាអតីតអគ្គមហេសីរបស់ព្រះបាទ ជ័យវម៌្មន ទី៦។

នៅក្នុងរជ្ជកាលព្រះបាទធរណីន្ទ្រវម៌្ម ទី១អង្គរនៅបន្តស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះរាជាមួយអង្គទៀត គឺព្រះបាទ នឫបតីន្ទ្រវម៌្ម។ ព្រះអង្គមានមរណនាមថា បរមនិស្កលបទ បន្ទាប់ពីសោយទិវង្គត ដោយសារចៅមីងព្រះអង្គ សូរ្យវម៌្ម ទី២ ធ្វើគតដណ្តើមរាជ្យ។

នៅក្នុងរជ្ជកាលព្រះបាទ ធរណីន្ទ្រវម៌្ម ទី១ មានសិលាចារឹកចំនួន ៦៖ ១ ជាភាសាសំស្ក្រឹត, ៤ ជាភាសាខ្មែរ និង ១ ជាភាសាសំស្ក្រឹតនិងជាភាសាខ្មែរ។ សិលាចារឹកទាំងនេះមាននៅសៀមរាប, តាកែវ (ភ្នំបយ៉ង្កោ), ព្រះវិហារ (ភ្នំសណ្តុក), និងនគររាជសីមា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# រចនាបថ បាពួន (១៣)

ស្ថាបត្យកម្មខ្មែរនៅពាក់កណ្តាល និងចុងសតវត្សទី ១១ ដែលជារចនាបថបាពួន បានឈានដល់កម្រិត កំពូលនៃការសាងសង់ប្រាសាទ-ភ្នំ ដែលខ្ពស់ចោត។ ប្រាសាទបាពួនមានថែវធ្វើពីថ្មកក់ព័ទ្ធជុំវិញប្រាង្គកណ្តាល មានកំផែង និងគោបុរៈជាច្រើន និងមានវិមានដែលសង់នៅតាមជ្រុង។ យើងសង្កេតឃើញថាមិនសូវមានការវិវត្តនៃក្បូរក្បាច់រចនាប៉ុន្មានទេ។ នៅក្នុងរចនាបថបាពួន លែងមានរាហូខ្ចាក់ស្ទឹកឈើហើយ។ ក៏ប៉ុន្តែអ្វីដែលថ្មីនោះ គឺផ្តែរទ្វារនៃរចនាបថបាពួនបង្ហាញពីទេវកថាឥណ្ឌា ដូចជារឿងរាមកេរ្តិ៍ជាដើម ចំណែកឯលើផ្តែហោជាងវិញ មានរចនាក្បូរក្បាច់ស្ទឹកឈើយ៉ាងស្រស់បំព្រង ហើយលែងមានក្បាលរាហូទៀតហើយ ដែលឆ្លុះបញ្ចាំងពីការត្រឡប់ទៅរកធម្មជាតិវិញ។

ហោជាងនៃប្រាសាទបាពួនមានពីរជាន់។ ជាន់ខាងមុខលម្អដោយនាគរាជក្បាលប្រាំ ដែលធ្លាក់នៅគែមហោជាង ដែលមានកន្ទុយជាប់គ្នានៅត្រង់កំពូលជ្រុងលើនៃហោជាង។ នៅលើខ្លួននាគរាជមានលម្អដោយក្បាច់រុក្ខជាតិរាងស្រួចៗ។ នៅកណ្តាលហោជាងមានលម្អដោយក្បាច់ភ្ញី រុក្ខជាតិដ៏ស្រស់បំព្រង។ ហោជាងជាន់ទីពីរលម្អ ដោយនាគរាជផងដែរ ហើយនៅលើខ្លួននាគរាជមានលម្អដោយក្បាច់រុក្ខជាតិរាងស្រួចៗផងដែរ។ រចនាបថរបស់ហោជាងនេះ យើងហៅថាជារចនាបថបាពួន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia





ចារឹកប៉ាលហាល K. 449 ( សវ ទី១១ )





ចារឹកវត្តព្រះធាតុ ទឹកផា K. 702 ( សវ ទី១១ )



## ២.១៤. ព្រះបាទសូរ្យវម៌្ម ទី២ (១១១៣-១១៥០)

ព្រះបាទសូរ្យវម៌្ម ទី២ ឡើងសោយរាជ្យ ដោយបង្រួបបង្រួមអាណាចក្រពីរគឺៈ (១) អាណាចក្ររបស់ព្រះបាទ ធរណីន្ទ្រវម៌្ម ទី១ និង (២) អាណាចក្ររបស់ព្រះបាទ នឫបតីន្ទ្រវម៌្ម ដែលបានសោយរាជ្យនៅអង្គរតាំងតែពីគ.ស. ១០៨០ មកម្ល៉េះ។ ព្រះបាទ សូរ្យវម៌្ម ទី២ ត្រូវបានរៀបចំអភិសេកដោយព្រាហ្មណ៍ ទិវាករបណ្ឌិត នៅឆ្នាំ ១១១៣។

ព្រះបាទសូរ្យវម៌្ម ទី២ បានបន្តការស្ថាបនាប្រាសាទព្រះវិហារ ប្រាសាទភ្នំជីសូរ្យ ប្រាសាទភ្នំសណ្តក និងប្រាសាទវត្តភូ។ ចំណែកសំណង់ថ្មី ព្រះអង្គបានកសាងប្រាសាទព្រះពិធូរ ប្រាសាទចៅសាយទេវតា ប្រាសាទធម្មានន្ទ ប្រាសាទបន្ទាយសំរែ និង ប្រាសាទអង្គរវត្ត ដែលជាស្នាដៃស្ថាបត្យកម្មខ្មែរសម្រាប់តម្កល់ព្រះវិស្ណុបដិមា ដែលមានព្រះបរមនាមថា បរមវិស្ណុលោក។

នៅក្នុងរជ្ជកាលព្រះបាទសូរ្យវម៌្ម ទី២ មានសិលាចារឹកចំនួន ១០ៈ ៣ ជាភាសាខ្មែរ និង ៧ ជាភាសាសំស្រ្កឹតនិងជាភាសាខ្មែរ។ សិលាចារឹកទាំង



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នេះមាននៅសៀមរាប, ព្រះវិហារ, បាត់ដំបង, ចំប៉ាសាក់ (វត្តភូ), និងតាកែវ (ភ្នំជីសូរ្យ)។

## រចនាបថ អង្គរវត្ត (១៤)

នៅចុងសតវត្សទី ១១ និងពាក់កណ្ដាលទីមួយនៃសតវត្សទី ១២ ស្ថាបត្យកម្មខ្មែរបានឈានដល់កម្រិតកំពូលហើយ បន្ទាប់ពីមានការវិវត្តក្នុងរយៈពេល ៩០០ ឆ្នាំមក ជាស្នាដៃស្ថាបត្យកម្ម និងសំណង់ ដែលគួរឱ្យរំភើបស្ញប់ស្ញែងក្រៃលែង។ ប្រាសាទទាំងអស់នៃរចនាបថ អង្គរវត្តសុទ្ធតែសាងសង់ឡើងដោយប្រើថ្មភក់ទាំងអស់ ពី គ.ស. ១.១០០ ដល់ គ.ស. ១.១៧៥។

នៅប្រាសាទអង្គរវត្ត ទីព្រលាន សាជី គោបុរៈ និងក្លោងទ្វារចូលកំពូលប្រាង្គប្រាសាទកណ្ដាល កំពែងថែវ និងបណ្ណាល័យបង្ហាញពីស្នាដៃដ៏អស្ចារ្យនៃស្ថាត្យកម្មខ្មែរបុរាណនិយម ដោយមានការបូកផ្សំគ្នារវាងប្រាសាទសាជីនិងប្រាសាទសង់ផ្ទាល់ដី។ បុព្វបុរសខ្មែរបានប្រើប្រាស់នូវបទពិសោធក្នុងការកសាងប្រាសាទបុរាណពីពេលមុន ដើម្បីរចនាលម្អ ផ្តែរទ្វារ សសរពេជ្រ ហោជាង សសរទ្រូ និង ទ្វារបញ្ឆោតឱ្យដល់កម្រិតកំពូល។

ផ្ដែរទ្វារ និងរូបចម្លាក់សម័យអង្គរវត្តបានផ្តល់តម្លៃទៅលើមនុស្ស និងភាពសុខុដុមរមនារវាងមនុស្សធម៌ និងវប្បធម៌។ ផ្ដែរទ្វារនៃរចនាបថអង្គរវត្តមានពីរប្រភេទ គឺផ្ដែរដែលគ្មានក្បាច់មែកឈើផ្ដេក និង ផ្ដែរដែលមានក្បាច់មែកឈើបាក់ជាកំណាត់ ៗ (រូបខាងក្រោម)។

## សិលាចារឹកភ្នំជីសូរ្យ K.32 (ឆ្នាំ ១១១៦)

សិលាមូលស្ថាបនា K.32៖ ចារឹកត្រូវបានតម្កល់នៅក្នុងប្រាង្គធំនៃប្រាសាទភ្នំជីសូរ្យ ហើយត្រូវបានលោក Aymonier រកឃើញ។ ចារឹកសរសេរ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាភាសាសស្រ្កឹតមាន ១០ បន្ទាត់ (៥ ស្លោក) ចាប់ផ្តើមពីសញ្ញាអូម ៩ បន្ទាត់កន្ទះ ជាភាសាខ្មែរ និង ១បន្ទាត់កន្ទះជាភាសាសំស្រ្កឹត ។ នៅមហាសករាជ ១០៣៨ (គ្រិស្តសករាជ ១១១៦) ព្រះគម្តែង ភ្នំហែក (ភិន្ទាចល) ដែលជាតាបសរបម្រើព្រះរាជា បានទៅធ្វើធម៌នៅអាស្រម កល្យាណាស្រម ហើយបានឱ្យតង្វាយជាខ្ញុំ និងដីដល់កម្រតេង ជគត ស្រីសូរ្យបព៌ត (ទេពភ្នំជីសូរ្យ)។ អ្នកណាដែលធ្វើឱ្យអន្តរាយដល់តង្វាយទាំងនេះ នឹងត្រូវបរាជ័យក្នុងលោកទាំងពីរ។ ដីទាំងនោះគឺៈ ស្រុកត្រពាំងជ្វិក និងដីស្រែភូមិបន្ទាចដាយ ស្រែនៅក្រោមអូក និងស្រែខ្សាច់។



n. 1 / K. 32

## ២.១៥. ព្រះបាទធរណីន្ទ្រវម៌្ម ទី២ យសោវម៌្ម ទី២ (១១៥២-១១៦៥)

ព្រះបាទធរណីន្ទ្រវម៌្ម ទី២ ដែលជាប្អូនជីដូនមួយបានឡើងស្នងរាជ្យពីព្រះបាទសូរ្យវម៌្ម ទី២។ ព្រះបាទ ធរណីន្ទ្រវម៌្ម ទី២ គោរពព្រះពុទ្ធសាសនាមហាយាន។ ព្រះអង្គមានអគ្គមហេសីព្រះនាម ចូឌាមណិ ដែលជាបុត្រីព្រះបាទហស៌វម៌្ម ទី៣។

នៅឆ្នាំ ១១២៥ ព្រះអគ្គមហេសីបានប្រសូត្របុត្រមួយអង្គព្រះនាម ជយវធ៌ន ដែលជាអនាគតព្រះបាទជយវម៌្ម ទី៧។

ព្រះរាជាដែលឡើងស្នងរាជ្យពីព្រះបាទធរណីន្រ្ទវម៌្ម ទី២ ព្រះនាមព្រះបាទយសោវម៌្ម ទី២។ នៅឆ្នាំ ១១៦៥ មន្រ្តីជាន់ខ្ពស់ម្នាក់បានជ្រែករាជ្យព្រះបាទយសោវម៌្ម ទី ២ ដោយមាននាមថាព្រះបាទ ត្រិភូវនាទិត្យវម៌្ម។

ព្រះអម្ចាស់ ជយវម៌ន ដែលកំពុងនៅចម្ប៉ាបានមកជួយសង្រ្គោះ តែជួយមិនទាន់ដោយសារតែព្រះបាទយសោវម៌្មទី២ត្រូវបានធ្វើគតទៅហើយ។

នៅឆ្នាំ ១១៧៧ ស្តេចចាមនាម ជយឥន្រ្ទវម៌្ម ទី៤ បានលើកទ័ពជើងទឹកវាយចូលអាណាចក្រខ្មែរ តាមដងទន្លេមេគង្គ ឡើងរហូតដល់បឹងទន្លេសាប និងវាយយករាជធានីអង្គរបាន។

នៅក្នុងរជ្ជកាលព្រះបាទ ត្រិភូវនាទិត្យវម៌្មមានសិលាចារឹកតែបីប៉ុណ្ណោះ គឺ៖ K. 418, K. 966, K. 1219។

## ២.១៦. ព្រះបាទត្រិភូវនាទិត្យវម៌្ម (១០៦៥-១១៧៧)

នៅឆ្នាំ ១១៦៥ មន្រ្តីជាន់ខ្ពស់ម្នាក់បានជ្រែករាជ្យព្រះបាទយសោវម៌្ម ទី ២ ដោយមាននាមថា ព្រះបាទត្រិភូវនាទិត្យវម៌្ម។

ព្រះអម្ចាស់ ជយវម៌ន ដែលកំពុងនៅចម្ប៉ាបានមកជួយសង្រ្គោះ តែជួយមិនទាន់ដោយសារតែព្រះបាទ យសោវម៌្ម ទី២ត្រូវបានធ្វើគតទៅហើយ។

នៅឆ្នាំ ១១៧៧ ស្តេចចាមនាម ជយឥន្រ្ទវម៌្ម ទី៤ បានលើកទ័ពជើងទឹកវាយចូលអាណាចក្រខ្មែរ តាមដងទន្លេមេគង្គ ឡើងរហូតដល់បឹងទន្លេសាប និងវាយយករាជធានីអង្គរបាន។

នៅក្នុងរជ្ជកាលព្រះបាទ ត្រិភូវនាទិត្យវម៌្ម មានសិលាចារឹកតែបីប៉ុណ្ណោះ គឺ៖ K. 418, K. 966, K. 1219។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## ២.១៧. ព្រះបាទជ័យវម៌្ម ទី៧(១០៨១-១២១៨)

ព្រះបាទជ័យវម៌្ម ទី៧ គឺជាព្រះរាជាដែលបានរំដោះអាណាចក្រខ្មែរពីចម្ប៉ាឱ្យមានឥស្សរភាពឡើងវិញ។ ព្រះអង្គជាបងប្អូនជីទួតមួយជាមួយព្រះបាទសូរ្យវម៌្ម ទី២ និងបានរៀបរាជាភិសេកជាមួយព្រះនាងជ័យរាជទេវីមុនឡើងគ្រងរាជ្យ។

ព្រះអង្គជាមេទ័ពទៅវាយប្រទេសចាមនៅវិជ័យ។ នៅពេលដែលព្រះបិតាព្រះអង្គព្រះបាទ ធរណីន្ទ្រវម៌្ម ទី២ សោយទិវង្គត ព្រះអង្គស្ថិតនៅចម្ប៉ានៅឡើយ។ នៅឆ្នាំ ១១៦៥ បន្ទាប់ពីទទួលបានដំណឹងថា មានមន្ត្រីជាន់



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ខ្ពស់ម្នាក់បានជ្រែករាជ្យ ព្រះបាទយសោវម៌្ម ទី២ ហើយឡើងគ្រងរាជ្យ ដោយមាននាមថាព្រះបាទ ត្រិភូវនាទិត្យវម៌្ម ព្រះបាទជ័យវម៌្ម ទី៧ ក៏យាងត្រឡប់មកអង្គរវិញ។ តែចម្ប៉ាបានវាយកាន់កាប់អង្គរបាននៅឆ្នាំ ១១៧៧។

បន្ទាប់ពីរំដោះប្រទេសពីចម្ប៉ា ព្រះបាទជ័យវម៌្ម ទី៧ទទួលរាជាភិសេក និងឡើងសោយរាជ្យនៅ យសោធរបុរៈ នៅគ.ស.១១៨១ នៅពេលដែលព្រះអង្គមានព្រះជន្មាយុ ៥០ ព្រះវស្សា ។

ព្រះអង្គបានរៀបចំរាជធានីឡើងវិញ ដោយស្ថាបនាកំពែង និងគូទឹកព័ទ្ធជុំវិញរាជធានី អង្គរទី៣ ឬ អង្គរធំ។

ព្រះបាទជ័យវម៌្ម ទី៧ គឺជាដែលបានសាងសង់ប្រាសាទជាច្រើន។ អង្គរទី៣ គឺជារាជធានី ដែលមានកំពែង និងគូទឹកព័ទ្ធជុំវិញ មានគោបុរៈ៥ និងមានប្រាសាទបាយ័ន នៅចំកណ្តាល។ ព្រះអង្គបានសាងសង់៖ ប្រាសាទបន្ទាយក្តី (បរិតជាគត), ប្រាសាទតាព្រហ្ម (រាជវិហារ), ប្រាសាទព្រះខ័ន (ជ័យស្រី), ប្រាសាទនាគព័ន្ធ (រាជ្យស្រី), តាសោម, ក្រោលគោ, បន្ទាយឆ្មារ, វត្តនគរ (កំពង់ចាម), តាព្រហ្ម (បាទី), ដែលមានប្រាង្គមុខបួន តំណាងលោកេស្វរៈ។

នៅក្នុងរជ្ជកាលព្រះបាទ ជ័យវម៌្ម ទី៧ មានសិលាចារឹកចំនួន ១១២៖ ២៨ ជាភាសាសំស្រ្កឹត, ៨៣ ជាភាសាខ្មែរ និង ១ ជាភាសាសំស្រ្កឹតនិងជាភាសាខ្មែរ។ សិលាចារឹកទាំងនេះនៅ៖ (១) បាយ័ន ចំនួន ៧ (២) ព្រះខ័ន ចំនួន ៣៤ (៣) តាព្រហ្មចំនួន ៣ (៤) ភិមានអាកាសចំនួន ២ (៥) បន្ទាយឆ្មារចំនួន ៥ (៦) អង្គរធំចំនួន ៣ (៧) សាយហ្វុង វៀងច័ន្ទ (៨) ភិម័យ (៩) ប្រាជិនបុរី និងនៅកន្លែងផ្សេងទៀត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# រចនាបថ បាយ័ន (១៥)

លក្ខណៈពិសេសនៃរចនាបថបាយ័ន នៅសតវត្សទី ១៣ គឺការសាង សង់ប្រាសាទដែលកំពូលមានមុខបួន ដែលជាតំណាង លោកេស្វរៈ ដែល ជាតក្កកម្មខាងផ្នែកស្ថាបត្យកម្មផង និងខាងផ្នែកសំណង់ផង ដែលយើង អាចចាត់ទុកថាជារូបចម្លាក់ដ៏ធំធេងនៅក្នុងសិល្បៈខ្មែរ ដែលផ្សារភ្ជាប់ទៅ នឹងជំនឿសាសនា។ សមិទ្ធផលដ៏ធំធេងមួយទៀត នៃរចនាបថបាយ័ន គឺការ សង់កំពែងថ្មបាយក្រៀម និងគូទឹកព័ទ្ធជុំវិញរាជធានីអង្គរធំ មានគោបុរៈ ចំនួន ៥ ដែលមានទទឹង ៣ គីឡូម៉ែត្រ និងបណ្ដោយ ១២ គីឡូម៉ែត្រ។ ប្រការនេះ គឺជាលើកទីមួយហើយដែល ព្រះមហាក្សត្រខ្មែរសង់កំពែងដើ ម្បីការពារក្រុងពីសត្រូវឈ្លានពាន។

តក្កកម្មនៃរចនាបថបាយ័ន គឺការសង់ប្រាង្គប្រាសាទបាយ័ន ដែលជា ស្នាដៃដ៏វិសេសវិសាលនៃបុព្វបុរសខ្មែរ។ ប្រាង្គកណ្ដាលនៃប្រាសាទបាយ័ន មានរាងមូល សម្រាប់តម្កល់បដិមាពុទ្ធរាជ្យមួយអង្គ ដែលមានកម្ពស់ជិត ៤ ម៉ែត្រ ហើយឆ្លុះបញ្ចាំងពីការចម្រើនលូតលាស់ និងភាពល្បីល្បាញខ្ចរខ្ចារ សុសសាយនៃលោកេស្វរៈ ដែលបែរមុខទៅទិសទាំង ៨ ដើម្បីសម្ដែងនូវ មេត្តាធម៌ដល់រាជធានី អាណាចក្រ ពិភពលោក និងចក្រវាឡទាំងមូល។ ប្រាសាទនៃរចនាបថបាយ័នឆ្លុះបញ្ចាំងពីតម្លៃបែបអរូបិយនៃសិល្បៈខ្មែរ ដោយឈរលើមូលដ្ឋាននៃគំរូតែមួយ ដោយរក្សានូវសមតាបានល្អឥតខ្ចោះ។



ផ្ដែរនៃរចនាបថបាយ័ន សតវត្សទី១៣ ប្រាសាទបាលីឡៃ




បក្រកពអង្គរនៅសតវត្សទី១១-១២



## ប្រាសាទបន្ទាយឆ្មារ

ប្រាសាទបន្ទាយឆ្មារ គឺជាបន្ទាយនៃបណ្តុំប្រាសាទដែលស្ថិតនៅលើអក្សរកើត-លិច ដែលមានទ្វារចូល៤ និងមានប្រាសាទ និងរបងខ្សែក្រវ៉ាត់ប្រាំជាន់ ទើបដល់ប៉មកណ្តាល។ ប្រាសាទបន្ទាយឆ្មារព័ទ្ធជុំវិញដោយគូទឹកទទឹងប្រវែង ៦ ម៉ែត្រ សាងសង់តាមរចនាបថបាយ័ន ដោយមានប៉ម ដូចនៅអង្គរធំ និងនៅប្រាសាទបាយ័នដែរ។ ប្រាសាទបន្ទាយឆ្មារសាងសង់លើផ្លូវពីអង្គរ ទៅប្រាសាទភិម័យ។ ក៏ប៉ុន្តែ សំណង់នៅប្រាសាទបន្ទាយឆ្មារមានតែនៅក្នុងគោបុរៈពីទី១ ដល់ទី៣ ប៉ុណ្ណោះ។

សិលាចារឹក K. 227៖ នៅគោបុរៈទី២ ទ្វារចូលខាងកើតនៃប៉មកណ្តាលនៃក្រុមប្រាសាទខាងកើត មេទ្វារត្បូង ជាភាសាខ្មែរ មាន ២៣+៦ បន្ទាត់។ ចារនៅចុងសតវត្សទី១២-ដើមសតវត្សទី១៣។ សិលាចារឹកនេះត្រូវបានឈ្មួញលក់នៅប្រទេសថៃ ហើយត្រូវអាជ្ញាធរថៃរឹបអូស និងប្រគល់មកកម្ពុជាវិញ។[53] នាពេលបច្ចុប្បន្នសិលាចារឹកនេះត្រូវបានតម្កល់ទុកនៅសារមន្ទីរជាតិនៃទីក្រុងភ្នំពេញ។

## សិលាចារឹកបន្ទាយឆ្មារ K. 227

សិលាចារឹក K. 227៖ សិលាចារឹកនេះចែកចេញជាពីរផ្នែក៖ (១) ផ្នែកទីមួយមាន ៦ បន្ទាត់និយាយពីព្រះនាម និងទីតាំងនៃរូបចម្លាក់ទេពនៅក្នុងប្រាង្គកណ្តាល (santuaire) (២) ផ្នែកទីពីរនិយាយពីព្រឹត្តិការណ៍គ្មានបរិច្ឆេទមួយ ដែលប្រហែលជាកើតឡើងនៅឆ្នាំ ១១៦០ មុនព្រះបាទជ័យវម៌្ម ទី៧ ឡើងសោយរាជ្យ ដែលនៅពេលនោះព្រះបាទយសោវម៌្ម ទី២ នៅគ្រងរាជ្យនៅឡើយ។ ព្រឹត្តិការណ៍ទី១ ភរត រាហូ បានវាយប្រឆាំង

53. វង់ សុធារ៉ា ២០១៦



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



*សិលាចារឹកបន្ទាយឆ្មារ K. 227 ចុងសតវត្សទី១២ ដើមសតវត្សទី១៣*

ព្រះបាទ យសោវម៌្ម ទី២ ហើយហៀបនឹងដណ្តើមបានព្រះរាជវាំង។ អ្នកអម្ចាស់ គ្រិទ្រកុមារ បានទៅជួយព្រះអង្គទាន់ ហើយបានផ្តួល ករត រាហូ បានតែមានសេនាបតីយោធាពីររូប (សញ្ជក) ត្រូវបាត់បង់ជីវិត។ អ្នកទាំងពីរទទួលបាននូវគោរមងារបច្ឆាមរណៈ។[54] ព្រឹត្តិការណ៍ទី២ គឺការធ្វើសឹកនៅចម្ប៉ា ដើម្បីវាយស្តេចចាម ជ័យឥន្ទ្រវម៌្មទី៤។ អ្នកអម្ចាស់ គ្រិទ្រកុមារ ស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ដូចគ្នា ហើយសេនាបតីយោធាពីររូបបានបាត់

54. Cœdès, 1929



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង់ជីវិត និង ទទួលបាននូវគោរមងារជាកិច្ចបច្ឆាមរណៈ ។[55]

(១) ០ អាគ្នេយកម្រតេង៍ជគតអជ៉ុនទេវ០

(២) ០ ឦសានកម្រតេង៍ជគតគ្រីធរទេវបុរទេវ០

(៣) ០ នៃឫតីកម្រតេង៍ជគតគ្រីទេវទេវ០

(៤) ០ វាយវ្យកម្រតេង៍ជគតគ្រីវទ្ធនទេវវស្សង៍មន្ត្រី០

(១) ០ នាករតេរាហុសំវុទ្ធិទ្រោហតវ្រះបាទគ្រីយគោវម្ម៌ទេ

(២) វ បិថ្ងៃង៍ចបវ្រះមន្ទិរ ឥសវលេនគរផោង៍បង្បិតយក

(៣) ន្តាលមត្តវាររតឥស្ស ស្តចថ្ងៃង៍ច្បង៍អញនក្សញ្ញកអជ៉ុនអ្ន

(៤) ក្សញ្ញកគ្រីធរទេវបុរ ច្បង៍ករសំតចស្បង្គ័តួលតោយវ្ន

(៥) ក ស្តចផ្ទលមុះផ្ទលករតេរាហុ ចំន្យររផ្សង្នៃប្រេឱយនាមវ្រះកំ

(៦) ម្រតេង៍អញគ្រីនបសិទ្ធវម្ម៌អញនក្សញ្ញកទេវបុរតេជាបុ

(៧) ត្រអ្នក្សញ្ញកគ្រីធរទេវបុរ ឱយនាមអំតេង៍តអ្នក្សញ្ញក្តវ្យរ

(៨) ស្អាបនារូបឥសកុសលបក្សផោង៍ ស្តចប្រកោប្យំបតនុក្រម០

(៩) ០ នាស្តចទៅទ្វីបចាម្បតបូវ្វិកាលស្រេច ស្តចចបទុគ្គិតិកុរុង៍

(១០) ចាម្បតជ្មោះគ្រីជយឥន្ទ្រវម្ម៌ប្រេថ្ងៃលេវ្នំចេត្តតាង៍ ស្តចវិង្សេរ

(១១) សេនាបតិចាម្ប ទំនេប្រក្វល្ប្កាយាង៍មហាតាល នាំចាម្បវេលាអផុ

(១២) យវ្យរទន្តបមុខវល តោយស្កតលបក្រោយ វញអញអ្នក្សមុទា

(១៣) យអ្យត្តប្រសមលេយ ស្តចបញ្ជ្យរវលផោង៍ ស្តចវិង៍ច្បង៍ករ

(១៤) លូះវ្នំត្រយា ចរលេវ្នំនោះ ចាម្បចៅំជុំ ឱយឆ្នូតថ្ងៃង៍ អ្នក្សមុទា

(១៥) យត្រូផ្សរ្យតស្ស គង៍អ្នកកយម្វយតបគុះ ស្តចច្បង៍ចុះតល្ពជេ

(១៦) ង៍វ្នំនោះ ចាម្បស្រោំសំតច អ្យតអ្នកម្វយតអាចច្បង្វលេយ អ្នក្ស

(១៧) ញ្ញកគ្រីយទេវអ្នក្សញ្ញកគ្រីវទ្ធនជាកុលេប្រតិជ្ញា ស្បង៍អ្នក្រ្សុក

(១៨) វិជយបុរ នាស្សោតអ្យះ តេលមានវ្រះសវ្វិជ្ញតិក្រោយហោង៍

55. Cœdès, 1929



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(១៩) គលទូលមន្ទុធ្បូងបង់ខ្លួនតោយវ្នកស្តច បង្គិតិង ចាម្បច្វែង
(២០) ច្រែនតិផ្គ្វលសល្ហែយ ចាម្បបោះនុលំវេងត្រ្វូតផ្ទៃ ស្បង្គត្វល
(២១) រោះប្រតិដ្ឋា០ បន្ទ្វល អំបលរាជបុណ្យ នាស្តចនាំអ្នកខ្មែរតំបិងប្វ
(២២) នធ្បូងអន្ទ្វែកែបិយតបប្រំបិយ ករគងឥស្ស ល្វះកម្ទុជទេគ
(២៣) ប្រសាទតអ្នក្សញ្ញកតវ្យ្យរ ឱយនាមអំតេងស្នាបនារូប០០

(១) នាពេលដែលករតរាហុផ្សំគំនិតក្បត់នឹងព្រះបាទស្រីយសោវម៌្មទេ-
(២) ហើយបានទៅដល់ព្រះមន្ទីរ អស់ពលនគរផងបោះបង់ ហើយថយ
(៣) (ដល់) កណ្តាលមត្តវារ រត់អស់ ស្តេចឡើងច្បាំង មេទ័ពអជុំន
(៤) អ្នកសញ្ញកគ្រីធរទេវបុរ ច្បាំងការ(ពារ)សម្តេច សឹងដួល (ត្វល) ដោយក្អែក
(៥) ស្តេចដល់ច្រមុះ ផ្តួល(ផ្ត្វល)ករតរាហុ ចំណោរមក ឱយនាមថា «វ្រះកំ
(៦) ម្រតេងអញគ្រីន្ទ្របសិង្ហវម៌្ម» ដល់មេទ័ពទេវបុរត ជាបុត្រ
(៧) អ្នក្សញ្ញកគ្រីធរទេវបុរ ឱយនាម «អំតេង» ដល់អ្នក្សញ្ញក ទាំងពីរ (វ្យរ)
(៨) ស្ថាបនារូប ចំពោះក្រុមញាតិ (ឥសកុសលបក្ស) ផង ស្តេចប្រទានទ្រព្យ (ប្រកប សំបត (សម្បត្តិ) និងយសសក្តិ (នុក្រម) ។[56]

56. អាំង ជូលាន មូលដ្ឋានរៀនខ្មែរបុរាណ ២០១៨



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia









សិលាចារឹកតាព្រហ្ម K. 273 សំស្ក្រឹត

## សិលាចារឹកតាព្រហ្ម K. 273

សិលាមូលស្ថាបនា K. 273 គឺជាចារឹកភាសាសំស្ក្រឹតដែលពិពណ៌នាពីប្រវត្តិរបស់ព្រះបាទជ័យវម៌្ម ទី៧៖

មាតារបស់ព្រះបាទជ័យវម៌្ម ទី៧ប្រសូតចេញពីរាជវង្សក្សត្រិយ៍គ្រងរាជ្យលើផែនពសុធាក្នុងសន្តតិវង្ស «គ្រីកម្ពុ» ព្រះនាម «គ្រេគ្ននវម៌្ម» ដែលត្រូវជាបុត្ររបស់គ្រេតវម៌្ម។ ព្រះបាទ គ្រេគ្ននវម៌្មប្រសូតនៅជយទិត្យបុរៈ ហើយបានឡើងសោយរាជ្យជាមហារាជានៃគ្រេគ្នបុរៈ។ ព្រះអង្គមានព្រះរាជបុត្រីមួយអង្គព្រះនាម «កម្ពុជរាជលក្ស្មី» ដែលបានរៀបអភិសេកជាមួយព្រះបាទភវវម៌្ម ទី២ និងប្រសូតបានបុត្រមួយអង្គព្រះនាម្រគីហស៌វម៌្ម (ទី៤)។ ព្រះបាទហស៌វម៌្មជាព្រះមហាក្សត្រដែលពូកែខាងធ្វើសឹកសង្គ្រាម ឈ្នះអស់មារសត្រូវ។ ព្រះអង្គមានព្រះរាជបុត្រីមួយអង្គព្រះនាម «គ្រី ជយចូឌាមណិ» ដែលមានរូបឆោមល្អភ្លឺផ្ទេក បីដូចជាដួងព្រះចន្ទរះលើភ្នំហេមពាន្ត មានសម្តីពីរោះដូចតូរ្យតន្ត្រី និងមានព្រះទ័យស្រឡាញ់ដល់សត្វលោកទាំងពួង។

ព្រះរាជបិតារបស់ព្រះបាទជ័យវម៌្ម ទី៧ប្រសូតចេញពីរាជវង្សនៃព្រះបាទជ័យវម៌្ម ទី៤។ បន្ទាប់ពីបានទទួលនូវអានុភាពរាជវង្សនៅគោជបុរៈរួចមក ព្រះបាទជ័យវម៌្ម ទី៤បានច្បាំងឈ្នះអស់មារសត្រូវបានស្ថាបនាប្រាសាទកេរ និងបានទៅគង់ប្រថាប់នៅ«មហិធរបុរៈ»។

បុត្រប្អូនស្រីរបស់ព្រះបាទជ័យវម៌្ម ទី៤ ព្រះនាម មហិធរាទិត្យ ដែលជាព្រះអនុជរបស់ព្រះបាទសូរ្យវម៌្ម ទី២។ អ្នកអម្ចាស់ មហិធរាទិត្យបានរៀបអភិសេកជាមួយព្រះនាង «រាជបទីន្ទ្រលក្ស្មី» មកពីរាជបទីគ្នរគ្រាម ហើយបានប្រសូតបុត្រមួយអង្គព្រះនាម ធរណីន្ទ្រវម៌្ម ទី២។

ព្រះបាទធរណីន្ទ្រវម៌្ម គឺជាព្រាហ្មណ៍ដ៏ប្រសើរបំផុត មានដំណើរដូចជាគ្រុឌ មានរូបសម្ផស្សដូចដួងព្រះច័ន្ទ មានកេរ្តិ៍ឈ្មោះក្រអូបសព្វទិសទី។ ព្រះអង្គជាពុទ្ធសាសនិកជន ដែលរៀនចេះចប់គម្ពីរពីគ្រូបាអាចារ្យនានា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រះបាទធរណីន្ទ្រវរ្ម័នបានរៀបអភិសេកជាមួយបុត្រីព្រះបាទហស៍វរ្ម័ន ទី៤ ព្រះនាម «ត្រីជយចូឌាមណិ» ហើយបានប្រសូតបុត្រមួយអង្គព្រះនាម ជ័យវរ្ម័ន ទី៧។

ព្រះបាទជ័យវរ្ម័ន ទី៧ គឺជាក្សត្រិយ៍ដែលមានរាជានុភាពមហិមា មានកម្លាំងពលំប្រៀបនឹងសត្វដំរី និងមានគុណសម្បត្តិលើសអស់ពពួកក្សត្រិយ៍។ ព្រះអង្គតែងតែធ្វើឱ្យសត្រូវបាក់ខ្ទបខ្ទាចព្រះដេស្ដារបស់ព្រះអង្គ។

ព្រះបាទជ័យវរ្ម័ន ទី៧ គឺជាក្សត្រិយ៍ដែលការពារប្រជារាស្ត្រដោយទឹកចិត្តស្រឡាញ់ និងមេត្តាករុណា។ ព្រះអង្គប្រកាន់ខ្ជាប់ថា «សេចក្ដីសុខ និងទុក្ខរបស់ប្រជារាស្ត្រ ជាសេចក្ដីសុខ និងទុក្ខរបស់ព្រះអង្គ»។

ក្រោយពីបានចេញច្បាំងជាមួយប្រទេសចម្ប៉ា ព្រះអង្គបានចាប់ និងលែងស្ដេចរបស់ចម្ប៉ា។

នៅពេលព្រះអង្គអភិសេកឡើងគ្រងរាជ្យជាព្រះមហាក្សត្រ ព្រះបាទជ័យវរ្ម័ន ទី៧បានថ្វាយតង្វាយស្វេតឆ័ត្រសម្រាប់ស្ដេចដល់ព្រះរាជគ្រូរបស់ព្រះអង្គ និងថ្វាយគោរមងារជា «ត្រីមង្គលាថទេវ» និវាសនដ្ឋាននៅរាជបតីន្ទ្រគ្រាម និងថ្វាយគោរមងាររាជវង្សដល់គ្រួសាររាជគ្រូទៀតផង។

ព្រះបាទជ័យវរ្ម័ន ទី៧បានថ្វាយផ្នែកមួយនៃព្រះបរមរាជវាំង ដល់ព្រះមាតាព្រះអង្គ និងមានស្ថាបនារូបបដិមាព្រះរាជមាតា «ត្រី ជយចូឌាមណិ» នៅប្រាសាទផងដែរ។

មានមន្ទីរពេទ្យចំនួន ១០២ ស្ថិតនៅក្នុងខេត្តផ្សេងៗទូទាំងប្រទេស (CXVII)។

ព្រះបាទជ័យវរ្ម័ន ទី៧បានស្ថាបនារូបបដិមាព្រះរាជគ្រូ៖ «ត្រីជយមង្គលាថទេវ» «ត្រីជយគីតីទេវ» និងរូបទេពចំនួន ២៦០ អមផងដែរ។

ព្រះអង្គបានថ្វាយតង្វាយជាច្រើនសព្វបែបយ៉ាងដល់ប្រាសាទតាព្រហ្ម។

អត្ថបទនេះតាក់តែងដោយ អ្នកអម្ចាស់ «ត្រីសូរ្យកុមារ» ដែលប្រសូតពីព្រះរាជអគ្គមហេសីរបស់ព្រះបាទជ័យវរ្ម័ន ទី៧។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ប្រាសាទព្រះខ័ន



សិលាចារឹកព្រះខ័ន K. 908

## សិលាចារឹកព្រះខ័នK. 908

សិលាមូលស្ថាបនា K. 908 រកឃើញដោយអភិរក្សអង្គរលោក Glaize នៅឆ្នាំ ១៩៣៩ នៅក្នុងគោបុរៈទី១ខាងកើត។ សិលាមូលស្ថាបនានេះដូចគ្នាបេះបិទជាមួយនឹងសិលាចារឹកតាមព្រហ្ម (កម្ពស់ ១,៨៥ ម៉ែត្រ ទទឹង ០,៥៨ ម៉ែត្រ) មាន ៧២បន្ទាត់ចារលើមុខទាំងសងខាង ជាអក្សរជ្រុង ដែលជាអក្សររជ្ជកាលព្រះបាទជ័យវរ្ម័ទី៧។

សិលាចារឹក K. 908 គឺជាអត្ថបទភាសាសំស្រ្កឹត ដែលមាន១៧៩ល្បះ (stances)។ ល្បះ ១៨ ដំបូងដូចគ្នានឹងសិលាចារឹកតាព្រហ្ម ដែលចាប់ផ្តើមពីការបួងសួងដល់ «ត្រៃរតនៈ» (ព្រះពុទ្ធ, លោកេស្វរៈ, ប្រាជ្ញាបារមិតា) សរសើរលោកិស្វរៈ និងប្រាជ្ញាបារមិតា ដែលជាមាតាព្រះពុទ្ធ ហើយពិពណ៌នា ពីប្រវត្តិរបស់ព្រះបាទជ័យវរ្ម័ទី៧។

ចាប់ពីល្បះទី១៩ទៅ សិលាចារឹកទាំងពីរខុសពីគ្នា។ សិលាចារឹកព្រះខ័ននិងតាព្រហ្មគឺជា«ប្រគស្តិ»(Praśasti)ឬការកោតសរសើរដល់ព្រះរាជា តែសិលាចារឹកព្រះ ខ័នមានអត្ថបទខុសផ្សេងពីសិលាចារឹកតាព្រហ្ម។

មានធម្មសាលា (សាលាសំណាក់) ចំនួន ១២១[57]

ល្បះ XXI៖ ព្រះរាជាជាក្សត្រិយ៍ស្រឡាញ់តែអំពើល្អ មានមនសិការខ្ពស់ប្រកបដោយការដឹងគុណ មានឫទ្ធិបារមី ព្រះបញ្ញាញាណ និងមានចំណេះដឹងខ្ពស់ខាងផ្នែកភាសាសំស្រ្កឹត មានបទពិសោធន៍ច្បាំងឈ្នះមារសត្រូវដែលគួរឱ្យគោរពកោតខ្លាច។

ព្រះអង្គបានកសាងប្រាសាទនៅតាមរាជធានីដែលវាយបានពីសត្រូវ ដើម្បីឧទ្ទិសដល់យុទ្ធជនដែលពលីជីវិតក្នុងសង្គ្រាម។

ល្បះ XXVIII៖ ចំពោះអ្នកដែលមានទ្រព្យសម្បត្តិហូរហៀរ ព្រះអង្គដែលជាស្តេចប្រកបដោយព្រះគតិបណ្ឌិត លើកបុត្ររបស់ព្រះអង្គ ដែល

57. Cœdès, 1941

មានរូបសម្ផស្សស្រស់ប្រិមប្រិយដើម្បីរៀបអភិសេក។

ល្បះ XXXII៖ នៅត្រង់កន្លែងដែលព្រះអង្គទទួលជ័យជម្នះលើសត្រូវ ព្រះអង្គបានស្ថាបនាទីក្រុងឈ្មោះ «ជយគ្រី» (ប្រាសាទព្រះខ័ន)។

ល្បះ XXXIV៖ ព្រះបាទជ័យវរ្ម័ ទី៧ បានស្ថាបនាប្រាសាទនៅមហាសករាជ ១១១៣(គស ១១៩១) ដើម្បីឧទ្ទិសដល់ «លោកេគ» ព្រះនាម «គ្រី ជយវម៌េគ្គរ» ដែលជាបិតារបស់ព្រះអង្គ។

ព្រះអង្គបានប្រទាននូវតង្វាយជាច្រើន (ចំណូល និងចំណាយ) ដល់ប្រាសាទ។

ល្បះ LII៖ ការបែកអង្ករដោយឥតគិតថ្លៃដល់សាស្ត្រាចារ្យ និងនិស្សិត បញ្ជាក់ថា ប្រាសាទព្រះខ័នគឺជាសាកលវិទ្យាល័យនៅរជ្ជកាលនោះ ហើយនៅល្បះ CVIII និយាយពីសាស្ត្រាចារ្យ ១ នាក់ និងសាស្ត្រាចារ្យរង ១៥ នាក់។

ល្បះ LIV៖ នៅពេលសង្ក្រាន្តឆ្នាំថ្មី និងពិធីបុណ្យចំនួន១៨ មានការបែកតង្វាយជាគ្រឿងឧបភោគបរិភោគ។

ល្បះ CXXVI៖ នៅទូទាំងប្រទេសមាន «ធម្មគាលា» (សាលាសំណាក់) (Gîtes d'étape avec du feu) ចំនួន ១២១។[58]

អ្នកអម្ចាស់ ស្រី វីរកុមារ ដែលជាបុត្ររបស់ព្រះបាទជ័យវរ្ម័ ទី៧ ជាមួយ ព្រះរាជអគ្គមហេសី ព្រះនាង រាជេន្ទ្រទេវី ដែលជាអ្នកប្រាជ្ញដ៏ឧត្តុង្គឧត្តមបំផុត ជាមេទ័ពគ្មានគូប្រៀប មានរូបសម្ផស្សគួរជាទីបេតី មានទេព្យកោសល្យខាងផ្នែកសិល្បៈ និងជាអ្នកគោរពព្រះធម៌យ៉ាងខ្ជាប់ខ្ជួន គឺជាអ្នកតែងអត្ថបទ «ប្រគស្តិ» សរសើរនេះឡើង។

58. Cœdes, 1941



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia





«ត្រៃរតនៈ»៖ព្រះពុទ្ធ




«ត្រៃរតនៈ»៖ ប្រាជ្ញាបារមិតា




«ត្រៃរតនៈ»៖ លោកេស្វរៈ



ប្រាសាទភិមានអាកាស



n. 241 A / K. 485 n. 241 B / K. 485 n. 241-C / K. 485

សិលាចារឹកប្រាសាទភិមានអាកាស K. 485

## សិលាចារឹកភិមានអាកាស K. 485

*សិលាចារឹក K. 485៖ ប្រាសាទភិមានអាកាស គឺជាប្រាសាទរចនាបថឃ្លាំងសាងសង់នៅចុងសតវត្សទី១០ ក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវម្ម័ (៩៤៤–៩៦៨) ហើយបញ្ចប់ដោយព្រះបាទសូរ្យវម្ម័ ទី១ (១០១១-១០៤៩) ដែលជាមជ្ឈមណ្ឌលនយោបាយនៃរាជធានីអង្គរនាពេលនោះ។ នៅឆ្នាំ ១៩១៦ អភិរក្សអង្គរ Marchal បានរកឃើញសិលាមូលស្តាបនា (កម្ពស់ ១,៧ ម៉ែត្រ ទទឹង០,៤៧ ម៉ែត្រ) កប់នៅក្នុងដីជើងប្រាសាទ ហើយបែកជា ៧០ បំណែក។ ចារឹកភាសាសំស្រ្កឹតនេះត្រូវបានផ្គុំឡើងវិញ មាន ៥២ បន្ទាត់ចារលើមុខទាំង៣ និង ៤៤ បន្ទាត់លើមុខទី៤ ហើយកំណាព្យទាំងអស់មាន ១០២ ល្បះ ចារដោយព្រះនាងឥន្ទ្រទេវី ជាភាសាសំស្រ្កឹតកម្រិតខ្ពស់។*[59]

*ចារឹកចាប់ផ្តើមពីទ្រឹស្តី «ត្រិកាយ» នៃពុទ្ធសាសនាមហាយាន (ព្រះពុទ្ធមានព្រះកាយបីគឺ៖ (១) ធម្មកាយ-ច្បាប់របស់ព្រះពុទ្ធដែលចូលនិព្វានដោយគ្មានព្រំដែន (២) សម្ភោគកាយ -កាយនៃការត្រេកត្រអាល ឬពន្លឺត្រចះត្រចង់ និង (៣) និម៌ាណកាយ-ការចាប់ជាតិរបស់ព្រះពុទ្ធ ឬការបង្កើតស្តែងចេញជាកាល និងកន្លែង។ បន្ទាប់មក គឺជាការថ្វាយបង្គំដល់ព្រះពុទ្ធ និងលោកិស្វរៈ។*

*ល្បះ IV-XXIX៖ គឺជាប្រគស្តិដល់ព្រះបាទជ័យវម្ម័ ទី៧៖ ព្រះអង្គប្រសូតដើម្បីគ្រងរាជ្យលើផែនដី។ បិតាព្រះអង្គព្រះនាម គ្រីធរណីន្ទ្រវម្ម័ទេវ និងមាតាព្រះនាមគ្រី ជយចូឌាមណិ ដែលជាក្សត្រិយ៍នៃនគរ ជយាទិត្យបុរៈ (តាមសិលាចារឹកតាព្រហ្ម ព្រះខ័ន និងប្រាសាទជ្រុង (ល្បៈទី VII) ជយាទិត្យបុរៈ គឺជាស្រុកកំណើតរបស់ គ្រេធ្មារវម្ម័ ដែលជាបុព្វការីជនរបស់ព្រះនាង ជយចូឌាមណិ។*

*ល្បះ V៖ ព្រះបាទជ័យវម្ម័ ទី៧ បានឡើងគ្រងរាជ្យនៅមហាសករាជ*

59. Cœdes, IC, II, P. 161-181



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១១០៣ (គសឆ្នាំ ១១៨១) ព្រះមហាសក្សត្រដ៏ឆ្នើមអង្គនេះ ល្បីល្បាញដោយស្នាព្រះហស្ដរបស់ព្រះអង្គ ប្រៀបបីដូចជាខ្សែរកគុជរបស់ទេពថែរក្សាទិសទាំងបួន។ នៅក្នុងពេលធ្វើសឹកសង្គ្រាម ព្រះអង្គផ្ដួលសត្រូវក្នុងមួយប៉ប្រិចភ្នែកប៉ុណ្ណោះ ហើយផ្ដួលរំលំដំរីសត្រូវដូចបានជួបនឹងស្ត្រីព្រហ្មចារីស្រស់ប្រិមប្រិយ៍ដូច្នេះដែរ។

ល្បះ V-XVII៖ ព្រះអង្គចេះច្បាស់នូវពល់គម្ពីរសាស្ត្រាផ្សេងៗ និងចេះវិទ្យាសាស្ត្រ ដើម្បីអាចបម្រើដល់ប្រជានុរាស្ត្ររបស់ព្រះអង្គ មានថាមពលខ្លាំងក្លាប្រៀបដូចដំរីសារ ឡើងដល់កំពូល មានកេរ្តិ៍ឈ្មោះល្បីរន្ទឺដូចកម្រងផ្កាភ្ញីផ្ទេកដាស់អស់ពួកទេពឱ្យតើនពីនិទ្រា។ ព្រះឥន្ទ្រ អាចកម្ចាត់សត្រូវបាន ដោយមានពួករក្សាលោកជួយ តែព្រះអង្គអាចកម្ចាត់សត្រូវបានដោយគ្រាន់តែប្រើរស្មីតេជៈរបស់ព្រះអង្គតែប៉ុណ្ណោះ។

ដោយមាន«គ្រុតិ» (វិទ្យាសាស្ដថ្មី) និង«ស្មតិ» (វិទ្យាសាស្ត្របុរាណ) នៃប្រាជ្ញាបតិ (អ្នកកសាងលោកនិងសន្តតិវង្ស) ពិភពលោកមានអានុភាពខ្លាំងជាងអាទិទេពបង្កើតលោក។

ល្បះ XX-XXV៖ ព្រះអង្គចេះគ្រប់គ្រងខ្លួនឯង និងជាក្សត្រិយ៍ប្រកបដោយទសពិធរាជធម៌ និងឈ្នះអស់ស្ដេចទាំងពួង (ឈ្នះស្ដេចទុយ៉ោធន) តែនៅពេលដែលគេសរសើរព្រះអង្គថាព្រះអង្គប្រសើរជាងយុធិឞ្ឋិរ (តួអង្គក្នុងរឿងមហាភារតៈ ដែលបាត់បង់ទ្រព្យនិងមហេសីដោយសារការលេងចត្រង្គ និងដោយសារល្បិចរបស់ប្អូនជីដូនមួយ ទុយ៉ោធន) ព្រះអង្គឱនព្រះភ័ក្ត្រចុះ។ ដោយមានគុណសម្បត្តិទាំងនេះ ព្រះអង្គគ្រប់គ្រងផែនដីទាំងមូល ហើយប្រជានុរាស្ត្ររស់នៅក្នុងក្ដីសុខក្សេមក្សាន្ត ដោយព្រះអង្គមិនត្រឹមតែឈ្នះលើកលិប៉ុណ្ណោះទេ តែឈ្នះលើមាសត្រូវទាំងអស់។

ល្បះXXVI-XXIX៖នៅក្នុងរជ្ជកាលមុនទោះបីជាដែនដីទាំងមូលស្ថិតនៅក្រោមរាជ្យមហាក្សត្រច្រើន តែប្រទេសជាតិក្ដៅខ្លោច តែនៅក្នុងរាជ្យរបស់ព្រះអង្គ ទោះបីជាមានក្សត្រតែមួយអង្គ ប្រជារាស្ត្ររស់នៅក្នុងក្ដីសុខ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្បេមក្សាន្ត។

ល្បះ XXX៖ ព្រះអង្គមានព្រះរាជអគ្គមហេសី ព្រះនាម គ្រីរាជេន្ទ្រទេវី ដែលមានរូបឆោមស្រស់ប្រិមប្រិយ និងមានរូបសម្ផស្សគួរជាទីបេតី មាតាព្រះនាម...បិតាព្រះនាម... ជីតាព្រះនាម គ្រីរុទ្រវម៌្ម និងជីដូនព្រះនាម រាជេន្ទ្រលក្ស្មី។

ល្បះ XXXVI-XXXIX៖ និយាយពីចាម និងដំណើររបស់ព្រះបាទជ័យវម៌្ម ទី៧ ទៅចម្ប៉ា។

ល្បះ XL-XLIII៖ ព្រះរាជអគ្គមហេសី គ្រីរាជេន្ទ្រទេវី ទ្រង់បានរស់នៅក្នុងសភាពជាអ្នកបួស (Ascétisme) និងបន់ស្រន់សូមឱ្យព្រះស្វាមីទៅធ្វើសឹកបានសេចក្ដីសុខ។

ល្បះ XLVII៖ ព្រះមាតាបីដូចដែនពសុធា ព្រះបិតារឹងមាំដូចភ្នំព្រះសុមេរុ និងបងស្រីព្រះនាង គ្រីឥន្ទ្រទេវី ប្រៀបបីដូចជាទន្លេគង្គា។

ល្បះ XL-XLIII៖ ព្រះរាជអគ្គមហេសី គ្រីរាជេន្ទ្រទេវី ជាក្សត្រិយ៍ប្រកបដោយ វត៌តិ (មានអាកប្បកិរិយា) ប្រីតិ (ចិត្តល្អ) ប្រៀបបីដូចជា សិទ្ធិ (ជោគជ័យ) ហើយបោះជំហានទៅមុខជានិច្ច។

ល្បះ LIX-LX៖ ព្រះនាងគ្រីឥន្ទ្រទេវី ជាបងបានបង្រៀនព្រះរាជអគ្គមហេសី ឱ្យគោរពព្រះពុទ្ធ និងប្រតិបត្តិតាមគន្លងដ៏ស្ងប់នៃព្រះសុគត ដែលបានឆ្លងផុតនូវភ្លើងមហន្តរាយ និងសមុទ្រទុក្ខ ហើយបានក្លាយខ្លួនជាពុទ្ធសាសនិកមួយព្រះអង្គ។

ល្បះ LXV-LXVII៖ នៅពេលដែលព្រះបាទ យសោវម៌្ម ត្រូវបាន...អ្នកបម្រើដែលមានមហិច្ឆតាជ្រែករាជ្យ ព្រះអង្គ (ព្រះបាទជ័យវម៌្ម ទី៧) បានយាងត្រឡប់ពីវិជ័យដោយប្រញាប់ ដើម្បីជួយដល់ព្រះរាជា។ តែព្រះរាជាត្រូវបានគេធ្វើគតរួចទៅហើយ។

ល្បះ LXVIII-LXX៖ គ្រី ជយ ឥន្ទ្រវម៌្ម ស្តេចនៃចម្ប៉ា មានចិត្តលោភលន់ដូចយក្ខ «រាវណា» ដឹកជញ្ជូនកងទ័ពតាមរទេះកុះករដូចមេឃ មកវាយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

«កម្ពុជទេស»។ នៅក្នុងសមរភូមិនៅភាគខាងត្បូង ដែលស្តេច «យមរាជ្យ» លេបត្របាក់ជីវិតយ៉ាងច្រើន ព្រះអង្គបានវាយឈ្នះស្តេចជ្រែករាជ្យ និង បានធ្វើគុតស្តេចនេះតែម្តង។ បន្ទាប់ពីចាញ់ក្នុងសឹកសង្គ្រាមហើយ ស្តេច ចម្ប៉ា ដែលមានទ័ពដូចមហាសមុទ្រគ្មានព្រំដែន និងបន្ទាប់ពីបានទទួល អភិសេក វាយយកបានក្រុងវិជ័យ និងប្រទេសឯទៀត ព្រះអង្គ (ព្រះបាទ ជ័យវម៌្ម ទី៧) បានទទួលដែនដីដ៏បរិសុទ្ធដែលក្លាយជាទឹកដីរបស់ព្រះអង្គ។

ល្បះ XLVII-LXXXI៖ បន្ទាប់ពីបានជួបព្រះភ័ក្ត្រព្រះស្វាមីវិញ ព្រះនាង បានថ្វាយតង្វាយដូចទន្លេគង្គាធ្លាក់ចុះពីលើមេឃ រៀបចំឱ្យនាដការិនីលេង រឿងក្នុងជាតក និងចែកចាយទ្រព្យសម្បត្តិ និងគ្រឿងឧបភោគបរិភោគដល់ អាទិទេព និងប្រជាជនក្រីក្រ។ ព្រះនាងបានទទួលយកក្មេងស្រីកំព្រាមក ចិញ្ចឹម ដោយបង្កើតភូមិឈ្មោះ ធម៌គីតិ ដើម្បីឱ្យពួកគេរៀនធម៌។ ព្រះនាង ថ្វាយដល់ប្រាសាទតឋាគតខាងកើត (ប្រហែលបន្ទាយក្តី) នូវស្គរមាស លម្អដោយក្រណាត់សូត្រចិន។

ល្បះ LXXXII-LXXXXIX៖ ព្រះនាងថ្វាយព្រះគោមាសពីរដល់ ប្រាសាទ គ្រីជយចូឌាមណិ (តាព្រហ្ម), ថ្វាយព្រះគោមាសពីរ និងគោពីរគូ ដល់ប្រាសាទ សុគត គ្រី ជយគ្រី (ព្រះខ័ន), ថ្វាយស្គមាស និងរូបបដិមានៃ ទេវបុត្រនៃកទ្រេគ្វរ ព្រះនាមទុន្ទភិដល់ប្រាសាទកទ្រេគ្វរ និងបានសាងរូប បដិមាទេព មហេគ្វរ ព្រះនាម្រគី ជយរាជមហេគ្វរ ថ្វាយប្រាសាទ គ្រី ជយ ក្សេត្រគរ (បាសែត, បាត់ដំបង) នូវរូប។

ល្បះ XCIII៖ ព្រះនាងដែលមានប្រាជ្ញាឈ្លាសវៃបានកសាងគ្រប់ទិស ទី នូវរូបបដិមានៃព្រះមាតា ព្រះបិតា បងប្អូន និងញាតិមិត្តរបស់ព្រះង្គ។

ល្បះ XCIV៖ ទោះបីជាព្រះនាងស្ម័គ្រស្មោះនឹងព្រះស្វាមីរហូតដល់ ព្រះនិព្វាន បន្ទាប់ពីព្រះស្វាមីបានអភិសេកជាព្រះរាជារួចមក ព្រះនាងបាន យាងចូលព្រះនិព្វាន។

ល្បះ XCVI-XCIX៖ ព្រះនាងបានសាងសង់រូបបដិមានៃគ្រី ជយរាជ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទេវី និងរូបបដិមានៃព្រះរាជាយ៉ាងច្រើនសន្ធឹកសន្ធាប់ តែព្រះនាងបានរក្សាក្នុងព្រះរាជវាំងនូវកិត្តិយសនៃព្រះជិនស្រី (ព្រះពុទ្ធ)។ នៅប្រាសាទនគេន្ទ្រតុង្គ និងប្រាសាទរបស់ តិលកោត្តារ ដែលត្រូវបានព្រះរាជាតែងតាំងជាប្រធានសាស្ត្រាចារ្យ ព្រះនាងបានបង្រៀនដល់ស្ត្រីជាច្រើន។ នគេន្ទ្រាគ្រមបានក្លាយទៅជាកន្លែងដែលស្នំស្តេចរៀនសូត្រ ដូចជាព្រះនាង សរស្វតីមកចាប់ជាតិ។

**ពិពណ៌នាពីព្រះនាង ឥន្ទ្រទេវីៈ**

ល្បះ C៖ នៅទីក្រុងឈ្មោះ «ទន្តិនិកេតន» បន្ទាប់មកនៅទីក្រុង «ត្រីសរស្វតីបុរ» និងចុងក្រោយនៅទីក្រុង «យគោធបុរ» បុត្រីនៃព្រាហ្មណ៍ ដែលមានឋានានុក្រមលេខ១ ក្នុងរាជវង្សានុវង្ស បានឡើងជាព្រះរាជអគ្គមហេសី។

ល្បះ CI៖ ព្រះនាងក្រាបបង្គំក្រោមល្អងធូលីព្រះបាទរបស់ព្រះរាជាគ្របដណ្តប់លើទន្លេគង្គា និងដោយកំហឹង ដាក់ជើងលើព្រះកេសព្រះសិរៈ ព្រះនាងបានផ្សព្វផ្សាយដល់ស្ត្រីដែលស្រឡាញ់វិទ្យាសាស្ត្រ នូវព្រះរាជហឫទ័យរបស់ព្រះមហាក្សត្រ ជាទឹកអម្រឹត ដែលមានទម្រង់ជាពុទ្ធិ។

ល្បះ CII៖ ព្រះនាងជាក្សត្រិយ៍ដែលមានប្រាជ្ញា ជាអ្នកប្រាជ្ញ មានភាពបរិសុទ្ធ និងបម្រើព្រះបាទ ត្រីជយវម៌្មទេវ ប្រកបដោយស្វាមីភក្តិ គឺជាអ្នកដែលតែង «ប្រគស្តិ» នេះឡើង ហើយក្រៅពីទេពកោសល្យផ្សេងៗទៀត ព្រះនាងល្បីល្បាញដូចកាំរស្មីភ្លឺចិញ្ចាចចិញ្ចែង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ចលនាប្រឆាំងព្រះពុទ្ធសាសនា





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.១៨. ព្រះបាទឥន្ទ្រវម្ម័ ទី២ និងជ័យវម្ម័ ទី៨ (១២១៨-១២៩៥)

ព្រះរាជបុត្រមួយអង្គនៃព្រះបាទជ័យវម្ម័ ទី៧ បានឡើងស្នងរាជ្យមានព្រះនាមព្រះបាទ ឥន្ទ្រវម្ម័ ទី២។ អាណាចក្រខ្មែររងការគំរាមកំហែងពីខាងក្រៅ។ ប្រទេសចម្ប៉ារងសម្ពាធពីប្រទេសវៀតណាម។ ចំណែកជនជាតិថៃបានមកតាំងទីលំនៅនៅខ្ពង់រាបកូរ៉ាត និងក្នុងជ្រលងនៃទន្លេចៅប្រ៉ាយ៉ា។ វិវាទរវាងចៅហ្វាយខេត្តខ្មែរ និងមេដឹកនាំសៀមពីនាក់នៅសុខោទ័យបាននាំឱ្យមានកើតសង្គ្រាម ហើយក្រុងសុវណ្ណលោកត្រូវបានសៀមរំដោះយកបាន។ នៅឆ្នាំ ១២២០ រដ្ឋសៀមត្រូវបានបង្កើតឡើងដឹកនាំដោយស្តេចព្រះនាម ឥន្ទ្របតីន្ទ្រាទិត្យ។

នៅសតវត្សទី ១៣ គឺជាសតវត្សនៃសង្គ្រាមសាសនានៅកម្ពុជា ដោយសារក្រោយគ.ស. ១២១៨ នៅក្នុងរជ្ជកាលព្រះបាទជ័យវម្ម័ ទី៨ (១២៤៣-៩៥) អាណាចក្រខ្មែរងាកទៅប្រកាន់យកព្រហ្មញ្ញសាសនា ជាសាសនារបស់រដ្ឋ។ គេបានកម្ទេចឬ ធ្វាក់ឡើងវិញរូបព្រះពុទ្ធបដិមានៅប្រាសាទអង្គរធំ ប្រាសាទព្រះខ័ន ប្រាសាទតាព្រហ្ម និងប្រាសាទបន្ទាយក្តី ការធ្វាក់ឡើងវិញរូបព្រះពុទ្ធ ឱ្យទៅជាឥសី ឬព្រះលិង្គ។ នៅឆ្នាំ ២០០១ អ្នកស្រាវជ្រាវដឹកនាំដោយលោកសាស្ត្រាចារ្យ Ishizawa បានរកឃើញនូវក្បាលព្រះ ពុទ្ធកប់ក្នុងដីចំនួន ២៧២ នៅប្រាសាទបន្ទាយក្តី។ គេឃើញមានសិលាចារឹក តែមួយប៉ុណ្ណោះគឺ K. 241 ប្រាសាទតាអាន។

## ២.១៩. សិលាចារឹក គឺជានិមិត្តរូបនៃភាពរុងរឿង

នៅឆ្នាំ ១២៩៦ ព្រះបាទឥន្ទ្រវម្ម័ ទី៣ ដែលត្រូវជាបុត្រសុណិសា (ប្រសា) របស់ព្រះបាទជ័យវម្ម័ទី៨ (១២៤៣-៩៥) បានឡើងសោយរាជ្យ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រះអង្គជាស្តេចដែលគោរពប្រណិបត្តិព្រះពុទ្ធសាសនាថេរវាទ។ នៅឆ្នាំ ១២៩៦ នោះ ចិនបានបញ្ជូនបេសកកម្មខាងផ្នែកពាណិជ្ជកម្ម ហើយបន្សល់ទុកនូវកំណត់ហេតុរបស់ ជីវ តាក្វាន់ ដែលក្លាយជាប្រភពដ៏សំខាន់នៃប្រវត្តិសាស្ត្រខ្មែរសម័យអង្គរ។

បន្ទាប់ពីព្រះបាទ ឥន្ទ្រវម៌្ម ទី៣ បានដាក់រាជ្យនៅឆ្នាំ ១៣០៨ ព្រះបាទស្រិន្ទ្រជ័យវម៌្ម (១៣០៨-២៧) បានឡើងសោយរាជ្យ ហើយចាប់ពីពេលនោះមកខ្មែរចាប់ផ្តើមសរសេរសិលាចារឹកជាភាសាបាលី ដែលបញ្ជាក់យ៉ាងច្បាស់ថា ព្រះពុទ្ធសាសនាថេរវាទ គឺជាសាសនារដ្ឋ (K. 754 វត្តគោកផុស សៀមរាប)។

ព្រះបាទ ជ័យវម៌បរមេស្វរ (១៣២៧-១៣៥៣) បានឡើងគ្រងរាជ្យបន្តពីព្រះបាទ ស្រិន្ទ្រជ័យវម៌្ម។

ក្រោយរជ្ជកាលព្រះបាទជ័យវម៌្ម ទី៧ ពោលគឺក្នុងរយៈពេលជាង ១៥០ ឆ្នាំ មកដល់ចុងសតវត្សទី១៤ មានសិលាចារឹកចំនួនតែ ២៥ប៉ុណ្ណោះ៖ ៦ ជាភាសាសំស្ក្រឹត, ១៣ ជាភាសាខ្មែរ, ២ ជាភាសាបាលី, និង ២ ជាភាសាសំស្ក្រឹតនិងខ្មែរ។ ប្រការនេះបង្ហាញពីការធ្លាក់ចុះនៃអារ្យធម៌ខ្មែរ។

## ២.២០. ការធ្លាក់ចុះនៃអង្គរ

ចាប់ពីពេលដែលព្រះពុទ្ធសាសនាថេរវាទ ត្រូវបានលើកតម្កើងជាសាសនារដ្ឋនៃអាណាចក្រខ្មែរនៅក្នុងឆ្នាំ១៣៣៦ រហូតដល់ពេលចាកចោលអង្គរនៅឆ្នាំ ១៤៣២ គឺមានរយៈពេលជិត១០០ឆ្នាំ។

ការធ្លាក់ចុះរបស់ខ្មែរនៅក្នុងស.វ.ទី១៤ នេះ គឺបណ្តាលមកពីការបាត់បង់បញ្ញវន្ត និងធនធានមនុស្សខ្មែរ ដែលធ្លាប់រៀនសូត្រជាភាសាសំស្ក្រឹត។ ទន្ទឹមនឹងនេះប្រវត្តិវិទូក៏បានលើកពីសម្មតិកម្មដទៃទៀត ដូចជា ផលវិបាកនៃការចាញ់សង្គ្រាមជាមួយសៀម និងបញ្ហាផ្លាស់ប្តូរបរិស្ថានជាដើម។

បុរាណវិទូបានលើកឡើងនូវមូលហេតុមួយទៀតនៃការធ្លាក់ចុះនៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អារ្យធម៌អង្គរ គឺអាចការរើងសួតហួតហែងនៃបារាយណ៍ និងប្រព័ន្ធធារាសាស្ត្រនៃតំបន់អង្គរ។

ប្រវត្តិវិទូក៏បានលើកឡើងពីការកើនឡើងនៃពាណិជ្ជកម្មនៅតំបន់ទន្លេចតុមុខនៃរាជធានីភ្នំពេញ ដែលអាចជាមូលហេតុនៃការផ្លាស់ប្តូររាជធានីផងដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី ៣

# ការវិវត្តនៃភាសាខ្មែរចាស់



# ផែនទីប្រភពភាសាខ្មែរចាស់



## ៣.១. ការវិវត្តនៃអក្ខរក្រមភាសាខ្មែរចាស់

តួអក្សរព្យញ្ជនៈនៃភាសា «ខ្មែរចាស់» និងតួអក្សរនៃភាសាសំស្ក្រឹតដូចគ្នាបេះបិទ ប៉ុន្តែមានភាពខុសគ្នាតិចតួច[60]៖

ទី១-ព្យញ្ជនៈភាសាខ្មែរចែកចេញជាព្យញ្ជនៈឃោសៈ (ក្រុមខ្យល់អ៊) និងព្យញ្ជនៈអឃោសៈ (ក្រុមខ្យល់អ) តែព្យញ្ជនៈសំស្ក្រឹតជាព្យញ្ជនៈខ្យល់អ ទាំងអស់។

ទី២-ភាសាខ្មែរមានព្យញ្ជនៈ«ស»តែមួយ ចំណែកឯសំស្ក្រឹតមានព្យញ្ជនៈសច្រើន។ ដូនតាខ្មែរយើងបានយកព្យញ្ជនៈនៃអក្ខរក្រមសំស្ក្រឹតមកកែលម្អ ដើម្បីបង្កើតជាអក្ខរក្រមខ្មែរបុរាណ លើកលែងតែព្យញ្ជនៈ ឞ និង ឝ ប៉ុណ្ណោះ។[61] ខ្មែរចាស់ប្រើតួអក្សរ «ស» ចំនួនបីគឺ៖ ស, ឞ និង ឝ ។ ព្យញ្ជនៈខ្មែរ បុរាណមានទាំងអស់ ៣៣ តួ ដូចសព្វថ្ងៃដែរ បើរាប់ទាំង «អ»។ ក៏ប៉ុន្តែអក្សរ «ឡ» ខ្មែរមិនបានយកមកប្រើនៅសម័យមុនអង្គរ។ ខ្មែរចាប់ផ្ដើមប្រើប្រាស់អក្សរ «ឡ» ជាលើកដំបូងនៅលើសិលាចារឹកភាសាបាលីនៅគោកស្វាយចេក (K-754) នៅឆ្នាំ ១៣០៩។[62]

ទី៣-ស្រៈនៃភាសា «ខ្មែរចាស់» និងតួអក្សរនៃភាសាសំស្ក្រឹតដូចគ្នាបេះបិទ ប៉ុន្តែមានភាពខុសគ្នាតិចតួច។[63]

«ខ្មែរចាស់» មានប្រើលេខខ្មែរ និងមានខ្នងរាយ ខ្នងដប់ និងខ្នងរយ។ ខ្មែរត្រូវបានគេកត់សម្គាល់ថា បានបង្កើតលេខ ០ មុនគេក្នុងពិភពលោក។

តាមរយៈការសិក្សានៃការវិវត្តនៃអក្ខរក្រម គេអាចបែកចែកភាសា «ខ្មែរចាស់» ជាពីរដំណាក់កាលគឺ៖

(១) ដំណាក់កាលទី១ សម័យមុនអង្គរ (សតវត្សទី៦-ទី៨) និង

(២) ដំណាក់កាលទី២ សម័យអង្គរ (សតវត្សទី៩-ទី១៤)។[64]

60. Ménétrier, E., 1985
61. ឡុង សៀម, 1996
62. វង់ សុធារ៉ា, 2003
63. Ménétrier, E., 1985
64. Pou, 1979



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# អក្ខរក្រមខ្មែរចាស់

| សតវត្សទី ៦ ដល់ទី៩ | សម័យទំនើប | ឡាតាំង |
|---|---|---|
|  | ក | k |
|  | ខ | kh |
|  | គ | g |
|  | ឃ | Gh |
|  | ង | ṇ |
|  | ច | c |
|  | ឆ | ch |
|  | ជ | j |
|  | ឈ | jh |
|  | ញ | ñ |
|  | ដ | ṭ |
|  | ណ | N |
|  | ត | t |
|  | ថ | th |
|  | ទ | d |
|  | ធ | |
| | ន | n |
|  | ប | b |
| | | |
|  | ភ | ph |
| | ព | b |
|  | ម | m |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



| | |
|---|---|
| យ | y |
| រ | r |
| ល | l |
| វ | v |
| ស | s |
| ឞ | ṣ |
| ឝ | ś |
| ហ | h |
| អ | a |
| អិ | |
| អី | |
| អុ | |
| អូ | |
| អេ | |
| អែ | |
| អោ | |
| អៅ | |
| អំ | |
| អះ | |
| ឥ | |
| ឦ | |
| ឧ | |
| ឩ | |
| ឯ | |



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

| | | |
|---|---|---|
|  | ឮ | |
|  | វិភម | |

## លេខខ្មែរចាស់



## អក្ខរក្រមខ្មែរចាស់មុនអង្គរពីសតវត្សទី៦ ដល់ទី៨








fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia


ព្រាហ្មី
មន
វ៉ោកាញ់
សតវត្សទី៦
សតវត្សទី៧
សតវត្សទី៨
បច្ចុប្បន្ន
ba
bha
ma
ya
ra
la
va
śa
ṣa
sa
ha
a
ព
ភ
ម
យ
រ
ល
វ
ឝ
ឞ
ស
ហ
អ

# ស្រៈខ្មែរចាស់មុនអង្គរពីសតវត្សទី៦ ដល់ទី៨



| | ព្រហ្មី | វ៉ាកាញ់ | សតវត្សទី៦ | សតវត្សទី៧ | សតវត្សទី៨ | បច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ā | | | | | | -ា |
| i | | | | | | -ិ |
| ī | | | | | | -ី |
| u | | | | | | -ុ |
| ū | | | | | | -ូ |
| e | | | | | | េ- |
| ai | | | | | | ែ- |
| o | | | | | | េ-ា |
| au | | | | | | េ-ៅ |
| uṃ | | | | | | -ុំ |
| aṃ | | | | | | -ំ |
| āṃ | | | | | | -ាំ |
| aḥ | | | | | | -ះ |
| uḥ | | | | | | -ុះ |
| eḥ | | | | | | េ-ះ |
| oḥ | | | | | | េ-ាះ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ស្រៈពេញតួខ្មែរបុរាណ ពីសតវត្សទី៦ ដល់ទី៨

| | សម័យមុនអង្គរ | បច្ចុប្បន្ន |
|---|---|---|
| ī |  | ឦ |
| u |  | ឧ |
| ṛ |  | ឫ |
| e |  | ឯ |
| ai |  | ឰ |
| o |  | ឱ |

# ស្រៈពេញតួខ្មែរបុរាណ ពីសតវត្សទី៦ ដល់ទី៨

| | សតវត្សទី៦-៧ | សតវត្សទី៨ | ពាក្យរាប់លេខ | បច្ចុប្បន្ន |
|---|---|---|---|---|
| 0 | • | | ឝូន្យ | ០ |
| ½ |  |  | កន្លះហ | ១/២ |
| 1 |  |  | មោយ៑ មោយ្យ | ១ |
| 2 |  |  | វេរ៑ ពេរ៑ | ២ |
| 3 |  |  | បិ បិយ៑ បិយ្យ | ៣ |
| 4 |  |  | បោន៑ បោន្ន | ៤ |
| 5 |  |  | ប្រំ | ៥ |
| 6 |  |  | ប្រំមោយ៑ | ៦ |
| 7 |  |  | ប្រំវេរ៑ | ៧ |
| 8 |  |  | ប្រំបិយ៑ | ៨ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | សតវត្សទី៦-៧ | សតវត្សទី៨ | ពាក្យរាប់លេខ | បច្ចុប្បន្ន |
|---|---|---|---|---|
| 9 |  |  | ប្រំបោនិ | ៩ |
| 10 |  |  | តបិ | ១០ |
| 20 |  |  | ភៃ ភៃយិ ភយិ | ២០ |
| 30 |  |  | ភៃតបិ | ៣០ |
| 40 |  |  | វើរភយិ | ៤០ |
| 50 |  |  | វើរភយិតបិ | ៥០ |
| 60 |  |  | បិភៃ | ៦០ |
| 70 |  |  | បិភៃតបិ | ៧០ |
| 80 |  |  | បោនិភៃ | ៨០ |
| 90 |  |  | បោនិភៃតបិ | ៩០ |
| 100 |  | | គតមោយិ ឬប្រំភៃ | ១០០ |
| 120 |  | | គតមោយិភៃ | ១២០ |
| 200 |  | | គតវើរ | ២០០ |
| 300 |  | | គតបិយិ | ៣០០ |
| 400 |  |  | មោយិស្លិច្វ ស្លិក | ៤០០ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ព្យញ្ជនៈខ្មែរចាស់សម័យអង្គរពីសតវត្សទី៩ ដល់ទី១៣








fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia




# ស្រៈនិស្ស័យខ្មែរបុរាណសម័យអង្គរពីសតវត្សទី៩ ដល់ទី១៣






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia


ៅ au
ុំ uṃ
ំ aṃ
ាំ āṃ
ះ aḥ
ុះ uḥ
េះ eḥ
ោះ oḥ

# ស្រៈពេញតួខ្មែរចាស់សម័យអង្គរពីសតវត្សទី៩ ដល់ទី១៣



# លេខខ្មែរចាស់សម័យអង្គរពីសតវត្សទី៩ ដល់ទី១២



| សតវត្សទី៩ | សតវត្សទី១០ | សតវត្សទី១១ | សតវត្សទី១២ | ពាក្យរាប់លេខ | បច្ចុប្បន្ន |
|---|---|---|---|---|---|
| • | ० ◎ • | ○ • | ° | ឝូន្យ | ០ |
|  |  | [illegible] |  | កន្លះ កន្លះហ៊ា កន្លាះ | ¹/២ |
| [illegible] | [illegible] | [illegible] | [illegible] | មោយ៑ មោយ្យ ម្វាយ៑ | ១ |
| [illegible] | [illegible] | [illegible] | [illegible] | វ្យរ៑ វ្យរ ព្យរ៑ ពិរ | ២ |
| [illegible] | [illegible] | [illegible] | [illegible] | បិ បិយ៑ បី | ៣ |
| [illegible] | [illegible] | [illegible] | [illegible] | បួន៑ បួន្ន ប្វាន៑ ប្វាន្ន | ៤ |
| [illegible] | [illegible] | [illegible] |  | ប្រម៑ ប្រំម៑ ប្រាម៑ ប្រាំ | ៥ |
| [illegible] | [illegible] | [illegible] |  | ប្រមួយ៑ ប្រម្វាយ៑ | ៦ |
| [illegible] | [illegible] |  |  | ប្រំវ្យល៑ | ៧ |
| [illegible] | [illegible] | [illegible] | [illegible] | ប្រំបិយ៑ ប្រំបីយ៑ ប្រំបិ | ៨ |
| [illegible] | [illegible] | [illegible] | [illegible] | ប្រំបួន៑ ប្រំបួន្ន | ៩ |
| [illegible] | [illegible] | [illegible] | [illegible] | ឝប៑ | ១០ |
| [illegible] | [illegible] | [illegible] | [illegible] | ភយ៑ ភៃ មួយ៑ភយ៑ | ២០ |

## ៣.២. វាក្យសព្ទនៃភាសាខ្មែរចាស់

*ការសិក្សាការវិវត្តនៃវាក្យសព្ទបានបង្ហាញឱ្យឃើញថា ពាក្យតែមួយភាគច្រើននៃខ្មែរចាស់ និងខ្មែរទំនើបបញ្ចប់ដោយព្យញ្ជនៈចុងក្រោយដូចគ្នា ថ្វីត្បិតតែមានការផ្លាស់ប្តូរសូរសាស្ត្រ ហើយដែលធ្វើឱ្យមានការផ្លាស់ប្តូរស្រៈក៏ដោយ។ ក៏ប៉ុន្តែ មានការលើកលែងក្នុងករណីពាក្យដែលបញ្ចប់ដោយព្យញ្ជនៈ «រ» ដែលត្រូវបានលុបចោលក្នុងខ្មែរទំនើប និងពាក្យដែលបញ្ចប់ដោយ «ស» ដែលត្រូវច្របាច់បញ្ចូលជាមួយព្យញ្ជនៈឃោសៈនៅខាងចុងនៅក្នុងខ្មែរទំនើប។*[65]

65. Jacob, 1976



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ពាក្យសម្គាល់ប្រុស និងស្រី

*យើងសង្កេតឃើញថាការវិវត្តវាក្យសព្ទពីខ្មែរចាស់ ទៅខ្មែរទំនើប គឺនៅក្នុងការប្រើប្រាស់ពាក្យសម្គាល់ «លិង្គ» ក្នុងភាសាខ្មែរចាស់។ នៅក្នុងភាសាខ្មែរទំនើប យើងប្រើពាក្យមួយគូរ ដើម្បីសម្គាល់ថាពាក្យនោះប្រើសម្រាប់សម្គាល់ «លិង្គ» គឺពាក្យ «ប្រុស» និង «ស្រី» ដែលជាពាក្យកម្ចីពីសំស្ក្រឹត* «puruṣa» *និង* «strī»*។ នៅក្នុងភាសាខ្មែរចាស់ ដើម្បីសម្គាល់ «លិង្គ» ប្រុស ឬស្រី គេត្រូវប្រើប្រាស់នូវសមាសនាម ដូចមាននៅក្នុងឧទាហរណ៍ខាងក្រោម៖ ពាក្យ «កុ» និង «កន្ដែ» សម្រាប់សម្គាល់ «នារី» ហើយពាក្យ «វ៉» សម្រាប់សម្គាល់បុរស តែត្រូវអានថា «វា»។*

*កុត្បោញ១ កុលចក១ កោនកុ៣*



*វាក្វារ១ កុកន្ដៅ១ កោនកុវាអលង១*



*កោនកុវាអលង = កូនប្រុសរបស់មនុស្សស្រីឈ្មោះអលង*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ព្យាង្គរាយ ផ្ញើជើង និងព្យាង្គតម្រួត

ពាក្យ គឺជាកាពរួមនៃសូរសំឡេងនិងន័យ។ ពាក្យអាចចែកចេញជា៖ (១) ពាក្យដើមដែលពុំអាចធ្វើជាឫសសម្រាប់បង្កើតពាក្យដទៃទៀតបាន ដូចជាពាក្យ មនុស្ស ក្របី គោ ស្វាបព្រា (២) ពាក្យដើមដែលអាចធ្វើជាឫសសម្រាប់បង្កើតពាក្យដទៃទៀតបាន ដូចជា៖ ឱយ > អំណោយ និង (៣) ពាក្យបង្កើតដែលគេអាចបំបែកជាពាក្យឫស និង ជាផ្នត់កម្លាយ ឬជាពាក្យបន្ថែមបាន ដូចជា៖ គេរាំ = គេ + រាំ។

**ព្យាង្គរាយ**

បរិភោគ 

**ផ្ញើជើង**

ក្ដុំ 

ត្មុរ (គោ) 

ក្របិ (ក្របី) 

**ព្យាង្គតម្រួត**

រាប្រ្ទ = រាស្ត្រ 

លង្កាយ៑ 



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



មន្ត្រី(K. 569 បន្ទាយស្រី សតវត្សទី១០)



កម្រេក( កម្រើក)(K. 484 ភិមានអាកាស)



ចិន្តា (K. 484 ភិមានអាកាស)



វន្ទះ (K. 484 ភិមានអាកាស)



ទក្សិន



(K. 331Sa ម្នាំ )



(K. 331Sa បំយ៉្យង )



ស្វប្ន( សប្តិ)



ចិចេំ( ចិញ្ចើម)



តុត( ដុត)



ផ្នេក( ភ្នែក)



ផ្លេង( ភ្លើង)



ជ្វន( ជូន)



(K. 331A. ជំនូន )



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia



( K. 563 រុង<អំរុង ជំ )



( K. 562 ខ្នេត )



( K. 426 ប្រទាន )



( K. 331A ក្នេត្ត )



( K. 331A( តិង>ត្មិង) ដេញ)



( K. 331A( តោង>ត្មោង) ទូង)



( K. 331A( ចាប>ឆ្មាប) ចាប់)



( K. 653 សំ>ផ្សំ )



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## គោលការណ៍នៃការបង្កើតពាក្យដោយកម្លាយ

ពាក្យក្នុងភាសាខ្មែរចាស់ត្រូវបានបង្កើតឡើង ដោយប្រើវិធីកម្លាយ (Morphology)។ ពាក្យក្លាយ គឺជាពាក្យដែលបង្កើតចេញមកពីពាក្យឫស ដោយបន្ថែមលើពាក្យឫសនោះនូវផ្នត់ដើម (Prefix) ឬផ្នត់ដែក (Infix)។ ពាក្យថ្មីៗដែលត្រូវបានបង្កើតឡើងដោយវិធីផ្នត់ដើម និងវិធីផ្នត់ដែកច្រើនតែពាក្យដែលតាងបញ្ញត្តិរូបី។

ផ្នត់ដើម

ប្រេ > បំរេ >  

>  

ផ្នត់ដែក

ឱយិ > អំនោយិ  > 

ពោច > ណ្ឋ៌ោចិ  >  (K. 852)

## ការបង្កើតពាក្យដោយការផ្សំ

ការបង្កើតពាក្យដោយការផ្សំមានច្រើនបែបៈ ការបន្ថែមពាក្យដើម ការបន្ថែមពាក្យចុង និងការផ្សំពាក្យ (នាមផ្សំ គុណនាមផ្សំ និងកិរិយាផ្សំ)។

### ការបន្ថែមពាក្យដើម

ការបង្កើតពាក្យដោយបន្ថែមពាក្យដើម គឺជាការបន្ថែមខាងដើមពាក្យឫស ដូចជាៈ ការ-, គេ-, អ្នក-, ជាដើម។ 

ពាក្យផ្សំបែបខ្មែរៈ គេរមិ = អ្នករបាំ 

អ្នកបំរេ (K. 331Sa) លលៃ សតវត្សទី៩



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ការផ្សំសូរត្ថអក្សរ

*ភាសាខ្មែរចាស់មានវិធីផ្សំពាក្យ ដើម្បីបង្កើតពាក្យថ្មី ដែលជាសមាស នាមៈ*

*កោនកុរ៉ាអលង៍ = កូនប្រុសរបស់មនុស្សស្រីឈ្មោះអលង៍*



## ៣.៣. វាក្យសម្ព័ន្ធក្នុងភាសាខ្មែរចាស់

*ការសិក្សាការវិវត្តនៃភាសាត្រូវផ្តោតលើវិធានក្នុងការបង្កើតល្បះ* (syntaxe) *ផងដែរ ដូចជាៈ* (១) *ប្រធាននៃល្បះ* (២) *កិរិយាស័ព្ទ និង* (៣) *កម្មវត្ថុនៃល្បះ។ នៅសតវត្សទី៧ ភាសាខ្មែរចាស់ត្រូវបានបង្កើតឡើងបាន ជាងមួយសតវត្សរួចមកហើយ។ យើងឃើញថា នៅក្នុងសិលាចារឹក* K.600 *គេអាចប្រើប្រាស់ភាសាខ្មែរចាស់ ដើម្បីកត់ត្រាពីសកម្មភាពខាងផ្នែកសាសនា និងពិពណ៌នាបានយ៉ាងល្អនូវអំណោយ ដែលពោញឪយបានធ្វើអំណោយ ជាខ្ញុំបម្រើដល់ព្រះក្បោញកម្រតាងអញ។*

## សម្ព័ន្ធឃ្លា

*ឃ្លាប្រយោគ ឬល្បះត្រូវមានប្រធាន កិរិយាស័ព្ទ និងកម្មបទៈ*



| *ប្រធាន* | *ការិយាស័ព្ទ* | *កម្មវត្ថុ* |
|---|---|---|
| *ពោញឪយ* | *ឱយ* | *គុំព្វតក្បោញកម្រតាងអញ* |
| *ពោញឪយ* | *ធ្វើអំណោយជា* | *ខ្ញុំដល់ក្បោញកម្រតាងអញ* |

## **សព្វនាម** ( Pronoun )

*សព្វនាមសម្រាប់ប្រើជំនួសកន្សោមនាម ដែលគេនិយាយរួចហើយ ដែលគេពុំទាន់និយាយ និងបង្ហាញបុគ្គលរួមក្នុងការប្រាស្រ័យទាក់ទងគ្នា។ សព្វនាមអាចចែកចេញជាថ្នាក់ផ្សេង៖ (១) សព្វនាមបុរិសៈ ដូចជា ខ្ញុំគេ (២) សព្វនាមចង្អុល (៣) សព្វនាមសំណួរ និង (៤) សព្វនាមឈ្នាប់។*

*សព្វនាមឈ្នាប់ «ពួត»*

*ពួត*  *ទៅឱ្យ*

*សព្វនាមឈ្នាប់ «តេល»*

*ពាក្យ «តេល» នៅក្នុងសិលាចារឹកមុនអង្គរត្រូវបានប្រើជាគុណនាម «ដែល» ដូចក្នុងសិលាចារឹកវត្តត្នោត (K. 38) មកបញ្ជាក់ដូចខាងក្រោម៖*

*គេក្ញុំបោញតាងអញតេលឱយតវ្រះស្វយំកុគេវ្រះផោងតេល = ខ្ញុំបម្រើ ដែលរបស់បោយតាងអញ ថ្វាយជូនព្រះស្វយម្ភូ មានព្រះអាទិទេពផងដែល*



## **ការប្រើវណ្ណយុត្តិ**



## **ការប្រើប្រាស់សញ្ញា** (០)

*០ បោញឧយឱយក្ញុំពួតក្បោញកម្រតាងអញ ០ វាក្វបិត១ វាកន្តាងស្រាង១ វាត្នោង១ វាក្វារ១ កុកន្តៅ១ កោនកុវាអលង១ កុយលេង១ ត្នុរ៦០ ក្របី២ វវេ១០ តោងត្មែំ៤០ ស្រេសទ្រេ២ ពួអំបោង០*

ផ្ទះគេរមិ០ ចរុមតី១

ឈ្មោះអ្នករបាំះ ចរុមតី ១

## ការប្រើប្រាស់ខ័ណ្ឌ

សញ្ញាខណ្ឌ (ៗ)  (K. 226)

## ៣.៤. ការវិវត្តវាក្យសព្ទពីខ្មែរចាស់ ទៅខ្មែរទំនើប

យើងអាចសិក្សាការវិវត្តនៃភាសា «ខ្មែរចាស់» ដោយផ្អែកលើះ (១) និយណ្ដសាស្ត្រ (sémantiuqe) ពោលគឺន័យរបស់ពាក្យ (២) សូរសាស្ត្រ (phonétique) គឺការបញ្ចេញសំឡេង និងវិធីអាន និង (៣) រូបសាស្ត្រ (morphologie) គឺវិធីភ្ជាប់ពាក្យតាមផ្នែកវេយ្យាករណ៍ (grammaire)ៗ ការសិក្សាការវិវត្តនៃភាសាត្រូវផ្ដោតលើវិធានក្នុងការបង្កើតឃ្លះ (syntaxe) ផងដែរដូចជាះ(១) ប្រធាននៃឃ្លះ(២) កិរិយាស័ព្ទនិង(៣) កម្មវត្ថុនៃឃ្លះៗ

លោកសាស្ត្រាចារ្យ Philip Jenner បានវិភាគយ៉ាងល្អិតល្អន់នូវវាក្យសព្ទនៃភាសាខ្មែរចាស់មុនសម័យអង្គរ ហើយបានរកឃើញថា សិលាចារឹកមុនអង្គរទាំងអស់ (ទាំងមាន និងគ្មានកាលបរិច្ឆេទ)ប្រើប្រាស់ពាក្យទាំងអស់ចំនួន ៥ ៨២៩ ពាក្យៗ សិលាចារឹក ដែលគ្មានកាលបរិច្ឆេទមានពាក្យទាំងអស់ចំនួន ៣ ២៧០ពាក្យ ហើយ ៥៣%នៃពាក្យទាំងនោះ គឺជាឈ្មោះរបស់ក្ញុំបម្រើ ហើយពាក្យយ៉ាងច្រើនលើសលប់ ជាពាក្យខ្មែរចាស់ៗ នៅក្នុងសិលាចារឹកដែលគ្មានកាលបរិច្ឆេទទាំងនោះ ពាក្យចំនួន ៩៣៣ ដែលស្មើនឹង ២៧% គឺជាពាក្យកម្ចី ដែលភាគច្រើន គឺជាកម្ចីពីវាក្យសព្ទសំស្ក្រឹតៗ ពាក្យមួយព្យាង្គមានចំនួន៣១% ហើយពាក្យកម្លាយពីរព្យាង្គមានចំនួន ៤២%ៗ ចំណែកឯសិលាចារឹក ដែលមានកាលបរិច្ឆេទមានពាក្យទាំងអស់ចំនួន ២



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៣៦៥ពាក្យ ហើយពាក្យចំនួន ១០០៨ ឬ៤២%នៃពាក្យទាំងនោះ គឺជាឈ្មោះរបស់ក្ញុំបម្រើ និងនរនាមឯទៀត។ នៅក្នុងសិលាចារឹកដែលមានកាលបរិច្ឆេទទាំងនោះ ពាក្យមួយព្យាង្គមានចំនួន៣៣% ហើយពាក្យចំនួន ៣០% គឺជាពាក្យកម្ចី ដែលភាគច្រើនលើសលប់ គឺជាកម្ចីពីវាក្យសព្ទសំស្ក្រឹត។[66]

## ការផ្លាស់ប្តូរអក្ខរក្រម

តាមរយៈការសិក្សានេះយើងឃើញថាថ្វីត្បិតតែអក្ខរក្រមភាសាខ្មែរចាស់មានការផ្លាស់ប្តូរ ទាំងនៅក្នុងសម័យបុរេអង្គរ (ពីសតវត្សទី៦ ដល់ទី៨) និងទាំងនៅក្នុងសម័យអង្គរ (ពីចុងសតវត្សទី៨ ដល់សតវត្សទី១២) តែយើងសង្កេតឃើញមានការប្រែប្រួលពីរសំខាន់ៗគឺៈ

(១) ការប្រែប្រួលអក្ខរក្រមពីបុរេអង្គរ មកសម័យអង្គរ ជាពិសេសនៅក្នុងអំឡុងដើមសតវត្សទី៩ នៅពេលដែលមានការផ្លាស់ប្តូររបបនយោបាយក្នុងរជ្ជកាលព្រះបាទជ័យវម្ម៌ ទី២ និងព្រះបាទជ័យវម្ម៌ ទី៣ នៅពេលបង្កើតអាណាចក្រខ្មែរ ដោយការបង្រួបបង្រួមដែនដី។





66. Jenner, 1980



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ការផ្លាស់ប្តូរអក្សរក្រម

(២) ការប្រែប្រួលអក្សរក្រមពីសម័យមុនរជ្ជកាលព្រះបាទជ័យវម៌្ម ទី៧ មកសម័យរជ្ជកាល ព្រះបាទជ័យវម៌្ម ទី៧ នៅក្នុងអំឡុងចុងសតវត្សទី១២-ដើមសតវត្សទី១៣ នៅពេលដែលមានការផ្លាស់ប្តូរសាសនារដ្ឋពីព្រហ្មញ្ញសាសនា មកព្រះពុទ្ធសាសនាមហាយាន។





## ការវិវត្តអក្សរក្រមខ្មែរ

| | |
|---|---|
|  | ព្រះកម្រតាងអញ (K.426 វត្តដើមឯក) |
|  | ព្រះកម្រតេងអញ (K.331Sa លលៃ) |
|  | ព្រះបាទកម្រតេងអញ ត្រីធរណីន្ទ្រវម៌្មទេវ(K.852) |
|  | ធូលីជេងព្រះកម្រតេងអញ (K.331Sa) |
|  | ព្រះបាទធូលីជេងព្រះកម្រតេងអញ (K.266 បាទជុំ) |
|  | កម្រតេងផ្ទែកពៅព្រះរាជា (K . 484 ភិមានអាកាស) |

# ការផ្លាស់ប្តូររបៀបសរសេរពាក្យ

| | | |
|---|---|---|
| ហ្វ=វ | មិនសូវមាន | ថ |
| េ | អ្យ | ថ |
| បន្ទេក | បន្ទ្យក | ក្រណាត់ |
| ក្ញុំ  | ខ្ញុំ | ខ្ញុំ |
| ក្មោង | ខ្មោញ | គោរមង៌ារ |
|  |  | ព្រះ |
| កុ  | តៃ  | ស្រី |
| ស្រី | ស្រី | ស្រី |
| ស្រី | ស្រី | ស្រី |

## ការវិវត្តសូរស័ព្ទ

យើងអាចសិក្សាការវិវត្តនៃសូរស័ព្ទ តាមរយៈការវិភាគពីការវិវត្តអក្ខរាវិរុទ្ធនៃពាក្យខ្មែរចាស់ និងខ្មែរទំនើប ដោយពិនិត្យការប្រើស្រៈ។ លោកសាស្ត្រាចារ្យ Sakamoto បានប្រើវិធីសាស្ត្រនេះដោយពិនិត្យពាក្យដូចគ្នានៅក្នុងខ្មែរចាស់ និងខ្មែរទំនើប។[67]

67. Sakamoto, 1970



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ការវិវត្តពាក្យពីខ្មែរចាស់សម័យមុនអង្គរ ដល់ខ្មែរទំនើប

| ខ្មែរចាស់ | ខ្មែរចាស់ | ខ្មែរទំនើប |
|---|---|---|
|  (K.600) | កោន | កូន |
|  (K.38) | ផោង | ផង |
|  (K.38) | គិ | គឺ |
|  (K.38) | ស្រេ | ស្រែ |
|  (K.38) | លុច | លិច |
|  (K.38) | ត្លៃ | ថ្ងៃ |
|  (K.38) | ត្រវង | ត្រពាំង |
|  (K.38) | ប្រេ | ប្រើ |
|  (K.38) | រាជ | រាជ |
|  (K.38) | បំរេ | បំរើ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
|  (K.600) | គិតនានេះ | គឺនៅទីនេះ |
|  (K.600) | មាស | មាស |
|  (K.600) | មាស | មាស |
|  (K.600) | ផ្ទះ | ឈ្មោះ |
|  (K.600) | ក្ដេ | ក្ដៃ |
|  (K.600) | វ្រះ | ព្រះ |
|  (K.331A) | ម្ទាំ | អ្នកពាំ |

## ការផ្លាស់ប្តូរពីសរសេរជាលេខមកជាពាក្យ






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ម្វយ = មួយ

វ្យរ = ពីរ

បិយ = បី

ប្វន = បួន

ប្រំ = ប្រាំ

ប្រាំម្វយ= ប្រាំមួយ

ប្រំវរ ឬ ប្រំវ្យល

ប្រាំពីរ ឬ ប្រាំពិល

ប្រំបិយ= ប្រាំបី



ប្រំប្វន = ប្រាំបួន

តប្ស = ដប់

តប្សបិយ = ដប់បី

តប្សប្វន = ដប់បួន

តប្សប្រំបិយ

= ដប់ប្រាំបី

តប្សប្រំបិយ

= ដប់ប្រាំបី

## ថ្ងៃ និង ទិស



អាទិត្យវារ = ថ្ងៃអាទិត្យ

ចន្ទ្រវារ = ថ្ងៃចន្ទ

អង្គាររវារ = ថ្ងៃអង្គារ

វុធវារ / វុទ្ធវារ = ថ្ងៃពុធ

វ្រហស្បតិវារ = ថ្ងៃព្រហស្បតិ៍

គុក្រវារ = ថ្ងៃសុក្រ

សៅរវារ / សនៃឝ្ចរវារ = ថ្ងៃសៅរ៍




## ការផ្លាស់ប្តូររបៀបសរសេរពាក្យ

លោក Cœdes៖ ទម្រង់នៃភាសាខ្មែរចាស់បុរេអង្គរ និងអង្គរ ឆ្លុះបញ្ចាំង តាមរយៈគ្រាមភាសាក្នុងតំបន់ផ្សេងៗ ដូចជា សៀមរាប និងសុរិន្ទ និង ភាគខាងត្បូងជាដើម។

លោក Jenner៖ ភាសាខ្មែរអង្គរអាចរកឃើញនៅក្នុងអត្ថបទមុនឆ្នាំ ៨០២។ ភាសាអង្គរអាចជាគ្រាមភាសានៅក្នុងភាសាខ្មែរភាគខាងជើង ជាជាងការផ្លាស់ប្តូរជាប្រព័ន្ធនៅក្នុងភាសាខ្មែរ។ ភាពខុសគ្នាគឺ៖ (១) ភាសាខ្មែរមុនអង្គរ គឺភាសាខ្មែរកណ្តាល និងភាសាខ្មែរភាគខាងត្បូង និង (២) ភាសាខ្មែរអង្គរ គឺភាសាខ្មែរនៅតំបន់ខាងជើង (សៀមរាប និងសុរិន្ទជាដើម)។ ក្រោយសតវត្សទី១៥ មជ្ឈមណ្ឌលនយោបាយបានផាកមកភាគខាងត្បូង និងកណ្តាលវិញ។

លោក Vickery៖ ក្នុងរយៈពេលជាង ៧ សតវត្ស មានការផ្លាស់ប្តូរយ៉ាងខ្លាំង ខាងផ្នែកសរសេរពាក្យ និងវេយ្យាករណ៍ មិនមែនតែរវាងសម័យកាលពីរ គឺបុរេអង្គរ និងអង្គរប៉ុណ្ណោះទេ តែការផ្លាស់ប្តូរនៅក្នុងសម័យអង្គរ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក៏មានដែរ៖

ការផ្លាស់ប្តូរវាក្យសព្ទធ្ងុះបញ្ចាំងការផ្លាស់ប្តូរខាងផ្នែកស្ថាប័ន

ឋានន្តរនាម «បោញ» លែងប្រើក្រោយសតវត្សទី៨

## ការផ្លាស់ប្តូររបៀបសរសេរពាក្យ

វាក្យសព្ទបុរេអង្គរ «អាជ្ញាវ្រះកម្រតាងអញ» អង្គរ «វ្រះគាសន» គឺ ព្រះរាជបញ្ញត្តិ

ដី ១០ «សរេ ឬ សទ្រេ» លែងប្រើក្រោយសតវត្សទី៨

ការផ្លាស់ប្តូរការដាក់ឈ្មោះប្រជាជនសាមញ្ញនៅសម័យបុរេអង្គរ និង សម័យអង្គរ

ការបង្កើតពាក្យថ្មី ពីពាក្យឫសឯកព្យាង្គ (CV(F)) (ព្យញ្ជនៈ-ស្រៈ-ព្យញ្ជនៈ/ស្រៈ) ដោយប្រើផ្នត់ដើម និងផ្នត់ដែក (CCVF) (ព្យញ្ជនៈ-ព្យញ្ជនៈ-ស្រៈ-ព្យញ្ជនៈ/ស្រៈ) ជួល>ឈ្នួល

ការផ្លាស់ប្តូរវេយ្យាករណ៍ខ្មែររវាងខ្មែរចាស់មុនអង្គរ និងខ្មែរចាស់សម័យ អង្គរ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៣.៥. មូលដ្ឋានគ្រឹះនៃភាសាខ្មែរចាស់




*ភាសា «ខ្មែរចាស់» វិវត្តក្រោមឥទ្ធិពលនៃព្រឹត្តិការណ៍នយោបាយ និងព្រឹត្តិការណ៍ផ្សេងទៀតដូចជាសាសនានិងសង្គម។ យើងសង្កេតឃើញថា ទំនាក់ទំនងរវាងភាសាសំស្ក្រឹត និងភាសាខ្មែរមានចរិតវិចារវិទ្យាៈ (១) ភាសាសំស្ក្រឹតមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើការវិវត្តភាសាខ្មែរចាស់ ដោយសារដូនតាខ្មែរបានខ្ចីពីភាសាសំស្ក្រឹត ដើម្បីអភិវឌ្ឍភាសាខ្មែរចាស់ (២) ភាសាខ្មែរមានឥទ្ធិពលទៅលើភាសាសំស្ក្រឹតនៅប្រទេសកម្ពុជាសម័យមុនអង្គរ និងនៅសម័យអង្គរ ដោយសារតែកំណាព្យជាភាសាសំស្ក្រឹតនៅកម្ពុជាគឺជាកំណាព្យដែលគេទទួលស្គាល់ថា សរសេរបានល្អជាងកំណាព្យជាភាសាសំស្ក្រឹតនៅប្រទេសឥណ្ឌាទៅទៀត។ តាមរយៈទំនាក់ទំនងរវាងជនជាតិឥណ្ឌា ដែលប្រើប្រាស់ភាសាសំស្ក្រឹត និងប្រជាពលរដ្ឋខ្មែរតាំងតែពីសម័យហ្វូណននេះហើយ ទើបយើងឃើញនូវកម្ចីពាក្យសំស្ក្រឹតជាច្រើននៅក្នុងភាសាខ្មែរចាស់។*[68]

68. Jenkins, 2014



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ការប្រើភាសាខ្មែរ និងភាសាសំស្ក្រឹត

អ្នកស្រាវជ្រាវបានធ្វើចំណាត់ថ្នាក់សិលាចារឹកខាងលើជា៖ (១) សិលាចារឹកជាភាសាសំស្ក្រឹតសុទ្ធ (២) សិលាចារឹកជាភាសាខ្មែរចាស់សុទ្ធ និង (៣) សិលាចារឹកជាភាសាសំស្ក្រឹត ជាមួយនឹងភាសាខ្មែរចាស់។ តាមការបូកសរុបរបស់លោក Phillipe Jenner សិលាចារឹកជាភាសាសំស្ក្រឹតមានចំនួនទាំងអស់ ៥០៣ អត្ថបទ។ ចំណែកឯសិលាចារឹកភាសាខ្មែរមានចំនួន ៦១៩ អត្ថបទ ដែលភាគច្រើនលើសលុប (៤៥៥ អត្ថបទ) ត្រូវបានចារនៅក្នុងសម័យអង្គរ។[69]

ថ្វីត្បិតតែនៅលើសិលាចារឹក អ្នកនិពន្ធបានប្រើប្រាស់ភាសាទាំងពីរ តែអត្ថបទខ្មែរចាស់មិនមែនជាអត្ថបទបកប្រែពីអត្ថបទសំស្ក្រឹតឡើយ ដោយសារតែអត្ថបទទាំងពីរនេះសរសេរពីរឿងរ៉ាវខុសគ្នា។ ក៏ប៉ុន្តែ ក៏មានអត្ថបទផ្នែកខ្លះនិយាយពីរឿងតែមួយដែរ។[70] ដូច្នេះហើយទើប លោកសាស្ត្រាចារ្យ Sheldon Pollock បានបង្កើតទ្រឹស្តីស្តីពីការបែងចែកតួនាទីរវាងភាសាសំស្ក្រឹត និងភាសាម្ចាស់ស្រុក៖ (១) ភាសាសំស្ក្រឹត ជាភាសាអក្សរសិល្ប៍ ភាសាសម្រស់ (aesthetic) ឬ ភាសានៃអ្នកកាន់អំណាច (២) ភាសាម្ចាស់ស្រុក ជាភាសាសម្រាប់កត់ត្រាបញ្ជីអំណោយ ដែលគេផ្តល់ឱ្យទីវត្តអារាម និងទីសក្ការៈបូជា។[71]

សិលាចារឹកក្នុងសម័យហ្វូណន រវាងសតវត្សទី៥ ដល់សតវត្សទី៦ សុទ្ធសឹងតែជាសិលាចារឹកជាភាសាសំស្ក្រឹតទាំងស្រុង។

សិលាចារឹកជាភាសាសំស្ក្រឹតត្រូវបានតែងនិពន្ធជាកំណាព្យ ចំណែកឯសិលាចារឹកជាភាសាខ្មែរបុរាណ ត្រូវបានតែងនិពន្ធជាភាសាធម្មតា។ ការតែងនិពន្ធជាភាសាខ្មែរបុរាណមិនមែនជាការបកប្រែពីភាសាសំស្ក្រឹតឡើយ។

---

69. ឡុង សៀម 1997
70. Chhom, 2019
71. Chhom, 2019

សិលាចារឹកជាភាសាខ្មែរបុរាណភាគច្រើនរៀបរាប់ពីបញ្ជីនៃការធ្វើអំណោយទៅដល់ប្រាសាទនានា។ សិលាចារឹកភាសាខ្មែរពិពណ៌នាពីការកសាងប្រាសាទ ស្រុក ភូមិស្ថាន សកម្មភាពសាសនា សង្គមកិច្ច កិច្ចការរដ្ឋបាល អំណោយទានដល់វត្តអារាម និងអាទិទេព នូវដីធ្លី ច្បារដំណាំ ស្រែចម្ការ ទាសាទាសី សត្វពាហនៈ និងគ្រឿងសក្ការបូជាជាដើម។ សិលាចារឹកទាំងនេះរៀបរាប់ផងដែរពីពិធីសក្ការបូជាទេវរាជ ការពានដីថ្មីដើម្បីរៀបចំស្រុក សាងសង់វត្តអារាម ជីកស្រះ សង់ទំនប់ទឹក ការតាំងទីលំនៅ។[72]

អ្នកប្រាជ្ញខ្មែរចេះភាសាសំស្ក្រឹតបានយ៉ាងស្ទាត់ជំនាញ និងបានតែងកំណាព្យចារលើសិលាចារឹកភាសាសំស្ក្រឹតត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ ហើយពេលខ្លះត្រឹមត្រូវជាងសិលាចារឹកភាគច្រើនរបស់ឥណ្ឌាថែមទៀតផង។[73] អ្នកប្រាជ្ញជាច្រើនបានចាត់ទុកថា គឺជាកាព្យសំស្ក្រឹតនៃសិលាចារឹកកម្ពុជាពីរោះជាងគេលើពិភពលោក។[74] របៀបសរសេរកំណាព្យប្រែប្រួលទៅតាមអ្នកនិពន្ធ។ សិលាចារឹកក៏មានគោលដៅផងដែរ ក្នុងការកត់ត្រាទង្វើប្រកបដោយបុណ្យ (puṇya) និង ទង្វើប្រកបដោយធម៌ (dharma) ឬទង្វើប្រកបដោយគុណូបការ។

តាមរយៈសិលាចារឹកភាសាសំស្ក្រឹត យើងអាចសន្និដ្ឋានបានថា ភាសាសំស្ក្រឹតបានក្លាយជាភាសាសម្រាប់បញ្ញវន្ត ក្នុងការរៀនសូត្រ។

---

72. ឡុង សៀម, 1997

73. Bhattacharya, 1991

74. អាំង ជូលាន, 2018



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## កម្ចីពីវាក្យសព្ទសំស្ក្រឹត

លោកសាស្ត្រាចារ្យ Philip Jenner បានវិភាគយ៉ាងល្អិតល្អន់នូវវាក្យសព្ទនៃភាសាខ្មែរចាស់មុនសម័យអង្គរ ហើយបានរកឃើញថា សិលាចារឹកមុនអង្គរទាំងអស់ (ទាំងមាន និងគ្មានកាលបរិច្ឆេទ)ប្រើប្រាស់ពាក្យទាំងអស់ចំនួន ៥ ៨៤៩ ពាក្យ។ សិលាចារឹក ដែលគ្មានកាលបរិច្ឆេទមានពាក្យទាំងអស់ចំនួន ៣ ៤៧០ពាក្យ ហើយ ៥៣%នៃពាក្យទាំងនោះ គឺជាឈ្មោះរបស់ក្ញុំបម្រើ ហើយពាក្យយ៉ាងច្រើនលើសលប់ ជាពាក្យខ្មែរចាស់។ នៅក្នុងសិលាចារឹកដែលគ្មានកាលបរិច្ឆេទទាំងនោះ ពាក្យចំនួន ៩៣៣ ដែលស្មើនឹង ២៧% គឺជាពាក្យកម្ចី ដែលភាគច្រើន គឺជាកម្ចីពីវាក្យសព្ទសំស្ក្រឹត។ ពាក្យមួយព្យាង្គមានចំនួន៣១% ហើយពាក្យកម្ចាយពីរព្យាង្គមានចំនួន ៤២%។ ចំណែកឯសិលាចារឹក ដែលមានកាលបរិច្ឆេទមានពាក្យទាំងអស់ចំនួន ២ ៣៦៥ពាក្យ ហើយពាក្យចំនួន ១០០៨ ឬ៤២%នៃពាក្យទាំងនោះ គឺជាឈ្មោះរបស់ក្ញុំបម្រើ និងនរនាមឯទៀត។ នៅក្នុងសិលាចារឹកដែលមានកាលបរិច្ឆេទទាំងនោះ ពាក្យមួយព្យាង្គមានចំនួន៣៣% ហើយពាក្យចំនួន ៣០% គឺជាពាក្យកម្ចី ដែលភាគច្រើនលើសលប់ គឺជាកម្ចីពីវាក្យសព្ទ សំស្ក្រឹត។[75]

ខ្មែរក៏បានខ្ចីគ្រាមភាសាឥណ្ឌា ដែលមិនមែនជាភាសាសំស្ក្រឹតមកប្រើក្នុងភាសាខ្មែរបុរាណផងដែរ ដែលលោកស្រីបណ្ឌិត ពៅ សាវរស ដាក់ឈ្មោះថាជា «ប្រាក្រិត» (prākrit) ដូចជាពាក្យ បល្ល័ង្ក (pallanka) អំពិល (aṃvil) ទោ (do) ជាដើម។

ពាក់ព័ន្ធនឹងកម្ចីពាក្យសំស្ក្រឹតក្នុងភាសាខ្មែរ អ្នកស្រាវជ្រាវបានធ្វើសេចក្តីសន្និដ្ឋានដូចតទៅ ៖

ទីមួយ-ពាក្យសំស្ក្រឹតដែលមានពីរ ឬបីព្យាង្គ ត្រូវបានបំលែងឱ្យទៅជាពាក្យខ្មែរ ដែលមានមួយព្យាង្គ ដែលមានមួយព្យាង្គមានក្រុមព្យញ្ជនៈ

75 Jenner, 1980



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅខាងដើម ដែលបណ្ឌិត ឡុង សៀម ហៅថានិន្នាការឯកព្យាង្គក្នុងការវិវត្ត សូរស័ព្ទភាសាខ្មែរ។

ទីពីរ-ពាក្យខ្មែរសុទ្ធ ឬពាក្យកម្ចី ដែលត្រូវបានបំលែងមកជាពាក្យខ្មែរមិនអាចលើសពីពីរព្យាង្គបានឡើយ ហើយនៅចុងពាក្យមិនអាចមានព្យញ្ជនៈលើសពីមួយទេ។ ចំណែកឯព្យញ្ជនៈចុងពាក្យនេះ អាចជាព្យញ្ជនៈច្រមុះ ប៉ុន្តែមិនអាចជាព្យញ្ជនៈបិទអាស្តីរេ ឬបិទសូន័រឡើយ។

ទីបី-ដូនតាខ្មែរបានខ្ចីពាក្យសំស្ក្រឹត និងពាក្យប្រាក្រិត (ពាក្យឥណ្ឌាចាស់) មកប្រើ ដោយមិនខ្វល់នឹងការបញ្ចេញសំឡេងទេ។[76]

ទីបួន-ដំណើរការបំលែងពាក្យពីសំស្ក្រឹត ឱ្យទៅជាពាក្យខ្មែរនេះប្រព្រឹត្តទៅយ៉ាងយឺតៗអស់ពេលជាច្រើនសតវត្ស។

ទីប្រាំ-ការប្រើប្រាស់ភាសាសំស្ក្រឹតជាភាសាផ្លូវការនៅសម័យអង្គរសម្រាប់តែងអត្ថបទរាជក្រឹត្យ និងរឿងនិពន្ធក្នុងផ្នែកសាសនា ជាមូលហេតុនៃការសរសេរមានពាក្យខ្មែរលាយឡំនឹងពាក្យសំស្ក្រឹត។

ទីប្រាំមួយ-កម្ចីពាក្យសំស្ក្រឹត ដើម្បីប្រើប្រាស់ជាពាក្យវប្បធម៌ ក្នុងវិស័យសាសនា នយោបាយ នីតិសាស្ត្រ និងរដ្ឋបាល ។

ទីប្រាំពីរ-កម្ចីពាក្យសំស្ក្រឹត ដើម្បីប្រើប្រាស់សម្រាប់ដាក់ឈ្មោះអាទិទេព (ទេវនាម) សម្រាប់សម្គាល់ឈ្មោះទីកន្លែង (ឋាននាម) និងសម្រាប់ដាក់ឈ្មោះមនុស្ស (នរនាម)។

ទីប្រាំបី-ការបញ្ជ្រាបពាក្យសំស្ក្រឹតទៅក្នុងភាសាខ្មែរ ដែលប្រើប្រាស់នៅក្នុងជីវភាពប្រចាំថ្ងៃ ដូចជាពាក្យ «កុមារ» «ប្រិមប្រិយ»។

គេយកពាក្យសំស្ក្រឹតជាគោល សម្រាប់បង្កើតពាក្យថ្មី ដូចជាការប្របាច់បញ្ចូលពាក្យបាលី និងសំស្ក្រឹតចូលគ្នា ដើម្បីបង្កើតពាក្យថ្មី ដូចជាពាក្យ៖ (១) អធិ+បតី= អធិបតី (២) ធម្ម+ិក= ធម្មិក (៣) វីរ+បុរស=វីរបុរស ជាដើម។ អ្នកប្រាជ្ញខ្មែរបានធ្វើខ្មែរនីយកម្មនៃពាក្យសំស្ក្រឹត ដោយ៖ (១)

76. Ménétrier, E., 1933



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កែប្រែសូររបស់ពាក្យសំស្ក្រឹត ដូចជាពាក្យ រណសិរ្ស និង មាតា (២) បង្រួញព្យាង្គ ដូចជាពាក្យ ពោធិ៍ ពេទ្យ៍ និងព្រហស្បតិ៍ ជាដើម។

ទោះបីជាមានពាក្យកម្ចីពីសំស្ក្រឹត និងបាលីយ៉ាងច្រើនក៏ដោយ ភាសាខ្មែរមិនស្ថិតនៅក្នុងអំបូរឥណ្ឌូ-អឺរ៉ុបឡើយ ដោយសារនេះគ្រាន់តែជាន័យរបស់ពាក្យ (sémantique) តែប៉ុណ្ណោះ ហើយចំណាត់ថ្នាក់ភាសា គេធ្វើតាមសូរសាស្ត្រ (phonétique) វិធីអាន ការផ្លាស់ប្ដូរកន្ទុយពាក្យ (morphologie) និងវេយ្យាករណ៍ជាដើម។

ភាសាខ្មែរចាស់បានខ្ចីពាក្យជាច្រើនពីភាសាសំស្ក្រឹត។ ពាក្យសំស្ក្រឹតដែលមានពីរ ឬ បីព្យាង្គ ត្រូវបានបំលែងឱ្យទៅជាពាក្យខ្មែរ ដែលមានមួយព្យាង្គ ដែលគេស្គាល់ថា និន្នាការឯកព្យាង្គក្នុងការវិវឌ្ឍសូរស័ព្ទភាសាខ្មែរ។ ជាទូទៅពាក្យខ្មែរសុទ្ធ ឬ ពាក្យកម្ចីដែលបំលែងមកជាពាក្យខ្មែរ មិនអាចលើសពីពីរព្យាង្គឡើយ។ នៅចុងពាក្យមិនអាចមានព្យញ្ជនៈលើសពីមួយទេ។ ព្យញ្ជនៈចុងពាក្យនេះអាចជាព្យញ្ជនៈច្រមុះ ប៉ុន្តែមិនអាចជាព្យញ្ជនៈបិទអាស្ពីរេ ឬ បិទសូន័រឡើយ។ ដំណើរការបំលែងពាក្យពីសំស្ក្រឹតទៅជាពាក្យខ្មែរបុរាណប្រព្រឹត្តទៅអស់រយៈពេលជាច្រើនសតវត្ស ។[77]

នៅក្នុងសិលាចារឹកទួល វត្តគំនូរ (K. 600) គេឃើញមានពាក្យកម្ចីសំស្ក្រឹតជាច្រើន ដែលខ្មែរខ្ចីពាក្យពីសំស្ក្រឹតមកប្រើ ដើម្បីបំពេញបន្ថែមពាក្យជាភាសាខ្មែរបុរាណ។ ពាក្យសំស្ក្រឹតត្រូវបានយកមកប្រើប្រាស់ជាឈ្មោះអ្នកចំរៀង និងអ្នករបាំផងដែរ ដែលជាឈ្មោះដែលមានច្រើនព្យាង្គ និងមានន័យដ៏ល្អ ដូចជា វស្សន្តមាលិកា (ផ្កាម្ទិះនាវស្សន្តរដូវ) គន្ធារី (មានគន្ធសម្បត្តិល្អ) ចារុមតី (ម្ហូបចំណីសម្រាប់ពិចារណា) អរុណាមតិ (ធម៌ពេលព្រលឹម) គន្ធិនី (មានក្លិនឈ្ងុយឈ្ងប់)។[78]

---

77. ឡុង សៀម. 1996

78. ឡុង សៀម, 1996

## សំស្ក្រឹតបានជ្រាបចូលក្នុងភាសាខ្មែរ

*កម្ចីវាក្យសព្ទសំស្ក្រឹតស្ដែងចេញតាមរយៈការប្រើប្រាស់ពាក្យសំស្ក្រឹតដ៏ច្រើនលើសលប់ នៅក្នុងសិលាចារឹកជាភាសាខ្មែរបុរាណ។ ក្នុងរយៈពេលជាច្រើនសតវត្ស វាក្យសព្ទសំស្ក្រឹតបានជ្រាបចូលក្នុងសរសៃសរសូងនៃវាក្យសព្ទខ្មែរ។*

*ជនជាតិខ្មែរបានខ្ចីពាក្យសំស្ក្រឹត ដើម្បីប្រើប្រាស់នៅក្នុងភាសាប្រចាំថ្ងៃ ដែលធ្វើឱ្យវប្បធម៌សំស្ក្រឹតចាក់ឫសចូលយ៉ាងជ្រៅនៅក្នុងវប្បធម៌ និងភាសាខ្មែរបុរាណ។ ពាក្យសំស្ក្រឹតត្រូវបានខ្មែរយកមកប្រើក្នុងភាសានិយាយ និងភាសាសាមញ្ញផងដែរ ដូចជា អក្សរៈ* (akṣara) *អគារ* (agāra) *អាគ្នេយ* (agneya) *អង្គៈ* (aṅga) *អង្គរក្ស* (aṅgarakṣa) *អង្គារ* (aṅgāra) *អតិថិ* (atithi) *អតីតៈ* (atīta) *អធិការ* (adhikāra) *អធិបតិ* (adhipati) *ឧបករណ៍* (upakaraṇa)។

*នៅដំណាក់កាលដំបូងនៃការវិវត្តនៃភាសាខ្មែរបុរាណ ដូនតាខ្មែរបានខ្ចីពាក្យសំស្ក្រឹតយកមកប្រើទាំងស្រុងតែម្ដង។ ដូច្នេះហើយ ទើបនៅសតវត្សទី៧ គេកម្រឃើញមានពាក្យដែលមានដើមកំណើតសំស្ក្រឹត ហើយបំលែងយ៉ាងពេញលេញជាភាសាខ្មែរបុរាណណាស់។ ដូនតាខ្មែរបំលែងពាក្យតិចតួចប៉ុណ្ណោះដូចជា៖ (១) ក្លិង្គ (ជនជាតិឥណ្ឌា) ភាសាសំស្ក្រឹតថា* Kalinga (K.1) (២) *ស្មើ (សម* - sama) *ផ្លែ* (K. 90) *ផល* (phala) (៣) *ព្រះ* (K. 600) *ឬ អាទិទេព ដែលមកពីពាក្យសំស្ក្រឹតថា វរ* (vara) *ដែលជាពាក្យបំលែងនាពេលនោះ។*[79]

*ឥទ្ធិពលដ៏ខ្លាំងក្លាលើសលប់នៃភាសាសំស្ក្រឹតនេះស្ដែងចេញ តាមរយៈការយកវាក្យសព្ទសំស្ក្រឹត សម្រាប់ប្រើជា៖ (១) វាក្យសព្ទផ្លូវការ និងពាក្យប្រើប្រាស់ប្រចាំថ្ងៃ (២) ឋាននាម (៣) នរនាម និង (៤) ទេវនាម ដែលគេរកឃើញនៅក្នុងសិលាចារឹកខ្មែរបុរាណ។*

---

79. *ឡុង សៀម*, 1996

## ៣.៦. នាមក្នុងភាសាខ្មែរចាស់

**១. ទេវនាម**

*ទេវនាមត្រូវបានបង្កើតឡើង ដោយប្រើប្រាស់ភាសាសំស្ក្រឹត ដែលជាភាសាពិសិដ្ឋខាងផ្នែកព្រហ្មញ្ញសាសនា៖ (១) គីវះ ទង្វើល្អ ឬបរមសុខ, (២) ភវះ វឌ្ឍនភាព ឬសម្បូររុងរឿង, (៣) អមោឃះ ដុះដាល, (៤) ភទ្រះ សោភ័ណ, (៥) ហរះ បំផ្លាយ (អ្វីដែលអាក្រក់), (៦) រុទ្រ, (៧) ឦសាន, (៨) វិរេទ្រ, (៩) គង្វៃស្រម, (១០) កម្រេទ្គូរ, (១១) ស្វយម្ភុ។*[80]

**២. នរនាម** (**អសាធារណនាម**)

*នរនាមដែលគេជួបប្រទះក្នុងសិលាចារឹកសម័យមុនអង្គរ និងអង្គរ គឺជាពាក្យទោលផង ពាក្យសមាសផង និងកន្សោមពាក្យផង។ មន្ត្រីជាន់ខ្ពស់ បព្វជិតជាន់ខ្ពស់ ព្រះរាជា និងព្រះអាទិទេពមានឈ្មោះជាភាសាសំស្ក្រឹតទាំងអស់។*[81]

**៣. នាមរបស់មន្ត្រី និងរាស្ត្រសាមញ្ញ**

*មនុស្សស្រទាប់ក្រោមមានឈ្មោះជាពាក្យខ្មែរផង និងសំស្ក្រឹតផង។ ចំណែកឯមនុស្សស្រទាប់លើវិញភាគច្រើនមានឈ្មោះជាពាក្យសំស្ក្រឹត។*

**៤. នាមព្រះមហាក្សត្រ**

*ព្រះនាមរបស់ព្រះមហាក្សត្រសម័យមុនអង្គរ និងសម័យអង្គរទាំងអស់ គឺជាពាក្យដែលមានដើមកំណើតពីភាសាសំស្ក្រឹតទាំងអស់៖ (១) ភវវម៌្ម ជនដែលព្រះឥសូរការពារ (២) ឥសានវម៌្ម ជនដែលព្រះឥសានការពារ*

---

80. *ឡុង សៀម*, 1996

81. *ឡុង សៀម*. 1996



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(៣) ជ័យវម៌្ម ប្រកបដោយជោគជ័យ (៤) ឥន្ទ្រវម៌្ម ជនដែលព្រះឥន្ទ្រការពារ (៥) សុរិយាវម៌្ម ជនដែលព្រះអាទិត្យការពារ

### ៥. ឋាននាម

ឋាននាម គឺជាពាក្យដែលគេយកមកហៅឈ្មោះទីតាំងផ្សេងនៅក្នុងប្រទេស។ នៅក្នុងសិលាចារឹកភាសាខ្មែរគេបានរកឃើញមានឋាននាមចំនួន ១៥០០៖ នៅក្នុងនោះ ឋាននាមដែលតាងឈ្មោះភ្នំ ព្រៃ បឹង ត្រពាំង ដី ខ្ពស់រាប ភូមិ តំបន់ និងស្រែ គឺជាឋាននាមដែលជាពាក្យខ្មែរ។ ចំណែកឯឋាននាមតាងឈ្មោះប្រទេស តំបន់ ទីក្រុង ប្រាសាទ និងទីសក្ការបូជា គឺជា ឋាននាមជាពាក្យសំស្ក្រឹត។ ស្ថាននាមជាភាសាសំស្ក្រឹត ត្រូវបានបង្កបង្កើតឡើងដោយមន្ត្រីជាន់ខ្ពស់ ដោយព្រាហ្មណ៍បុរោហិត ដែលបម្រើការនៅព្រះរាជវាំង។ ឈ្មោះរាជធានីនៃកម្ពុជាជាច្រើនជំនាន់៖ (១) វ្យាធបុរៈ (ទីក្រុងរាជាដែលជាព្រានប្រមាញ់ដំរី ឬ បាភ្នំ) (២) ឥសាន្តបុរៈ (ទីក្រុងព្រះឥសាន្ត ឬសំបូរព្រៃគុក, K. 314) (៣) ហរិហរាល័យបុរៈ (ទីក្រុងព្រះវិស្ណុ និងព្រះឥសូរ ឬលលៃ,K. 235) (៣) យសោធរបុរៈ (ទីក្រុងដ៏ស្រស់ប្រិមប្រិយ៍ ឬ អង្គរធំ,K. 70)

## ឋានន្តរនាមក្នុងភាសាខ្មែរចាស់

### ៦. ឋានន្តរនាម

ប្រព័ន្ធឋានន្តរនាមនៅសម័យអង្គរអាចចែកចេញជាបីថ្នាក់ (A, B, C) និងពីរកម្រិត៖ (១) ប្រព័ន្ធឋានន្តរនាមក្រុមជាន់ខ្ពស់ (CSS) និង (២) ប្រព័ន្ធឋានន្តរនាមក្រុមជាន់ទាប (CSI)។[82]

### ៦.១. ប្រព័ន្ធឋានន្តរនាមក្រុមជាន់ខ្ពស់ (CSS)

នៅក្នុងប្រព័ន្ធឋានន្តរនាមថ្នាក់ខ្ពស់នេះ មានឋានន្តរនាមបីថ្នាក់ទៀត

82. ឡុង សៀម. 1997b



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គឺ៖ (១) ថ្នាក់ A (២) ថ្នាក់ B និង (៣) ថ្នាក់ C ដែល B និង C គឺជាឋានន្តរនាមខ្ពស់ជាង A។

A1៖ «តាញ» សម្រាប់នារីវណ្ណៈអភិជន ដែលមានស្វាមីជា «លោញ» ឬ «វាប»។ ពាក្យនេះក្លាយមកពីពាក្យ «តាង» ឬ«តាំង»

B1៖ «ម្រតាង» ឬ «ម្រតេង» សម្រាប់មន្ត្រីព្រះមហាក្សត្រ៖ ម្រតាងសភាបតិ (ប្រធានតុលាការ) ម្រតាងខ្លោញ ឃ្លាង (ប្រធានឃ្លាំង) ម្រតាញកុរុង (អភិបាលខេត្ត)។

C1៖ កម្រតេង៖ ជាឋានន្តរនាមខ្ពស់ជាងគេ ដែលអាចក្លាយទៅជា «ព្រះកំម្រតេង» និង «ព្រះកម្រតេងអញ» សម្រាប់មហាមន្ត្រីសង្ឃ ឬ រាជគុរុ។ នរនាមសម្គាល់ព្រះមហាក្សត្រគឺ៖«ធូលីជេងធូលីព្រះបាទព្រះកម្រតេងអញ ស្រីជយវម៌្ម»

A2៖ «តេង» សម្រាប់នារីវណ្ណៈអភិជន ដែលមានស្វាមីជា «លោញ»។ «តេងត្វន» សម្រាប់ស្ត្រីចំណាស់នៃវណ្ណៈអភិជន។ ក៏ប៉ុន្តែ ក្នុងរជ្ជកាលព្រះបាទសូរ្យវម៌្មទី១ ឋានន្តរនាមនេះប្រើប្រាស់ត្រឹមអ្នកបម្រើក្នុងវត្តអារាមតែប៉ុណ្ណោះ។

B2៖ «ស្តេង» ឬ «ស្តេញ» សម្រាប់ក្រុមរាជវង្សានុវង្ស និងព្រះសង្ឃ៖ ស្តេងអញសិវចារ្យ K. 349។

C2៖ «កំស្តេង»៖ ជាឋានន្តរនាមសម្រាប់មន្ត្រីជាន់ខ្ពស់ ទាំងគ្រហស្ថ ទាំងព្រះសង្ឃ។

A3៖ «លោញ» សម្រាប់កូនប្រុសមន្ត្រីជាន់ខ្ពស់ មន្ត្រីស្ថាបនករ ឬ សេនាបតី (មេទ័ព)។ «លោញ» អាចឡើងស័ក្តិទៅជា «កំម្រតាងអញ»។

B3៖ «ក្លោញ» ឬ «ខ្លោញ» សម្រាប់មេ ឬ អ្នកគ្រប់គ្រង ដូចជា៖ (១) ខ្លោញវល ជាមេទ័ព (២) ខ្លោញវ្នំ ជាអធិការវត្ត (៣) ខ្លោញស្រុក ជាមេស្រុក (៤) ខ្លោញឃ្លាង ជាប្រធានឃ្លាំង (៥) ខ្លោញសិក្សា ជាប្រធាននិស្សិត (៦) ខ្លោញស្រុ ជាអ្នកត្រួតពន្ធស្រូវ និង (៧) ខ្លោញបយ្យង ជា ប្រធាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រេងឥន្ធនៈ។ នាពេលបច្ចុប្បន្ន ពាក្យនេះក្លាយទៅជា «មេក្មោង»។

C3៖ «កំតួន»៖ ជាឋានន្តរនាមសម្គាល់ព្រះមហាក្សត្រ ជាពិសេសព្រះបាទជយវម៌្មទី១។ចំណែក«កំលោញ»សម្រាប់សម្គាល់ចៅអធិការវត្ត។

A4៖ «វាប» សម្រាប់មន្ត្រី និងអ្នកមុខអ្នកការតាមស្រុក ខេត្ត និងព្រះបរមរាជវាំង។ ម្យ៉ាងទៀត ឋានន្តរនាម «វាប» សម្រាប់សម្គាល់មនុស្សនៅក្រោមវណ្ណៈអភិជន។ ឋានន្តរនាម «ហ្យង» មានន័យថា ខ្លាំងពូកែ ត្រូវបានប្រើសម្រាប់សម្គាល់នារីនៃវណ្ណៈអភិជាន ឬ ក្សត្រី។

B4៖ «ស្តេច» សម្រាប់មន្ត្រីជាន់ខ្ពស់ ជាទីប្រឹក្សាព្រះមហាក្សត្រ។ ឋានន្តរនាម«អំចាស»មកពីពាក្យ«ចស»ឬ«អ្នាស»ដែលមានន័យថា ចាស់ ហើយសម្រាប់សម្គាល់ចាស់ព្រឹទ្ធាចារ្យនៅតាមស្រុក ដែលទទួលខុសត្រូវខាងការគ្រប់គ្រងរដ្ឋបាល និងចរិយាធម៌។

C4៖ «សំតាច»៖ ជាឋានន្តរនាមសម្រាប់ព្រះមហាក្សត្រ។

## ៦.២. ប្រព័ន្ធឋានន្តរនាមក្រុមជាន់ទាប (CSI)

នៅក្នុងសិលាចារឹក គេប្រើឋានន្តរនាមដើម្បី៖ (១) សម្គាល់ភេទ ដូចជា លោក និងលោកស្រី (២) សម្គាល់អាយុ ដូចជា ក្មេងប្រុស និងក្មេងស្រី កូនប្រុស និងកូនស្រី (៣) សម្រាប់សម្គាល់តួនាទី ដូចជា ក្ញុំ អ្នកបម្រើ អ្នកសំអា អ្នកចំរៀង និងអ្នករបាំជាដើម។ ឋានន្តរនាមនេះ មានការផ្លាស់ប្តូរ ដូចមាននៅក្នុងតារាងខាងក្រោម។

A2៖«តេង» សម្រាប់នារីវណ្ណៈអភិជន ដែលមានស្វាមីជា «លោញ»។ «តេងតួន» សម្រាប់ស្ត្រីចំណាស់នៃវណ្ណៈអភិជន។ ក៏ប៉ុន្តែ ក្នុងរជ្ជកាលព្រះបាទសូរ្យវម៌្មទី១ ឋានន្តរនាមនេះប្រើប្រាស់ត្រឹមអ្នកបម្រើក្នុងវត្តអារាមតែប៉ុណ្ណោះ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | សម័យមុនអង្គរ | សម័យអង្គរ |
| --- | --- | --- |
| មនុស្សប្រុស | វ( សតវត្សទី៦ឬ៧)<br>វា( សតវត្សទី៦ឬ៨)<br>វយោ( អ្នកបម្រើជាន់ខ្ពស់) | សិ<br>សី |
| មនុស្សបស្រី | កុ<br>កុយា( ស្ត្រីគ្មានប្ដី)<br>អ្មេ( អ្នកមើលក្មេង) | តៃ( មកពីកន្តៃ)<br>តៃយ<br>អ្មេ |
| កុមារ | ប៉ោវ<br>ប៉ោកុ<br>កោនវ<br>កោនកុ | សិប៉ោ<br>តៃប៉ោ<br>ទេវសិ<br>ទេវតៃ |

# ស្ថាននាម

ឋាននាម ជាភាសាសំស្ក្រឹតមានជាអាទិ៍ ឈ្មោះរាជធានីនៃកម្ពុជាជាច្រើនជំនាន់៖

(១) វ្យាធបុរៈ ( ទីក្រុងរាជាដែលជាព្រានប្រមាញ់ដំរី ឬ បាភ្នំ)

(២) ឥសានបុរៈ ( ទីក្រុងព្រះឥសាន្ត ឬ សំបូរព្រៃគុក, K. 314)

(៣) ហរិហរាល័យបុរៈ ( ទីក្រុងព្រះវិស្ណុ និងព្រះឥសូរ ឬ លលៃ, K. 235)

(៣) យសោធបុរៈ ( ទីក្រុងដ៏ស្រស់ប្រិមប្រិយ៍ ឬ អង្គរធំ, K. 70)

(៥) កម្ពុបុរៈ (អង្គរធំ) ទីក្រុងតាបសកម្ពុ

សិលាចារឹកត្រូវបានប្រើប្រាស់ផងដែរ សម្រាប់កំណត់ព្រំប្រទល់ស្រុកភូមិស្ថាន និងដីស្រែចម្ការរបស់វត្តអារាម និងរបស់ពួកអភិជន ដែលបានមកពីព្រះរាជអំណោយ។ សិលាចារឹកខ្លះពិពណ៌នាពីជម្លោះដីធ្លីនៅជំនាន់អង្គរផងដែរ ដោយសារមានអ្នកមកទន្ទ្រានយកដីរបស់ស្មេរ។ តាមរយៈការសិក្សា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សិលាចារឹក លោក ឡុង សៀម បានស្រង់នាមឈ្មោះមនុស្ស (anthroponymes) ចំនួន ៥០០០ និងស្ថាននាម (toponymes) ចំនួន ១៥០០។ ស្ថាននាមទាំងនេះ គឺជាពាក្យខ្មែរបុរាណ ឬសំស្ក្រឹត ហើយដែលបន្តនៅប្រើប្រាស់ក្នុងពេលបច្ចុប្បន្នផងដែរ។ ស្ថាននាមសំស្ក្រឹតត្រូវបានប្រើប្រាស់ សម្រាប់ដាក់ឈ្មោះប្រាសាទ ព្រះវិហារ រាជធានី ទីក្រុង ភូមិភាគ ដែនដី និងទីតាំងភូមសាស្ត្រផ្សេងៗ។

អ្នកស្រាវជ្រាវបានរកឃើញថា ពាក្យ «កម្ពុជា» មកពីពាក្យ «កម្ពុជទេស» (kamvujadeça) ដែលជាពាក្យសំស្ក្រឹតមានន័យថា «ប្រទេសកូនចៅនៃមហាឥសីកម្ពុ» ចារនៅក្នុងសិលាចារឹកភាសាខ្មែរ នៅវត្តសំរោង ស្រុកបាភ្នំ (K. 956, ស.វ. ទី៩) និងនៅក្នុងសិលាចារឹកស្តុកកក់ធំ ខេត្តប្រាជិនបូរី (K. 235, គ.ស. ១០៥២)។

## សតវត្សទី៩ (គស ៨៩៣) K. 331





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## សតវត្សទី១៣ ( គស ១១០៧ ) K. 484B



## ខ្មែរកណ្ដាល បាខែង( មហាសករាជ ១៥០៤ )K. 465





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ភាសាខ្មែរកណ្ដាល-សិលាចារឹកអក្សរទំនើប



# ភាសាខ្មែរសម័យកណ្ដាល





# ភាសាខ្មែរសម័យទំនើប



បណ្ដាំ លោកឪជំ

ហៃសិក្ខាកាមទាំងឡាយ!

អ្នកមានវាសនាថ្លៃថ្លាខ្ពង់ខ្ពស់ណាស់ ដែលបានមកជួប ព្រះគុណធ្ងន់ ជាកំពូលនៃឃ្លាំងត្រៃវេទ ដែលបង្ហូរមិនចេះ រីងស្ងួតផ្ដល់ឲ្យសិស្សឥតព្រំដែន។

ពេលកូនរៀនចេះវិជ្ជាប្រើការបាន ពេលនោះលាភ សក្ការៈ និងហូរចូលមករកកូនឥតព្រំដែនដែរ ក៏ប៉ុន្តែកូនត្រូវចងចាំថា វិជ្ជាដែលកូនចេះ គឺមានឧបជ្ឈាយ៍ ដឹកដៃកូន អប់រំកូន ឲ្យដើរផ្លូវ ឧបេក្ខា ជាផ្លូវកណ្ដាល បើកូនត្រេកអរនឹង លាភ សក្ការៈ ហួសពេកធ្វើឲ្យកូនវង្វេងភ្លេចអស់បណ្ដាំគ្រូ ពេលនោះ កូននឹងអភ័ព្វ អស់មួយជីវិត។

កូនអើយ ! វិជ្ជាឥតព្រំដែន វិជ្ជាកូនចេះពេលណា លាភ និង កេរ្តិ៍មានដល់កូនពេលនោះ តែវិជ្ជាដែលកូនចេះ ពេលប្រើ ត្រូវពិចារណាដល់អាយុជីវិតសត្វ។



*វប្បធម៌រលត់ ជាតិរលាយ*
*វប្បធម៌ពណ្ណរាយ ជាតិថ្កើងថ្កាន*

# គន្ថនិទ្ទេស

## I. ខេមរភាសា


*ពៅ សាវរស* (2013). *សទ្ទានុក្រម សំស្ក្រឹត-ខ្មែរ-បារាំង* Editions Angkor. *ភ្នំពេញ*

*ឃៀង រ៉ីបុត្រ* (1995). *សិលាចារឹកកម្ពុជាសម័យមុនអង្គរ. ភាគទី១. ឯកសារប្រើប្រាស់ផ្ទៃក្នុង សម្រាប់បង្រៀនថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ. សាកលវិទ្យាល័យភូមិន្ទភ្នំពេញ*

*វង់ សុធារ៉ា* (2003). *សិលាចារឹកនៃប្រទេសកម្ពុជាសម័យមុនអង្គរ* Editions Angkor. *ភ្នំពេញ*

*វង់ សុធារ៉ា* (2016). *សិលាចារឹកនៃប្រទេសកម្ពុជាសម័យអង្គរ* Editions Angkor. *ភ្នំពេញ*

*ឡុង សៀម* (1996). *វាក្យស័ព្ទសំស្ក្រឹតដំបូងក្នុងភាសាខ្មែរបុរាណ និងឋាននាមខ្មែរមានប្រភពពីភាសាសំស្ក្រឹត* (L'influence du sanscrit dans l'ancien khmer et les toponymes khmers d'origine sanscrit). *«កម្ពុជសុរិយា», ឆ្នាំទី ៥០ លេខ ១ ឆ្នាំ ១៩៩៦, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ. ភ្នំពេញ*

*ឡុង សៀម* (1997a). *ស្ថាននាមវិទ្យាខ្មែរ តាមឯកសារសិលាចារឹកប្រទេសកម្ពុជា* ( *សតវត្សទី* VI-XIV) (Toponymie Khmère). *ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ. ភ្នំពេញ*

*ឡុង សៀម* (1997b). *ឋានន្តរនាម សម័យអង្គរ. «កម្ពុជសុរិយា», ឆ្នាំទី ៥១ លេខ ១ ឆ្នាំ ១៩៩៧, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ. ភ្នំពេញ*

*ឡុង សៀម* (2000). *វចនានុក្រមខ្មែរបុរាណ* ( *តាមរយៈសិលាចារឹកបុរេអង្គរ សតវត្សទី៦-៨* ). Phnom Penh





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Printing House. ភ្នំពេញ

អាំង ជូលាន (2010). កម្ពុជាក្សរ. កម្រងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ. លេខ ៩, ធ្នូ ២០១០. ភ្នំពេញ

អាំង ជូលាន (2018). មូលដ្ឋានរៀនខ្មែរបុរាណ. យសោធរ, Yosothor. ភ្នំពេញ

## II. ឯកសារបរទេស

BHATTACHARYA, Kamaleswar (1991). *Recherches sur le vocabulaire des inscriptions sanskrites du Cambodge*. EFEO, Vol. CLXVII. Paris.

BRUGUIER, Bruno et Juliette LACROIX (2013). *Preah Khan, Koh Ker et Preah Vihear: les provinces septentrionales.* Tome V, Guide archéologique du Cambodge. Editions du Patrimoine: Phnom Penh.

BRUGUIER, Bruno et Juliette LACROIX (2017). *De Thala Borivat à Srei Santhor. Le bassin du Mékong*. Tome IV, Guide archéologique du Cambodge. Phnom Penh.

CHHOM, Kunthea (2016). *Le rôle du sanscrit dans le développement de la langue khmère: Une étude épigraphique du VIe au XIVe siècle.* Sāstrā Publishing House: Phnom Penh.

CHHOM, Kunthea (2019). Sanskrit Elements in Old Khmer. Presentation at the Royal University of Fine Arts. Yasothor, Phnom Penh.

CŒDES, George (1929). EC 24. *Nouvelles données chronologiques et*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

*généalogiques sur la dynastie de Mahindharapura.* BEFEO 29: 297-330.

CŒDES, George (1931). *Études Cambodgiennes:* XXV.- *Deux Inscriptions Sanskrites du FOU-NAN.*, t. XXXI, 1931, P. 8.

CŒDES, George et DUPONT, Pierre (1943). *Les stèles de Sdok Kak Thom, Phnom Sandak et Práah Vihār*. In: BEFEO. TOME 43, pp. 56-154.

CŒDES, George (1951). *Inscriptions du Cambodge*, Volume I-VIII, EFEO, Paris: E. De Boccard.

CŒDES, George (1968). *The Indianized States of Southeast Asia*. Edited by Walter F. Vella. Translated by Susan Brown Cowing. Kuala Lumpur and Singapore: University of Malaya Press.

FINOT, Louis (1928). *Nouvelles inscriptions du Cambodge*. In: Bulletin de l'Ecole française d'Extrême-Orient. Tome 28 N◦1, 1928. pp. 43-80.

JACOB, Judith (1976). «*An Examination of the Vowels and final Consonants in Correspondences between pre-Angkor and modern Khmer* ». Oceanic Linguistics Special Publications. 42 (19): 19-38. Retreived 5 July 2019.

JACQUES, C., (2004). *L´Empire khmer. Cités et sanctuaire*, Ve-XIIIe siècles, Fayard, Paris, 2004.

JENKINS, Kristina (2014). «*A Brief Historical Analysis of Khmer*». Retreived on 28 September 2019.

JENNER, Philip (1980). *Chrestomathy of Pre-Angkorian Khmer, I:*

*Dated Inscriptions from the Seventh and Eight Centuries*. Vol. 1. N.p.: University of Hawaii at Manoa.

MÉNÉTRIER, E. (1933). «*Le vocabulaire cambodgien dans des rapports avec le sanskritet le pâli*. In: BEFEO, Tome 33, P. 994-997.

POU, Savaros (1979). «*Une description de la phrase en vieux-khmer*», Mon-Khmer Studies, VIII, P. 139-69. Reprinted in POU,Savaros (2003). Choix d´articles de Khmerologie.

Reyum Publishing: Phnom Penh.

POU, Savaros (1992). *Dictionnaire Vieux Khmer-Français-Anglais*. Cedoreck: Paris.

SAKAMOTO, Y. (1970). «*e de khmer ancien*». Journal of Asian and Africaon Studies. 3:28-43. Tokyo; cited in JACOB, Judith (1976). «*An Examination of the Vowels and final Consonants in*

*Correspondences between pre-Angkor and modern Khmer*». Oceanic Linguistics Special Publications. 42 (19): 19-38. Retreived 5 July 2019.

VARASARIN (Uraisi) *Les éléments khmers dans la formation de la langue siamoise* Paris, SELAF, 1984, 412 p.

VICKERY, Michael, (1998). *Society, Economics, and Politics in Pre-Angkor Cambodia: The 7th-8th Centuries*. The Center for East Asian Cultural Studies for UNESCO. The Tokyo Bunko, Komiyanma Printing: Tokyo.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ក្នុងនីតិកាលទី៦នៃរាជរដ្ឋាភិបាលកម្ពុជា។

លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នៅឆ្នាំ១៩៨៨ និងបណ្ឌិតនៅឆ្នាំ១៩៩១ ផ្នែកសេដ្ឋកិច្ចអន្តរជាតិពីវិទ្យាស្ថានទំនាក់ទំនងអន្តរ-ជាតិក្រុងម៉ូស្គូ ព្រមទាំងសញ្ញាបត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពីវិទ្យាស្ថានធានារ៉ាប់រង( CII) ប្រទេសអង់គ្លេស និងវិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី( MII)។ នៅឆ្នាំ២០១២ លោកបណ្ឌិតទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រអន្តរជាតិពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅកម្ពុជា និងពីសាកលវិទ្យាល័យLyon II នៃសាធារណរដ្ឋបារាំង ព្រមទាំងទទួលបានវិញ្ញាបនបត្រផ្នែកនីតិសមុទ្រពីបណ្ឌិត្យសភា Rhodes ផ្នែកនីតិសាស្ត្រនិងគោលនយោបាយសមុទ្រ។ នៅឆ្នាំ២០១៨ លោកបណ្ឌិតទទួលបានសញ្ញាបត្របណ្ឌិតផ្នែកអប់រំពីសាកលវិទ្យាល័យចូឡាឡុងកន។

លោកបណ្ឌិតធ្លាប់បានបម្រើការងារក្នុងបេសកកម្មការទូត និងក្នុងវិទ្យាស្ថានស្រាវជ្រាវ ជាអ្នកវិភាគនយោបាយ និងសេដ្ឋកិច្ច។ ចាប់តាំងពីឆ្នាំ១៩៩៩មក លោកបណ្ឌិតបានចូលបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទទួលបន្ទុកការងារសំខាន់ៗរួមមាន អ្នកសម្របសម្រួលការងារស្រាវជ្រាវនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងជាអនុប្រធានទី១នៃនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ។ បន្ទាប់មក ក្នុងឆ្នាំ២០០១ លោកបណ្ឌិតបានត្រូវតែងតាំងជាអគ្គលេខាធិការរងទទួលបន្ទុកគោលនយោបាយរួមមាន គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ ហិរញ្ញវត្ថុ កិច្ចការអាស៊ាន ឧស្សាហកម្ម ហិរញ្ញវត្ថុ ការវិភាគសេដ្ឋកិច្ច និងទទួលបន្ទុកក្នុងការសម្របសម្រួលជាមួយមូលនិធិ

រូបិយវត្ថុអន្តរជាតិ( IMF) និងធនាគារពិភពលោក( World Bank)។

ពីឆ្នាំ២០០៤ដល់ឆ្នាំ២០១០ លោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកបណ្ឌិតធ្លាប់ចូលរួមកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ានបូកបី ពីឆ្នាំ២០០០ដល់២០១០។ ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣ លោកត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងតួនាទីនេះ លោកធ្លាប់ធ្វើជាតំណាងប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាល G20 ក្នុងឋានៈដែលប្រទេសកម្ពុជាជាប្រធានអាស៊ាន នៅឆ្នាំ២០១២។ លោកបណ្ឌិតក៏បម្រើការងារជាអ្នកសម្របសម្រួលកិច្ចពិភាក្សាគោលនយោបាយរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយធនាគារអភិវឌ្ឍន៍អាស៊ី( ADB) មូលនិធិរូបិយវត្ថុអន្តរជាតិ( IMF) និងធនាគារពិភពលោក( World Bank)។

ក្នុងតំណែងជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ( SNEC) ដែលជាស្ថាប័នខាងផ្នែកគោលនយោបាយសេដ្ឋកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា លោកបណ្ឌិតបានសរសេរឯកសារគោលនយោបាយជាច្រើន និងបានអមដំណើរ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្និសីទអន្តរជាតិ ដូចជាមហាសន្និបាតអង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ព័ន្ធ កិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលអាស៊ីបូអ៊ាំ និងវេទិកាអន្តរជាតិជាច្រើនទៀត។

លោកបណ្ឌិតបាននិពន្ធសៀវភៅជាច្រើនក្បាល ជាភាសាខ្មែរ អង់គ្លេស និងបារាំង ស្តីអំពីការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា និងហិរញ្ញវត្ថុសាធារណៈ ហើយស្នាដៃចុងក្រោយ ក្រោមចំណងជើងថា «Cambodian Economy: Charting the Course for a Bright Future» ត្រូវបានជ្រើសរើសបោះពុម្ពផ្សាយដោយវិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍( ISEAS) នៃប្រទេសសិង្ហបុរី។ ស្នាដៃចុងក្រោយរបស់លោក គឺ «ប្រវត្តិសាស្ត្រកម្ពុជា ក្នុងបរិបទសកលលោក» ។

# ស្នាដៃរបស់អ្នកនិពន្ធ

១- L'Économie du Cambodge : La lutte pour le développement, 2005

២- Essais économiques, 2007

៣- Les finances publiques du Cambodge, 2007

៤- Cambodia: Recent Macroeconomic and Financial Sector Development, 2008

៥- Three Essays on Macroeconomic Management of Cambodia, 2008

៦- Introduction to Insurance, 2008

៧- ម៉ាក្រូសេដ្ឋកិច្ច - ឆ្នាំ២០០៩

៨- Public Finance in Cambodia, 2009

៩- ហិរញ្ញវត្ថុសាធារណៈ - ឆ្នាំ២០០៩

១០- ប្រាសាទព្រះវិហារ - ឆ្នាំ២០០៩

១១- Cambodian Economy: Chartering the Course of a Brighter Future. A Survey of Progress, Problems and Prospects, 2009

១២- L'économie du Cambodge: Nouvelles frontières du développement socio-économique, 2010

១៣-Regards sur le différend maritime khméro-thaïlandais à la lumière de la jurisprudence internationale, 2012

១៤- ទស្សនាទានស្តីពីវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់ដ៍ ក្នុងបរិបទនៃយុត្តិការអន្តរជាតិ - ឆ្នាំ២០១៣

១៥- សេដ្ឋកិច្ចកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង ៖ វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត - ឆ្នាំ២០១៥

១៦- កំណែទម្រង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព - ឆ្នាំ២០១៦

១៧- គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃប្រទេសកម្ពុជា នាសម័យទំនើបនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា( ទសវត្សរ៍ ឆ្នាំ១៩៨០) - ឆ្នាំ២០១៧

១៨- នីតិអន្តរជាតិសេដ្ឋកិច្ច - ឆ្នាំ២០១៧

១៩- *Series of Lectures in Public International Law, 2018*

២០- សិក្សាសង្ខេបស្ដីពីទស្សនវិជ្ជា - ឆ្នាំ២០១៨

២១- *Droit International Économique, 2018*

២២- *Education Reform in Cambodia, 2018*

២៣-វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរក្នុងការលើកកម្ពស់អំណាន នៅកម្ពុជា - ឆ្នាំ២០១៩

២៤- ប្រវត្តិសាស្ត្រកម្ពុជា ក្នុងបរិបទសកលលោក - ឆ្នាំ ២០១៩